ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍បូកសរុប

# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ប្រចាំឆ្នាំ ២០១០-២០១១ និងទិសដៅឆ្នាំ ២០១១-២០១២



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី ០៥-០៧ ខែ មេសា ឆ្នាំ ២០១១

# មាតិកា

## ជំពូក ១ ៖ ស្ថានភាពរួម

ទំព័រ


I- **សេចក្តីសង្ខេប** ៖ ........................................................................ ៣
II-**សេចក្តីផ្តើម** ៖ ........................................................................ ៦
III-**គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**..... ៨
*៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល* (Rectangular Strategy)............... ៨
*៣.២-ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០០៩-២០១៣* ..................... ៨
*៣.៣-ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ* ........................................................................ ១០
*៣.៤-យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក*............................................ ១២
IV-**កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ**. ....................................................... ១៣
*៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ*.............................................. ១៤
*៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១០*....................................................... ១៤
*៤.៣-ការវិវឌ្ឍន៍នៃផលិតកម្មកសិកម្មរយៈពេល ៥ ឆ្នាំ*........................................ ១៧


## ជំពូក ២ ៖ លទ្ធផល និងទិសដៅ


V-**លទ្ធផលឆ្នាំ ២០១០-២០១១ និងទិសដៅឆ្នាំ ២០១១-២០១២** ..................... ២៨
*៥.១-ផលិតកម្មដំណាំស្រូវ និងដំណាំផ្សេងៗ*................................................ ២៨
*៥.១.១-លទ្ធផល* ................................................................................ ២៨
*៥.១.២-វាយតម្លៃ និងសំណើ* .................................................................. ៣៥
*៥.១.៣-វិធានការ*.................................................................................... ៣៥
*៥.២-ផលិតកម្ម និងបសុព្យាបាល*................................................................ ៣៧
*៥.២.១-លទ្ធផល* .................................................................................... ៣៨
*៥.២.២-វាយតម្លៃ និងសំណើ*. .................................................................. ៤៦
*៥.២.៣-វិធានការ*................................................................................... ៤៦
*៥.៣-ផលិតកម្មដំណាំកៅស៊ូ* .................................................................... ៤៧
*៥.៣.១-លទ្ធផល* .................................................................................... ៤៧
*៥.៣.២-វាយតម្លៃ និងសំណើ* ................................................................... ៥២
*៥.៣.៣-វិធានការ* .................................................................................... ៥២
*៥.៤-លទ្ធផលការងាររុក្ខកម្ម* ...................................................................... ៥៣
*៥.៤.១-លទ្ធផល* .................................................................................... ៥៣

៥.៤.២-វាយតម្លៃនិងសំណើ ...................................................... ៥៧
៥.៤.៣-វិធានការ ...................................................... ៥៨
៥.៥-ការងារជលផល ...................................................... ៥៩
៥.៥.១-លទ្ធផល ...................................................... ៦០
៥.៥.២-វាយតម្លៃនិងសំណូមពរ ...................................................... ៦៣
៥.៥.៣-វិធានការ ...................................................... ៦៤
៥.៦-ការងារសេវាកម្មនិងការគាំទ្រ ...................................................... ៦៥
៥.៦.១-ការងារផែនការ និងវិនិយោគ ...................................................... ៦៥
៥.៦.២-ការងារសហប្រតិបត្តិការអន្តរជាតិ ...................................................... ៧២
៥.៦.៣- ការងារកិច្ចការរដ្ឋបាល ...................................................... ៧៥
៥.៦.៤-ការងារនិតិកម្មកសិកម្ម ...................................................... ៧៦
៥.៦.៥- ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង ...................................................... ៨០
៥.៦.៦- ការងារស្រាវជ្រាវកសិកម្ម ...................................................... ៨៣
៥.៦.៧- ការងារផ្សព្វផ្សាយកសិកម្មនិងពង្រឹងសហគមន៍កសិកម្ម ...................................................... ៨៨
៥.៦.៨- ការងារគ្រឿងយន្តកសិកម្ម ...................................................... ៩៣
៥.៦.៩- ការងារកសិឧស្សាហកម្ម ...................................................... ៩៤
៥.៦.១០- ការងារយេនឌ័រ ...................................................... ៩៦
៥.៧-ធនធានមនុស្សនិងថវិកា ...................................................... ៩៩
៥.៧.១- ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ...................................................... ៩៩
៥.៧.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ ...................................................... ១០២
៥.៧.៣- ការងារគណនេយ្យ និង ហិរញ្ញវត្ថុ ...................................................... ១១០
៥.៨-កម្មវិធី និងគម្រោងជំនួយផ្តល់ដោយដៃគូអភិវឌ្ឍន៍ ...................................................... ១១៥

## ជំពូក ៣ ៖ វាយតម្លៃ និងសន្និដ្ឋាន

VI-**វាយតម្លៃរួម** ...................................................... ១២៥
VII-**ទិសដៅរួម** ...................................................... ១២៦
VII- **វាយតម្លៃ និងសន្និដ្ឋាន** ...................................................... ១៣១
-ឧបសម្ព័ន្ធ

# ជំពូក ១
# ស្ថានភាពរួម

## I- សេចក្តីសង្ខេប ៖

*ឆ្នាំ ២០១០ គឺជាឆ្នាំទី ៣ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ មុតមាំ និងគតិបណ្ឌិតរបស់* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

*មកទល់ពេលនេះ ការងារបង្កបង្កើនផលរដូវវស្សា និងរដូវប្រាំង ត្រូវបានបញ្ចប់ជាស្ថាពរ និងជាការឈានដល់ពេលកំណត់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រារព្ធធ្វើសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ ២០១០-២០១១ និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំ ២០១១-២០១២ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីសមិទ្ធផល ដែលសម្រេចបានជាវិជ្ជមាន ក៏ដូចជាការប្រមូលផ្តុំនូវមតិយោបល់ ទស្សនៈទៅលើបញ្ហាប្រឈមទាំងឡាយ និងការវិភាគលើបទពិសោធន៍ល្អៗ ជាពិសេសអនុសាសន៍គន្លឹះដ៏មានតម្លៃរបស់* **សម្តេចនាយករដ្ឋមន្ត្រី** *ដើម្បីជាត្រីវិស័យក្នុងការរៀបចំជាចក្ខុវិស័យ ជាយុទ្ធសាស្ត្រ និងលើកទិសដៅអនុវត្តបន្តនៅឆ្នាំបន្ទាប់ ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាទៅនឹង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា។*

*នារយៈពេលមួយឆ្នាំកន្លងមកនេះ បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិ រួមមានកង្វះខាតទឹកដោយសារកួនរដូវប្រាំងនៅពាក់កណ្តាលរដូវវស្សា គ្រោះទឹកជំនន់ ជាពិសេស ជំនន់ទឹកភ្លៀងចុងរដូវវស្សា (ចាប់ពីពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកា) ព្រមទាំងភាពស្ថិតនៅក្រោមការប៉ះទង្គិចដោយកលយុគ្គវិបត្តិសេដ្ឋកិច្ចពិភពលោក តែក្រោមការខិតខំប្រឹងប្រែង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួម ដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការកើនឡើងគួរឱ្យកត់សំគាល់។ ជាក់ស្តែងស្រូវរដូវវស្សា ឆ្នាំ២០១០ នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃគ្រោះធម្មជាតិខ្លះ ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកំរិតល្អទូទាំងប្រទេស។ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីសរុបជាង ២,៣៩ លានហិកតា ដែលមានទិន្នផលជាមធ្យមចំនួន ២,៧៦ តោន/ហិកតា ដោយទទួលបរិមាណផល សរុបប្រមាណជាង ៦,៥៤ លានតោន និងស្រូវរដូវប្រាំងឆ្នាំ ២០១០-២០១១ លើផ្ទៃដីជាង ០,៤០៤ លានហិកតា ដែលមានទិន្នផលជាមធ្យម ៤,២០តោន/ហិកតា ដោយទទួលបានបរិមាណផលសរុបជាង ១,៦៩ លានតោន។ សរុបទាំងរដូវវស្សា និងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុបជាង ២,៧៩ លានហិកតា ដោយទទួលបរិមាណផលសរុបប្រមាណ ៨,២៤ លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ២,៩៧ តោន/ហិកតា។ ដូច្នេះតុល្យភាពស្បៀង យើងនៅសល់ជាង ២,៥១ លានតោនអង្ករ គិតជាស្រូវជាង ៣,៩៣ លានតោន លើសឆ្នាំមុនជាង ០,៤២ លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំកន្លងមកជាង ១,២៣ លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំណាស់។ ដោយឡែក ផលិតកម្មស្រូវតាមគោលការណ៍ធម្មជាតិ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយផ្ទៃដីអនុវត្តសរុបកើនដល់ជាង ៥៩.៧៨៥ ហិកតា ជាមួយនឹងទិន្នផលមធ្យម*

៣,៥៣ តោន/ហិកតា និងមានកសិករអនុវត្ត ប.វ.ស ជាង ១១២ ពាន់គ្រួសារ កើនលើសឆ្នាំមុន ៧,៧ ភាគរយ ហើយតួលេខនេះ មានការកើនឡើងគួរឱ្យកត់សំគាល់បើប្រៀបធៀបទៅនឹងឆ្នាំ ២០០០ ដែលមានតែ ២៨ គ្រួសារ អនុវត្តលើផ្ទៃដីត្រឹមតែ ១,៦ ហិកតា ជាការសាកល្បងតែប៉ុណ្ណោះ។ សូមបញ្ជាក់ថា ខេត្តដែលធ្វើស្រូវប្រព័ន្ធប្រពលវប្បកម្ម តាមគោលការណ៍ធម្មជាតិច្រើនជាងគេ គឺខេត្តតាកែវ ដែលមានកសិករចំនួនជាង ៣៤ ពាន់គ្រួសារ លើផ្ទៃដីជាង ២១ ពាន់ហិកតា។ ចំពោះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុនៗ ជារួមឈានមកដល់ពេលបច្ចុប្បន្ន ការងារបង្កបង្កើនផលឆ្នាំ ២០១០-២០១១ នេះ ទទួលបានផលយ៉ាងល្អប្រសើរ។

ជារួមផលិតកម្មសត្វនៅកម្ពុជាជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្ដីត្រូវការក្នុងស្រុក និងគោ-ក្របីត្រូវបាននាំចេញទៅបរទេសមួយចំនួនផងដែរ។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ ឃើញថាផលិតកម្មគោកើនប្រមាណ ៤% ក្របីថយចុះ ៣%។ ការចិញ្ចឹមបក្សីពីឆ្នាំ ២០០៦ ដល់ ២០១០ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពី ១៥ លានក្បាល ដល់ ២០,៦ លានក្បាល។ ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗ និងចំការ។ល។ កំពុងមានការរីកចំរើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូចមធ្យម និងធំ។ គួរកត់សំគាល់ថា មកដល់ឆ្នាំ ២០១០ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ១៨១.៤៣០ ហិកតា គឺកើនឡើង ៣៩,៦% ប្រៀបធៀបទៅនឹងឆ្នាំ ២០០៩ ក្នុងនោះ ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

វិស័យព្រៃឈើកំពុងតែត្រូវធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ មកទល់នឹងឆ្នាំ២០១០ នេះ សកម្មភាពដាំឈើជាចំការ សម្រេចបានសរុបចំនួន ២៨.៨៣៥ ហត ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបានចំនួន ១.០៤០ ហត ក្រុមហ៊ុនវិនិយោគឯកជនដាំដុះបានចំនួន ២៦.៧៧៥ ហត គ្រួសារឯកជនខ្នាតតូចដាំបាន ៩៧៣ ហត។ ទន្ទឹមនឹងនោះ សហគមន៍ព្រៃឈើសរុបចំនួន ៥១០ សហគមន៍ ត្រូវបានបង្កើតឡើង ហើយគ្រប់គ្រងលើផ្ទៃដីសរុបចំនួន ៤៦៧.៨៨៤ ហិកតា។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ៣,៨៥% គឺ ពី ៣៩០ ពាន់តោននៅឆ្នាំ ២០០៩ ដល់ ៤០៥ ពាន់តោន នៅឆ្នាំ ២០១០ ហើយអាជីវកម្មនេសាទសមុទ្រសម្រេចបាន ៨៥ ពាន់តោន កើនលើសឆ្នាំមុន ១៣%។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ សម្រេចបាន ៦០ ពាន់តោន កើនបាន ២០% និងសហគមន៍នេសាទមានចំនួន ៤៦៩ សហគមន៍ ត្រូវបានបង្កើតឡើង។

ការពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្ម និងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល ដូចជាការងារ

*វិនិយោគសាធារណៈ ការរៀបចំគម្រោងជាច្រើនសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើ វិស័យកសិកម្មមានការកើនឡើង ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម កាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានធ្វើកាន់តែច្រើនផងដែរ។*

*តាមការរៀបរាប់ខាងលើ យើងអាចវាយតម្លៃបានថា បរិមាណផលិតកម្មស្រូវមានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំកន្លងមក ជារួមការងារបង្កបង្កើនផលកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំកំពុងវិវឌ្ឍន៍ល្អ និងមានការចាប់អារម្មណ៍ខ្ពស់ពីប្រជាកសិកររបស់យើង។*

*នេះជារបត់មួយដែលកសិករយើងកំពុងកែទម្លាប់ពីកសិកម្មបុរាណ ដោយផ្អែកតាមយថាផលមកជាកសិកម្មលក្ខណៈជឿនលឿន និងស៊ីជម្រៅ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញថា ការដាំដុះដំណាំរួមផ្សំផ្សេងទៀត ដោយមិនពឹងផ្អែកតែលើស្រូវតែមួយមុខ ក៏បាននិងកំពុងទទួលការយកចិត្តទុកដាក់ផងដែរ។ ជារួមចំពោះមុខ និងទៅអនាគត យើងជឿជាក់ថា ការងារបង្កបង្កើនផលកសិកម្មនៅតែមានសក្តានុពល និងមានការវិវឌ្ឍន៍រីកចម្រើនច្រើន ដែលជាប្រភពកំណើននៅជនបទដ៏មានស្ថេរភាព។ សម្រាប់អនាគត ការអភិវឌ្ឍន៍ផលិតកម្មកសិកម្ម គឺទាមទារការជំរុញខ្លាំងលើការអភិវឌ្ឍផ្នែកគុណភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ជាងបរិមាណផលិតផល និងតម្រង់ទិសទៅរកការធ្វើកសិ-ពាណិជ្ជកម្ម។*

*ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិ-បត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។*

*ជាសន្និដ្ឋាន កសិកម្មកម្ពុជាសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញ និងអនុ-វត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

## II- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម នៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ ៨០ ភាគរយ រស់នៅជនបទ ហើយដែលក្នុងនោះ ភាគច្រើន លើសលុប ប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គម បែបនេះ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងចាត់ទុកថាវិស័យកសិកម្ម គឺជាវិស័យដែលមានអាទិភាពខ្ពស់ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិរបស់ខ្លួន។

ចាប់ពីទស្សវត្សឆ្នាំ ១៩៩០ រហូតមកទល់បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្ត ជាបន្តបន្ទាប់នូវយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្ម និងជនបទ ដោយកាត់បន្ថយភាពក្រីក្របានក្នុងកំរិតមួយសមស្រប តាមរយៈការបង្កើនផលិតភាព កសិកម្ម ធានានូវស្ថេរភាពសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារកសិករ ហើយ ដែលថ្មីៗកន្លងមកនេះ វិស័យនេះអាចធានាបាននូវអតិរេកនៃផលិតផលកសិកម្ម បម្រើឱ្យការនាំចេញ ទៀតផង។ យើងបានពិនិត្យឃើញថា កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាទាំងនេះ បានឆ្លុះបញ្ចាំងតាមរយៈ ការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ដែលត្រូវបានរៀបចំឡើង ដោយ ឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្រ្ត របស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្រ្ត ចតុកោណដំណាក់កាលទី ២ នៃរាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ននេះ។

ជាការពិតឆ្នាំ ២០១០ គឺជាឆ្នាំទី ៣ នៃការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ២ របស់ រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃមោះមុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែល ក្នុងនោះការលើកស្ទួយវិស័យកសិកម្ម គឺជាមុំមួយដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើក កម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ការកែទម្រង់ដីធ្លី និងបោសសំអាតមីន ការកែទម្រង់វិស័យ នេសាទនិងជលផល និងការកែទម្រង់វិស័យព្រៃឈើ គឺជាមុខព្រួញស្នូល ដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្ម ទទួលបាន ជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមានកត្តាអវិជ្ជមាននៃធម្មជាតិ រួមមាន កង្វះខាតទឹកខ្វះៗ ដោយសារឥទ្ធិពលកូនរដូវប្រាំងអូសបន្ទាយពីពាក់កណ្តាលខែសីហា រហូតដល់ពាក់ កណ្តាលខែកញ្ញា និងជួបគ្រោះទឹកជំនន់ដោយទឹកភ្លៀងចាប់ពីសប្តាហ៍ទី ២ ខែតុលា ដល់សប្តាហ៍ទី ១ ខែ វិច្ឆិកា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញ ជា ពិសេសការបង្កបង្កើនផលដំណាំជាយុទ្ធសាស្រ្តជាអាទិ៍ ដំណាំស្រូវ កៅស៊ូ និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងនេសាទ មិនត្រឹមតែអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងអាច នៅសល់ស្បៀងសម្រាប់នាំចេញទៀតផង។ នៅពេលដែលពិភពលោកកំពុងជួបប្រទះវិបត្តិស្បៀង និង ការធ្លាក់រួញចុះនៃសេដ្ឋកិច្ច កម្ពុជាបានខិតខំបង្កើននូវផលិកម្មដំណាំស្បៀង សំដៅរួមចំណែកដោះ

ស្រាយបញ្ហានេះ ដោយសារយើងមានសក្តានុពល អំណោយផលយ៉ាងធំធេងរបស់វិស័យកសិកម្មនេះ ជាពិសេសផលិតកម្មដំណាំស្រូវអាចពង្រីកសក្តានុពលផលិតកម្ម និងជំរុញការនាំចេញលើកស្ទួយជីវភាព ប្រជាពលរដ្ឋតាមជនបទ និងបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

ប្រជាពលរដ្ឋគ្រប់តំបន់ និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹក ប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានសភាពសកម្ម និងមានសារសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងរាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លា លើវិស័យកសិកម្មនេះ។

ការរីកចំរើននៃវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដែលរួមចំណែកយ៉ាងច្រើន ក្នុងកំណើនផលិតផលសរុបក្នុងស្រុក (GDP) និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ ការគ្រប់គ្រងបែងចែក និងការប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ រួមនឹងការខិតខំដោះស្រាយនូវរាល់បញ្ហាដែលមានចំពោះមុខ និងការទប់ស្កាត់សកម្មភាពរំលោភបំពានយកដី ដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នៃប្រទេសអ្នកផ្តល់ជំនួយ ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រកសិកម្ម និងទឹក សំដៅជំរុញលើកកំពស់បង្កើនផលិតភាពកសិកម្ម ធានាឱ្យបាននូវបរិមាណនិងគុណភាព ធានាសន្តិសុខស្បៀង និងទីផ្សារក្នុង-ក្រៅប្រទេស។ គ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹងពីមួយថ្ងៃទៅមួយថ្ងៃ តាមរយៈកម្មវិធីកែទម្រង់ និងការពង្រឹងអភិបាលកិច្ចល្អ។ មិនតែប៉ុណ្ណោះ វិស័យកសិកម្ម បាននិងកំពុងស្រូបទាញបាននូវទុនវិនិយោគ ទាំងពីអ្នកវិនិយោគក្នុង និងក្រៅប្រទេស កាន់តែធំឡើង ជាលំដាប់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ជារួមផ្នែកផលិតកម្មកសិកម្មអាចវាយតម្លៃបានថា ទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ពិសេសលើបរិមាណផលិតផលស្រូវ បានកើនប្រមាណ ៨,៧% លើសឆ្នាំមុន ទន្ទឹមនឹងការកែទម្រង់លើវិស័យព្រៃឈើ និងជលផល បានដំណើរការទៅមុខ ប្រកបដោយលទ្ធផលជាទីមោទនៈ គួបផ្សំនឹងការផ្តល់សេវាកម្មគាំទ្រ និងការផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យា មានសភាពកាន់តែសកម្ម ចូលជ្រៅដល់មជ្ឈដ្ឋានប្រជាកសិករ។ ទោះជាយ៉ាងណាក្តី ការរីកចំរើនក្នុងវិស័យកសិកម្ម ក៏មិនអាចកាត់ផ្តាច់បានពីការរួមចំណែកឧបត្ថម្ភពីបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានដែរ ជាពិសេសការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញប្បទាន ដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីចូលរួមជំរុញវិស័យនេះ។

ឆ្នាំនេះរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលជាកត្តាសំខាន់មួយថ្មីថែមទៀត ក្នុងការជំរុញផលិតកម្មស្រូវ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំរួចហើយនូវផែនការសកម្មភាពរបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយនេះ ហើយគ្រប់ភាគីពាក់ព័ន្ធ ពិតជារួមគ្នាអនុវត្ត គួបផ្សំនឹងការចូលរួមចំណែក ទាំងផ្នែកបច្ចេកទេស និងធនធានថវិកា សម្រាប់អនុវត្តការងារនេះឱ្យសម្រេចបានលទ្ធផលតាមការគ្រោងទុក។

ជាការសន្និដ្ឋាន វិស័យកសិកម្មបច្ចុប្បន្ននេះ មានការអភិវឌ្ឍន៍ប្រកបដោយមោទនភាព ជាពិសេសផលិតកម្មកសិកម្មកម្ពុជា នៅតែបន្តឈានចូលដល់ដំណាក់កាលល្អបំផុត ក្នុងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា។

## III- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy)

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់ការលើកកំពស់វិស័យកសិកម្ម សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតសំខាន់ទៅលើការលើកកំពស់ផលិតភាព និងពិពិធកាវូបនីយកម្មកសិកម្ម កំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និងកំណែទម្រង់ព្រៃឈើ។

ចតុកោណយុទ្ធសាស្ត្រទាំងបួនសំរាប់ជម្រុញកំណើនសេដ្ឋកិច្ច គឺ ៖ ១-ការលើស្ទួយវិស័យកសិកម្ម ២-ការអភិវឌ្ឍផ្នែកឯកជននិងការងារ ៣-ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៤-ការកសាងសមត្ថភាព និង អភិវឌ្ឍន៍ធនធានមនុស្ស។

ការលើកស្ទួយវិស័យកសិកម្មរួមមាន: (ទី១)-ការលើកកំពស់ផលិតភាព និងពិពិធកម្មកសិកម្ម (ទី២)-កំណែទម្រង់ដីធ្លីនិងការបោសសំអាតមីន (ទី៣)-កំណែទម្រង់ជលផល និង (ទី៤)-កំណែទម្រង់ព្រៃឈើ។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកំពស់វិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុករួមជាមួយធនធានថវិកា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្លូវថ្នល់ ធារាសាស្ត្រ និងអគ្គិសនី ព្រមទាំងឥណទានទីផ្សារ និងការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀងសម្រាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហាររូបត្ថម្ភ និងបង្កើនការនាំចេញផលិតផលកសិកម្ម។

### ៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ត្រូវបានរៀបចំឡើង ដោយឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ក៏បានរៀបចំធ្វើឱ្យមានសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកំពស់និងជំរុញការអភិវឌ្ឍកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ បានកំណត់ចក្ខុវិស័យ ដើម្បី "ធានាឱ្យមានស្បៀងគ្រប់គ្រាន់និងមានសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ភាពក្រីក្រត្រូវបានកាត់បន្ថយ ហើយបង្កើនផលិតផលសរុបក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ និងធានាឱ្យបានការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ប្រកបដោយចីរភាព"។

ដើម្បីសំរេចបាននូវទស្សនៈវិស័យនេះ សកម្មភាពគាំទ្រជាច្រើនត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ច ដូចជាការផ្តល់នូវសេវាកម្មមានគុណភាពខ្ពស់

ហើយជានាបាននការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយសុវត្ថិភាព ជាពិសេសបង្កើនផលិតផលកសិកម្ម និងតម្លៃបន្ថែម ដោយផ្អែកលើនិរន្តរភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ចនៃការចំណាយលើវិស័យកសិកម្ម ។

ទិសដៅគោលនយោបាយរួម ត្រូវបានកំណត់សំដៅ «ធានាបាននសន្តិសុខនិងសុវត្ថិភាពស្បៀង បង្កើនប្រាក់ចំណូលគ្រួសារ បង្កើតការងារ តាមរយៈការលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្ម កសិកម្ម និងពាណិជ្ជកម្មកសិកម្ម ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ ដល់ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយចីរភាព»។

ដើម្បីសំរេចបានគោលដៅជាយុទ្ធសាស្ត្រចំបងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តកំណត់នូវទិសដៅគោលនយោបាយ ជាយុទ្ធសាស្ត្រតាមវិស័យអនុវិស័យដែលមានស្រាប់ដូចខាងក្រោម ៖

ទិសដៅគោលនយោបាយទី-១៖ សន្តិសុខស្បៀង ផលិតភាព និង ពិពិធកម្មកសិកម្ម

ទិសដៅគោលនយោបាយទី-២៖ ពង្រីកទីផ្សារសំរាប់ផលិតផលកសិកម្ម

ទិសដៅគោលនយោបាយទី-៣៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍនស្ថាប័ន និង បញ្ញត្តិច្បាប់

ទិសដៅគោលនយោបាយទី-៤៖ កំណែទម្រង់ជលផល

ទិសដៅគោលនយោបាយទី-៥៖ កំណែទម្រង់ព្រៃឈើ

ដើម្បីធ្វើឱ្យសម្រេចបានគោលដៅនៃយុទ្ធសាស្ត្រទាំងប្រាំខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំងនោះរួមមាន ៖

កម្មវិធីទី ១ ៖ បង្កើនផលិតភាព និង ពិពិធកម្មកសិកម្ម

កម្មវិធីទី ២ ៖ ជំរុញការចូលទីផ្សារ នៃផលិតផលកសិកម្ម

កម្មវិធីទី ៣ ៖ ពង្រឹងស្ថាប័ន ក្របខ័ណ្ឌច្បាប់ និង អភិវឌ្ឍន៍ធនធានមនុស្ស

កម្មវិធីទី ៤ ៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

កម្មវិធីទី ៥ ៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយនិរន្តរភាព

ក្នុងគោលដៅសម្រាប់ជំរុញការលើកកម្ពស់ផលិតភាព និង ពិពិធកម្មកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានខិតខំ និងយកចិត្តទុកដាក់ជាសំខាន់ នូវយុទ្ធវិធីមួយចំនួនដូចខាងក្រោម៖

- ផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើនផលិតភាពកសិកម្ម និងការធ្វើពិពិធភាវូបនីយកម្ម ក្នុងវិស័យកសិកម្ម ព្រមទាំងការជំរុញកសិ-ឧស្សាហកម្មឱ្យបានខ្លាំងក្លា ដោយត្រូវយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសដៅ ពីការអភិវឌ្ឍតាមបែប "វិបុលកម្ម" ទៅកាន់ការអភិវឌ្ឍតាមបែប "ប្រពលវប្បកម្ម" ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ ធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ជាពិសេស កសិផលសម្រេច ។
- យកចិត្តទុកដាក់លើអន្តរាគមន៍ សំដៅជួយដល់ការបង្កើនផលិតកម្មកសិកម្ម តាមបច្ចេកទេសសមស្រប ការស្រាវជ្រាវពីការអភិវឌ្ឍផលិតកម្ម និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឱ្យបាន

- *ពង្រឹងនិងពង្រីក "សេវាផ្សព្វផ្សាយកសិកម្ម" ដោយជំរុញការផ្តល់សេវានេះ ឱ្យទៅដល់ថ្នាក់មូលដ្ឋាន ពិសេស ការពង្រឹងសេវាថ្នាក់ស្រុក ឃុំ និងត្រូវតម្រង់ទិសជ្រើសរើសក្រុមគោលដៅដែលត្រូវទទួលផល ជាពិសេសការយកចិត្តទុកដាក់ដល់ក្រុមកសិករ ដែលជាសមាជិកសហគមន៍អភិវឌ្ឍន៍កសិកម្ម ឬសហករណ៍កសិកម្ម និងផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំ-ភូមិ (ផ្តោតលើការពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ ឱ្យក្លាយជាអ្នកផ្សព្វផ្សាយកសិកម្មភូមិ) ព្រមទាំងធានាស្ថេរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម ដែលបាន និងកំពុងអនុវត្ត ។*
- *ជំរុញនិងបង្កើតបរិយាកាសអនុគ្រោះ ឱ្យកាន់តែប្រសើរឡើងថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជន ទាំងក្នុងនិងក្រៅប្រទេស ឱ្យចូលរួមក្នុងផលិតកម្មកសិកម្ម ពិសេសផលិតកម្មដំណាំកសិ-ឧស្សាហកម្ម និងស្វាគមន៍ចំពោះការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើននិងធានាឱ្យបាននូវការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករ ក្នុងការដាំដុះ និងចិញ្ចឹមសត្វ។*
- *ផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផលទីផ្សារក្នុងស្រុក ដោយយកចិត្តទុកដាក់លើការអនុវត្តប្រព័ន្ធ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" និងជំរុញការឈានចូលទីផ្សារពិភពលោក តាមរយៈការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពកសិផល ឱ្យស្របតាមស្តង់ដារអន្តរជាតិ យកចិត្តទុកដាក់ដល់ការអនុវត្តល្អក្នុងផលិតកម្មកសិកម្ម និងការផ្តល់សេវាព័ត៌មានទីផ្សារកសិកម្ម។*

**៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ**

*ឯកសារគោលនយោបាយ ស្តីពី «ការជំរុញផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករ» ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ កន្លងទៅនេះ ដោយ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** *ហើយដែលគ្រប់ភាគីដែលពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវតែរៀបចំផែនការសកម្មភាព សម្រាប់អនុវត្តដាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវទិសដៅ ធ្វើយ៉ាងណាឱ្យកម្ពុជាមានផលិតផលស្រូវដែលផលិតលើសប្រមាណជាង ៤ លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង ១ លានតោន នៅឆ្នាំ ២០១៥ ។*

*ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលំអិតរបស់ខ្លួន សំដៅឆ្លើយតប និងសម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករ បានកំណត់ច្បាស់ នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺៈ (ទី១) វិធានការគោលនយោបាយ ដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ពាក់ព័ន្ធនឹងការប្រមូលទិញ និងការកែច្នៃ (ទី៣) ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយ ដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។*

ដើម្បីឆ្លើយតបបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ "*ការបង្កើនផលិតភាព ពិសេសប្រពលវប្បកម្មដំណាំស្រូវ និងពិពិធភាវូបនីយកម្ម*" គឺជាចំណុចគន្លឹះ ដែលនឹងត្រូវយកចិត្តទុកដាក់និង ត្រូវផ្តោតទៅលើការបង្កើនសេវាកម្ម និងអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ និងពិសេសការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បានៗល។ ម្យ៉ាងទៀត ការសម្របសម្រួល និងគាំទ្រវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ តម្រូវតាមស្តង់ដារទីផ្សារអន្តរជាតិ គឺជាការចាំបាច់ និង ត្រូវតែគាំទ្រឱ្យបានខ្លាំងក្លា។

ដោយឡែក ការប្រមូលផ្តុំផលិតកម្ម ក៏ជាចំណុចគ្រឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំ តាមរយៈ "*សហគមន៍កសិកម្ម ឬ សហករណ៍កសិកម្ម*" ព្រោះប្រសិន បើផលិតផលស្រូវនៅរាយប៉ាយគ្រប់ទីកន្លែង និងចម្រុះទៅដោយប្រភេទពូជច្រើនមុខនោះ គុណភាពស្រូវពិតជាមិនអាចឆ្លើយតបបាន ទៅនឹងសេចក្តីត្រូវការឡើយ។ ដូចនេះ ទាមទារឱ្យមានការប្រមូលផ្តុំផលិតកម្មជាចាំបាច់ ហើយសហគមន៍កសិកម្ម គឺជាមជ្ឈមណ្ឌលផលិត និងផ្គត់ផ្គង់ដ៏សំខាន់នាពេលអនាគត។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវតម្រង់ទិសនៃការធ្វើអន្តរាគមន៍ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីផលិតក្នុងទ្រង់ទ្រាយធំនាពេលខាងមុខ។ ម្យ៉ាងវិញទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏នឹងត្រូវយកចិត្តទុកដាក់ខ្លាំងក្លាដល់ផ្នែកឯកជនពិសេសបណ្តាក្រុមហ៊ុនដែលចូលរួម ក្នុងការធ្វើផលិតកម្មកសិកម្មនៅកម្ពុជាផងដែរ។

ការផ្សារភ្ជាប់រវាង ក្រុមអ្នកផលិត និងអ្នកប្រមូលទិញ តាមយន្តការ «*ផលិតកម្មកសិកម្មតាមកិច្ចសន្យា*» គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ផងដែរ ក្នុងការសម្រេចបាននូវទិសដៅគោលនយោបាយនេះ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានអំពីទីផ្សារស្រូវ ក៏ជាមធ្យោបាយដ៏សំខាន់មួយ ដើម្បីឱ្យកសិករ-ពាណិជ្ជករមានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មកសិកម្មនេះ។ លើសពីនេះទៀតនោះ ការសម្រួលពាណិជ្ជកម្ម និងការនាំចេញ តាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទ លិខិតបទដ្ឋានក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាវិធានការចាំបាច់និងត្រូវពង្រឹងបន្ថែមទៀត។

ផ្អែកលើសារសំខាន់នេះនិងភាពចាំបាច់នៃឯកសារគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំនូវផែនការសកម្មភាពរបស់ខ្លួន ដោយបានលំអិតនូវអ្វីដែលជាសកម្មភាព និងការកិច្ចត្រូវអនុវត្ត និងបានដាក់ចុះជាសកម្មភាពជាក់ស្តែងនានា ដល់អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តវិធានការគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

មកទល់នឹងពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានកំណត់រួចហើយ នូវប្រភេទពូជស្រូវសំខាន់ៗចំនួន ១០ ប្រភេទ សម្រាប់ជំរុញផលិតកម្ម រួមមាន៖

- ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន ៣ ពូជ: ពូជសែនពិដោរ ពូជជលសារ និង ពូជ IR66
- ពូជស្រូវកណ្តាលចំនួន ៤ ពូជ: ពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនស
- ពូជស្រូវធ្ងន់ចំនួន ៣ ពូជ: ពូជរាំងជ័យ ពូជខា៤ និង ពូជខា៦ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងត្រូវអនុវត្តនូវបណ្តាសកម្មភាពធំៗមួយចំនួន ដូចជាៈ

(ទី-១) វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវៈ ត្រូវយកចិត្តទុកដាក់លើការសម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ដី ជាតុចូលកសិកម្ម ការពង្រឹងនិងពង្រីកសមត្ថភាព CARDI ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការពង្រីករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្មដល់ថ្នាក់ឃុំ ការរៀបចំគម្រោងផែនការ ដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងតួនាទីរបស់អង្គការកសិករ ពិសេសការលើកកម្ពស់សមត្ថភាពរបស់កសិករ និងសហគមន៍កសិកម្ម ក្នុងការខ្ចីនិងការប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ការរៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដី និងផ្សព្វផ្សាយឲ្យបានទូលាយ ការរៀបចំកសាងច្បាប់ស្តីពី ការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ការធ្វើជំរឿនកសិកម្មជាតិ ការរៀបចំច្បាប់ស្តីពី «សហគមន៍កសិកម្ម» និងជំរុញការពិភាក្សាឱ្យបានលឿននូវអនុក្រឹត្យស្តីពី «ផលិតកម្មកសិកម្មតាមកិច្ចសន្យា» ។ល។

(ទី-២) វិធានការពាក់ពន្ធ័នឹងការប្រមូលទិញ និងការកែច្នៃស្រូវៈ យកចិត្តទុកដាក់ដល់ការពង្រឹងសហគមន៍កសិកម្ម ឱ្យមានលទ្ធភាពអនុវត្តតាមទស្សនទាន «ទីផ្សារស្រូវបើកចំហ» ដោយត្រូវផ្តោតលើសកម្មភាពៈ -ផ្តល់វគ្គបណ្តុះបណ្តាលអំពីទស្សនទានទីផ្សារស្រូវបើកចំហ និងលិខិតបទដ្ឋាន ពាក់ពន្ធ័នឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា -បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពគ្រប់គ្រងទីផ្សារស្រូវបើកចំហ និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដល់សហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍គំរូ -បង្កើតនិងដំណើរការទីផ្សារស្រូវបើកចំហ ដល់សហគមន៍កសិកម្មគំរូ ។ល។

(ទី-៣) វិធានការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករៈ ត្រូវរៀបចំចងក្រងនិងផ្សព្វផ្សាយឯកសារស្តីពី «នីតិវិធីនៃការនាំចេញទំនិញ ជាកម្មវត្ថុការត្រួតពិនិត្យភូតគាមអនាម័យ» សិក្សាពីសមាសភាពចម្រៀលើអង្ករនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាសភាពចម្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រងនិងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពី សមាសភាពចម្រៃលើអង្ករ រៀបចំតំបន់គ្មានសមាសភាពចម្រៃ សម្រាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការ របស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពី «វិធានភូតគាមអនាម័យ» ពង្រឹងសមត្ថភាព ដោយបំពាក់សម្ភារបច្ចេកទេស ដើម្បីជំរុញការអនុវត្តការរំងារធូបទកម្ម (Fumigation) រួមសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីកំណត់ស្តង់ដារគុណភាពអង្ករកម្ពុជាឲ្យស្របតាមស្តង់ដារអន្តរជាតិ ជំរុញការរៀបចំច្បាប់ស្តីពីភូតគាមអនាម័យ អនុក្រឹត្យ និងប្រកាសនានា ដែលពាក់ពន្ធ័ ។ល។

(ទី-៤) វិធានការស្វែងរកទីផ្សារៈ ត្រូវផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុក ក្នុងតំបន់ និងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និង ចរាចរស្រូវ-អង្ករ និងវិភាគអំពីស្ថានការទីផ្សារតំបន់ និង អន្តរជាតិ ។ល។

### ៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក មានទស្សនៈវិស័យ "ធានាឱ្យមានស្បៀង និងទឹកគ្រប់គ្រាន់ និងមានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ភាពក្រីក្រត្រូវបានកាត់បន្ថយ និងរួមចំណែកក្នុងការលូតលាស់សេដ្ឋកិច្ចជាតិ (បង្កើនផលិតផលសរុបក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ) និងធានាឱ្យបាននូវចីរភាពធនធានធម្មជាតិ "។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការ ដើម្បីគៀងគរជំនួយនិងធនធានសំរាប់អនុវត្ត ជាពិសេស អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក

តាមរយៈយន្តការសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជំនួយអភិវឌ្ឍន៍ផ្លូវការ និងយន្តការក្រុមការងារបច្ចេកទេសនានា។ ទស្សនៈវិស័យ ទិសដៅ និងកម្មវិធី របស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ គឺសមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ហើយក៏ស្របតាមដំណើរការវិវឌ្ឍន៍ និងនិន្នាការប្រកួតប្រជែងនៅលើទីផ្សារនៅក្នុងតំបន់ និងលើសកលលោក និងតាមតម្រូវការសេដ្ឋកិច្ចទីផ្សារសេរី។ ប្រការទាំងអស់នេះហើយ ដែលធ្វើឱ្យដៃគូអភិវឌ្ឍន៍នានា មានការចូលរួមយ៉ាងពេញទំហឹង ក្នុងការកសាងយុទ្ធសាស្ត្រនេះ និងបានសន្យាផ្តល់ជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់គាំទ្រសកម្មភាពទាំងឡាយ ដែលមានចែងក្នុងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹកនេះ។

ផ្អែកលើទស្សនៈវិស័យរយៈពេលវែង យុទ្ធសាស្ត្រនេះ មានគោលដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ធានាបាននូវសន្តិសុខស្បៀង និងការលូតលាស់សេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាព និងពិពិធកម្មកសិកម្មបង្កើនការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក។ ដើម្បីសម្រេចបាននូវគោលដៅនេះ យុទ្ធសាស្ត្របានកំណត់នូវ "កម្មវិធី" សំខាន់ចំនួន ៥ គឺៈ ទី(១) កម្មវិធីគាំទ្រដល់ការពង្រឹងសមត្ថភាព និងគ្រប់គ្រងស្ថាប័ន សម្រាប់វិស័យកសិកម្ម និងទឹកៈ ទី(២) កម្មវិធីគាំទ្រសន្តិសុខស្បៀង ទី(៣)កម្មវិធីគាំទ្រកសិកម្មនិងកសិ-ពាណិជ្ជកម្ម ទី(៤) កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រព និងដីធ្លី ទី(៥) កម្មវិធីស្រាវជ្រាវអប់រំ និងផ្សព្វផ្សាយសម្រាប់កសិកម្ម និងធនធានទឹក។

ដោយផ្អែកលើទិសដៅនេះ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយម នាំមុខនោះ និងដោយមានការសម្របសម្រួលពីដៃគូអភិវឌ្ឍន៍ បានកំណត់រៀបចំកម្មវិធីទាំង៥ រួចជាស្ថាពរ។ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដោយមានការជួយឧបត្ថម្ភគាំទ្រ និងសម្របសម្រួលពីដៃគូអភិវឌ្ឍន៍ បានពិនិត្យនិងរៀបចំធ្វើសុខដុមនីយកម្មកម្មវិធីទាំង ៥ នេះ ក្នុងគោលបំណង ដើម្បីកំណត់អាទិភាពកម្មវិធីទាំងអស់ ឱ្យមានលក្ខណៈស្របគ្នាទាក់ទងគ្នា និងតាមលំដាប់។ ជាលទ្ធផលការធ្វើសុខដុមនីយកម្មកម្មវិធីនេះ កំណត់បាននូវផ្នែក (Component) ចំនួន ០៦ ដែលរួមមាន ផ្នែកទី១ ៖ គោលនយោបាយ និង បទបញ្ញត្តិ ផ្នែកទី២ ៖ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ផ្នែកទី៣ ៖ ការស្រាវជ្រាវ និងការអប់រំ ផ្នែកទី៤ ៖ សន្តិសុខស្បៀង ផ្នែកទី៥ ៖ ការគ្រប់គ្រងធនធានទឹកនិងដីកសិកម្ម និង ផ្នែកទី៦ ៖ កសិ-ពាណិជ្ជកម្មនិងទីផ្សារ។ ផ្នែកទាំង ៦នៃកម្មវិធីនេះ គ្រោងនឹងប្រើប្រាស់ថវិកាសរុបប្រមាណ ៥០១ លានដុល្លារអាមេរិក សម្រាប់អនុវត្តរយៈពេល ០៤ ឆ្នាំ ខាងមុខ។

## IV- **កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ**

វិស័យកសិកម្មមានសារៈសំខាន់បំផុត ក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះ អាចផ្តល់នូវប្រភពស្បៀងអាហារ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម និងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្ម ចូលទៅក្នុងទីផ្សារអន្តជាតិ។ នេះគឺជាចំណុចគន្លឹះចំបងបំផុត ដែលអាចបញ្ជាក់បានថា វិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

## ៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់មួយទៀត ក្នុងកិច្ចការសង្គមក៏ដូចជា ការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺ វិស័យកសិកម្ម អាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជន រហូតដល់ប្រមាណជិត ៧០% និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈ ការធ្វើផលិតកម្មកសិកម្មនេះ។

ការខិតខំប្រឹងប្រែងកន្លងមករបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជំរុញការអភិវឌ្ឍវិស័យកសិកម្ម បានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ របស់ប្រជាជនកម្ពុជា ជាក់ស្តែងភាពក្រីក្របានថយចុះពីកម្រិត ៤៧% នៅឆ្នាំ ១៩៩៤ មកត្រឹម ៣៥% នៅឆ្នាំ ២០០៤ ហើយតាមការប៉ាន់ស្មានថ្មីៗនេះ បានបង្ហាញថា អាត្រានៃភាពក្រីក្រនេះ បានថយចុះមកនៅ ៣០% នៅឆ្នាំ ២០០៧។ ដូចនេះ យើងអាចវាយតម្លៃបានថា ជាមធ្យមភាគ ភាពក្រីក្របានថយចុះជាង ១% ក្នុងមួយឆ្នាំៗ។

សន្តិភាព និងការបង្រួបបង្រួមជាតិ និងស្ថេរភាពសង្គមគឺ ជាកត្តាគន្លឹះសម្រាប់ការកសាងប្រទេស ពិសេសការអភិវឌ្ឍវិស័យកសិកម្មនេះ។ គោលនយោបាយគាំទ្រដល់ការរីកលូតលាស់នៃវិស័យកសិកម្ម ក៏ជាកត្តាជំរុញមួយទៀតយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យនេះ ដែលធ្វើឱ្យសហគមន៍ផ្តល់ជំនួយនានា យកចិត្តទុកដាក់ជួយគាំទ្រយ៉ាងខ្លាំងក្លា។ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញការអនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្ម ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូល នៅជនបទ ធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋទូទៅ។ ម្យ៉ាងវិញទៀត សក្តានុពលភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មដូចជា កត្តាដីកសិកម្ម ដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភពធនធានទឹក និងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចរុញការរីកលូតលាស់សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបន្ថែមទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ជំរុញផលិតភាពកសិកម្ម ដោយខិតខំពង្រឹងថែមទៀត នូវប្រសិទ្ធភាពសេវាកម្មគាំទ្រដូចជា: ការងារស្រាវជ្រាវ និងផ្សព្វផ្សាយ ការអភិវឌ្ឍនូវទីផ្សារកសិកម្ម និងបទដ្ឋានគតិយុត្តនានា ក៏បានកែលំអបំពេញបន្ថែមនិងកសាងថ្មី ដែលបានជួយឱ្យការងារដឹកនាំអនុវត្តសកម្មភាពនានា មានលក្ខណៈប្រសើរ និងមានប្រសិទ្ធភាព ។

## ៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១០

### ៤.២.១- ការចូលរួមចំណែកនៃវិស័យសេដ្ឋកិច្ចសំខាន់ៗក្នុង GDP ឆ្នាំ ២០១០ (Constant Price)




ប្រភពទិន្នន័យ: តួលេខបណ្តោះអាសន្នរបស់NIS ក្រសួងផែនការ ខែមីនា ឆ្នាំ២០១១

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល ២៩% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១០ នេះ។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ ២៨% និងវិស័យសេវាកម្មប្រហែល ៤៣%។ ការកើននូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺបានកើនឡើងដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានសភាពទ្រឹង និងមានសន្ទុះថយចុះ ចាប់ពីឆ្នាំ ២០០៨ និង ២០០៩កន្លងទៅនេះ ដោយឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក បន្តមានមកទល់ពេលនេះ។

### ៤.១.២-ការចូលរួមចំណែកជាភាគរយផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០០១-២០១០




គួរកត់សំគាល់ដែរថា ការចូលរួមចំណែកជាភាគរយនៃផ្នែកកសិកម្មក្នុង GDP ជារួម មាននិន្នាការថយចុះពី ៣៤,៤% នាឆ្នាំ ២០០១ មកនៅត្រឹម ២៨,១% នៅឆ្នាំ ២០០៦ និងបន្តការថយចុះប្រមាណ ២៦,៧% នៅឆ្នាំ ២០០៧ និង បានកើនឡើងវិញចំនួន ២៨% នៅឆ្នាំ២០០៩។ សភាពការណ៍នេះ បង្ហាញអំពីភាពប្រកួតប្រជែងរីកចំរើនរួម នៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយក្នុងនោះ វិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណ និងគុណភាព។ នាឆ្នាំ ២០១០ កន្លងទៅនេះ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP បានបន្តកើនឡើងពី ២៨% (ឆ្នាំ ២០០៩) ដល់ ២៩% ឆ្នាំ ២០១០ (តាមការប៉ាន់ស្មានដំបូងរបស់NIS) ។

### ៤.១.៣-តម្លៃបន្ថែមសរុប (GVA) ផ្នែកកសិកម្មចាប់ពីឆ្នាំ ១៩៩៩-២០១០



ការធ្លាក់ចុះនូវចំណែកជាភាគរយ (%) របស់វិស័យកសិកម្មក្នុង GDP រយៈពេល៩ឆ្នាំកន្លងមក (១៩៩៩-២០០៧) មិនមែនមានន័យថាផលិតកម្មកសិកម្មធ្លាក់ចុះនោះទេ។ ផ្ទុយទៅវិញតម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី ៥.០៧៨ ពាន់លានរៀល នៅឆ្នាំ១៩៩៩ រហូតដល់ ៧.៩៩៤ ពាន់លានរៀល នៅឆ្នាំ ២០០៩ (កើនប្រហែលជាង ៤០%) និងបានបន្តកើនថែមទៀតដល់ ៨.៣១៣ ពាន់លានរៀលឆ្នាំ២០១០ នេះ(តម្លៃគិតតាមថ្លៃស្ថេរឆ្នាំ២០០០)។

### ៤.១.៤-កំណើន ( %) នៃវិស័យកសិកម្មចាប់ពីឆ្នាំ ១៩៩៩-២០១០




ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំ ប្រមាណជា ៤-៥% (២០០៦-២០១០) កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដូចដែលបានបង្ហាញតាមក្រាហ្វិកខាងលើ ហើយការប្រែប្រួលនេះ មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះវិស័យកសិកម្មពឹងផ្អែកច្រើននៅឡើយលើកត្តាធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។

នៅឆ្នាំ១៩៩៩ កំណើននៃវិស័យកសិកម្មនេះមានប្រមាណ២,២% ប៉ុណ្ណោះ។ នាឆ្នាំ២០០១ វិស័យកសិកម្មកើនក្នុងរង្វង់ ៣,៦% ឆ្នាំ ២០០៣ កើនប្រហែល ១០.៥% និងនៅឆ្នាំ ២០០៥ កើនខ្លាំងរហូតដល់ ១៥,៧% (អាស្រ័យដោយភាពអនុគ្រោះខ្លាំងពីធម្មជាតិ ពិសេសកត្តាទឹកភ្លៀង និងមិនមានបញ្ហា សត្វល្អិតបំផ្លាញ) ។ នៅឆ្នាំ ២០០៦ វិស័យកសិកម្មបានកើនប្រមាណ ៥,៥% និងឆ្នាំ ២០០៩ មានកំណើនប្រហែល ៥,៤%។ ដោយឡែក ឆ្នាំ២០១០នេះ កំណើនមានប្រហែលជាង ៤,៥% (តាមការប៉ាន់ស្មានដំបូងរបស់ NIS)។ គួរកត់សំគាល់ដែរថា នៅឆ្នាំ ២០០០ ២០០២ ២០០៤ កំណើនផ្នែកកសិកម្មជាចំនួនអវិជ្ជមាននេះ គឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ ដែលរួមមាន ទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។

### ៤.១.៥-សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម ឆ្នាំ២០១០



ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជាភាគរយ (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ ២០១០ មានចំនួនជាងពាក់កណ្តាល ពោលគឺ ៥៣,៨% នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកច្រើនបន្ទាប់ពីដំណាំ គឺមានប្រមាណ ២៧,៣% ផលិតកម្មសត្វបានចូលរួម ១២,៨% និង អាជីវកម្មព្រៃឈើមានត្រឹមតែ ៦,១% ប៉ុណ្ណោះ។

ផលិតកម្មដំណាំ ពិសេសស្រូវ នៅតែជាមុខដំណាំសំខាន់ សំរាប់ការរកចំណូលរបស់កសិករ។ មុខរបរអាជីវកម្មបន្ទាប់ គឺអាចសន្និដ្ឋានថា អាជីវកម្មនេសាទ (មានសមាសភាគប្រមាណ ២៥-២៧%) និងផលិតកម្មសត្វមានការចូលរួមតិចជាងអាជីវកម្មនេសាទ (១៥% ក្នុងកំឡុងពេល ៤ ឆ្នាំកន្លងទៅនេះ ២០០៦-២០០៩)។ ដោយឡែក អាជីវកម្មព្រៃឈើ មាននិន្នាការថយចុះជាបន្តបន្ទាប់ (សមាសភាគចូលរួមក្នុងវិស័យកសិកម្ម មានត្រឹមតែប្រមាណ ៦,១% នាឆ្នាំ២០១០) ។

### ៤.១.៦-សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម




ការបង្ហាញតាមក្រាហ្វិកឃើញថា ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំង ដែលសមាសភាគរបស់ផ្នែកនេះមានចំនួន ៥០,៨% នៅឆ្នាំ ២០០៦ និងមាននិន្នាការកើនឡើង ៥២,២% នៅឆ្នាំ ២០០៧ និងកើនឡើងរហូតដល់ ៥២,៩% នៅឆ្នាំ ២០០៩។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះ បានកើនប្រហែល ៣% បើប្រៀបធៀប នឹងឆ្នាំ ២០០៦។ ចំពោះសមាសភាគផ្នែកជលផល មានការប្រែប្រួលពី ២៥,៩% នៅឆ្នាំ ២០០៦ រហូតដល់ ២៧,៣% នាឆ្នាំ ២០១០ ហើយផ្នែកនេះបានទទួលរងនូវកត្តាជះឥទ្ធិពលទឹកទន្លេ នៅឆ្នាំ២០០៧ ដែលធ្វើឱ្យការចូលរួមថយត្រឹម ២៤,៨% និងបានកើនឡើងវិញពី ២៥% នៅឆ្នាំ ២០០៨ ដល់ ២៧,៣% នាឆ្នាំ ២០១០ នេះ។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើមានការថយចុះជាបន្តបន្ទាប់បើធៀបនិងឆ្នាំ ២០០៦ ពី ៧,៥% មកត្រឹមតែ ៦,១% នៅឆ្នាំ ២០១០។ រីឯសមាសភាគផ្នែកបសុសត្វមានការប្រែប្រួល និងថយចុះ បើធៀបរយៈពេលឆ្នាំ ៥ កន្លងទៅនេះ (១៥,៨% ឆ្នាំ ២០០៦ ថយមកត្រឹម ១៥,៣% ឆ្នាំ២០០៩ និង ១២,៨% ឆ្នាំ២០១០)។

## ៤.៣-ការវិវឌ្ឍន៍នៃផលិតកម្មកសិកម្មរយៈពេល ៥ ឆ្នាំ

### ៤.៣.១-ការវិវឌ្ឍន៍ផលិតកម្មដំណាំស្រូវ

ផលិតកម្មស្រូវ នៅតែជាផលិតកម្មចម្បងមួយ សម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅជនបទស្ទើរតែទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលកន្លងមកនេះ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិសរបស់រាជរដ្ឋាភិបាល ដោយមានការ

ចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការរីកចំរើនឡើងគួរឱ្យកត់សំគាល់។

ជាក់ស្តែងផលិតកម្មស្រូវប្រចាំឆ្នាំ ២០១០ នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិ ពិសេសគ្រោះជំនន់ទឹកជំនន់ រាំងស្ងួត ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកំរិតល្អប្រសើរទូទាំងប្រទេស។ ផលិតកម្មដំណាំស្រូវអនុវត្តបានសរុបចំនួន ២,៧៩ លានហិកតា ផ្ទៃដីអាចប្រមូលផលបានមានចំនួន ២,៧៧ លានហិកតា និងទិន្នផលមធ្យមប្រចាំឆ្នាំទទួលបានចំនួន ២,៩៧ តោន/ហិកតា។ ផ្ទៃដីចំនួនប្រហែល ២០.៦៦១ ហិកតា ត្រូវបានទទួលរងដោយគ្រោះធម្មជាតិនាឆ្នាំ ២០១០ កន្លងទៅនេះ ពិសេសគ្រោះជំនន់ទឹកជំនន់ ការរាំងស្ងួត និងសត្វចង្រៃបំផ្លាញ។ តែទោះជាយ៉ាងណាក្តី កម្ពុជាអាចទទួលបានបរិមាណផលស្រូវចំនួន ៨,២៤ លានតោន និងអាចសល់ស្បៀង (អង្ករ) សរុបចំនួនៈ ២,៥ លានតោន (បរិមាណស្បៀងសល់គិតជាស្រូវនៅសល់ប្រមាណជា ៣,៩ លានតោន)។ ផលិតផលស្រូវដែលទទួលបាននេះ ខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំកន្លងមក ប្រមាណជាង ២ លានតោនស្រូវស្មើនឹង ១,៥ លានតោនអង្ករ ដែលនេះជាជោគជ័យមួយគួរជាទីមោទនៈបំផុតសម្រាប់កម្ពុជា។

តារាង ៖ ប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ ២០០៦/២០១០

| បរិយាយ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ប្រៀបធៀបកំណើន ២០១០/២០០៩ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហត) | 2,541,433 | 2,585,905 | 2,615,741 | 2,719,080 | 2,795,892 | **2.82%** |
| ផ្ទៃដីប្រមូលផល (ហត) | 2,516,415 | 2,566,952 | 2,613,363 | 2,674,603 | 2,777,323 | **3.84%** |
| ទិន្នផល (ត/ហត) | 2.489 | 2.621 | 2.746 | 2.836 | 2.970 | **4.74%** |
| បរិមាណផល (ត) | 6,264,123 | 6,727,127 | 7,175,473 | 7,585,870 | 8,249,452 | **8.75%** |
| ស្បៀងសល់ (អង្ករ) | 1,433,880 | 1,649,640 | 2,025,033 | 2,244,598 | ***2,516,752*** | **12.12%** |
| ស្បៀងសល់ (ស្រូវ) | 2,240,438 | 2,577,562 | 3,164,114 | 3,507,185 | ***3,932,425*** | **12.12%** |

ក្រាហ្វិកទី ១៖ បង្ហាញសមាសភាគចូលរួមនៃផ្ទៃដីដាំដុះស្រូវវស្សាតាមប្រភេទ ឆ្នាំ ២០១០




ជារួមពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីអនុវត្ត ផ្ទៃដីប្រមូលផល និងបរិមាណផល មានការវិវឌ្ឍន៍ឈានឡើងជាលំដាប់ សមិទ្ធផលទទួលបានទាំងនេះ ក៏ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ស្ថាប័ន

ពាក់ព័ន្ធ និងអាផ្ទាធរមូលដ្ឋាន ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ បានជួយធ្វើឱ្យវិស័យកសិកម្មមានដំណើរការល្អគួរលាស់ ទាំងការរៀបចំគ្រប់គ្រងទាំងបច្ចេកទេសដាំដុះ ដោយបានបង្កើនការអប់រំណែនាំដល់ប្រជាកសិករ ឱ្យកែប្រែទម្លាប់ចាស់ បង្កើនចំណេះដឹងក្នុងផលិតកម្ម និងបច្ចេកទេសកែច្នៃផលិតផលកាន់តែប្រសើរឡើង។

ផ្ទៃដីដាំដុះប្រភេទស្រូវកណ្តាលមានប្រមាណ ៤៩% (ប្រជាកសិករទទួលយកនូវបច្ចេកទេស សម្រាប់ដាំដុះប្រភេទស្រូវនេះច្រើន) ប្រភេទស្រូវស្រាលមានប្រមាណ ២៤% និងស្រូវធ្ងន់មានប្រហែល ២១%។ ដោយឡែកស្រូវចំការ និងស្រូវឡើងទឹក មានសមាសភាគតិចតួច (ស្រូវចំការ ២% និងស្រូវឡើងទឹក ៤%)។

**ក្រាហ្វិកទី ២ ៖ បង្ហាញការវិវត្តន៍នៃផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលចាប់ពីឆ្នាំ ២០០១-២០១០ (រយៈពេល ១០ ឆ្នាំ)**




ផលិតកម្មស្រូវរដូវវស្សាមានចំណែកប្រមាណជាង ៨៦% នៃផ្ទៃដីផលិតកម្មស្រូវទូទាំងប្រទេស។ ប្រទេសកម្ពុជាទទួលរងនូវគ្រោះទឹកជំនន់ គ្រោះរាំងស្ងួតពាក់កណ្តាលរដូវនៅតំបន់ខ្លះ និងបញ្ហាសត្វល្អិតចង្រៃកើតមាននៅតំបន់មួយចំនួន បានធ្វើឱ្យផ្ទៃដីប្រមូលផល និងបរិមាណផលមានភាពប្រែប្រួលចុះឡើងមិនទៀងទាត់។ ផ្ទៃដីដាំដុះស្រូវរដូវវស្សាឆ្នាំ ២០១០ សម្រេចបានប្រមាណជាង ២,៣៩ លានហិកតា ដែលមានទិន្នផលជាមធ្យមចំនួន ២,៧៦ តោន/ហិកតា ដោយទទួលបរិមាណផលសរុបប្រមាណជាង ៦,៥២ លានតោន និងស្រូវរដូវប្រាំង ២០១០-២០១១ សម្រេចបានលើផ្ទៃដីដាំដុះជាង ០,៤០៤ លានហិកតា ដែលមានទិន្នផលជាមធ្យម ៤,២ តោន/ហិកតា ដោយទទួលបានបរិមាណផលសរុបជាង ១,៦៩ លានតោន។

**ក្រាហ្វិកទី ៣ ៖ បង្ហាញការវិវត្តន៍នៃបរិមាណផលស្រូវរដូវវស្សារដូវប្រាំង និងប្រចាំឆ្នាំចាប់ពីឆ្នាំ ២០០១-២០១០ ៖**




ក្នុងរយៈពេល ៥ ឆ្នាំ ចុងក្រោយ ពី ២០០៦ ដល់ ២០១០ យើងពិនិត្យឃើញថា បរិមាណផលសរុបប្រចាំឆ្នាំ ក៏ដូចជាបរិមាណផលស្រូវរដូវវស្សា និងស្រូវរដូវប្រាំង មានការកើនឡើងជាលំដាប់ ទោះបី

ជួបប្រទះនូវគ្រោះធម្មជាតិដូចជា ទឹកជំនន់ រាំងស្ងួត និងសត្វល្អិតបំផ្លាញខ្លះៗក៏ដោយ។ នៅឆ្នាំ ២០១០ នេះ បរិមាណផលសរុបកើនឡើងជាងឆ្នាំ ២០០៩ ប្រមាណ ៦៦៣.៥៨២ តោន ស្មើនឹង ៨,៧៥% ដោយសារការខិតខំស្តារឡើងវិញនូវផ្ទៃដីដែលបានខូចខាត និងម្យ៉ាងទៀត គឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការមានផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។

ក្រាហ្វិកទី ៤ ៖ បង្ហាញអំពីកំណើនផលិតកម្មស្រូវពីឆ្នាំ ២០០៦-២០១០




កំណើននៃផលិតកម្មដំណាំស្រូវ មានការប្រែប្រួលតាមឆ្នាំនីមួយៗ អាស្រ័យដោយលក្ខខណ្ឌ និងភាពអនុគ្រោះនៃកត្តាទឹក និងសមត្ថភាពទប់ទល់ស្តារពីការខូចខាត។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៩ ផ្ទៃដីអនុវត្តដាំដុះបានកើនប្រហែល ២,៨% ផ្ទៃដីប្រមូលផលកើន ៣,៨% និងបរិមាណផលកើន ៨,៧%។ ជារួមផលិតផលស្រូវ បានកើនឡើងធៀបនឹងឆ្នាំកន្លងទៅ (ពោលគឺកើនពី៥,៧% ឆ្នាំ២០០៩ ដល់ ៨,៧% ឆ្នាំ២០១០) ដែលទាំងអស់នេះ គឺដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានជំរុញឱ្យវិស័យកសិកម្ម មានដំណើរការលូតលាស់ទាំងបរិមាណនិងគុណភាព ពិសេសការគ្រប់គ្រងទាំងផ្នែកបច្ចេកទេសដាំដុះ និងការកែច្នៃផលិតផលកាន់តែប្រសើរឡើង។

## ៤.៣.២- ការវិវឌ្ឍន៍ដំណាំកសិកម្ម ៤ មុខពីឆ្នាំ ២០០១-២០១០

ក្រាហ្វិកទី ៥ ៖ បង្ហាញអំពីផ្ទៃដីដំណាំ ៤ មុខ ឆ្នាំ ២០០១-២០១០ (ពោត ដំឡូងមី សណ្តែកបាយ និង សណ្តែកសៀង)



តារាងៈ ផ្ទៃដីដាំដុះដំណាំរដូវសំខាន់ៗ៤មុខៈ

ឯកតាៈ ផ្ទៃដីដាំដុះគិតជាហិកតា

| មុខដំណាំ | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត | 80,215 | 80,470 | 93,362 | 91,203 | 90,732 | 108,836 | 142,391 | 163,106 | 206,058 | 213,622 |
| ដំឡូងមី | 14,239 | 19,563 | 25,740 | 22,749 | 30,032 | 97,918 | 108,122 | 179,945 | 160,326 | 206,226 |
| សណ្តែកបាយ | 29,431 | 39,802 | 44,940 | 39,089 | 60,570 | 85,140 | 65,261 | 45,605 | 49,599 | 69,206 |
| សណ្តែកសៀង | 31,997 | 33,438 | 53,064 | 84,886 | 118,760 | 75,053 | 76,981 | 74,413 | 96,388 | 103,198 |
| សរុបដំណាំ៤មុខ | 155,882 | 173,273 | 217,106 | 237,927 | 300,094 | 366,947 | 392,755 | 463,069 | 512,371 | 592,252 |

*ជារួមផ្ទៃដីដាំដុះដំណាំរដូវ មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំសំខាន់ៗ (ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង) មាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងបានពី ៥១២.៣៧០ ហិកតា (ឆ្នាំ២០០៩) ដល់ ៥៩២.២៥០ ហិកតា (ឆ្នាំ២០១០) ពោលគឺកើនប្រហែល ១៥%។*

*ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម សរុបទូទាំងប្រទេសសម្រាប់ឆ្នាំ ២០១០ សម្រេចបានប្រមាណ ៧៥២.៦៣៩ ហិកតា កើនលើសឆ្នាំមុន ១២,៣% និងបរិមាណផលសរុបនៃដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មប្រចាំឆ្នាំ ក៏មានការកើនឡើងដែរ គឺបានកើនពី ៥,៤ លាន តោន ឆ្នាំ២០០៩ ដល់ ៦,១ លានតោន ឆ្នាំ ២០១០ (កើនប្រមាណ ១៣%)។ ទន្ទឹមនឹងនោះ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន ១៩០.០០០ ហិកតា កើនលើសឆ្នាំមុន ៩ %។ ដូចនេះ ផ្ទៃដីដាំដុះដំណាំទូទាំង ប្រទេសសម្រេចបាន ៣,៧៣ លានហិកតា (ផ្ទៃដីដាំដុះដំណាំស្រូវចំនួន ២,៧៩ លានហិកតា ផ្ទៃដីដាំដុះ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មចំនួន ០,៧៥ លានហិកតា និងផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ចំនួន ០,១៩ លានហិកតា។*

### ៤.៣.៣- ការវិវឌ្ឍន៍នៃផលិតផលបសុសត្វ

ក្រាហ្វិកទី ៦ ៖ បង្ហាញអំពីការវិវត្តន៍សត្វនៅកម្ពុជាពីឆ្នាំ ២០០៦-២០១០




*ជារួមផលិតកម្មសត្វនៅកម្ពុជា ជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍គួរកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះ អាចជានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងកន្ទងមកគោ ក្របី មួយចំនួនត្រូវបាននាំចេញទៅបរទេស។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វរយៈពេល ៥ ឆ្នាំ (២០០៦-២០១០) ឃើញថា ផលិតកម្មគោកើនបានចំនួន ៤.១៨%។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ ២០០៩ ការចិញ្ចឹមគោបានថយចុះពី ៣,៥៧លានក្បាល មកត្រឹម ៣,៤៨លាន*

ក្បាល ថយចុះប្រហែល ២,៦% រីឯក្របីសរុបមានចំនួនជាង ៧០២ លានក្បាល ថយចុះ ៩ % និងជ្រូកចិញ្ចឹមបានប្រមាណជាង ២លានក្បាល ថយចុះប្រមាណ ៣,២%។ ការថយចុះនេះ គឺមូលហេតុបណ្តាលមកពីជម្ងឺឆ្លងសត្វ (ពិសេស ជម្ងឺអុតក្តាម និងជម្ងឺជ្រូកត្រចៀកខៀវ) ចលនាពាណិជ្ជកម្មសត្វនាំចូលមិនផ្លូវការ និងថ្លៃដើមផលិតកម្មខ្ពស់ (ចំណីថ្លៃ)។ល។ ដែលធ្វើឱ្យកសិករលំបាកប្រកួតប្រជែង។

ក្រាហ្វិកទី ៧ ៖ បង្ហាញអំពីបំរែបំរួលស្ថិតិសត្វស្លាបនៅកម្ពុជាពីឆ្នាំ ២០០៥-២០១០




ការចិញ្ចឹមសត្វស្លាបពីឆ្នាំ ២០០៦ ដល់ ២០១០ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពីជាង ១៥ លានក្បាល ដល់ ២០,៦៨ លានក្បាល ជាមួយនោះ ឆ្នាំ ២០១០ សត្វស្លាបមានការកើនឡើងចំនួន ៣% បើប្រៀបធៀបនឹងឆ្នាំ ២០០៩ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករយល់ដឹងជាបណ្តើរៗនូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងពីវិធានការទប់ស្កាត់ជម្ងឺឆ្លង។ ជាពិសេស ការផ្សព្វផ្សាយទូលំទូលាយក្នុងជួរកសិករ ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងជានាបាននូវការផ្គត់ផ្គង់សាច់ ស៊ុត នៅក្នុងប្រទេស និងកសិដ្ឋានផលិតកម្មមានលក្ខណៈស្របច្បាប់ជាបណ្តើរៗដែរ។ គួរកត់សម្គាល់ថា មានករណីជម្ងឺកើតសត្វស្លាបកើតមាននៅតំបន់មួយចំនួន ប៉ុន្តែត្រូវបានការពារបានយ៉ាងមានប្រសិទ្ធភាព ទន្ទឹមនោះ ពាក់ព័ន្ធនឹងការងារផលិតកម្ម និងបសុព្យាបាលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចុះនូវវិធានការមួយចំនួន ដើម្បីជំរុញការចិញ្ចឹមសត្វស្លាបទាំងកំរិតគ្រួសារ និងកំរិតកសិដ្ឋាន ក៏ដូចជាបានលើកទឹកចិត្តវិនិយោគលើការចិញ្ចឹម មាន់សាច់ និងស៊ុត។

ជាសរុបមកការចិញ្ចឹមសត្វ មានសន្ទុះធ្លាក់ចុះបន្តិចតាមបែបគ្រួសារ និងបែបពាណិជ្ជកម្ម បើធៀបនឹងឆ្នាំ ២០០៩ លើកលែងការចិញ្ចឹមសត្វស្លាប។ ប៉ុន្តែចំពោះការកែលំអពូជសត្វ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើស ពូជសត្វជាកត្តាសំខាន់ ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័សធន់នឹងជម្ងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារបានឆាប់ទៀតផង។ ចំណែកឯចំណីសត្វ និងដំណាំចំណីសត្វ ប្រជាកសិករមានការចូលរួមយ៉ាងសកម្ម និងយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចក្នុងស្រុកយ៉ាងផុសផុល។

### ៤.៣.៤- ការអភិវឌ្ឍន៍ផលិតផលកៅស៊ូ

កៅស៊ូជាដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់ ជួយទ្រទ្រង់ដល់សង្គម-សេដ្ឋកិច្ចជាតិ ចូលរួមការពារបរិស្ថាន ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារហូរច្រោះដី ។

នៅក្នុងឆ្នាំ ២០១០ បរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក ផលិតបានមានចំនួនជាង ១០ លានតោន គឺកើនឡើង ៦,៤៤% បើប្រៀបធៀបជាមួយផលិតផលឆ្នាំ ២០០៩ ដែលមានចំនួន ៩,៣៩ លានតោន។ ជាមួយគ្នានេះ ការប្រើប្រាស់កៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ ២០១០ មានបរិមាណចំនួន ១០,១៨ លានតោន គឺបានកើនឡើងចំនួន ៨,៥% បើប្រៀបធៀបជាមួយការប្រើប្រាស់ឆ្នាំ ២០០៩ ដែលមានចំនួន ៩,៣៨ លានតោន ។ ដូច្នេះសន្និធិប្រចាំឆ្នាំនៅតាមបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិ គឺមានតិចតួចណាស់។ កត្តានេះ បានធ្វើឲ្យតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ មានសន្ទុះកើនឡើងនាពេលបច្ចុប្បន្ន ក៏ដូចថ្ងៃអនាគតផងដែរ ។

នៅឆ្នាំ ២០១០ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនដល់ចំនួន ១៨១.៤៣០ ហិកតា គឺកើនឡើង ៣៩,៦% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៩ (ផ្ទៃដីដាំកៅស៊ូឆ្នាំ ២០០៩ មានចំនួន ១២៩.៩២០ ហិកតា) ក្នុងនោះ ផ្ទៃដីចំការកៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ចំនួន ៤៧.០៩២ ហិកតា ផ្ទៃដីវិនិយោគថ្មីស្ថិតក្រោមសម្បទានដីសេដ្ឋកិច្ចមានចំនួន ៥២.៥២៨ ហិកតា និងផ្ទៃដីកៅស៊ូគ្រួសារមានចំនួន ៨១.៨១៣ ហិកតា។

ក្រាហ្វិកទី ៨: ផ្ទៃដីដាំដុះកៅស៊ូតាមប្រភេទឆ្នាំ២០១០




សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជា មានការកើនឡើងជាលំដាប់ អាស្រ័យដោយសារតម្លៃកៅស៊ូបានឡើងខ្ពស់ គួបផ្សំស្ថានភាពនយោបាយ-សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និង គោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជន ដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច (កើន ១៣៥% ធៀបនឹងឆ្នាំ ២០០៩) និងផ្នែកកៅស៊ូគ្រួសារ (កើន៣៤,៨% ធៀបនឹងឆ្នាំ២០០៩) ដោយបានធ្វើឲ្យផ្ទៃដីដាំដុះកៅស៊ូ កើនឡើងគួរជាទីមោទនៈ។

ដោយឡែក ចំពោះចម្ការកៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ ពុំមានការកើនឡើងផ្ទៃដីដាំដុះថ្មីគួរឲ្យកត់សម្គាល់ទេ គឺធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់ និងដាំឡើងវិញតែប៉ុណ្ណោះ ពោលគឺកើនឡើងប្រហែល ០,៤៣% បើប្រៀបធៀបនឹងឆ្នាំ២០០៩ កន្លងទៅ ។

*ក្រាហ្វិកទី ៩ ៖ ការវិវត្តន៍នៅក្នុងការដាំដុះកៅស៊ូ ២០០៦-២០១០*




### ៤.៣.៥- ការវិវឌ្ឍន៍ផ្នែករុក្ខកម្ម

នៅឆ្នាំ ២០១០ នេះ រដ្ឋបាលព្រៃឈើបានធ្វើការវាយតម្លៃធនធានគម្របព្រៃឈើឆ្នាំ២០១០ ដោយប្រើប្រាស់រូបភាពពីផ្កាយរណប LANDSAT របស់សហរដ្ឋអាមេរិកបានចប់ជាស្ថាពរ ដោយចុះធ្វើការផ្ទៀងផ្ទាត់លទ្ធផលដល់ទីតាំងជាក់ស្តែងចំនួន ១០៤ ចំណុច ក្នុងខេត្តចំនួន ១៣។ ជាលទ្ធផលបឋមឃើញថា គម្របព្រៃឈើកម្ពុជាមាននៅសល់ ១០.៣៣៩.៨២៦ ហិកតា ស្មើនឹង ៥៦,៩៤% (ថយចុះ ២,១៥% ស្មើនឹង ៣៩០.៩៥៥ ហិកតា បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦) ។

ជាក់ស្តែងនៅឆ្នាំ ២០១០ កន្លងទៅ ការងារធំៗមួយចំនួន ពាក់ព័ន្ធនឹងសកម្មភាពវិស័យព្រៃឈើមានដូចខាងក្រោម ៖

-ការផ្គត់ផ្គង់ឈើមូល-ឈើអារគ្រប់ប្រភេទសំរាប់ប្រើប្រាស់ក្នុងស្រុកនៅឆ្នាំ ២០១០នេះ មានចំនួន ៦៨.៣៤០ម$^{៣}$ (ឈើមូល ៦៤.៨២៨ម$^{៣}$ និងឈើអារ ៣.៥១២ម$^{៣}$) ដែលឈើទាំងនោះមានប្រភពមកពីព្រៃគុបដេញថ្លៃ ឈើដែលបានពីការឈូសឆាយសំអាតដីក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ហើយមានមួយចំនួនទៀត ជាឈើដែលបានមកពីការសំអាតអាងរ៉ារីអគ្គីសនីស្ទឹងអាតៃ និងឬស្សីជ្រុំ។ ក្រៅពីនេះ នៅមានអនុផលព្រៃឈើផ្សេងៗជាច្រើនមុខទៀត ត្រូវបានប្រមូល និងប្រើប្រាស់ផងដែរ

-ការងារបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រេចបាន ៣.៦៤០បង្គោល គិតជាប្រវែងប្រមាណ ៥៣៨ គីឡូម៉ែត្រ។ ថវិកាដែលបានប្រើប្រាស់ក្នុងការងារនេះ បានមកពីថវិការដ្ឋចំនួន ១.១៤៩បង្គោល ស្មើ ១៥១ គីឡូម៉ែត្រ អនុវត្តនៅក្នុងខណ្ឌរដ្ឋបាល ព្រៃឈើកំពង់ចាម កំពង់ធំ ព្រះវិហារ សៀមរាប បាត់ដំបង ពោធិសាត់ ព្រះសីហនុ និងកំពង់ឆ្នាំង និងថវិកាឧបត្ថម្ភ ដោយអង្គការដានីដាចំនួន ២.៤៩១បង្គោល ស្មើនឹង ៣៨៧ គីឡូម៉ែត្រ អនុវត្តនៅខណ្ឌរដ្ឋបាលព្រៃឈើខេត្ត កំពត ក្រចេះ កំពង់ស្ពឺ មណ្ឌលគីរី និងរតនគីរី

-បានសម្របសម្រួលបោះបង្គោលព្រំព្រៃ ដាក់ស្លាកការពារ និងធ្វើសារពើភណ្ឌព្រៃឈើដៃគូបានចំនួនសរុប ១៣៥ ឡូតិ៍

-បានចាប់ឃាត់និងរឹបអូសឈើគ្រប់ប្រភេទបានសរុបចំនួន ១០.០៧៩ម$^{៣}$៦៥៧ និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសបញ្ជូនទៅតុលាការចំនួន ៨២នាក់

-រដ្ឋបាលព្រៃឈើបានស្រង់ស្ថិតិដីព្រៃឈើ ដែលត្រូវបានរំលោភបំពានចំនួន ១១.១៧៩ហត ធ្វើការដេកហូតដោយពុំបានចេញដីកា ចំនួន ១.៥៨៩ ហិកតា ចេញដីកាបដិសេធដកហូតដីព្រៃឈើមកវិញមានចំនួន ១៩ដីកា ស្មើនឹង ១៧.៧៩៣ ហិកតា ស្រង់ស្ថិតិរណារយន្តបានចំនួន ៧០ គ្រឿង និងដកហូតបានចំនួន ៤៥០ គ្រឿង

-សមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើមូលដ្ឋាន បានចុះធ្វើការត្រួតពិនិត្យ និងចាប់ឃាត់ឈើល្មើសច្បាប់ពីបណ្តាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច នៅតាមបណ្តាខេត្តមួយចំនួន ដែលបានលួចកាប់ឈើពីប្រភពខាងក្រៅ នាំមករក្សាទុកធ្វើសន្និធិខុសច្បាប់ក្នុងដីសម្បទានរបស់ខ្លួនចំនួន ១២ករណី មានបរិមាណឈើចម្រុះប្រភេទ ចំនួន ១.៣៣៧ ម៣។

ក្រាហ្វិកទី ១០ ៖ បង្ហាញអំពីការដាំដុះឈើពីឆ្នាំ ២០០៦-២០១០




សកម្មភាពដាំឈើជាចំការសរុបបានចំនួន ២៨.៨៣៥ ហត ក្នុងនោះ រដ្ឋបាលព្រៃឈើដាំបាន ១.០២០ ហត ក្រុមហ៊ុនវិនិយោគឯកជនដាំដុះបានចំនួន ២៦.៧៧៥ ហត គ្រួសារឯកជនខ្នាតតូចដាំបាន ៩៧៣ ហត។ ការងារថែទាំ ដាំជួសចំការឈើចាស់របស់រដ្ឋបាលព្រៃឈើ និងកងទ័ពសម្រេចបានលើផ្ទៃដីទំហំ ៦.០៧៧ ហត ក្រុមហ៊ុនវិនិយោគឯកជនបានឈូសឆាយសំអាតដីចំនួន ៤៧.១៤៣ ហត។ ជាមួយគ្នានេះ ការងារបណ្តុះកូនឈើនៅតាមបណ្តាថ្នាលបណ្តុះកូនឈើ នៅគ្រប់កន្លែងក្នុងប្រទេសសម្រេចបានចំនួន ៩.៧៧០.២៦០ ដើម និងបានចែកជូនដល់ប្រជាជន និងដាំតាមទីសាធារណៈ អស់ ៨.១៧១.១៣៥ ដើម ។

ក្រាហ្វិកទី ១១ ៖ បង្ហាញអំពីសហគមន៍ព្រៃឈើពីឆ្នាំ ២០០៦-២០១០




នៅឆ្នាំ ២០១០ នេះ រដ្ឋបាលព្រៃឈើបានសហការជាមួយដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន

សម្របសម្រួល រៀបចំអភិវឌ្ឍសហគមន៍ព្រៃឈើសរុបចំនួន ៥១០ សហគមន៍ លើផ្ទៃដីសរុបចំនួន ៤៦៧.៨៨៤ ហិកតា ។

### ៥.៣.៦- ការវិវឌ្ឍន៍ផ្នែកផលិតកម្មជលផល

នៅក្នុងឆ្នាំ ២០១០ នេះ រដ្ឋបាលជលផលបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រី ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្សការបង្រ្កាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងបទដ្ឋានបច្ចេកទេសមួយចំនួនទៀតដែលបានរៀបចំត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តជានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយ ប្រសិទ្ធភាព ។

ជាមួយការរីកចំរើននេះដែរក្នុងឱកាសប្រារព្ធទិវាមច្ឆជាតិ ១ កក្កដា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែបានផ្តល់អនុសាសន៍ដ៏ថ្លៃថ្លាពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផល ដែលទាក់ទងដល់ការបង្រ្កាបបទល្មើស ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង ឧបករណ៍ឆក់ត្រី ការបង្កើតកន្លែងអភិរក្សធនធានជលផល ការរៀបចំនិងគ្រប់គ្រងពង្រឹងសហគមន៍នេសាទ ជំរុញការអភិវឌ្ឍវារីវប្បកម្ម ការថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងជាដើម ។ល។

-***អាជីវកម្មនេសាទទឹកសាប:*** អាជីវកម្មទឹកសាបអនុវត្តបាននៅឆ្នាំ ២០១០ សរុបចំនួន ៤០៥.០០០ តោន កើនលើសឆ្នាំមុនប្រមាណ ៣,៨៥% និងមានការថយចុះប្រមាណ ៤,០៤ % រយៈពេល ៥ ឆ្នាំ (ឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០) ប៉ុន្តែអាជីវកម្មនេសាទទឹកសាបនេះ មានការថយចុះបន្តិចពីឆ្នាំ ២០០៧ និងឆ្នាំ ២០០៩ ពោលគឺបានថយចុះពី ៣៩៥.០០០ តោន មកត្រឹម ៣៩០.០០០ តោន ឆ្នាំ ២០០៩ (ថយចុះប្រមាណ ១,២៧%)

-***អាជីវកម្មនេសាទសមុទ្រ:*** ការធ្វើអាជីវកម្មនេសាទសមុទ្រអនុវត្តបាន ៨៥.០០០តោន ក្នុងឆ្នាំ ២០១០ និងមានកំណើន ៤០,៥ % រយៈពេល៥ឆ្នាំ រយៈពេល៥ឆ្នាំ (២០០៦-២០១០)

-***ការអភិវឌ្ឍវារីវប្បកម្ម:*** ការចិញ្ចឹមត្រី បង្គា អនុវត្តបាន ៦០.០០០ តោន (ត្រី ៥៩.៩៣៥ តោន បង្គា ៦៥តោន) ស្មើ ១០០% នៃផែនការ ៦០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ១០.០០០តោន ឬកំណើន ២០% ប្រចាំឆ្នាំ ។ ជាមួយគ្នានោះ ការចិញ្ចឹមក្រពើអនុវត្តបាន ២៨៣.០០០ក្បាល ស្មើ ១៤១,៥% នៃផែនការ ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៩៨.០០០ក្បាល និងការភ្ញាស់កូនត្រីពូជ អនុវត្តបាន ១១០.៤៤០.០០០ក្បាល ស្មើ ១៣៨% នៃផែនការ ៨០.០០០.០០០ ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៤០.៦៩០.០០០ក្បាល។ ទន្ទឹមនឹងនោះ បានបង្កើតកន្លែងភ្ញាស់ត្រីនៅទូទាំងប្រទេសបានចំនួន ២៧៣កន្លែង ក្នុងនោះមាន ២៦០កន្លែង ជារបស់ប្រជាជន តាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល និងបានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន ៦៥៥កន្លែង ដែលនៅក្នុងខេត្តកំពង់ស្ពឺ ច្រើនជាងគេចំនួន ១៥៥ កន្លែង និងខេត្តសៀមរាបចំនួន ៩០ កន្លែង។ ជាមួយគ្នានោះ កន្លែងដែលបានរៀបចំហើយធ្វើឱ្យផលត្រីតាមវាលស្រែកើនពី ៤-៦ដង ជាមធ្យម នេះអាចបញ្ជាក់បានថា ប្រជាកសិករ និងប្រជានេសាទ បានទទួលយកនូវបច្ចេកទេសវារីវប្បកម្ម ដែលក្រសួងបានអនុវត្តកន្លងមក។




ក្រាហ្វិកទី ១២ ៖ បង្ហាញអំពីផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មរយៈពេល ៥ ឆ្នាំ

*លទ្ធផលដែលទទួលបានក្នុងវិស័យជលផល បានដាក់ចេញនូវវិធានការឱ្យគ្រប់អធិការដ្ឋាន និង ខណ្ឌរដ្ឋបាលជលផលទាំងអស់អនុវត្តតាមអនុសាសន៍របស់* **ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** *រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឃើញថា សកម្មភាពទាំងអស់នេះ មានការរីកចំរើនគួរជាទីមោទនៈ។ ជាមួយគ្នានេះដែរ រដ្ឋបាលជលផលក៏បានសហការជាមួយគម្រោងអង្គការក្រៅរដ្ឋាភិបាល និងប្រទេស ផ្តល់ជំនួយនានា ក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វ ផ្សាយវារីវប្បកម្ម និងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល ដើម្បីកិច្ចអភិវឌ្ឍន៍វិស័យ វារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល។*

*ម្យ៉ាងវិញទៀត ការជំរុញបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងអង្គការ នានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី បានជួយជម្រុញថែមទៀត ដល់ការលើកស្ទួយវិស័យជលផលនេះ និងបានជួយដល់ការអភិវឌ្ឍជីវភាព រស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ជនបទ ឱ្យមានភាពរីកចំរើនឈានឡើងជាលំដាប់នាពេលកន្លងមក។ ការខិតខំអនុវត្តអនុសាសន៍ របស់សម្តេចនាយករដ្ឋមន្ត្រី " ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ " បានធ្វើឱ្យវិស័យជលផលមានការរីកចំរើនគួរជាទីមោទនៈ។*

# ជំពូក ២
# លទ្ធផល និង ទិសដៅ

## V-លទ្ធផលឆ្នាំ ២០១០-២០១១ និងទិសដៅ ឆ្នាំ ២០១១-២០១២

### ៥.១- ផលិតកម្មដំណាំស្រូវ និងដំណាំផ្សេងៗ

#### ៥.១.១- លទ្ធផល

ក- ស្ថានភាព និងសភាពការណ៍សំខាន់ៗ ៖ រួមមាន

ក.១- ស្ថានភាពទឹកភ្លៀងរដូវវស្សាឆ្នាំ ២០១០ ៖(ឧបសម្ព័ន្ធទី ១)

ជារួមទូទាំងប្រទេសសភាពការណ៍អាកាសធាតុ ពិសេសទឹកភ្លៀងនៅរដូវវស្សាឆ្នាំ ២០១០ មានអំណោយផលជាមធ្យមនៅដើមរដូវ និងល្អប្រសើរនៅចុងរដូវ តែជួបការរាំងស្ងួតកណ្តាលរដូវវស្សាចាប់ពីពាក់កណ្តាលខែ សីហា រហូតដល់ពាក់កណ្តាលខែ កញ្ញា មានខេត្ត បាត់ដំបង កំពង់ឆ្នាំង ក្រចេះ ព្រះវិហារ និងស្ទឹងត្រែង។ល។ និងជួបគ្រោះទឹកជំនន់ដោយទឹកភ្លៀងចាប់ពីពាក់កណ្តាលនៃខែ តុលា ដល់ដើមខែ វិច្ឆិកា ឆ្នាំ ២០១០ មានខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ កណ្តាល រាជធានីភ្នំពេញ ព្រះវិហារ ពោធិសាត់ សៀមរាប ព្រះសីហនុ តាកែវ និងឧត្តរមានជ័យ។

ក.២-ស្ថានភាពទឹកជំនន់ឆ្នាំ ២០១០

នៅសប្តាហ៍ទី ២ នៃខែ តុលា ដល់សប្តាហ៍ទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខេត្តមួយចំនួនជួបប្រទះនឹងគ្រោះជំនន់ទឹកភ្លៀង ដូចជាខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កំពង់ធំ កណ្តាល រាជធានីភ្នំពេញ ព្រះវិហារ ពោធិសាត់ សៀមរាប ព្រះសីហនុ តាកែវ និងឧត្តរមានជ័យ។

ក.៣-សភាពការណ៍សំខាន់ៗផ្សេងៗទៀត

ឆ្នាំ ២០១០ នេះ ការងារបង្កបង្កើនផលលើដំណាំស្រូវ ទទួលរងនូវឥទ្ធិពលនៃការរាតត្បាត ដោយមមាចត្នោតនៅខេត្ត មណ្ឌលគីរី ព្រះវិហារ ស្វាយរៀង និងប៉ៃលិន។ ដោយឡែកសកម្មភាពវិនិយោគពាណិជ្ជកម្ម និងសេវាកម្មក្នុងវិស័យកសិកម្មមានសកម្មភាពផុសផុលយ៉ាងខ្លាំងក្លា។

ខ-ដំណាំស្រូវ ៖ (ឧបសម្ព័ន្ធទី ២-៩)

-ផ្ទៃដីអនុវត្តសរុបទូទាំងឆ្នាំ ២.៧៩៥.៨៩២ ហត លើសឆ្នាំមុន ៧៦.៨១២ ហត ក្នុងនោះ រដូវវស្សាអនុវត្តបាន ២.៣៩១.០១៦ហត លើសឆ្នាំមុនចំនួន ៥៦.៧៨៨ហត និងរដូវប្រាំងសរុបចំនួន ៤០៤.៨៧៦ហត លើសឆ្នាំមុន ២០.០២៤ ហត

-ផ្ទៃដីខូចខាតសរុបចំនួន ២០.៦៦១ ហត ក្នុងនោះរដូវវស្សាខូចខាត ២០.៥៨៩ ហត តែស្តារបានវិញ ២.០៩១ ហត នឹងរដូវប្រាំងខូចខាតសរុវចំនួន ៧២ ហត

-ផ្ទៃដីប្រមូលផលសរុប ៖ ២.៧៧៧.៣២៣ ហត លើសឆ្នាំមុន ១០២.៧២០ ហត ក្នុងនោះ រដូវវស្សា ២.៣៧២.៥១៩ ហត លើសឆ្នាំមុនចំនួន ៨១.៩៦៧ ហត និងរដូវប្រាំងសរុបចំនួន ៤០៤.៨០៤ ហត លើសឆ្នាំមុនចំនួន ២០.៧៥៣ ហត

-ទិន្នផលមធ្យមប្រចាំឆ្នាំ ៖ ២,៩៧០ តោន/ហត លើសឆ្នាំមុន ០,១៣៤ តោន/ហត ក្នុងនោះ រដូវវស្សា ២,៧៦០ តោន/ហត (លើសឆ្នាំមុន ០,១៤០ តោន/ហត) និងរដូវប្រាំង ៤,២០១ តោន/ហត (លើសឆ្នាំមុន ០,០៧៥ តោន/ហត)

-បរិមាណផលទទួលបានសរុប៖ ៨.២៤៩.៤៥២ តោន លើសឆ្នាំមុន ៦៦៣.៥៨២ តោន ក្នុងនោះ

*ដូវវស្សា ៦.៥៤៨.៧០៩ តោន លើសឆ្នាំមុន ៥៤៧.៣២៤ តោន និងដូវប្រាំងឆ្នាំ ២០១០-២០១១ ចំនួន ១.៧០០.៧៤៣ តោន លើសឆ្នាំមុនចំនួន ១១៦.២៥៨ តោន*

*-តុល្យភាពស្បៀង៖សល់ ២.៥១៦.៧៥២ តោនអង្ករគិតជាស្រូវ ៣.៩៣២.៤២៥ តោនលើសឆ្នាំមុនចំនួន ៤២៥.២៤០ តោន។*

**គ-ដំណាំកសិកម្មរួមផ្សំ** (*ឧបសម្ព័ន្ធទី ១០-១៧*)

**គ.១- ដំណាំរួមផ្សំ៖**

*ដំណាំរួមផ្សំអនុវត្តបានសរុប ៥៥៣.២៣៨ ហត លើសឆ្នាំមុន ៦២.៤៦៥ ហត និងបរិមាណផលសរុប ៥.៥៤៩.៦២៩ តោន លើសឆ្នាំមុន ៦៨២.០៦១ តោន។*

**គ.២- ដំណាំឧស្សាហកម្ម៖**

*ដំណាំឧស្សាកម្មអនុវត្តបានសរុប ១៩៩.៤០១ ហត លើសឆ្នាំមុន ២០.១៨៤ ហត និងបរិមាណផលសរុប ៥៨៨.៩០៣ តោន លើសឆ្នាំមុន ៣១.១៦១ តោន។*

*ពិនិត្យជារួមលទ្ធផលដំណាំកសិកម្ម បានអភិវឌ្ឍន៍ជាប្រវត្តិសាស្ត្រដ៏ល្អប្រសើរ ដែលកន្លងមកប្រទេសកម្ពុជាពុំធ្លាប់ជួបប្រទះនូវសមិទ្ធផលនៃវិស័យកសិកម្ម មានការរីកចម្រើនដូចពេលនេះ ពិសេសដំណាំស្រូវបានកើនឡើងលើសផែនការដែលបានគ្រោងទុក*

**ឃ-ដំណាំអចិន្ត្រៃយ៍**

*ដំណាំឈើហូបផ្លែ និងដំណាំអចិន្ត្រៃយ៍ ក៏មានការអភិវឌ្ឍន៍កើនឡើងជាបន្តបន្ទាប់។ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍អនុវត្តបានក្នុងឆ្នាំ ២០១០ មានសរុបចំនួន ១៩០.០០០ ហិកតា កើនលើសឆ្នាំមុន ៩%។ ដោយឡែក ចំពោះបរិមាណផលដំណាំអចិន្ត្រៃយ៍មួយចំនួនដូចជា ស្វាយចន្ទីសរុបចំនួន ៨៣.៣៨០ តោន ស្វាយសរុបចំនួន ២៧៩.៩៨០តោន ធូរេនសរុបចំនួន ២៨.៩០០តោន និងក្រូចសរុបចំនួន ២៤.៦៦០តោន។*

**៥.១.១.១-ការងារផ្នែកកសិកម្ម**

*អគ្គនាយកដ្ឋានកសិកម្មជាអង្គភាពសេនាធិការឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានបេសកកម្ម ដឹកនាំគ្រប់គ្រង និងធ្វើសកម្មភាពជំរុញការអភិវឌ្ឍវិស័យផលិតកម្មដំណាំកសិកម្ម ដើម្បីចូលរួមចំណែក (១) ធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ (២) គ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថភាពផលិតផល (៣) ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម (៤) កាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនចំណូលដល់កសិករដោយតម្លៃបន្ថែមលើកសិផល និង(៥) ធានាទីផ្សារកសិផល ។*

*អគ្គនាយកដ្ឋានកសិកម្ម បាន និងកំពុងអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដោយផ្តោតលើការងារស្រាវជ្រាវ និងអភិវឌ្ឍស្នូលសំខាន់ៗមួយចំនួនមានជាអាទិ៍ (១) ការគ្រប់គ្រងធនធានដីកសិកម្ម (២) ការអភិវឌ្ឍដំណាំកសិកម្មគ្រប់ប្រភេទ (៣) ការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (៤) ការស្រាវជ្រាវអភិវឌ្ឍ និងជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម (៥) ការផ្សព្វផ្សាយកសិកម្ម និង (៦) ការត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ ។*

*ក្នុងឆ្នាំ ២០១០ កន្លងមកនេះ ដោយមានការគាំទ្រទាំងផ្នែកស្មារតី និងសម្ភារថវិកាពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កិច្ចចូលរួមសហការ និងការគាំពារពីដៃគូអភិវឌ្ឍនានា ការចូលរួមសហការស្អិតរមួតពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងជាពិសេសការ*

ចូលរួមរបស់ប្រជាកសិករ ជាមួយគ្នានោះ បាននិងកំពុងប្រែក្លាយនូវបេសកកម្មដ៏ធំធេងនេះ ឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធិភាព ក្នុងការចូលរួមចំណែកក្នុងការជំរុញការអភិវឌ្ឍន៍ និងកំណើនវិស័យផលិតកម្មដំណាំកសិកម្ម ដោយសម្រេចបានសមិទ្ធផលសំខាន់ៗគួរជាទីមោទនៈ ។

ជាក់ស្តែង ផលិតកម្មដំណាំស្រូវដែលជា "មាស ស" របស់កម្ពុជា និងជាផ្នែកមួយដ៏សំខាន់បំផុតសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជនបទ ចូលរួមទ្រទ្រង់ជីវភាពប្រជាជនកម្ពុជាទាំងនៅទីជនបទ និងទីក្រុង សមិទ្ធិផលសម្រេចបានដ៏ត្រចះត្រចង់ នេះពិតជាមិនអាចកាត់ផ្តាច់បានពីការអនុវត្តការងារដ៏សកម្មរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអគ្គនាយក ដ្ឋានកសិកម្មតាមជំនាញដូចខាងក្រោមបានឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តួចផ្តើមរៀបចំសន្និបាតកសិករទូទាំងប្រទេស ដោយឈរលើទស្សនៈបំផុសនូវគំនិតច្នៃប្រឌិត ផ្លាស់ប្តូរបទពិសោធន៍ និងគំនិតបង្កើតថ្មីដល់កសិករ។ ក្នុងន័យនេះ កាលពីថ្ងៃទី ២១-២២ ខែ កុម្ភៈ ឆ្នាំ ២០១១ កន្លងទៅនេះ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសន្និបាតកសិករទូទាំងប្រទេសលើកទី ២ ក្នុងគោលបំណងដើម្បីធ្វើការប្រឡងប្រជែងជ្រើសរើសកសិករឆ្នើមដែលមានស្នាដៃឯក លើប្រធានបទចំនួន ៦ គឺៈ

- ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ
- ប្រព័ន្ធកសិកម្មចម្រុះ
- ការចិញ្ចឹមសត្វ
- ការចិញ្ចឹមត្រី
- ការកែច្នៃគ្រឿងយន្ត និងឧបករណ៍កសិកម្ម
- ការកែច្នៃផលិតផលកសិកម្ម និងជលផល

សន្និបាតកសិករឆ្នាំនេះ ប្រព្រឹត្តទៅប្រកបដោយមោទនភាព និងទទួលបានលទ្ធផលដ៏ល្អប្រសើរ ដោយមានសមាជិក-សមាជិកា ចូលរួមសរុបចំនួន ២១៥ នាក់ ក្នុងនោះ មានថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពក្រោមឱវាទ មន្ទីរកសិកម្មរាជធានី ខេត្ត អង្គការជាដៃគូរ និងកសិករជាបេក្ខភាពប្រឡងប្រណាំងគ្រប់រាជធានី ខេត្ត ទាំង ២៤ ទូទាំងប្រទេស។ នីតិវិធីនៃការប្រឡងជ្រើសរើសមាន ៣ ដំណាក់កាលគឺទី ១ ការវាយតម្លៃលើចំណេះដឹងបច្ចេកទេសនៃការអនុវត្តន៍ និងទេពកោសល្យនៃការពន្យល់បកស្រាយ។ ដំណាក់កាលទី ២ គឺចុះវាយតម្លៃការអនុវត្តផ្ទាល់ដោយផ្អែកលើផ្ទៃដីអនុវត្តពិតប្រាកដ និងលទ្ធផលនៃការទទួលយកនូវគំនិតថ្មី និងការច្នៃប្រឌិត ការផ្សព្វផ្សាយដល់អ្នកជិតខាង និងភាពឧស្សាហ៍ព្យាយាមក្នុងការងារផលិតកម្មនៅមូលដ្ឋាន។ ដំណាក់កាលទី ៣ គឺការធ្វើបទបង្ហាញនៅក្នុងអង្គសន្និបាតកសិករទូទាំងប្រទេសនាថ្ងៃទី ២១-២២ ខែ កុម្ភៈ ឆ្នាំ ២០១១។

បន្ទាប់ពីធ្វើការវាយតម្លៃ គណៈមេប្រយោគបានធ្វើការចម្រាញ់ជ្រើសរើសយកកសិករឆ្នើមចំនួន ៥នាក់ដែលត្រូវទទួលជ័យលាភីពីលេខ ១ ដល់លេខ ៥ សម្រាប់ប្រធានបទនីមួយៗ ចំពោះកសិករមកពីខេត្តចំនួន ១៥ គឺ ខេត្តបាត់ដំបង តាកែវ កណ្តាល កំពង់ឆ្នាំង ព្រៃវែង បន្ទាយមានជ័យ ស្វាយរៀង កំពង់ចាម រតនគីរី កំពត ស្ទឹងត្រែង ក្រចេះ សៀមរាប កំពង់ធំ និងខេត្តព្រះសីហនុ។

### ៥.១.១.២- ស្រាវជ្រាវ និងអភិវឌ្ឍដំណាំស្រូវ

ការស្រាវជ្រាវដំណាំស្រូវ ស្វែងរកបច្ចេកទេសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំស្រូវ។ ក្នុងឆ្នាំ ២០១០កន្លងមកនេះ អគ្គនាយកដ្ឋានកសិកម្ម ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងថវិកាជំនួយពីដៃគូរអភិវឌ្ឍមួយចំនួន បានអនុវត្តការងារពិសោធន៍

ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅតាមកសិដ្ឋាន ស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករមានជាអាទ៍ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធិភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្រ្តដាំដុះដំណាំស្រូវផ្សេងៗទៀត មានចំនួនសរុប ៥៥ ពិសោធន៍។

ក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ពូជសុទ្ធល្អ និងបានដំណើរការផលិតកម្មពូជលើផ្ទៃដីសរុបចំនួន ៥៥ ហិកតា ទទួលបានបរិមាណផលពូជស្រូវសុទ្ធល្អ ចំនួន ១១០តោន ផ្សព្វផ្សាយជូនប្រជាកសិករ។ លើសពីនេះ ផ្នែកបច្ចេកទេសចុះធ្វើការត្រួតពិនិត្យ និងវាយតំលៃគុណភាពគ្រាប់ពូជនៅខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តពោធិសាត់ ខេត្តកំពង់ចាម ខេត្តកំពង់ធំ និង ខេត្តស្ទឹងត្រែង បានចំនួន ១.០៥៤,៤ តោន ។

ដោយឡែក ការលើកកំពស់ និងការទទួលយកបច្ចេកវិជ្ជាផលិតកម្មដំណាំស្រូវ សម្រាប់ដំណើរការជំរុញប្រពលវប្បកម្ម និងបង្កើនផលិតភាពប្រព័ន្ធកសិកម្មមានដំណាំស្រូវជាមូលដ្ឋាន បានដំណើរការការធ្វើស្រែបង្ហាញ ការរៀបចំកម្មវិធីទស្សនកិច្ច ការបណ្តុះបណ្តាល ដែលមានកសិករចូលរួមសរុបចំនួន ៣.១១៩នាក់ ក្នុងនោះកសិករចំនួន ៥៨៩នាក់ បន្ថែមទៀតបានទទួលការបណ្តុះបណ្តាលអំពី ការងារប្រពលវប្បកម្មដំណាំស្រូវ (ប.វ.ស)។ ផ្នែកដំណាំស្រូវ និងលេខាធិការដ្ឋាន ប.វ.ស ជាសេនាធិការសហការជាមួយអង្គការ OXFAM ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា បានកែសម្រួល និងចងក្រងសៀវភៅបទដ្ឋានបច្ចេកទេស ប.វ.ស ផ្ទាំងរូបភាព និងខិតប័ណ្ណផ្សព្វផ្សាយ ដែលត្រៀមនឹងបោះពុម្ពផ្សព្វផ្សាយក្នុងពេលឆាប់ៗខាងមុខនេះ ។

### ៥.១.១.៣- ការស្រាវជ្រាវ និងអភិវឌ្ឍសាកវប្បកម្មដំណាំ

#### ក- ការស្រាវជ្រាវ និងអភិវឌ្ឍសាកវប្បកម្មដំណាំរួមផ្សំ

ការអភិវឌ្ឍអនុវិស័យ ស្រាវជ្រាវ និងអភិវឌ្ឍសាកវប្បកម្ម និងដំណាំរួមផ្សំនេះ សម្រេចបានសមិទ្ធផល ៖

-បានដំណើរការពិសោធន៍ជ្រើសរើសពូជដំណាំហូបផ្លែ និងរុក្ខជាតិលំអចំនួន ៥០ ពិសោធន៍ មានកសិករចូលរួមចំនួន ២៤៥នាក់។ តាមរយៈការងារស្រាវជ្រាវនេះ ពូជដំណាំចំនួន ០៥ពូជ ត្រូវបានពង្រីករួមមាន ពូជដំណាំស្រការនាគចំនួន ៣០០ ដើម ពូជផ្កាកូឡាបចំនួន ៦០០ដើម ពូជផ្កាគ្រីហ្សង់តែមចំនួន ៦០០ដើម ពូជផ្កាចំបីក្រហមចំនួន ៦០០ដើម ពូជផ្កាស្មៀរឿងចំនួន ១០០០ដើម ។

-បានស្រាវជ្រាវអភិរក្ស និងបន្សុទ្ធពូជដំណាំបន្លែចំនួន ០៣ពូជ និងដំណាំរួមផ្សំដទៃទៀតបានចំនួន ០៥ពូជ។

-បានចងក្រងឯកសារស្តីពីឈើហូបផ្លែនៅតំបន់ពាយ័ព្យចំនួន ១៦៧ឃុំ នៅក្នុងខេត្ត បាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ ។

-បានអនុវត្តការធ្វើស្រែបង្ហាញផ្សព្វផ្សាយពូជដំណាំរួមផ្សំ ដើម្បីលើកកំពស់ពិពិធកម្មដំណាំជាលក្ខណៈគ្រួសារបានចំនួន ២១០កន្លែង មានកសិករចូលរួមសរុប ៨៤០នាក់ ។

#### ខ- ការស្រាវជ្រាវ និងអភិវឌ្ឍសាកវប្បកម្មដំណាំឧស្សាហកម្ម

សមិទ្ធផលការងារសំខាន់ៗពាក់ព័ន្ធនឹងផ្នែកនេះ បានផ្តោតជាសំខាន់ទៅលើការអភិរក្ស និងអភិវឌ្ឍពូជដំណាំមួយចំនួន ដូចជា ដំណាំពោត ដំណាំមន ដំណាំសណ្តែក ដំណាំម្រេច និងរុក្ខជាតិគម្របដី លទ្ធផលសម្រេចបានដូចជា៖

-បានផលិតពូជដំណាំឧស្សាហកម្មលើផ្ទៃដីចំនួន ៣៥ហិកតា ទទួលបានបរិមាណផលចំនួន ៤០តោន

-បានពិសោធន៍សំរិតសំរាំងពូជពោតចំនួន ២១ពូជ (ពោតសម្រាប់ចំណីសត្វចំនួន ១០ពូជ ពោតផ្អែមចំនួន ៦ពូជ និងពោតស (ដំណើប)ចំនួន ០៥ពូជ)។ អ្នកបច្ចេកទេសកំពុងបន្តដំណើការពិសោធន៍បន្សាំពូជពោតទាំងនេះនៅលើចំការរបស់កសិករ ដើម្បីឈានទៅធ្វើការរំដោះពូជ និងផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់នាពេលខាងមុខ

-បានដំណើរការស្រែពិសោធន៍ស្រាវជ្រាវស្តីពី ការជ្រើសរើសពូជដំណាំឧស្សាហកម្ម និងបច្ចេកទេសដាំដុះសមស្របតាមប្រព័ន្ធកេរ្យត្របរិស្ថានចំនួន ១៣ពិសោធន៍

-បានដំណើរការស្រែបង្ហាញស្តីពី ការដាំដុះដំណាំឧស្សាហកម្មចំនួន ៤០០ស្រែបង្ហាញ ។

### ៥.១.១.៤- ការស្រាវជ្រាវ និងអភិវឌ្ឍធនធានដីកសិកម្ម

ជាក់ស្តែងក្នុងឆ្នាំ ២០១០ ការងារគ្រប់គ្រងធនធានដីកសិកម្ម បាននិងកំពុងទទួលបានការយកចិត្តទុកដាក់ និងលើកកំពស់ទាំងការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសគ្រប់គ្រងដីជាតិដីល្អៗ ជូនដល់ស្រទាប់ប្រជាកសិករ សម្រាប់ការកសាងផែនការការប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយចីរភាពសម្រេចបានលទ្ធផលសំខាន់ៗះ

-បានចងក្រងឯកសារបច្ចេកទេសអំពី ការកំណត់តំបន់ដាំដុះសម្រាប់ស្រុកអូរាំងឪ នៅខេត្តកំពង់ចាម ដែលពិពណ៌នាអំពីលក្ខណៈរបស់ដី និងចំណាត់ថ្នាក់ដី និងបានរៀបចំផែនទីការប្រើប្រាស់ដីកសិកម្ម និងស្ថិតិការប្រើប្រាស់ដីកសិកម្មជាក់ស្តែងតាមប្រភេទដំណាំទូទាំងខេត្តព្រៃវែង ។

-បានដំណើរការស្រែបង្ហាញអំពី ប្រសិទ្ធិភាពជីគីមីលាយជីធម្មជាតិចំនួន ៤០០ពិសោធន៍ តាមតំបន់គោលដៅចំនួន ២០ ដោយមានកសិករចំនួន ៤០០គ្រួសារចូលរួមអនុវត្តផ្ទាល់។ លទ្ធផលនៃស្រែបង្ហាញនេះបញ្ជាក់ថា ការប្រើជីគីមីកន្ទះកំរិតណែនាំ និងថែមជីកំប៉ុស្តចំនួន ១៥តោន នោះកសិករទទួលបានទិន្នផលខ្ពស់ ជាករណីបណ្តាអ្នកស្រាវជ្រាវ និងអ្នកផ្សព្វផ្សាយត្រូវតែជំរុញឲ្យកសិករចេះប្រើប្រាស់ជីគីមីលាយជីធម្មជាតិ ឲ្យសមស្របតាមលក្ខណៈបច្ចេកទេស ដែលជាកត្តាមួយប្រសើរបំផុតក្នុងការកែលំអដីជាតិដី រក្សាគុណភាពដីជាតិដី និងបង្កើនទិន្នផលដំណាំ ។

-បានដំណើរការបើកសាលារៀនស្រែកសិករអំពី បច្ចេកទេសធ្វើជីកំប៉ុស្តចំនួន ៤០ កន្លែង មានកសិករចូលរួមសរុបចំនួន ១២០០នាក់ និងមានកសិករចំនួន ៧០០គ្រួសារបានសាងសង់រោងជីកំប៉ុស្ត ។

-បានចូលរួមចុះសិក្សា និងវាយតំលៃដីសម្បទានសេដ្ឋកិច្ចបានចំនួន ២៥ក្រុមហ៊ុន នៅតាមបណ្តាខេត្តចំនួន ០៧ ដែលមានផ្ទៃដីសរុបចំនួន ២៥៧.៥៨៩ហិកតា ។

### ៥.១.១.៥- ការអភិវឌ្ឍបច្ចេកទេសការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

ក្នុងឆ្នាំ ២០១០ ក្រៅពីការងារចុះពិនិត្យតាមដានសភាពការណ៍នៃការរាតត្បាតរបស់សមាសភាពចង្រៃ និងដឹកនាំកិច្ចអន្តរាគមន៍កំចាត់សមាសភាពចង្រៃនៅទូទាំងប្រទេស ក៏បានអនុវត្តសកម្មភាពមួយចំនួន ដោយទទួល បាន លទ្ធផលដូចខាងក្រោមះ

-បានចងក្រងបញ្ជីឈ្មោះសមាសភាពចង្រៃលើដំណាំដំឡូងមី

-បានចងក្រងទិន្នន័យគ្រឹះសមាសភាពចង្រៃក្នុងប្រព័ន្ធកុំព្យូទ័រសម្រាប់ដំណាំស្រូវ ដំណាំប៉េងប៉ោះ ដំណាំសណ្តែក ដំណាំដំឡូង ដំណាំកៅស៊ូ និងដំណាំតែ

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មល្អដើម្បីបង្កើនគុណភាពផលិតផល និងសុវត្ថិភាពចំណីអាហារចំនួន ៣៦វគ្គ មានកសិករចូលរួមចំនួន ១២៦០នាក់

-បានបើកវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកសិកម្មចំនួន ៣៦វគ្គ មានកសិករចូលរួមចំនួន ១២៦០នាក់

-បានដំណើរការវគ្គបណ្តុះបណ្តាលស្តីពី វិធានការកំចាត់សត្វល្អិតចង្រៃលើដំណាំបន្លែចំនួន ៣៦វគ្គ មានកសិករចូលរួមចំនួន ១១៦០នាក់

-បានដំណើរការស្រែពិសោធន៍ស្តីពី ការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិតផ្សំពីរុក្ខជាតិលើដំណាំចំនួន ១៤៤ ពិសោធន៍

-បានធ្វើអង្កេតរុយចោះផ្លែលើដំណាំស្វាយនៅខេត្ត កំពង់ស្ពឺ កំពត ព្រះសីហនុ កំពង់ចាម និង កណ្តាល និងបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពអំពីការអង្កេត និងកំចាត់រុយចោះផ្លែមន្ត្រីបច្ចេកទេសមកពីមន្ទីរកសិកម្មនៃ ខេត្ត ទាំង ០៥ ចំនួន ៧០នាក់

ទាក់ទងនឹងការជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារបរទេស ក្នុងឆ្នាំ ២០១០ កន្លងមកនេះ អគ្គនាយកដ្ឋានកសិកម្ម បានចាត់បញ្ជូនមន្ត្រីបច្ចេកទេសភូតគាមអនាម័យចុះធ្វើការត្រួតពិនិត្យផលិតនាំចេញបានចំនួន ២៦៨លើក និងផ្តល់វិញ្ញាបនប័ត្រភូតគាមអនាម័យចំនួន ៦២០ច្បាប់ សម្រួលដល់ការនាំចេញផលិតផលកសិកម្មចំនួន ១៣មុខទំនិញ មានបរិមាណសរុបចំនួន ១០៥.២៥៩តោន ក្នុងនោះមុខទំនិញសំខាន់ៗរួមមាន៖ អង្ករ (៥៥.៣០១តោន) ចំណិតឈើអាកាស្យា (៣២.០០០តោន) ប្រេងដូងខៅ (៨.៤២៣តោន) និងពោតក្រហម (៦.៦៣៥តោន)។ ជាការគួរឲ្យកត់សំគាល់នោះ គឺ ផលិតផលអង្ករកម្ពុជាបាននាំចេញទៅកាន់ទីផ្សារបរទេសចំនួន ៣១ប្រទេស ដែលភាគច្រើន (៦១,២%) ជាបណ្តាប្រទេសអឺរ៉ុប ក្នុងនោះ បារាំងជាប្រទេសនាំមុខគេ ដែលបានស្រូបយកផលិតផលអង្ករកម្ពុជាចំនួន ៣១.៥៥២តោន។ បណ្តាប្រទេសដែលបាននាំចូលអង្ករលើសពីមួយពាន់តោនពីកម្ពុជារួមមាន៖ ប្រទេសប៉ូឡូញ (៣.៦៤៨តោន) ប្រទេសលីទុអានី (២.៧៣៦តោន) ប្រទេសព័រទុយហ្គាល់ (១.៩៥៤តោន) ប្រទេសរុស្សី (១.៧៥២តោន) ប្រទេសបេឡារូស (១.៤១៦តោន) ប្រទេសអូស្ត្រាលី (១.២៤៩តោន) ប្រទេសហូឡង់ (១.១៩៨តោន) ប្រទេសម៉ាឡេស៊ី (១.១១១តោន) ចក្រភពអង់គ្លេស (១.០១៩តោន) ។

**៥.១.១.៦- ការពង្រឹងការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍**

មន្ទីរពិសោធន៍ជាតិកសិកម្មក្នុងឆ្នាំ ២០១០ នេះ សម្រេចបានសមិទ្ធិផល សំខាន់ៗដូចខាងក្រោម៖

-បានបើកវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពបច្ចេកទេស មន្ត្រីរាជការមន្ទីរពិសោធន៍ជាតិ ចំនួន ០១វគ្គ មានសិក្ខាកាមចូលរួមចំនួន ១៥នាក់។ វគ្គបណ្តុះបណ្តាលបានផ្តោតលើការវិភាគគុណភាពទឹក វិធីសាស្ត្រយកសំណាកដី ដី ថ្នាំកសិកម្ម និងរុក្ខជាតិ ការប្រើប្រាស់ឧបករណ៍ GPS ការវិភាគគុណភាពថ្នាំកសិកម្ម និងវិធីសាស្ត្របកស្រាយលទ្ធផលវិភាគដី

-បានផ្តល់សេវាពិសោធន៍វិភាគដី និងដីបានចំនួនសរុប ១០០សំណាក ក្នុងនោះ ដីចំនួន ៤៤ សំណាក និងដីចំនួន ៥៦សំណាក

-បានចុះប្រមូលសំណាកដី ដី ថ្នាំកសិកម្ម និងរុក្ខជាតិយកមកធ្វើការវិភាគ និងកត់ត្រាទិន្នន័យបានចំនួន ១៦០០សំណាក។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់សេវាកម្មវិភាគថ្នាំកសិកម្ម និងកាកសំណល់គីមី មន្ទីរពិសោធន៍ជាតិកសិកម្ម បានរៀបចំជាវិធីសាស្ត្រវិភាគបានចំនួន៣៧វិធីសាស្ត្រ និងក្រោមក្របខណ្ឌសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន មន្ទីរពិសោធន៍ជាតិបាន និងកំពុងបណ្តុះ

បណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីបច្ចេកទេសអំពី វិសាស្ត្រវិភាគដី និងថ្នាំកសិកម្មដោយប្រើឧបករណ៍វិភាគទំនើបៗ

**៤.១.១.៧- ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

-បាន និងកំពុងពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពី "ការការពារដំណាំ និងភូតគាមអនាម័យ"

-បាន និងកំពុងព្រាងសេចក្តីព្រាងច្បាប់ស្តីពីសហករណ៍កសិកម្ម"

-បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី "ការគ្រប់គ្រងពាងជាងផលិត កែច្នៃ ដំឡើង និងពាងជាងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម" (បាន និងកំពុងពិនិត្យកែសម្រួលបន្ទាប់ពីបានដាក់ឆ្លងគណៈរដ្ឋមន្ត្រី)

-បានរៀបចំប្រកាសស្តីពី "បទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍អភិវឌ្ឍកសិកម្ម" (ក្រសួងបានអនុម័តរួចហើយ)

-បានរៀបចំប្រកាសស្តីពី "បញ្ជីឈ្មោះសមាសភាពចង្រៃភូតគាមអនាម័យ និងបង្កគ្រោះថ្នាក់ដែលត្រូវហាមឃាត់ចូលព្រះរាជាណាចក្រកម្ពុជា" (ក្រសួងបានអនុម័តរួចហើយ)

-ប្រកាសស្តីពី "នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ" (ក្រសួងបានអនុម័តរួចហើយ)

-ប្រកាសស្តីពី "ការដាក់ឲ្យប្រើប្រាស់នូវវិធាននៃការអនុវត្តកសិកម្មល្អ ក្នុងការងារផលិតកម្មផ្លែឈើ និងបន្លែស្រស់" (ក្រសួងបានអនុម័តរួចហើយ)

-បានរៀបចំសេចក្តីព្រាងប្រកាសរួមស្តីពី "សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ" (បានដាក់ជូនក្រសួងរួចហើយ)

-បាន និងកំពុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ច្បាប់ដីកសិកម្ម" ដោយបានបង្កើតក្រុមការងារ និងរៀបចំការប្រជុំពិគ្រោះយោបល់ផ្ទៃក្នុងបានចំនួន ០៣លើក ធ្វើការទំនាក់ទំនងប្រមូលព័ត៌មាន និងឯកសារពីស្ថាប័នពាក់ព័ន្ធ និងបានប្រជុំពិគ្រោះយោបល់ ជាមួយទីប្រឹក្សាបច្ចេកទេសរបស់អង្គការ FAO ចំនួន ០១លើក ។

**៤.១.១.៨- ការងារកម្មវិធីស្តីពីវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM)**

ជាលទ្ធផលក្នុងឆ្នាំ ២០១០ នេះ ក្រោមការឧបត្ថម្ភថវិកាដោយប្រទេស ស៊ុយអែត បានដំណើរការសាលារៀនចំការកសិករសរុបចំនួន ៧៤ សាលា ដោយមានកសិករសរុបចំនួន ១៨៩៣ នាក់ (ស្ត្រីចំនួន ៨២២ នាក់) បន្ថែមទៀតបានទទួលការបណ្តុះបណ្តាលឲ្យក្លាយជាកសិករ IPM ក្នុងនោះ ៖

-បានដំណើរការសាលារៀនចំការកសិករលើដំណាំបន្លែសរុបចំនួន ៥០សាលា មានកសិករចូលរួមចំនួន ១.២១១នាក់ ក្នុងនោះស្ត្រីចំនួន ៥៩២នាក់

-បានដំណើរការសាលារៀនស្រែកសិករលើដំណាំស្រូវសរុបចំនួន ២៤សាលា មានកសិករចូលរួមសរុបចំនួន ៦៨២នាក់ ក្នុងនោះស្ត្រីចំនួន ២៣០នាក់ ។

ដោយឡែក កសិករសរុបចំនួន ១៦៣៦នាក់ (ស្ត្រីចំនួន ៧៥៦នាក់) ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលរួចហើយ បានទទួលការពង្រឹងសមត្ថភាពបន្តពីកម្មវិធី វិធានការចម្រុះគ្រប់គ្រងដំណាំតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

-សកម្មភាពក្រោយសាលារៀនចំការកសិករលើដំណាំបន្លែសរុបចំនួន ៣២កន្លែង មានកសិករចូលរួមចំនួន ៥៣១នាក់ ក្នុងនោះស្ត្រីចំនួន ២៨០នាក់

-សកម្មភាពក្រោយសាលារៀនចំការកសិករលើដំណាំស្រូវសរុបចំនួន ១៩កន្លែង មានកសិករចូលរួមចំនួន ៣៣៤នាក់ ក្នុងនោះស្ត្រីចំនួន ១៣៤នាក់

-ដំណើរការក្លឹបចាស់លើដំណាំបន្លែសរុបចំនួន ២៤ក្លឹប មានកសិករចូលរួមសរុប ៣៨៧នាក់ ក្នុងនោះស្ត្រី ចំនួន ១៩៥នាក់ ។

-ដំណើរការក្លឹបចាស់លើដំណាំស្រូវសរុបចំនួន ២២ក្លឹប មានកសិករចូលរួមសរុប ៣៨៤នាក់ ក្នុងនោះស្ត្រី ចំនួន ១៤៧នាក់ ។

**៩.១.២-វាយតំលៃ និងសំណើ**

ក្នុងឆ្នាំ ២០១០ នៃអាណត្តិទី ៤ នៃរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** ទោះបីស្ថិតនៅក្នុងដំណាក់កាលពឹងផ្អែកលើធម្មជាតិ និងជាញឹកញាប់បានទទួលរងការគំរាមកំហែង ពីគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់ក្តី វិស័យកសិកម្មកម្ពុជាបាន និងកំពុងមានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយក្តីសង្ឃឹមថា វិស័យនេះពិតជានឹងក្លាយជាឆ្អឹងខ្នងយ៉ាងរឹងមាំសម្រាប់ការពន្លឿន និងការពង្រីកមូលដ្ឋានអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា បន្តចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស្វាហាប់ និងចីរភាព។ ការសម្រេចបាននូវកំណើនផលិតកម្មស្រូវក្នុងឆ្នាំ ២០១០ កន្លងមកនេះជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗជាច្រើន ជាមូលដ្ឋានគាំទ្រដល់ក្តីសង្ឃឹម និងលទ្ធភាពនៃការសម្រេចបាននូវចក្ខុវិស័យស្តីពី ការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសនាំចេញ មាសស (អង្ករ) ដ៏សំខាន់មួយ ក្នុងចំណោមប្រទេសនាំចេញអង្ករក្នុងពិភពលោក ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ដូចដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី ៤ នៅក្នុងឯកសារគោលនយោបាយស្តីពី "ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ"។ និយាយជារួម គឺវិស័យកសិកម្មកម្ពុជាកំពុងតែមានការវិវត្តប្រកបដោយអត្ថន័យទាំងបរិមាណ និងគុណភាព។ ប្រជាកសិករកាន់តែមានសមត្ថភាពជានាបាននូវភាពម្ចាស់ការ នៅក្នុងដំណើរការផលិតកម្ម ដោយសារការខិតខំរបស់រាជរដ្ឋាភិបាលដែលបាន និងកំពុងធ្វើឲ្យមានការរីកចំរើនជាបណ្តើរៗ នូវមូលដ្ឋានបម្រើឲ្យផលិតកម្ម និងពាណិជ្ជកម្មសិកម្ម ពិសេសការរីកចំរើនខាងប្រព័ន្ធធារាសាស្ត្រយន្តូបនីយកម្មកសិកម្ម ពូជដំណាំមានគុណភាព បច្ចេកទេសដាំដុះ និងថែទាំដំណាំថ្មីៗ និងយន្តការសម្របសម្រួលទីផ្សារផលិតផលកសិកម្ម ។ល។ ព្រមជាមួយគ្នានេះ ប្រជាកសិករក៏កំពុងតែមានការកែប្រែទំលាប់ និងផ្នត់គំនិតជាបណ្តើរៗ ក្នុងការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្ម និងពិពិធកម្មដំណាំត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស ដែលជាផ្លែផ្កាកើតចេញពីការបំពេញការងារមិនចេះនឿយហត់ និងប្រកបដោយស្មារតីទទួលខុសត្រូវ និងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកសិកម្ម និងអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ក្រោមការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី សម្ភារ ថវិកា និងការដឹកនាំចង្អុលបង្ហាញប្រកបដោយប្រសិទ្ធិភាពរបស់ថ្នាក់ដឹកនាំក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ជាន់ថ្នាក់ ពិសេស **ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**៩.១.៣-វិធានការ**

- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ន រួមមាន៖

▪ ច្បាប់ការពាររុក្ខជាតិ និងភូតគាមអនាម័យ ច្បាប់ដីកសិកម្ម និងច្បាប់សហគមន៍កសិកម្ម

- រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម
- អនុក្រឹត្យស្តីពី"ការគ្រប់គ្រងពាងជាងផលិត កែច្នៃ ដំឡើង និងពាងជាងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម"
- អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពី "ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ" និងអនុក្រឹត្យស្តីពី "បុណ្យដារលាន"
- ប្រកាសរួមស្តីពី"សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ"
- ប្រកាសស្តីពី"ការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ"
- វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់និងត្រារបស់មន្ត្រីភូតគាមអនាម័យ

- ជំរុញការលើកកំពស់ផលិតភាព និងពិពិធកាវូបនីយកម្មកសិកម្ម តាមរយៈការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗនូវគោលដៅនៃគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា

- ពង្រឹង និងពង្រីកសេវាអប់រំផ្សព្វផ្សាយបច្ចេកទេស ជូនដល់ប្រជាកសិករឲ្យបានកាន់តែទូលំទូលាយ និងសីជម្រៅថែមទៀត តាមរយៈការកសាងមណ្ឌលផ្សព្វផ្សាយកសិកម្មឃុំ និងដំណើរការសកម្មភាពកសាងសមត្ថភាពមូលដ្ឋានគ្រប់រូបភាព ដូចជាការបើកសាលារៀនស្រែកសិករ ការបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ការធ្វើស្រែបង្ហាញ ការផ្លាស់ប្តូរទស្សនកិច្ចសិក្សា។ល។ ដើម្បីពង្រីកការទទួល យកទៅអនុវត្តនូវបច្ចេកទេសសមស្រប ក្នុងចំណោមប្រជាកសិករទាក់ទងនឹងការដាំដុះ និងថែទាំដំណាំ ការគ្រប់គ្រងដីជាតិដី ការការពារដំណាំ ការប្រើប្រាស់ និងថែទាំគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ការប្រមូលផល ទុកដាក់ និង កែច្នៃក្រោយពេលប្រមូលផល

- រៀបចំចុះបញ្ជី និងព្រងឹងសហគមន៍កសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំ ក្នុងភាពជាដៃគូរជាមួយផ្នែកឯកជននានា ដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មី និងឥណទានគ្រប់គ្រាន់សម្រាប់ការពង្រីកផលិតកម្ម ជាពិសេសដំណាំស្រូវតម្រង់ឆ្ពោះទៅកាន់ទីផ្សារនាំចេញ

- ជំរុញការងារអង្កេតសិក្សា វាយតម្លៃ និងការធ្វើសារពើភ័ណ្ឌការប្រើប្រាស់ដីកសិកម្មឱ្យបាននៅទូទាំងប្រទេស ដើម្បីទទួលបាននូវទិន្នន័យជាក់លាក់ជាធាតុចូល សម្រាប់បម្រើឱ្យការរៀបចំផែនការ អភិវឌ្ឍវិស័យកសិកម្ម ដោយអាចកំណត់បានដំបន់ដាំដុះជាក់លាក់ តម្រង់ទិសដល់ការធ្វើប្រពលវប្បកម្ម និងពិពិធកាវូបនីយកម្មកសិកម្ម ជាពិសេសនៅតាមតំបន់មានប្រភពទឹក

- ពង្រឹងឡើងវិញរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យគ្រឿងយន្តកសិកម្មរាជធានី-ខេត្ត ដោយរៀបចំផែនការដាក់ឲ្យផ្នែកនេះដំណើរការបានល្អប្រសើរឡើងវិញ និងត្រូវបង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍនានារួមទាំងវិស័យឯកជន ដើម្បីអភិវឌ្ឍយន្តូបនីយកម្មកសិកម្មនៅកម្ពុជាឲ្យមានប្រសិទ្ធភាព និងចីរភាព

- រៀបចំទិវាផ្កាជាការដាស់រំលឹកដល់គ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត ឱ្យមានការយកចិត្តទុកដាក់ខិតខំជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍដំណាំលម្អ

- ពង្រឹង និងពង្រីកសមត្ថភាពពិសោធន៍វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកា ដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យ

គ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធ្វើបទកម្មលើផលិតផល និងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកំពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងជានាសុខភាពសាធារណៈ

- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍជាតិអន្តរជាតិ និងផ្នែកឯកជន សំដៅគៀងគរជំនួយឧបត្ថម្ភគ្រប់ប្រភេទចាំបាច់សម្រាប់ការចូលរួមចំណែក ក្នុងបុព្វហេតុការស្រាវជ្រាវ អភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាដើម្បីលើកកំពស់ផលិតភាព និងពិពិធភាវូប-នីយកម្មកសិកម្ម

- បន្តនូវប្រពៃណីល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្ម ការិយាល័យកសិកម្មស្រុក ក៏ដូចជាមន្ទីរ ការិយាល័យជំនាញពាក់ព័ន្ធឱ្យបានល្អប្រសើរ ដើម្បីធ្វើយ៉ាងណាឱ្យកសិករទទួលបានបន្ថែមទៀតនូវព័ត៌មានថ្មីៗស្តីពី បច្ចេកទេសផលិតកម្មកសិកម្ម ទាន់សភាពការណ៍ និងមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងស្មារតីសាមគ្គីភាពទូលាយ ។

### ៥.២-ផលិតកម្ម និងបសុព្យាបាល (ឧបសម្ព័ន្ធទី ១៨-២៦)

សមិទ្ធផលធំៗជាច្រើន កំពុងមានឥទ្ធិពលជាវិជ្ជមានទៅលើការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទាក់ទាញ វិនិយោគទុន ដែលជាបុព្វលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។ សមិទ្ធផលសម្រេចបាន ដោយសារការខិតខំកអនុវត្តន៍នូវគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ដោយសារការជួយឧបត្ថម្ភគាំទ្រ ពីរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន កិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា និងការចូលរួមចំណែកយ៉ាងសកម្មពីវិស័យឯកជន និងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជនកម្ពុជា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ បានទាន់ពេលវេលា។

ទន្ទឹមនឹងនោះ ជម្ងឺឆ្លងសត្វ គឺនៅជាបញ្ហាប្រឈមសំខាន់បំផុត ដែលបាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការប្រយុទ្ធប្រឆាំង ជាពិសេសជំងឺផ្តាសាយបក្សី ដែលបានផ្ទុះឡើងចំនួន ០២ កន្លែង នៅក្នុងភូមិប្រឡាយមាស ឃុំរមេញ ស្រុកកោះអណ្តែត ខេត្តតាកែវ នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១០ និងនៅភូមិពាមស្តី ឃុំព្រែកជ្រៃ ស្រុកកំពង់លាវ ខេត្តព្រៃវែង នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១០។ ក្រៅពីជម្ងឺនេះ នាពាក់កណ្តាល និងចុងឆ្នាំ ២០១០ នេះ ជម្ងឺជ្រូកត្រចៀកខៀវ និងជម្ងឺអុតក្តាម គឺមានការផ្ទុះរាលដាលយ៉ាងខ្លាំងក្លានៅក្នុងខេត្តមួយចំនួនធំ ដែលបង្កឱ្យសត្វជាច្រើនរយក្បាលឈឺ និងងាប់។ ជាមួយគ្នានោះ ការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ចាត់វិធានការជួយសង្គ្រោះទាន់ទាន់ពេលវេលា ជាពិសេសក្រោមការដឹកនាំដ៏ឈ្លាសវៃ និងដំផ្ទើមរបស់**ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំក្រសួង និងរួចសហការមន្ត្រីបច្ចេកទេស មន្ទីរកសិកម្មខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ ប្រជាកសិករម្ចាស់សត្វ និងម្ចាស់ជំនួយពីអង្គការជាតិ និងអន្តរជាតិនានា។

### ៤.២.១-លទ្ធផល

#### ៤.២.១.១-តាមគោលដៅ និងយុទ្ធសាស្ត្រសំខាន់ៗ

ក្នុងឆ្នាំ ២០១០ នេះ បានកំណត់គោលដៅ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍អនុវិស័យផលិតកម្ម និងបសុព្យាបាល ដើម្បីបង្កើននូវផលិតភាពសត្វ ដោយធានាបាននូវកំលាំង អូសទាញការពារ និងទប់ស្កាត់ជំងឺឆ្លងសត្វ សុខភាពសាធារណៈម្ហូបអាហារ និងការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីប្តូរជារូបិយបណ្ណ័ សម្រាប់ជាចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ជាមួយនឹងការអនុវត្តការងារលើនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យរយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោង និងសកម្មភាពកម្មវិធីជាអទិភាពទាំងនេះ សម្រាប់ការអនុវត្តឱ្យស្រប តាមគោលនយោបាយជាតិរួមមាន៖

-កសាងច្បាប់ និង អភិវឌ្ឍធនធានមនុស្ស

-ការកាត់បន្ថយអត្រាសត្វឈឺ និងងាប់

-ការធ្វើឱ្យប្រសើរឡើងនូវសុខភាពសាធារណៈ ពិសេសជំងឺឆ្លងពីសត្វទៅមនុស្ស និងជីវសុវត្ថិភាព

-ជម្រុញធ្វើឱ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វ និងធ្វើឱ្យប្រសើរឡើងនូវពូជសត្វ

-ជម្រុញការកែច្នៃលាមកសត្វ តាមរយៈការបង្កើតឡជីវឧស្ម័ន

-ជម្រុញការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករ ដោយមានជីវសុវត្ថិភាពនៅកន្លែងមានឡជីវឧស្ម័ន

-បង្កើន និងពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយលើការងារផលិតកម្មសត្វ និងសុខភាពសត្វ

-ជម្រុញឱ្យប្រសើរឡើងនូវឥណទានក្នុងការសាងសង់ឡជីវឧស្ម័ន និងការចិញ្ចឹមសត្វ

-លើកទឹកចិត្តការវិនិយោគលើការចិញ្ចឹមសត្វ សេវាសុខភាពសត្វ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារសត្វ និងផលិតផលមានដើមកំណើតពីសត្វ

#### ៤.២.១.២-លទ្ធផលសំរេចបានក្នុងឆ្នាំ ២០១០

លទ្ធផលសំខាន់ៗនៃវិស័យផលិតកម្ម និងបសុព្យាបាលឆ្នាំ ២០១០ សម្រេចបានដូចខាងក្រោម៖

- កសិដ្ឋាន និងកន្លែងចិញ្ចឹមសត្វសរុប ៤.១១៤កន្លែង ដែលមានសត្វសរុបចំនួន ២.៦១២.៤៦៣ក្បាល ក្នុងនោះ កសិដ្ឋានមាន់ពង មាន់សាច់ ៣០៧ កសិដ្ឋានទា ៥៦៨ កសិដ្ឋានជ្រូក ៣.០៩៥ កសិដ្ឋាន គោ ៦៣ កន្លែង គោទឹកដោះ ១ កន្លែង និងកសិដ្ឋានពពែចៀមចំនួន ៦៧ កន្លែង

- ស្ថានីយចិញ្ចឹមសត្វជ្រូកសរុប ចំនួន ២៦៣ ក្បាល ក្នុងនោះ មេ មានចំនួន ១៥០ ក្បាល បាមានចំនួន ២៣ ក្បាល និងកូនជ្រូកចំនួន ៩០ ក្បាល។ នៅក្នុងឆ្នាំ ២០១០ ស្ថានីយបានបង្កាត់មេជ្រូកបានចំនួន ១៥៥ ក្បាល ក្នុងនោះ មានមេ ១៣០ ក្បាល បង្កើតកូនបានលក់កូនជ្រូកពូជចំនួន៨៧១ក្បាល ជូនដល់កសិករនៅតាមរាជធានី ខេត្ត ក្រុងទូទាំងប្រទេស

- ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ បានរៀបចំ និងកំពុងជម្រុញលើការចិញ្ចឹម ការថែទាំ ការបង្កាត់ពូជ កែលំអពូជគោ ការដាំដំណាំចំណីសត្វក្នុងស្ថានីយ ជាពិសេសកែច្នៃចំណីគោត្រៀមសម្រាប់រដូវប្រាំងដែលខ្វះស្មៅ ឱ្យការចិញ្ចឹមគោក្នុងស្ថានីយមាននិរន្តរភាព។ ក្នុងស្ថានីយគោសរុបចំនួន ១៩៦ក្បាល ក្នុងនោះញី ១៥៤ ក្បាល និងឈ្មោល ៤២ ក្បាល កូនកើតថ្មី ៦ ក្បាល ក្នុងនោះកំផែងសែន ៤ ក្បាល គោលក់ ៦ ក្បាល គោងាប់ ៨ ក្បាល។ ស្ថានីយបានចែកពូជស្មៅទៅតាមបណ្តាខេត្តមួយចំនួន៖ ឃីងគ្រាសខេត្តកំពង់ចាម ចំនួន ២០០ បាច់ ខេត្ត កំពង់ធំចំនួន ២០០ បាច់ ខេត្តកណ្តាល ២០០ បាច់ តាកែវចំនួន ១៥០

- ការកែលំអរពូជសត្វ និងការដាំដំណាំចំណីសត្វ កំពុងតែមានការរីកចំរើនល្អប្រសើរ និងពង្រីកការផ្សព្វផ្សាយពូជសត្វ និងពូជស្មៅជាបន្តទៅតំបន់ផ្សេងៗ ទូទាំងប្រទេសយ៉ាងផុសផុល

- គំរោងសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ បានអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ ខេត្ត ប្រកបដោយជោគជ័យ មាន សរុបចំនួន ១០.១៤៦ឡ ក្នុងនោះនាឆ្នាំ ២០១០ ផលិតបានចំនួន ៣.៧៤៤ឡ

- ព័ត៌មានទីផ្សារសត្វ និងផលិតផលសត្វ មានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយពីតំលៃសត្វ និងផលិតផល សត្វដល់ប្រជាកសិករនៅតាមមូលដ្ឋាន សម្រាប់ជាមូលដ្ឋានក្នុងការលក់ដូរសត្វរបស់កសិករ និងការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្ត នៅទូទាំងប្រទេស ដោយសហការជាមួយអង្គការជាដៃគូ និងផ្នែកឯកជន គឺមានការអនុវត្តបានល្អប្រសើរជាងឆ្នាំមុនៗ

- ជម្ងឺអុតក្តាម សារទឹក បូសខ្យល់ ជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀត គឺត្រូវបានចាត់ទុកថា ជាជម្ងឺឆ្លងដ៏សំខាន់ ដែលនៅតែបន្តការបង្កនូវភាពស្មុគ្រស្មាញ បំផ្លិចបំផ្លាញ និងគ្រោះមហន្តរាយដល់អាយុជីវិតមនុស្ស សត្វ

- ជម្ងឺផ្តាសាយបក្សី គឺនៅជាបញ្ហាចំបងមានការផ្ទុះឡើងចំនួន ០១ករណី នៅខេត្តតាកែវ និង ព្រៃវែង

- ការទប់ស្កាត់ជម្ងឺឆ្លងសត្វ: បានពង្រឹងការត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វពង្រឹងការស្រាវជ្រាវ យកវត្ថុវិភាគ ធ្វើការផ្សព្វផ្សាយជាប្រចាំនូវផលប៉ះពាល់នៃជម្ងឺឆ្លង វិធានការការពារ និងជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វនៅតាមផ្ទះ ក៏ដូចជានៅតាមកសិដ្ឋាន ចុះស្រាវជ្រាវ និងទប់ស្កាត់តាមគ្រប់ ច្រកនាំចូលពិសេសបណ្តាខេត្តតាមព្រំដែន រាយការណ៍ជាប្រចាំពីស្ថានភាពវិវត្តន៍នៃជម្ងឺឆ្លង និងលទ្ធផលនៃការអនុវត្តវិធានការទាំងឡាយ

- ការទប់ស្កាត់បទល្មើស: ការឃាត់ចាប់ និងដុតកំទេចចោលតាមវិធានបសុពេទ្យផលិតផលសត្វខុសច្បាប់នាំមកពីប្រទេសជិតខាងមានចំនួន ១៣៧ ករណី

- ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ការនាំចេញសត្វគោ ក្របីក្នុងស្រុកគោឆ្លងកាត់ ការនាំចូលជ្រូក ព្រមទាំងបាននាំចេញ-ចូលសត្វ និងផលិតផលមានដើមកំណើតសត្វប្រភេទផ្សេងទៀត

- ភ្នាក់ងារសុខភាពសត្វភូមិសរុបចំនួន ១២.៤៧៤ នាក់ ក្នុងនោះ បានធ្វើការបំពាក់បំប៉នបន្ថែមចំនួន ១៧៨៨ នាក់ ដោយគំរោង AHICPEP របស់ធនាគារពិភពលោក។ ភ្នាក់ងារសុខភាពសត្វភូមិ ក្នុងឆ្នាំ ២០១០ បានថយចុះចំនួន ៧៧៦ នាក់ (- ៥,៨៦%) ធៀបនឹងឆ្នាំ២០០៩

-សត្តឃាតដ្ឋានដែលមានគោលការណ៍អនុញ្ញាតចំនួន ៧៨ កន្លែង នៅតាមបណ្តារាជធានី ខេត្ត បានធ្វើរោគវិនិច្ឆ័យចំនួន ២៣.២២៣ សំណាកវត្ថុវិភាគ។ លទ្ធផលវិភាគបានរកឃើញនូវប្រភេទមេរោគ និងជម្ងឺមួយចំនួនដូចជា មេរោគជំងឺផ្តាសាយបក្សី H5N1 លើបក្សីនៅខេត្តតាកែវ និងព្រៃវែង ជម្ងឺសារទឹកគោ-ក្របី ជំងឺអុតក្តាមគោ ក្របី និងជ្រូក ជំងឺប៉េស្តជ្រូក រកឃើញមានកំរិតអង់ទីបូឌីជម្ងឺជ្រូកត្រចៀកខៀវ ជម្ងឺញូវកាសលើបក្សី និងជំងឺបង្កដោយប៉ារ៉ាស៊ីតមួយចំនួនទៀត

-អង្កេតតាមដាន និងស្រាវជ្រាវជម្ងឺសត្វ បានសិក្សាស្រាវជ្រាវកន្លែងផ្ទុះជម្ងឺសារទឹក អុតក្តាម និងប៉េស្តជ្រូក នៅតាមបណ្តារាជធានី ខេត្ត និងតាមដានឃ្លាំមើលពីស្ថានភាពជម្ងឺផ្តាសាយបក្សី នៅតាមបណ្តា

ភូមិនៅទូទាំងប្រទេស ដោយប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ ព្រមទាំងនៅតាមទីផ្សារលក់បក្សីរស់ រាជធានី ខេត្តផងដែរ

-ប្រព័ន្ធព័ត៌មានជំងឺសត្វ មានការរៀបចំជាលក្ខណៈប្រព័ន្ធបានល្អប្រសើរ ពីមូលដ្ឋានរហូតដល់ថ្នាក់ជាតិ គឺរាជធានី ខេត្ត បានរាយការណ៍បន្តជូនក្រសួង ប្រទេសជិតខាង អង្គការអន្តរជាតិនានា ពិសេសអង្គការ OIE, FAOតាមរយៈ ARAHIS និង WAHIS និងអ្នកពាក់ព័ន្ធដទៃទៀត

-កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផលល្អគួរឱ្យកត់សំគាល់ ដូចជា ការកសាងលិខិតបទដ្ឋានគតិយុត្តនៃអនុក្រឹត្យលេខ ១៦ និង ១០៨ អនក្រ.បក ស្ទើរតែបានបញ្ចប់សព្វគ្រប់ទាំងស្រុងៗ ក្រោយពីបានប្រជុំផ្ទៃក្នុងនាយកដ្ឋាន និងមានការចូលរួមកែសម្រួលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាច្រើនលើកច្រើនសារ ទើបការរៀបចំសេចក្ដីព្រាងច្បាប់ផលិតកម្ម សត្វ និងសុខភាពសត្វបានចប់សព្វគ្រប់ ដោយមាន ១៤ ជំពូក និង ១៣៣ មាត្រា ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១។

-ការផ្សព្វផ្សាយបច្ចេកទេស គឺគំពុងតែមានការចាប់អារម្មណ៍ និងមានការគាំទ្រពីគ្រប់ជំនាញអង្គការជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយជាច្រើន ហើយបាននឹងកំពុងតែអនុវត្តយ៉ាងសកម្ម នៅតាមមូលដ្ឋានរាជធានី ខេត្តទូទាំងប្រទេស។ សហការជាមួយដៃគូរអភិវឌ្ឍន៍មួយចំនួនដូចជាៈ OIE, SEAFMD, FAO, WHO, SLPP, WB, USDA, USAID, JICA, ACIAR, IPC និង SNV ។ល។

### ៥.២.១.៣- ការងារវិទ្យាស្ថានជាតិស្រាវស្រាវបសុព្យាបាល

#### ក- ស្ថានភាពជំងឺឆ្លងសត្វ

ជម្ងឺអុតក្ដាម សារទឹក បូសខ្យល់ ផ្ដាសាយបក្សី ជ្រូកត្រចៀកខៀវ និងជម្ងឺផ្សេងៗទៀត គឺ ត្រូវបានចាត់ទុកថាជាជំងឺធ្ងន់ធ្ងរសំខាន់ ដែលនៅតែបន្តការបង្កនូវបញ្ហាស្មុគ្រស្មាញ បំផ្លិចបំផ្លាញ និងបង្កគ្រោះមហន្តរាយដល់អាយុជីវិតរបស់មនុស្ស និងសត្វជារៀងរាល់ឆ្នាំ។ ចំពោះព្រូនហ្វាស្យូឡា និងពពួកប៉ារ៉ាស៊ីតផ្សេងៗទៀត ក៏នៅតែបង្កឱ្យមានបញ្ហាជំងឺ ជានិច្ចជាកាលនៅលើគោ-ក្របី និងសត្វដទៃទៀត។ ដោយឡែក ជំងឺធ្ងន់ដែលច្រើនកើតនៅលើសត្វជ្រូកដូចជា សារទឹក សាល់ម៉ូណែលឡា ប៉េស្ដជ្រូក កញ្រ្ជឹល ជ្រូកអុតក្ដាមជ្រូក អូហ្យេស្គី។ល។ រីឯបក្សី ជំងឺដែលជួបប្រទះច្រើនជាងគេគឺ ញីវកាស អុតមាន់ រាគទា។ ចំពោះជំងឺផ្ដាសាយបក្សី ដែលជាជំងឺធ្ងន់រាតត្បាតសាហាវនោះ ក៏បានផ្ទុះឡើង ០២ ករណីផងដែរ ។

ជំងឺអុតក្ដាម ៖ មានការផ្ទុះឡើងចំនួន ៨២ កន្លែង ក្នុងនោះ គោឈឺចំនួន ៣៧.៨២៧ ក្បាល (ងាប់ចំនួន ៩៧៣ ក្បាល) ក្របីឈឺចំនួន ១.៨១៩ ក្បាល (ងាប់ចំនួន ១៨៥ ក្បាល) ជ្រូកឈឺចំនួន ៩៩៦ ក្បាល (ងាប់ចំនួន ២១៧ ក្បាល) នៅតាមបណ្ដាខេត្ត បន្ទាយមានជយ័ កំពង់ស្ពឺ កំពង់ចាម កំពត តាកែវ ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង សៀមរាប កំពង់ធំ កណ្ដាល បាត់ដំបង ព្រះវិហារ ឧត្តរមានជយ័ និងខេត្តក្រចេះ។

ជំងឺសារទឹក ៖ មានការផ្ទុះឡើងចំនួន ៥២ កន្លែង ក្នុងនោះ គោឈឺចំនួន ១.៥៧៩ ក្បាល (ងាប់ ចំនួន ១២៤ ក្បាល) និងក្របីឈឺចំនួន ៩២៨ ក្បាល (ងាប់ ចំនួន ២៦៩ ក្បាល) នៅតាមបណ្ដា កំពត កណ្ដាល ក្រចេះ ព្រៃវែង បាត់ដំបង ពោធិសាត់ កោះកុង សៀមរាប និងស្វាយរៀង។

បូសខ្យល់ ៖ បានផ្ទុះឡើងចំនួន ០២ កន្លែង ក្នុងនោះ គោឈឺចំនួន ៧៣ ក្បាល (ងាប់ ០៦ ក្បាល) និង ក្របីឈឺចំនួន ០៨ ក្បាល នៅខេត្ត ក្រចេះ និងខេត្តកំពង់ឆ្នាំង។

ប៉េស្ដជ្រូក ៖ បានផ្ទុះឡើងចំនួន ១៧ កន្លែង ក្នុងនោះ ជ្រូកឈឺចំនួន ១៨៤ ក្បាល (ងាប់ ១១០ ក្បាល) នៅខេត្តកោះកុង និងខេត្តសៀមរាប។

ជម្ងឺត្រចៀកខៀវជ្រូក ៖ បានរកឃើញ លើសត្វជ្រូកនាំចូលខុសច្បាប់ពីប្រទេសជិតខាង និងបានដុតកម្ទេចចោលជ្រូក នៅខេត្ត កំពង់ចាម ខេត្តស្វាយរៀង និងខេត្តកណ្តាល ហើយបានចូលរួមបាញ់ថ្នាំរំងាប់មេរោគនៅទីកន្លែង ជ្រូកឈឺ និងងាប់សរុបចំនួន ៥.០១២ ក្បាល នៅតាមបណ្តាខេត្ត កណ្តាល កំពង់ចាម កំពង់ឆ្នាំង ព្រៃវែង និងខេត្តតាកែវ ។

**ខ- ការបង្ក្រាបបទល្មើស និងការទប់ស្កាត់ជំងឺឆ្លងសត្វ**

-បានបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន ៣១ករណី ក្នុងនោះ គោ-ក្របីចំនួន ២៤០ក្បាល និងជ្រូកចំនួន ៥១៩ក្បាល។ បានសម្រេចដោះលែងចំនួន ០៣ករណី និងធ្វើការដុតកំទេចចោលតាមវិធានបសុពេទ្យលើសត្វជ្រូកនាំចូលពីប្រទេសវៀតណាមចំនួន ៤៦ ក្បាល ។

-បានបង្ក្រាបបទល្មើស ដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន ១៣៧ ករណី ក្នុងនោះ មានគោ ក្របីចំនួន ១២៦ក្បាល ជ្រូកចំនួន ២.២០៣ក្បាល មាន់ ទាចំនួន ៤៤៤ក្បាល ស៊ុតបក្សី ៤.៧៥០គ្រាប់ និងផលិតផលសត្វចំនួន ១៣០.៣៣១ គីឡូក្រាម។ ជាពិសេសធ្វើការដុតកំទេចចោលគោមានជំងឺចំនួន ០៥ ក្បាល ជ្រូកនាំចូលពីប្រទេសវៀតណាមចំនួន ១២៦ ក្បាល មាន់ ទា ចំនួន ៤៤៤ ក្បាល ស៊ុតបក្សីចំនួន ៤.៧៥០ គ្រាប់ និងផលិតផលសត្វចំនួន ១០២.២៦៥ គីឡូក្រាម ។

**៥.២.១.៤-ការងារបសុព្យាបាល**

**ក. ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ**

បានចែកចាយវ៉ាក់សាំង ថ្នាំព្យាបាល ថ្នាំសំលាប់មេរោគ ឧបករណ៍សម្ភារៈបសុពេទ្យ ដល់មូលដ្ឋាន វ៉ាក់សាំងអុតក្តាមចំនួន ៣២.៦០០ កំរិត វ៉ាក់សាំងសាទឹកចំនួន ១.៧៩៩.០០០កំរិត វ៉ាក់សាំងបូសខ្យល់ចំនួន ១៤.០០០ កំរិត សឺរ៉ាំង ៤៩៧ គ្រឿង ម្ជុល ១.២៣០ ប្រអប់ ថ្នាំព្យាបាល ០៧ មុខចំនួន ១.១០២ ដប ថ្នាំសំលាប់មេរោគ TH4 ចំនួន ៤.១៨២ លីត្រ អាកុល ៤៥ លីត្រ ដង្កៀប ៧០ គ្រឿង សំឡីចំនួន ៤៦ គក្រ និងទែម៉ូម៉ែតចំនួន ១១៨គ្រឿង។

លទ្ធផលសម្រេចចាក់ថ្នាំការពារ ចំពោះសត្វគោ-ក្របី ជម្ងឺសារទឹក ១.៥៧០.១២៩ ក្បាល ជម្ងឺអុតក្តាម ៩៨.០៤៣ ក្បាល និងជំងឺបូសខ្យល់ ១៨.៦៨៦ ក្បាល រីឯជ្រូកជម្ងឺសារទឹក ១៥៤.៤៤៨ ក្បាល ជម្ងឺប៉េស្ត ១៩៧.៣៤៥ក្បាល ជម្ងឺសាល់ម៉ូ ១១៣.០៥២ក្បាល ជំងឺអុតក្តាម ៦.៨០៣ក្បាល ជម្ងឺអូហ្សេស្គី ៩.៨៧៦ក្បាល និងបក្សីជម្ងឺញូវកាស ៦១៤.៥០៧ ក្បាល ជម្ងឺអាសន្នរោគ ៖ ២៨២.៦៥៦ក្បាល ជម្ងឺអុត ១៩៧.២១៤ ក្បាល ។

**ខ. ការងារត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ**

នៅក្នុងឆ្នាំ ២០១០ ការត្រួតពិនិត្យសត្វ និងផលិតមានដើមកំណើតពីសត្វ ដែលបាននាំចេញ នាំចូល និងនាំឆ្លងកាត់ប្រទេសកម្ពុជា សត្វគោ-ក្របីក្នុងនាំចេញក្រៅប្រទេសចំនួន ៤១.៩៣៦ ក្បាល ការនាំសត្វគោពីប្រទេសថៃឆ្លងកាត់សរុបចំនួន ១០៦.៤០៨ ក្បាល ការនាំជ្រូកចូលចំនួន ៣០៧.៧៣៨ ក្បាល ជ្រូកសាច់ចំនួន៣០៣.៤០៦ ក្បាល ជ្រូកពូជចំនួន ៤.៣៣២ ក្បាល (មេបាពូជ និងកូន) កូនមាន់ពូជនាំចូល ៥១.៨០២ ក្បាល សាច់គោនាំចូល ៩៦.៣៤៣ គ.ក្រ នាំស្វាចេញក្រៅប្រទេសចំនួន ១២.៥៨៣ ក្បាល ការនាំស្បែកគោ-ក្របីក្នុងស្រុកចេញក្រៅប្រទេសចំនួន ១.៤៤៣.៩៧០ តោន។

### ៥.២.១.៥- ការងារវិទ្យាស្ថានជាតិស្រាវស្រាវបសុព្យាបាល

#### ក- ការធ្វើរោគវិនិច្ឆ័យជំងឺសត្វ

សហការនិងចុះស្រាវជ្រាវអង្កេតតាមដានជំងឺសត្វ នៅទូទាំងប្រទេស បានទទួល និងចុះយកវត្ថុវិភាគ ដើម្បីវិភាគរកមេរោគបង្កជម្ងឺ និងធ្វើរោគវិនិច្ឆ័យជម្ងឺសត្វ។ ចំនួនវត្ថុវិភាគ ដែលទទួលបានមានចំនួន ២៣.២២៣ វត្ថុវិភាគ ក្នុងនោះ ផ្នែកប៉ារ៉ាស៊ីតសាស្ត្រ ៣.២២៣ វត្ថុវិភាគ បាក់តេរីសាស្ត្រ ៣.២៥៤ លោហិតសាស្ត្រ ៤.៣១៤ សេរ៉ូមសាស្ត្រ ១២.៣៨៤ និងសរីរៈរោគសាស្ត្រ ៤៨ វត្ថុវិភាគ។ លទ្ធផលវិភាគ បានរកឃើញនូវប្រភេទមេរោគ និងជម្ងឺមួយចំនួនដូចជា មេរោគជម្ងឺផ្តាសាយបក្សី/H5N1 លើបក្សីនៅ ខេត្តតាកែវ និងព្រៃវែង សារទឹក អុតក្តាម (គោ ក្របី) និងជ្រូក ជម្ងឺញូវកាសលើបក្សី និងប៉េស្ត បានរកឃើញមានកំរិតអង់ទីបូឌីជំងឺត្រចៀកខៀវលើជ្រូក និងជំងឺបង្កដោយប៉ារ៉ាស៊ីតរួមមាន ហ្វាស្យូឡា ទ្រីប៉ាណូសូម Strongylus Paramphistom និង Monizia។

#### ខ- ការអង្កេតតាមដាន និងការស្រាវជ្រាវជំងឺសត្វ

អង្កេតតាមដានស្រាវជ្រាវកន្ទែងផ្ទុះជំងឺសារទឹក ជំងឺអុតក្តាម និងជំងឺប៉េស្តជ្រូក នៅតាមបណ្តារាជធានី ខេត្ត។ តាមដានឃ្លាំមើលពីស្ថានភាពជំងឺផ្តាសាយបក្សី នៅតាមបណ្តាភូមិនៅទូទាំងប្រទេស ដោយប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ និងបណ្តាញការងារនានា។ ពិនិត្យតាមដានទូវវត្តមានវីរុសផ្តាសាយបក្សីនៅតាមទីផ្សារលក់បក្សីរស់ក្នុងរាជធានីភ្នំពេញ បាត់ដំបង សៀមរាប ពោធិសាត់ កំពង់ចាម តាកែវ បន្ទាយមានជ័យ ស្វាយរៀង កណ្តាល និងកំពត តាមរយៈការយកតំបារពីក្លូអាក់ តំបារពីបំពង់ ខ្យល់ និងសេរ៉ូមឈាមទា និងស្រាវជ្រាវទប់ស្កាត់ការផ្ទុះជំងឺផ្តាសាយបក្សីនៅខេត្តកំពង់ចាម។

#### គ- ប្រពន្ធ័ពត៏មានជំងឺសត្វ

រាល់ការផ្ទុះជំងឺឆ្លងសត្វនៅតាមបណ្តារាជធានី ខេត្ត ផ្តល់ព័ត៌មានជាបន្ទាន់ ដើម្បីឱ្យវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលមានលទ្ធភាពរាយការណ៍ពី ស្ថានភាពជំងឺសត្វ ទៅប្រពន្ធ័ព៌ត៌មានសុខភាពសត្វនៅក្នុងតំបន់អាស៊ី (ARAHIS) និងប្រពន្ធ័ពត៌មានសុខភាពសត្វពិភពលោក (WAHIS) បានទាន់ពេលវេលា។ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺសត្វ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលបានសហការជាមួយអង្គការនានា មួយចំនួនដូចជា: OIE, FAO, WB, USDA, USAID , JICA, ACIAR, IPC។ ល។

#### ឃ- ការងារផ្សព្វផ្សាយបច្ចេកទេស

ការផ្សព្វផ្សាយបច្ចេកទេស គឺគំពុងតែមានការចាប់អារម្មណ៍ និងមានការគាំទ្រពីគ្រប់ជំនាញ អង្គការជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយជាច្រើន ហើយបាននឹងកំពុងតែអនុវត្តយ៉ាងសកម្ម នៅតាមមូលដ្ឋានរាជធានី ខេត្តទូទាំងប្រទេស។ ទន្ទឹមនឹងនោះ បានរៀបចំចងក្រងឯកសារ និងអត្ថបទសម្រាប់ចុះផ្សព្វផ្សាយក្នុងទស្សនាវដ្តីក្រសួងកសិកម្ម និងបានចុះផ្សព្វផ្សាយ ប្រជុំ និងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមសត្វ វិធានការទប់ស្កាត់ជំងឺឆ្លងសត្វ ការកែលំអរពូជសត្វ ការដាំដំណាំចំណីសត្វ ការយល់ដឹងពីឡជីវឧស្ម័ន អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធ។ មធ្យោបាយនៃការផ្សព្វផ្សាយអនុវត្តតាមរូបភាពដូចជា: ការជួបប្រជុំ ផ្សព្វផ្សាយ តាមវិទ្យុ ទូរទស្សន៍ វេទិកាសាធារណៈ បទសម្ភាសន៍ ចែកចាយខិតប័ណ្ណ ដាក់តាំងរូបភាពបង្ហាញទស្សនៈកិច្ចសិក្សា ការអនុវត្តបង្ហាញដាក់ស្តែង ។ល។

### ៥.២.១.៦-ការងារផលិតកម្មសត្វ

#### ក- ការចិញ្ចឹមសត្វតាមលក្ខណ:គ្រួសារ

**តារាងទី ១. ស្ថិតិសត្វ ឆ្នាំ២០១០ និងការប្រៀបធៀបឆ្នាំ ២០១០/២០០៩**

| ប្រភេទសត្វ | ចំនួនសត្វសរុប (*ក្បាល*) | | ប្រៀបធៀបឆ្នាំ ២០០៩-២០១០ | |
|---|---|---|---|---|
| | ឆ្នាំ ២០០៩ | ឆ្នាំ ២០១០ | ចំនួនសត្វកើន ឬ ថយ (*ក្បាល*) | ភាគរយ (%) |
| គោ | ៣.៥៧៩.៨៨២ | ៣.៤៨៤.៦០១ | -៩៥.២៨១ | -២.៦៦ |
| ក្របី | ៧៣៩.៦៤៦ | ៧០២.០៧៤ | -៣៧.៥៧២ | -៥.០៧ |
| គោ-ក្របី | ៤.៣១៩.៥២៨ | ៤.១៨៦.៦៧៥ | -១៣២.៨៥៣ | -៣.០៧ |
| កំលាំងអូសទាញ | ១.៨៧៣.៧៧៧ | ១.៦២៦.២៤៣ | -២៤៧.៥៣៤ | -១៣.២១ |
| ជ្រូក | ២.១២៦.៣០៤ | ២.០៥៧.៤៣១ | -៦៨.៨៧៣ | -៣.២៣ |
| សត្វស្លាប | ២០.១៩២.៨១១ | ២០.៨៣៤.២៩៥ | ៦៤១.៤៨៤ | ៣.១៧ |

*-សត្វគោជាលក្ខណ:គ្រួសារ មានការថយចុះចំនួន ២.៦៦ ភាគរយ (ស្មើនឹង ៩៥.២៨១ ក្បាល ) បើធៀបនឹងស្ថិតិសត្វឆ្នាំ ២០០៩។ ការថយចុះនេះ បណ្តាលមកពីការអភិវឌ្ឍន៍ទូរយន្តទូបនីយកម្ម និងមានទីផ្សារគោក្នុងស្រុក ក៏ដូច ខាងក្រៅស្រុក។*

*-ការចិញ្ចឹមក្របីជាលក្ខណ:គ្រួសារ មានការថយចុះចំនួន ៥.០៧ ភាគរយ (ស្មើនឹង ៣៧.១៦៥ ក្បាល) នៅឆ្នាំ ២០១០ បើប្រៀបធៀបស្ថិតិនៅឆ្នាំ ២០០៩។ ការថយចុះនេះ បណ្តាលមកពីប្រជាជនកម្ពុជា មិនសូវចូលចិត្តបរិភោគសាច់ក្របី ដាងសាច់គោ និងម្យ៉ាងទៀតប្រជាកសិករមានការលំបាកក្នុងការស្វែងរកតំបន់ដែលមានទឹកនិងចំណីគ្រប់គ្រាន់ សម្រាប់ការចិញ្ចឹមក្របី ជាពិសេសនៅក្នុងអំឡុងពេលនៃរដូវប្រាំង ក្នុងខណ:ដែលសត្វក្របីមានតម្រូវការទឹកច្រើន។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍នៃការចិញ្ចឹមក្របីគឺ ត្រូវតែជម្រុញថែមទៀតដើម្បីបំពេញនឹងការធ្លាក់ចុះ។*

*-ការចិញ្ចឹមជ្រូកជាលក្ខណ:គ្រួសារ មានការថយចុះប្រមាណ ៣.២៣ ភាគរយ (ស្មើនឹង ៦៨. ៨៧៣ ក្បាល) នៅឆ្នាំ ២០១០ នៅពេលប្រៀបធៀបនឹងស្ថិតិសត្វឆ្នាំ ២០០៩។ នេះបញ្ជាក់ថា ប្រជាកសិករបានចំណាយថវិកាច្រើនលើការផលិត ឬទិញចំណីសម្រាប់ការចិញ្ចឹមជ្រូក ដែលធ្វើឱ្យថ្លៃដើមនៃការចិញ្ចឹមជ្រូករបស់ប្រជាកសិករមានតម្លៃខ្ពស់ ប្រសិនបើប្រៀបធៀបនឹងប្រទេសជិតខាង និងម្យ៉ាងទៀត ដោយសារនៅ ចុងឆមាសទី២ឆ្នាំ ២០១០ នេះ ក៏ទទួលរងពីការរាតត្បាតជំងឺជ្រូកត្រចៀកខៀវពី ប្រទេសជិតខាងផងដែរ*

*-ដោយឡែកការចិញ្ចឹមបក្សីជាលក្ខណ:គ្រួសារ មានការកើនឡើងគួរឱ្យកត់សម្គាល់ នៅឆ្នាំ ២០១០ នេះ គឺមានចំនួន ៣.១៧ ភាគរយ (ស្មើនឹង ៦៤១.៤៨៤ ក្បាល) បើប្រៀបធៀបទិន្នន័យនៅឆ្នាំ ២០០៩។*

#### ខ- កសិដ្ឋានចិញ្ចឹមសត្វឯកជន

**តារាងទី ២. ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វឯកជនឆ្នាំ ២០១០ និងការធៀបនឹងឆ្នាំ ២០១០/២០០៩**

| ប្រភេទកសិដ្ឋានចិញ្ចឹមសត្វ | ចំនួនកសិដ្ឋាន | | ចំនួនសត្វសរុប (ក្បាល) | | ការប្រៀបធៀបចំនួនសត្វសរុប ឆ្នាំ ២០០៩-២០១០ | |
|---|---|---|---|---|---|---|
| | ២០០៩ | ២០១០ | ២០០៩ | ២០១០ | កើន ឬ ថយ (ក្បាល) | ភាគរយ (%) |
| មាន់សាច់ និង ស៊ុត | ៤១៤ | ៣០៧ | ៥៣៣.០៧១ | ១.៥៣៥.៥០៥ | ១.០០២.៤៣៤ | ៦៥.២៨ |
| ទាសាច់ និងស៊ុត | ១.៨៨៨ | ៥៦៨ | ១.៩៦៥.១៣ | ៩០៧.២៧៩ | -១.០៥៧.៨៥៦ | -១១៦.៦០ |
| ក្រួច | | ១២ | | ៤.៥០៩ | | |
| ជ្រូកសាច់ | ១.៣៦៧ | ៣.០៩០ | ៩៨.២៩១ | ១៥៥.៨៩៦ | ៥៧.៦០៥ | ៣៦.៩៥ |
| ជ្រូកពូជ | | ៥ | | ៣.៥៥៤ | | |
| គោ-ក្របី | ៥២ | ៦៣ | ៦.៤៥៣ | ៣.៩៩០ | -២.៤៦៣ | -៦១.៧៣ |
| គោ-ក្របីទឹកដោះ | | ១ | | ៨០ | | |
| សេះ | | ១ | | ៤១ | | |
| ចៀម | | ២ | | ៤០ | | |
| ពពែ | ១ | ៦៥ | ១៨០ | ១.៥៦៩ | ១.៣៨៩ | ៨៨.៥៣ |

**គ- ស្ថានីយចិញ្ចឹមសត្វរដ្ឋ**

**គ១- *ស្ថានីយចិញ្ចឹមជ្រូកពូជបង្កាញកម្ពុជា-ចិន***

*ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន បានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការឧបត្ថម្ភគាំទ្ររបស់សាធារណៈរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលកម្ពុជា មានជ្រូកសរុបចំនួន ២៦៣ ក្បាល ក្នុងនោះ មេចំនួន ១៥០ ក្បាល បាចំនួន ២៣ ក្បាល និងកូនជ្រូកចំនួន ៩០ ក្បាល។ ទន្ទឹមនឹងនោះ បានបង្កាត់មេជ្រូកបានចំនួន ១៥៥ ក្បាល ក្នុងនោះ មានមេ ១៣០ ក្បាល បង្កើតកូនបានលក់កូនជ្រូកពូជចំនួន ៨៧១ក្បាលជូនដល់កសិករនៅតាមរាជធានី ខេត្ត ក្រុងទូទាំងប្រទេស។*

**គ២-*ស្ថានីយ៍ចិញ្ចឹមគោពូជភ្នំតាម៉ៅ***

*ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ បានរៀបចំ និងកំពុងជម្រុញលើការចិញ្ចឹម ការថែទាំ ការបង្កាត់ពូជកែលំអពូជគោ ការដាំដំណាំចំណីសត្វក្នុងស្ថានីយ ជាពិសេសកែច្នៃ ចំណីគោត្រៀមសម្រាប់រដូវប្រាំងដែលខ្វះស្មៅ ឱ្យការចិញ្ចឹមគោក្នុងស្ថានីយមាននិរន្តរភាព។ ស្ថានីយគោសរុបចំនួន ១៩៦ ក្បាល ក្នុងនោះញី ១៥៤ក្បាល និងឈ្មោល ៤២ក្បាល កូនកើតថ្មី ៦ក្បាល ក្នុងនោះកំផែងសែន ៤ក្បាល គោលក់ ៦ក្បាល គោងាប់ ៨ក្បាល។ គោពូជកំផែងសែនក្នុងឆ្នាំ ២០១០ មានចំនួន ៣២ ក្បាល ជាអំណោយដ៏ថ្លៃថ្លារបស់* **ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** *រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។*

*ស្ថានីយបានចែកពូជស្មៅទៅតាមបណ្តាខេត្តមួយចំនួន ឃីងក្រាសខេត្តកំពង់ចាម ចំនួន ២០០ បាច់ខេត្ត កំពង់ធំចំនួន ២០០ បាច់ ខេត្តកណ្តាល ២០០ បាច់ តាកែវចំនួន ១៥០ បាច់ ចែកពូជស្មៅឃីងក្រាសដល់ប្រជាជន នៅឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវចំនួន ២៥០ បាច់ និងចែកស្មៅឃីងក្រាស ដល់ភូមិភាគពិសេសចំនួន ១០០០ ដើម និងបានប្រមូល គ្រាប់ស្មៅហ្គីណេ និងស្មៅរ៉ូស្សីទុកដាំឆ្នាំក្រោយដាំស្មៅឃីងក្រាសបាន ៤០អា។*

**ឃ- ការកែលំអពូជសត្វ**

*ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញ កម្ពុជា-ចិន បានផ្សព្វផ្សាយពូជជ្រូកយកសៀរ ឡិនដ្រេស ដុយរ៉ុក នាំ*

ពូជគោកំផែនសែនដើម្បីបង្កាត់ និងផ្សព្វផ្សាយពូជ បង្កើតមជ្ឈមណ្ឌលបង្កាត់ពូជគោ ជ្រូក តាមបែបសប្បនិមិត្ត ដោយនាំយកមកពីបរទេសនូវស្មែមគោយកមកបង្កាត់ជាមួយគោក្នុងស្រុក ចែកពូជគោ ជ្រូក មាន់ ដល់កសិករចិញ្ចឹមសត្វនៅតាមបណ្តាខេត្តនានា នៅទូទាំងប្រទេស និងចិញ្ចឹមសត្វបង្ហាញ ដូចជាចិញ្ចឹមគោ ជ្រូក មាន់ ។ល។

**ង- ការកែលំអចំណីសត្វ**

ការដាំដំណាំចំណីសត្វ គឺមានគាំទ្រ និងការជ្រោមជ្រែងយ៉ាងសកម្ម ពីរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ។ ស្ថានីយចិញ្ចឹមគោពូជកំភ្នំតាម៉ៅ ដាក់ខ្ទែងស្តុកពូជសត្វ និងពូជស្មៅច្រើនប្រភេទ សម្រាប់ធ្វើការ ផ្សព្វផ្សាយទៅខេត្តផ្សេងៗទៀត ជាពិសេសពូជស្មៅយីងក្រាសជាអាហារ បន្ថែមសម្រាប់គោ ក្របី។

ពូជដំណាំចំណីសត្វ ដែលបានផ្សព្វផ្សាយដល់កសិករនាពេលបច្ចុប្បន្ន រួមមាន ៖ Simung Malato, Paspalum, Stylo184 Marandu Ruzi Elephant grass, King grass កន្ទំថេត ទ្រីចាន់ដារ៉ា ។ល។ ខេត្តកំពង់ចាម និងខេត្តតាកែវ គឺជាខេត្តគំរូ ដែលទទួលបានជោគជ័យក្នុងការដាំដំណាំចំណីសត្វ សម្រាប់ការផ្សព្វផ្សាយដល់កសិករក្នុងខេត្តដទៃផ្សេងទៀត ។

ក្រៅពីខេត្តពីរខាងលើនេះ ខេត្តមួយចំនួនទៀត ក៏មានការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងដាំដំណាំចំណីសត្វដែរ ដើម្បីផ្សព្វផ្សាយដល់កសិករ រួមមានខេត្តកណ្តាល បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ មណ្ឌលគិរី ពោធិសាត់ រតនៈគិរី ព្រៃវែង និងខេត្តសៀមរាប។

**ច- ការអភិវឌ្ឍនកម្មវិធីឡជីវឧស្ម័ន**

ចាប់ពីឆ្នាំ ២០០៦ រហូតដល់ឆ្នាំ ២០១០ ការកសាងឡជីវឧស្ម័នសរុប ចំនួន ១០.១៤៦ឡ ក្នុងនោះ នៅឆ្នាំ ២០១០ ឡជីឧស្ម័នបានសាងសង់ចំនួន ៣.៧៤៤ឡ។

**តារាងទី ៤៖ ចំនួនឡជីវឧស្ម័ននៅកម្ពុជាចាប់ពីឆ្នាំ ២០០៦ ដល់ ២០១០**

| ខេត្ត | ចំនួនឡជីវឧស្ម័នដែលបានសាងសង់ | | | | | |
|---|---|---|---|---|---|---|
| | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | សរុប |
| កំពង់ចាម | ១១៣ | ២៥០ | ៤០០ | ៤៩៧ | ៤៨៤ | **១៧៤៤** |
| កណ្តាល | ៨៧ | ៨១ | ១០០ | ១៣៣ | ២៨១ | **៦៨២** |
| ស្វាយរៀង | ៦១ | ១៣៦ | ៣៣២ | ៥២៥ | ៥២២ | **១៥៧៦** |
| តាកែវ | ៣១ | ៤៥០ | ៦៨៦ | ៤០៥ | ៦១៩ | **២១៩១** |
| កំពង់ស្ពឺ | ៤ | ២៣២ | ២៨៩ | ២៣៥ | ៣៦២ | **១១២២** |
| កំពង់ឆ្នាំង | ០ | ០ | ១៥៥ | ១៩៨ | ១៦៨ | **៥២១** |
| កំពត | ០ | ១ | ៣៥៧ | ៣៧៧ | ៦៩៦ | **១៤៣១** |
| ព្រៃវែង | ០ | ០ | ២១ | ២៤៦ | ៤៣៨ | **៧០៥** |
| សៀមរាប | ០ | ០ | ០ | ០ | ៦៧ | **៦៧** |
| ពោធិ៍សាត់ | ០ | ០ | ០ | ០ | ៧៤ | **៧៤** |
| បាត់ដំបង | ០ | ០ | ០ | ០ | ២២ | **២២** |
| កំពង់ធំ | ០ | ០ | ០ | ០ | ១១ | **១១** |
| សរុបរួម | **២៩៦** | **១១៥០** | **២៣៤០** | **២៦១៦** | **៣៧៤៤** | **១០១៤៦** |

### ឆ- ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋានរបស់រាជធានី ខេត្ត

ក្នុងឆ្នាំ ២០១០ ការអភិវឌ្ឍន៍ការចិញ្ចឹមសត្វនៅតាមមូលដ្ឋាននៃរាជធានី ខេត្តនៅទូទាំងប្រទេស ដោយមានការសហការជាមួយអង្គការដៃគូ និងផ្នែកឯកជន គឺហាក់ដូចជាមានការធ្លាក់ចុះបន្តិច ដោយសារមានកត្តាជាច្រើន ដែលបង្កឲ្យមានបញ្ហាប្រឈមក្នុងកិច្ចដំណើរការវិវត្តន៍ ការងារចិញ្ចឹមសត្វនេះ។ ទន្ទឹមនឹងនោះ បាននឹងកំពុងខិតខំប្រឹងប្រែង ស្វែងរកគ្រប់មធ្យោបាយ និងវិធីសាស្រ្តសំខាន់ៗ ដើម្បីដោះស្រាយរាល់បញ្ហា នឹងមានវិធានការចុះណែនាំដល់អ្នកចិញ្ចឹមសត្វ ពីរបៀបចិញ្ចឹមសត្វ ការបង្កើតសហគមន៍ចិញ្ចឹមសត្វ ការផ្តល់ឥណទាន សម្រាប់ចិញ្ចឹមសត្វ និងកម្មវិធីដទៃផ្សេងៗទៀត។

### ៩.២.២-វាយតម្លៃ និងសំណើ

វិស័យផលិតកម្ម និងបសុពេទ្យាបាល កាន់តែមានសារៈសំខាន់ក្នុងវិស័យសេដ្ឋកិច្ចជាតិ និងមានតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងក្នុងតំបន់ ដូចជាការផ្តល់នូវ កំលាំងអូសទាញផ្តល់សាច់ស៊ុត វត្ថុធាតុដើម ចំណូលគ្រួសារ និងចំណូលសេដ្ឋកិច្ចជាតិ។

ឆ្នាំ ២០១០ ផលិតកម្មសត្វគោមានការថយចុះចំនួន ២.៦៦ ភាគរយ សត្វក្របីថយចុះ ចំនួន ៥.០៧ ភាគរយ និងជ្រូកថយចុះចំនួន ៣.២៣ ភាគរយ បើប្រៀបធៀបស្ថិតិសត្វឆ្នាំ ២០០៩។ ការថយចុះផលិតកម្មសត្វ គឺបណ្តាលមកពីជំងឺឆ្លងសត្វ (ជំងឺអុតក្តាម និងជំងឺជ្រូក ត្រចៀកខៀវ) ពាណិជ្ជកម្មសត្វ និងកត្តាចំណី។ ប៉ុន្តែផ្ទុយទៅវិញចំនួន សត្វស្លាបមានការកើនចំនួន ៣.១៧ ភាគរយ បើប្រៀបធៀបឆ្នាំ ២០០៩ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករបានយល់ដឹងជាបណ្តើរៗ នូវបច្ចេកទេសចិញ្ចឹមបក្សីតាមគោលការណ៍ជីវសុវត្ថិភាព និងយល់ដឹង ពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ដោយមានការផ្សព្វផ្សាយបានទូលំទូលាយ និងមានការយល់ដឹងច្រើនរបស់ប្រជាជនក្នុងឆ្នាំ ២០១០ នេះ កសិដ្ឋានចិញ្ចឹមសត្វមានការរត់រកច្បាប់ជាបណ្តើរៗ។

សមិទ្ធិផលទាំងអស់នេះ សម្រេចបានដោយសារមានការគាំទ្រពីរាជរដ្ឋាភិបាល ពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាពិសេសពីសំណាក់**ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់រាជធានី-ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ និងដោយមានកិច្ចសហប្រតិបត្តិការ និងជំនួយឧបត្ថម្ភពីបណ្តាប្រទេសនានា ដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនជាដើម។

### ៩.២.៣-វិធានការ

- ការកែលំអរពូជ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិន និងការបង្កាត់ពូជគោសាន់តា និងស៊ីមប្រា ដោយសិប្បនិម្មិតនៅខេត្តពោធិសាត់ ការបង្កាត់ជ្រូកពូជដោយសិប្បនិម្មិតនៅខេត្តតាកែវ ការ បង្កាត់ពូជមាន់ ឃេអាយ នៅខេត្តសៀមរាប ហើយផ្សព្វផ្សាយពូជបន្តដល់ខេត្តផ្សេៗទៀត ។
- ដំណាំចំណីសត្វនៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ជាកន្លែងផ្សព្វផ្សាយពូជស្មៅ និងចែកចាយពូជទៅតាមបណ្តាខេត្តនានា និងដាំស្មៅបង្ហាញ នៅតាមខេត្ត ស្រុក ផ្សេងទៀត។
- បន្តការគ្រប់គ្រងកាកសំណល់សត្វ និងពង្រឹងការសាងសង់ឡជីវឧស្ម័ន ។
- ពង្រឹងការ ទប់ស្កាត់នូវជម្ងឺអុតក្តាម សាទឹក បូសខ្យល់ ជំងឺជ្រូកត្រចៀកខៀវ ជំងឺផ្តាសាយបក្សី ។
- ការរៀបចំសេចក្តីច្បាប់ស្តីពី ផលិតកម្មសត្វ និងសុខភាពសត្វ ប្រកាស និងលិខិតបទដ្ឋាននានាសម្រាប់បំរើវិស័យផលិតកម្មនិងបសុព្យាបាល ។

## ៥.៣-ផលិតផលដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី ២៧-៣៤)

កៅស៊ូជាដំណាំកសិ-ឧស្សាហកម្មរយៈពេលវែង ដែលបានបំពេញតួនាទីយ៉ាងសំខាន់ជួយទ្រទ្រង់ដល់សង្គម-សេដ្ឋកិច្ចជាតិតាមរយៈនីហរ័ណកម្មផលិតផលជ័រ និងឈើកៅស៊ូ ដែលជាចំណែកមួយក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ បង្កើតការងារនៅជនបទ បង្កើនប្រាក់ចំណូល និងទប់ស្កាត់ធ្វើចំណាកស្រុករបស់កសិករ។ ម្យ៉ាងវិញទៀតដំណាំកៅស៊ូក៏បានចូលរួមការពារបរិស្ថាន ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការពារហូរច្រោះដី ។

នៅក្នុងឆ្នាំ ២០១០ បរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក ផលិតបានមានចំនួន ១០.០០៣.០០០ តោន គឺកើនឡើង ៦.៤៤% បើប្រៀបធៀបជាមួយផលិតផលឆ្នាំ ២០០៩ ដែលមានចំនួន ៩.៣៩៨.000 តោន។ កត្តាដែលរួមចំណែកជំរុញឲ្យមានការកើនឡើងនូវផលិតផលនេះ ដោយសារៈ (១) តម្លៃជ័រកៅស៊ូយ៉ាងខ្ពស់ខុសពីធម្មតា បានលើកទឹកចិត្តដល់កសិករ ធ្វើឲ្យការប្រមូល ផលជ័រពីដើមកៅស៊ូប្រកបដោយប្រសិទ្ធិភាពសេដ្ឋកិច្ច (២) ផ្ទៃដីដាំដុះឆ្នាំ ២០០៣ និង ២០០៤ ក្នុងបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិបានមកដល់បក្កភាពបើកចៀរជ័របានហើយ (៣) កសិករបានប្រើប្រាស់មធ្យោបាយផ្សេងៗយ៉ាងច្រើនក្នុងការប្រមូលផលដូចជា ការប្រើថ្នាំរំញោច ការបង្កើនចង្វាក់ ចៀរជ័រ និងដាក់ក្បាំងគម្របការពារទឹកភ្លៀង (៤) រក្សា និងការពន្យាពេលក្នុងការកាប់ដើមកៅស៊ូចាស់ៗ សម្រាប់ដាំឡើងវិញ ទុកធ្វើការប្រមូលផលសិន។

ជាមួយគ្នានេះ ការប្រើប្រាស់កៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ ២០១០ មានបរិមាណចំនួន ១០.១៨២.០០០ តោន គឺបានកើនឡើងចំនួន ៨.៥០% បើប្រៀបធៀបជាមួយការប្រើប្រាស់ឆ្នាំ ២០០៩ ដែលមានចំនួន ៩.៣៨៤.០០០តោន ។ ដូច្នេះសន្និធិប្រចាំឆ្នាំនៅតាមបណ្តាប្រទេសផលិត កៅស៊ូធម្មជាតិគឺមានតិចតួចណាស់។ កត្តានេះ បានធ្វើឲ្យតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិ មានសន្ទុះកើនឡើងនាពេលបច្ចុប្បន្ន ក៏ដូចថ្ងៃអនាគតផងដែរ ។

### ៥.៣.១-លទ្ធផល

នៅឆ្នាំ ២០១០ ចំការកៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ និងចម្ការកៅស៊ូគ្រួសារ ព្រមទាំង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដំណើរការអនុវត្តទៅតាមផែនការរៀងៗខ្លួន ក្នុងនោះ មុខព្រួញសំខាន់ៗ រួមមានការធ្វើអាជីវកម្ម ផលិតកម្ម នីហរ័ណកម្ម ការកាប់ដើមកៅស៊ូចាស់ៗ និងការដាំកៅស៊ូឡើងវិញ ដោយទទួលបានលទ្ធផលដូចខាងក្រោមនេះ ៖

#### ៥.៣.១.១- ការងារអាជីវកម្មផលិតកម្ម និងការអភិវឌ្ឍន៍ដំណាំកៅស៊ូ

**ក- ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ**

- ផ្ទៃដីចៀរជ័រ ៣៨.៤០៦ ហិកតា ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារ ចំនួន ១៧.៤៣៥ ហិកតា
- ផលិតផលកៅស៊ូស្ងួត ៤២.២៥០តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ១៩.២០០តោន
- ការនាំចេញកៅស៊ូស្ងួត ៤២.០០០តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ១៩.០០០តោន

- ការដាំដុះកៅស៊ូសរុបចំនួន ៤៤.៣១០ ហិកតា ក្នុងនោះ កៅស៊ូកសិ-ឧស្សាហកម្មសរុបប្រមាណ ចំនួន ៣៤.៧៥៧ ហិកតា និងកៅស៊ូគ្រួសារចំនួន ៩.៥៥៣ហត និងផ្ទៃដីកូនកៅស៊ូកំពុងថែទាំសរុបចំនួន ១៤៣.០២៨ហត ។

**ក្រាហ្វិកបង្ហាញពីផលិតផល និងការនាំចេញកៅស៊ូឆ្នាំ ២០០៦-២០១០ (តោន)**




**ខ- ការងារបណ្តុះបណ្តាល**

បានបើកវគ្គបណ្តុះបណ្តាលគំរូស្ថិតិកៅស៊ូខ្នាតអន្តរជាតិមួយ មានរយៈពេល០១សប្តាហ៍ ដែលមានសិក្ខាកាមចូលរួមចំនួន ២៥ នាក់ មកពីអគ្គនាយកដ្ឋានកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងពីគ្រប់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ។

**គ- ក្របខណ្ឌច្បាប់**

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋានកៅស៊ូ បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ដែលគ្រោងនឹងបញ្ចប់នាចុងឆ្នាំ ២០១១ នេះ ។

ជាមួយគ្នានេះ អគ្គនាយកដ្ឋានកៅស៊ូ បាន និងកំពុងកសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូរយៈពេល១០ឆ្នាំផងដែរ។

**ឃ- ការងារស្រង់ស្ថិតិកៅស៊ូគ្រួសារ**

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋានកៅស៊ូ បានចុះស្រង់ស្ថិតិចម្ការ កៅស៊ូនៅខេត្តគោលដៅចំនួន ៤ គឺខេត្តរតនគីរី មណ្ឌលគីរី ក្រចេះ និងស្ទឹងត្រែង ជាលទ្ធផលៈ

- ខេត្តរតនគីរី មានកៅស៊ូគ្រួសារចំនួន ៩៣៨ គ្រួសារ ស្មើចំនួន ២១.២៧៦ហ.ត
- ខេត្តមណ្ឌលគីរី មានកៅស៊ូគ្រួសារចំនួន ៤៣៩គ្រួសារ ស្មើចំនួន ៦.២៨០ហ.ត
- ខេត្តក្រចេះ មានកៅស៊ូគ្រួសារចំនួន ១.០៧៨គ្រួសារ ស្មើចំនួន ៥.៦៥០ហ.ត
- ខេត្តស្ទឹងត្រែង មានកៅស៊ូគ្រួសារចំនួន ៨៨គ្រួសារ ស្មើចំនួន ៩១០ហ.ត

**ង- ការចូលរួមសន្និសីទ និងសន្និបាតអន្តរជាតិ**

ក្នុងឋានៈជាសមាជិកពេញសិទ្ធិ នៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ អគ្គនាយកដ្ឋានកៅស៊ូ តែងបានចូលរួមប្រជុំសន្និសីទនៃអង្គការទាំងពីរនេះ នៅប្រទេសឥណ្ឌា និងប្រទេសឥណ្ឌូនេស៊ី ព្រមទាំងបានធ្វើការទំនាក់ទំនងជាប្រចាំជាក្រុមសិក្សាកៅស៊ូអន្តរជាតិផងដែរ ។

ឃ- ការអភិវឌ្ឍន៍ដំណាំកៅស៊ូជាលក្ខណៈគ្រួសារ

ចាប់តាំងពីឆ្នាំពី២០០៣មក ការដាំដុះកៅស៊ូលក្ខណៈគ្រួសារ-ឯកជន ដែលប្រើប្រាស់ទុនខ្លួនឯងផ្ទាល់មានការរីកលូតលាស់យ៉ាងខ្លាំងក្លា ទាំងតំបន់ប្រពៃណី និងតំបន់មិនប្រពៃណីដែលពីមុនជាតំបន់មិនធ្លាប់ដាំកៅស៊ូក៏ដោយ ។គិតមកត្រឹមឆ្នាំ២០១០នេះ ផ្ទៃដីចំការកៅស៊ូគ្រួសារនៅទូទាំងប្រទេស សរុបមានចំនួន ៨១.៨១៣ហត និងបានបែងចែកទៅតាមបណ្តាខេត្ត។

៥.៣.១.២- ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ក- កិច្ចសហប្រតិបត្តិការ

ក្នុងកិច្ចខិតខំរិតចំណងកិច្ចសហការរយៈពេលវែង និងមិនកំណត់លើវិស័យស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រកៅស៊ូ (១)រវាងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសកលវិទ្យាល័យគ្យូស៊ូ ពិធីសារនៃការយោគយល់គ្នាមួយត្រូវបាន រៀបចំឡើងដោយមានការចុះហត្ថលេខារវាង**ឯកឧត្តម លី ផល្លា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ជាមួយនឹងភាគីជប៉ុនដោយលោក Setsuo Arikawa ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យគ្យូស៊ូ ដែលបានប្រព្រឹត្តទៅនៅទីក្រុង Fukuoka។ (២)កិច្ចសហការរវាងមជ្ឈមណ្ឌល CIRAD,ក្រុមហ៊ុន Michelin និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសិក្សាអំពី ភាពធន់ទ្រាំនៃក្លូន CMS ទៅនឹងជម្ងឺដែលកើតមានលើស្លឹកកៅស៊ូ (SALB) ក្នុងលក្ខខណ្ឌបរិស្ថានប្រទេសកម្ពុជា។ (៣)សហប្រតិបត្តិការរវាងមជ្ឈមណ្ឌលសម្រាប់ការប្តូរវប្បធម៌ និងបច្ចេកទេសខាងកើត-លិច ជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អំពីសរីរវិទ្យានៅលើដើមកៅស៊ូ។

ខ- ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ

ក្នុងការពង្រឹងគុណភាពផលិតផលកៅស៊ូធម្មជាតិកម្ពុជាឱ្យទទួលបាននូវទំនុកចិត្ត មាននិរន្តរភាព និងទទួលស្គាល់ ជាសាកលតាមប្រព័ន្ធគ្រប់គ្រងគុណភាពតាមស្តង់ដាអន្តរជាតិ ISO/IEC 17025:2005 សកម្មភាព និងសមិទ្ធិផល របស់មន្ទីរពិសោធន៍យថាប្រភេទក្នុងឆ្នាំ ២០១០ ត្រូវបានកត់សម្គាល់ដូចជា (១)ការធ្វើតេស្តភាគសំណាកបានចំនួន ២៥២ភាគសំណាក (២)បានទទួលនូវការធ្វើសវនកម្មជាលើកទី ២ ដោយ BoA ដើម្បីរក្សាសុពលភាពវិញ្ញាបនបត្រ ទទួលស្គាល់ និងពង្រឹងប្រពន្ធ័គ្រប់គ្រងគុណភាពតាមស្តង់ដារអន្តរជាតិ ISO/IEC 17025:2005 (៣)ធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ ក្នុងស្រុក៤ដង ដើម្បីវាយតម្លៃសមត្ថភាពបុគ្គលិក និងមន្ទីរពិសោធន៍មូលដ្ឋានចំនួន០៥ ដែលបានចូលរួម (៤)ត្រួតពិនិត្យ និងវាយតម្លៃពេងចក្រកែច្នៃ ហើយនិងមន្ទីរពិសោធន៍មូលដ្ឋានរបស់ក្រុមហ៊ុនចំការកៅស៊ូ ដើម្បីអនុវត្តនូវបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងវិញ្ញាបនកម្មកៅស៊ូ។ (៥)ចងក្រងសៀវភៅណែនាំ អត្ថបទស្រាវជ្រាវ និងឯកសារបទដ្ឋានផ្សេងៗ សម្រាប់ការពង្រឹងគុណភាពកៅស៊ូ TSRs (៦)ទទួលនិស្សិតវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាចំនួន៣នាក់ សាកលវិទ្យាល័យភូមិន្ទកសិកម្ម២នាក់ និងបុគ្គលិកក្រុមហ៊ុន ស៊ីហ៍រីសសស់លីមីតធីតចំការកៅស៊ូស្នួល ៣នាក់ ឱ្យធ្វើកម្មសិក្សាអំពីការស្រាវជ្រាវវិធីសាស្ត្រ វិភាគកៅស៊ូធម្មជាតិ ការបង្កកកៅស៊ូធម្មជាតិដោយប្រើកំហាប់ អាស៊ីតផ្សេងគ្នា ការសាកល្បងប្រើវិធីសាស្ត្រផ្សេងគ្នាក្នុងការសម្ងួតកៅស៊ូសន្ទឹកការធ្វើតេស្ត និងចេញវិញ្ញាបនបត្រ បញ្ជាក់គុណភាពកៅស៊ូ សិក្សាអំពីប្រពន្ធ័ គុណភាព ISO/IEC 17025:2005 និង ISO 9001:2000 (៧)ទទួល នូវការធ្វើទស្សនកិច្ចរបស់អង្គការ និងជំនាញការមួយចំនួនរួមមានប្រតិភូសាជីវកម្មអភិវឌ្ឍន៍ក្រៅប្រទេសជប៉ុន (JODC) អង្គការ UNIDO និងជំនាញការផ្សេងៗទៀតក្នុងការវាយតម្លៃការរីកចម្រើន របស់មន្ទីរពិសោធន៍ក្នុងការធ្វើតេស្ត និងការទទួលស្គាល់ពីអន្តរជាតិ។

## គ- ផ្នែកស្រាវជ្រាវក្សេត្រសាស្ត្រ

### គ.១-ផ្នែកជម្រើសរុក្ខវិទ្យាកៅស៊ូ:

កែលម្អក្លូនកៅស៊ូ និងរុក្ខសម្ភារកៅស៊ូ ក្នុងលក្ខខណ្ឌបរិស្ថាននៃប្រទេសកម្ពុជា សំដៅបង្កើនផលិតភាពចំការកៅស៊ូ សកម្មភាព និងសមិទ្ធិផលបង្កាត់ពូជក្នុងឆ្នាំ ២០១០ ត្រូវបានកត់សម្គាល់ដូចជា (១)តាមដានចំការពិសោធន៍ក្លូនទ្រង់ទ្រាយធំចំនួន ២១ ចំការ នៅក្នុងស្ថានីយ និងនៅតាមបណ្តាចំការកៅស៊ូឧស្សាហកម្ម (២)បង្កើតចំការពិសោធន៍ក្លូនទ្រង់ទ្រាយធំ ០១ ដែលមានចំនួន ០៨ ក្លូន នៅមណ្ឌលគិរីដោយសហការជាមួយក្រុមហ៊ុន Khaou Chuly Development Co. LTD(KCD) (៣)រៀបចំអនុសាសន៍ក្លូនសម្រាប់ការដាំដុះ២០១១-២០១៣ (៤)រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី អនុសាសន៍ក្លូនសម្រាប់ដាំដុះ ២០១១-២០១៣ (៥)រៀបចំលិខិតបទដ្ឋានដើម្បីគ្រប់គ្រងក្លូនកៅស៊ូ ដែលធ្វើឱ្យសម្រេចបាននូវប្រកាសលេខ ៥៤៤ ប្រក.កសកស្តីពី "**ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ**" ចុះថ្ងៃទី ១៨/០៨/២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៦)បេសកកម្មពិនិត្យជម្ងឺកៅស៊ូជាមួយជំនាញការវៀតណាម នៅខេត្តរតនគិរី (៧)ត្រួតពិនិត្យច្បារពូជកៅស៊ូកសិករនៅភូមិច្រកត្រាវ ឃុំមេមត់ ស្រុកមេមត់ ខេត្តកំពង់ចាម និងច្បារពូជកៅស៊ូរបស់ក្រុមហ៊ុនអិមអឌីវ៉ាប់បើរផ្វេនថេសិន ស្ថិតនៅស្រុកកែវផុស ខេត្តព្រះសីហនុ បានចំនួន១២,៥ ហ.ត សរុបមានចំនួន៦៦,៨៣៤ គល់ (៨)ដាំ និងថែទាំក្លូន CMS ចំនួន៩ ក្លូន (ជឌជ 312, CD 1174, CDC 56, FDR 4575,MDX 607, PMB 1, FDR 5665, FDR 5788 និង MDX 624) នៅក្នុងច្បារពូជ Collection សរុបចំនួន៤២ដើម (៩)ទទួលទស្សនកិច្ច និងពិភាក្សាការងារជាមួយអ្នកជំនាញក្រុមហ៊ុន Michelin ពាក់ព័ន្ធនឹងក្លូន CMS នៅស្ថានីយ៍ពិសោធន៍របស់វិទ្យាស្ថាន។

### គ.២- ផ្នែកដាំដុះ និងការពារដំណាំកៅស៊ូ

បង្កើនប្រសិទ្ធភាពនៃការដាំដុះកៅស៊ូ បង្កើនផលិតភាព ដីកសិកម្មធ្វើឱ្យប្រសើរឡើង នូវការគ្រប់គ្រងដីរជាតិដី និងបង្កើនតម្លៃបន្ថែម តាមរយៈនៃការរៀបចំនូវប្រព័ន្ធដំណាំ ចន្លោះរងកៅស៊ូ សកម្មភាព និងសមិទ្ធិផលរបស់ការិយាល័យដាំដុះ និងការពារនៅឆ្នាំ២០១០ត្រូវបានកត់សម្គាល់ (១)តាមដាន និងថែទាំការពិសោធន៍ លើពិធីសារវិធីដាំដុះកូនកៅស៊ូ (Tests on planting methods 2005-2009) ការពិសោធន៍អំពី ប្រព័ន្ធដំណាំចម្រុះស្មៅចំណីសត្វនៅចន្លោះរងកៅស៊ូបង្កើតចំការបង្ហាញប្រភេទឈើក្នុងស្រុក ដែលមានចំនួន ១០-១២ប្រភេទ ដាំនៅតាមចន្លោះរងកៅស៊ូ ចំការផលិតគ្រាប់ពូជឈើម៉ៃសាក់ដាំនៅតាមចន្លោះរងកៅស៊ូ ចំការពិសោធន៍ផលិតកម្មជីវម៉ាសនៅចន្លោះរងកៅស៊ូ និងការពិសោធន៍អំពីការដាំផ្កាល់ ហើយនិងផលិតផលជីវម៉ាសផ្អែកលើប្រព័ន្ធដំណាំនៅចន្លោះជួរភ្លោះសរុបចំនួន ០៩ចំការ (២)តាមដាន និងថែទាំការពិសោធន៍លើពិធីសារប្រើប្រាស់ជីលើកូនកៅស៊ូ ពិសោធន៍ដង់ស៊ីតេចំនួនដើម ពិធីសារពិសោធន៍ទំនាក់ទំនងរវាងការលូតលាស់ជាមួយនឹងអាកាសធាតុ ហើយនិងការចៀរជ័រចំនួន ៦ចំការ (៣)គ្រប់គ្រងឧបករណ៍ពិសោធន៍មាន Flux Tower, Sap Flow Sensors, ឧបករណ៍ វាស់វែង Photosynthesis របស់ដំណាំកៅស៊ូ។

### គ.៣- ផ្នែកសរីរសាស្ត្រ និងអាជីវកម្មកៅស៊ូ

បង្កើនលទ្ធភាពនៃការប្រមូលផលជ័រកៅស៊ូ ទៅតាមសក្តានុពលសរីរសាស្ត្រនៃក្លូននីមួយៗ ពិធីសារជាច្រើនត្រូវបានរៀបចំឡើងដោយការិយាល័យសរីរសាស្ត្រ-អាជីវកម្ម ត្រូវបានកត់សម្គាល់ដូចជា (១)បន្តការតាមដាន និងវាយតម្លៃ ការពិសោធន៍អំពីការធ្វើរំញោចកម្មលើសង្វាក់ចៀរ d/3 (yield potential d/3) ចំនួន ០៥ ឡូត៍ពិសោធន៍ នៅលើក្លូនចំនួនបួនគឺ PB 235, PB330, GT1 និងជ្រៅ ២៣០ នៅស្ថានីពិសោធន៍របស់

វិទ្យាស្ថាន និងនៅក្រុមហ៊ុនចំការកៅស៊ូក្រែក (២)បន្តការតាមដានការពិសោធន៍អំពីការធ្វើរំញោចកម្មលើសង្វាក់ចៀរ d/4(yield potential d/4) ចំនួន០៤ ឡូត៍ ពិសោធន៍នៅលើក្លូន PB330, GT1, RRIM712 និង PB260 (៣)បន្តតាមដានប្រសិទ្ធភាព នៃការប្រើប្រាស់របាំងការពារទឹកភ្លៀង (Rainguard) លើក្លូន PB260 និង PB330 (៤)បន្តតាមដានប្រសិទ្ធភាព នៃថ្នាំរំញោចមួយចំនួន ដែលមានវត្តមានលើទីផ្សារនៅកម្ពុជា (៥)រៀបចំពិធីសារពិសោធន៍ថ្មីអំពី ការបើកមុខចៀរលើទំហំដើមផ្សេងៗគ្នា មានដូចជា រង្វង់ទំហំដើម ៤៥ស.ម ៥០សម ៥៥ស.ម និង ៦០ស.ម លើក្លូន PB260។

### គ.៤- ស្ថានីយ៍អនុវត្ត

សម្រួលដល់ដំណើរការសិក្សាស្រាវជ្រាវរបស់ការិយាល័យជំនាញរបស់វិទ្យាស្ថាន ស្ថានីយអនុវត្តបានបំពេញនូវកិច្ចការមួយចំនួនដូចជា (១)រៀបចំថ្នាលបណ្តុះកូនកៅស៊ូទំហំ០,៤ហ.ត (២)ដាំដុះពិសោធន៍ថ្មីបានចំនួន៣១,២៥ហ.ត (៣)បើកមុខចៀរជ័រថ្មីចំនួន ៤៥,៨០ហ.ត (៤)ប្រមូលទឹកជ័រ និងផលិតជ័រកៅស៊ូស្ងួតបានចំនួន២៨១,២១០ត (៥)ជួសជុលផ្លូវក្នុងឡូត៍កៅស៊ូបានប្រវែង៤គ.ម (៦)សាងសង់អាងផ្គត់ផ្គង់ទឹក ឱ្យកម្មករចំនួន ១៣អាង ដែលមានចំណុះសរុប ៧៦ម៣ (៧)រៀបចំវគ្គផ្សព្វផ្សាយពាក់ព័ន្ធនឹងបច្ចេកទេសកៅស៊ូដល់កសិករចំនួន០២លើក (៨)រៀបចំពិធីសំណេះសំណាលមន្ត្រីវិទ្យាស្ថានក្នុងខួប ៥៥ឆ្នាំ នៃការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (៩)ទទួលជំនាញការ និងភ្ញៀវបរទេសមកបំពេញការងារនៅស្ថានីយ៍ចំនួន២១នាក់ ភ្ញៀវជាតិចំនួន ០៦ នាក់។ (១០) ផ្គត់ផ្គង់មែកពូជកៅស៊ូឱ្យដល់កសិករបានចំនួន៣៣២០ម។

### គ.៥- ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ

#### គ.៥.១- ការបណ្តុះបណ្តាល

-សិក្ខាសាលាផ្សព្វផ្សាយសេចក្តីប្រកាសដល់បណ្តាក្រុមហ៊ុន អ្នកវិនិយោគដំណាំកសិឧស្សាហកម្មកៅស៊ូ ស្តីអំពី "ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ "

-ថ្នាក់ដឹកនាំវិទ្យាស្ថាន និងការិយាល័យជំនាញចំនួន ២រូប បានអញ្ជើញទៅចូលរួមសន្និសីទក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា IRRDB

-បញ្ជូនមន្ត្រីថ្នាក់ការិយាល័យបង្កាត់ពូជ ០១រូប ទៅចូលរួមសិក្ខាសាលាស្តីពី ជម្ងឺកៅស៊ូ និងមន្ត្រីសរីរសាស្ត្រ និងអាជីវកម្មមួយរូបឱ្យទៅបំពាក់បំប៉ន និងបង្កើនសមត្ថភាពបន្ថែម នៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ IRRDB នៅប្រទេសម៉ាឡេស៊ី

-បង្ហ្វឹកកសិករអំពី បច្ចេកទេសធ្វើថ្នាលបណ្តុះកូនកៅស៊ូ វិធីធ្វើច្បារពូជ វិធីដាំដុះ និងថែទាំ កូនកៅស៊ូ នៅស្រុកបរកែវ ខេត្តរតនគីរី ដែលមានកសិករចូលរួមប្រមាណជាង ៤០នាក់

-ផ្សព្វផ្សាយដល់កសិករ និងម្ចាស់ច្បារពូជកៅស៊ូលើខ្លឹមសារប្រកាសស្តីពី " ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ " ហើយនិងបច្ចេកទេសទូទៅដាំដុះកៅស៊ូចំនួន០៣លើក នៅតាមបណ្តាខេត្ត ដែលមានសក្តានុពលដាំដំណាំកៅស៊ូ ក្នុងនោះមានខេត្តកំពង់ចាម ខេត្តរតនគីរី និងក្រុងប៉ៃលិន ដោយមានអ្នកចូលរួម សរុបមានចំនួន ១០៥នាក់

-បញ្ជូនថ្នាក់គ្រប់គ្រងមន្ទីរពិសោធន៍យថាប្រភេទ ទៅចូលរួមសិក្ខាសាលា និងវគ្គផ្សព្វផ្សាយចំនួនពីរលើកស្តីពី កិច្ចពិគ្រោះយោបល់ ជាមួយស្ថាប័នពាក់ព័ន្ធកសាងសមត្ថភាពពាណិជ្ជកម្ម-គំពោងមេគង្គតំណាក់កាលទី៣ របស់អង្គការ UNIDO និង "Etiquette of Business and Service Knowledge" នៅក្រុងភ្នំពេញ

-ទទួលការធ្វើទស្សនកិច្ចសិក្សារបស់និស្សិត មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ធ្វើការស្វែងយល់អំពី ចំការពិសោធន៍ក្លូន ទ្រង់ទ្រាយធំ LSCT AA01, AA02

-ទទួលនិស្សិតមកពីសាកលវិទ្យាល័យស្វាយរៀងចំនួន២១នាក់ មកធ្វើទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់អំពី គុណភាពកៅស៊ូ CSR ប្រពន្ធ័ការធ្វើតេស្ត ហើយនិងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

គ.៨.២- ការបណ្តុះបណ្តាល

*បញ្ជ្រាបនូវការយល់ដឹង និងព័ត៌មានផ្សេងៗអំពី វិស័យកៅស៊ូ វិទ្យាស្ថានបានធ្វើការតាក់តែង និងបោះផ្សាយនូវក្រដាស ផ្ទត់កូនសៀវភៅ និងឯកសារមួយចំនួនចែកជូន ដល់អ្នកដែលមានអាជីពវិស័យកៅស៊ូ កសិករកៅស៊ូគ្រួសារ និងអ្នកដែលមានបំណងស្វែងយល់អំពីវិស័យកៅស៊ូ ដែលរួមមាន (១)ផ្ទាំងក្រដាសផ្សព្វផ្សាយ (Poster) ចំនួន១០មុខ (២)ក្រដាសផ្ទត់ចំនួន០២មុខ (៣)ព្រឹត្តិបត្រព័ត៌មាន (CRRI- Newletter) ចំនួន ០៦លេខ (៤)ទិនានុប្បវត្តិចំនួន ០២លេខ (៥)កូនសៀវភៅណែនាំបច្ចេកទេសចំនួន០២មុខ និង(៦)សៀវភៅរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០០៩-២០១០។*

## ៨.៣.២-វាយតម្លៃ និងសំណើ

*ក្រោយពីរាជរដ្ឋាភិបាលបានធ្វើអវិនិយោគចំការកៅស៊ូរដ្ឋទាំង៧ និងបានកែសម្រួលអគ្គនាយកដ្ឋានកៅស៊ូ ជាអង្គភាពរដ្ឋបាលថ្នាក់កណ្តាល តែពុំមានរចនាសម្ព័ន្ធដល់ថ្នាក់មូលដ្ឋាន និងដោយថវិកា មធ្យោបាយធ្វើដំណើរ មធ្យោបាយបម្រើការងារ និងធនធានមនុស្សនៅមានកម្រិត ។ ដើម្បីគ្រប់គ្រងវិស័យកៅស៊ូ ជានាទទួលបានប្រសិទ្ធិភាពខ្ពស់ និងប្រកបដោយចីរភាព គឺត្រូវមានការ គាំទ្រពីថ្នាក់ដឹកនាំ និងមានការចូលរួមទទួលខុសត្រូវរបស់មន្ត្រីជំនាញ ស្ថាប័នពាក់ព័ន្ធ និងពីគ្រប់ ប្រតិបត្តករកៅស៊ូទាំងអស់ផងដែរ ។*

*ជាសំណូមពរ ស្នើផ្តល់ថវិកា មធ្យោបាយ ឧបករណ៍ សម្ភារ និងក្របខណ្ឌថ្មីជាធនធានមនុស្ស និងមានរចនាសម្ព័ន្ធគ្រប់គ្រងពីលើដលើក្រោម ឱ្យបានសមស្របតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានកៅស៊ូ ។*

## ៨.៣.៣-វិធានការ

*- បន្តរៀបចំកសាងច្បាប់កៅស៊ូ និងលិខិតគតិយុត្តិ ពាក់ព័ន្ធនឹងការដាំដុះ ការប្រមូលផល ការកែច្នៃ ការដឹកជញ្ជូន និងការនាំចេញ ។*

*-ចុះសិក្សាស្រាវជ្រាវអំពីសក្តានុពល នៃប្រភេទដីដែលអាចដាំកៅស៊ូបាន* ( Latosols, Red yellow podzols,and Regurs....) *នៅតំបន់មួយចំនួនក្នុងទូទាំងប្រទេស ។*

*-បង្កើតការិយាល័យកៅស៊ូតាមខេត្ត ដើម្បីងាយស្រួល សិក្សាអំពីសក្តានុពលដីដែលកបនឹងដំណាំកៅស៊ូ តាមដាន ត្រួតពិនិត្យការងារបច្ចេកទេស រៀបចំការចុះបញ្ជិកា ប្រមូល ទិន្នន័យ ចងក្រងស្ថិតិ កៅស៊ូ និងផ្ទេរបច្ចេកវិទ្យា ព្រមទាំងផ្តល់ព័តមានកៅស៊ូ ឲ្យដល់អ្នកពាក់ព័ន្ធនឹង វិស័យកៅស៊ូបានទាន់ ពេលវេលា និងមានប្រសិទ្ធិភាព ។*

*- យកចិត្តទុកដាក់កែលំអគុណភាពកៅស៊ូ ចាប់តាំងពីការដាំដុះរហូតដល់ចេញជាផលិតផលជ័រ និងឈើកៅស៊ូ ដោយចុះពិនិត្យបណ្តាថ្នាលបណ្តុះកូន ច្បារពូជកៅស៊ូ ការចេញវិញ្ញាបនបត្រ បញ្ជាក់ពូជកៅស៊ូ និងការកែច្នៃកៅស៊ូ។*

*- ចុះស្រង់ស្ថិតិកៅស៊ូគ្រួសារ និងផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ ក្នុងខេត្តគោលដៅ ចំនួន ០៥ គឺខេត្តបាត់ដំបង ប៉ៃលិន កំពង់ចាម កំពង់ធំ និងព្រះវិហារ ក្នុងគោលបំណង អភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ។*

*- ចុះស្រង់ទិន្នន័យរោងចក្រ-សិប្បកម្មកែច្នៃផលិតផលកៅស៊ូនៅទូទាំងប្រទេស*

- អនុវត្តការងារមន្ទីរពិសោធន៍តាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025 និងចុះបំពេញបេសកកម្ម នៅបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងពេងចក្រកែច្នៃកៅស៊ូក្រុមហ៊ុន និងធ្វើការពិសោធន៍ភាគសំណាក យថាប្រភេទកៅស៊ូពីបណ្តាក្រុមហ៊ុនចំការកៅស៊ូ និងអនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញ

- រៀបចំថ្នាលបណ្តុះកូនទំហំ ០,៣ ហ.ត ដាំដុះពិសោធន៍កៅស៊ូថ្មីចំនួន ១២ហ.ត បំប៉ោ និងបង្កើន បរិមាណមែកពូជកូន CMS និងបើកមុខចៀរកៅស៊ូថ្មីទំហំ ៤៧,៧៦ហ.ត

- បន្តផ្សព្វផ្សាយប្រកាសស្តីពី "ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ"

-បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសរៀបចំច្បារពូជកៅស៊ូ និងចុះទៅបើកវគ្គបណ្តុះបណ្តាល បច្ចេកទេស ជំនាញនៅតាមបណ្តាខេត្តដែលមានសក្តានុពល និងចូលរួមសកម្មភាពការងារជាមួយអង្គការ UNIDO

- ចូលរួមធ្វើសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍បច្ចេកវិទ្យា និងចំណេះដឹងលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ ។

-ចូលរួម និងសហការជាមួយស្ថាប័ន ភ្នាក់ងារហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការ ផ្តល់ហិរញ្ញប្បទានដល់ការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស ៕

## ៥.៤-លទ្ធផលការងាររុក្ខកម្ម

### ៥.៤.១-លទ្ធផល ឆ្នាំ ២០១០

#### ៥.៤.១.១- ការប្រមូលចំណូលពីវិស័យព្រៃឈើ

ដោយមានការខិតខំប្រឹងប្រែងយ៉ាងយកចិត្ត ទុកដាក់ពីថ្នាក់ដឹកនាំនិងមន្ត្រីរដ្ឋបាលព្រៃឈើគ្រប់ ជាន់ថ្នាក់ ការប្រមូលចំណូលពីវិស័យព្រៃឈើសរុបចំនួន ៤៥.៩៧១.១៣៦.៧៩៣៛ (សែសិបប្រាំពាន់ ប្រាំបួនរយចិតសិបមួយលានមួយរយសាមសិបប្រាំមួយពាន់ប្រាំពីររយកៅសិបបីរៀលគត់) ស្មើនឹង ២៥០% នៃផែនការ ក្នុងនោះ ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋចំនួន ២៨.២២៣.៧៥៩.៨២៥៛០០ ចំណូល ពីថ្លៃសួយសារសត្វគ្រប់ប្រភេទចំនួន ៣០៥.៥៩២.៨៧១៛០០ ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌ កម្មចំនួន ១៧.៤១៦.៧៨៩.៥៩៧៛០០ និងបានមកពីការជួលអចលកម្មចំនួន ២៤.៩៩៤.៥០០៛០០។

#### ៥.៤.១.២- ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេស

បានរៀបចំកម្មវិធីព្រៃឈើជាតិសម្រេចជាស្ថាពរ ដោយរាជរដ្ឋាភិបាលចុះហត្ថលេខាកាលពីខែ តុលា ឆ្នាំ ២០១០ ហើយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ បានប្រារព្ធប្រកាសដាក់ឲ្យប្រើប្រាស់ កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០។ ចំពោះការកសាងលិខិតបទដ្ឋានក្រោមច្បាប់វិញ រដ្ឋបាលព្រៃឈើ បានរៀបចំនូវអនុក្រឹត្យស្តីពី ការបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាប ផ្សេងទៀត នៅទីតាំងអន្លង់ព្រីងស្រុកកំពង់ត្រាច ខេត្តកំពត ហើយត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុម័តដាក់ ឱ្យប្រើប្រាស់កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១០។ ក្រៅពីនេះ នៅមានអនុក្រឹត្យ និងប្រកាសមួយចំនួន ទៀតដែលបានរៀបចំរួច និងត្រៀមដាក់ប្រជុំពិភាក្សាផ្ទៃក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេច ឬមានវិធានការបន្ត។ នៅក្នុងឆ្នាំនេះដែរ ក្រសួងបាននឹងកំពុងរៀបចំតាក់តែងជាសេចក្តី ព្រាងច្បាប់ស្តីពី សត្វព្រៃដែលសង្ឃឹមថានឹងសម្រេចបានទទួលការអនុម័តក្នុងឆ្នាំ ២០១១ នេះ។

៨.៤.១.៣- ការដាំឈើ **និងស្ដារព្រៃឈើ**

ក្នុងឆ្នាំ ២០១០ កន្លងទៅនេះ គឺជាឆ្នាំដែលសកម្មភាពដាំឈើបានកើនឡើងយ៉ាងខ្លាំងក្លាជាងរាល់ឆ្នាំ ដោយសារមានការយកចិត្តទុកដាក់ដាំឈើរយៈពេលវែងនៅតាមបណ្ដាវត្តអារាម និងទី សាធារណៈនានាទូទាំងប្រទេស។

ការផ្ដល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ សម្រាប់ការដាំឈើជាដៃគូ រដ្ឋបាលព្រៃឈើកំពុងដំណើរការចចារកិច្ច ព្រមព្រៀងធ្វើដៃគូជាមួយក្រុមហ៊ុន Oji Paper Co.,Ltd ដើម្បីអភិវឌ្ឍការងារដាំឈើលើផ្ទៃដីទំហំ ១០.០០០ ហិកតា នៅស្ថានីយម្សៅក្រដាសហ៊ុនសែន-មានខេត្តកំពង់ឆ្នាំង។ គម្រោងការមួយទៀត គឺគម្រោងដៃគូដាំឈើជាមួយ ក្រុមហ៊ុន Think Biotech Co.,Ltd លើផ្ទៃដី ៣០.០០០ហិកតា នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលកំពុងដំណើរការពិភាក្សា និងស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល។ រីឯគម្រោងដាំឈើជាដៃគូជាមួយក្រុមហ៊ុន Double A Co.,Ltd, លើផ្ទៃដី ១៤.០០០ហិកតា នៅស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើ ស្វាយលើ ខេត្តសៀមរាប នោះត្រូវបានពន្យាពេលសិក្សា ដោយសារតែមានបញ្ហាមួយចំនួន។

ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវាទូទាំងប្រទេសសម្រេចបាន ៦៦ហិកតា និងបានចែកជូនកូនឈើបានចំនួន ១៤.៨៤០ ដើម។ ការប្រារព្ធបុណ្យរុក្ខទិវាថ្នាក់ជាតិ ៩ កក្កដា ឆ្នាំ ២០១០ ត្រូវបានរៀបចំ នៅភូមិស្ដុកជ្រៃ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ លើផ្ទៃដីចំនួន ២០ហិកតា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**។ ការដាំដើមឈើនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង លើផ្ទៃដី ២២ ហិកតា ក្រោមអធិបតីភាពឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ២ នៃវុឌ្ឍសភាជាតិ។

៨.៤.១.៤- ការងារស្រាវជ្រាវ និងបណ្ដុះបណ្ដាល

- បានសហការជាមួយនិងវិទ្យាស្ថានស្រាវជ្រាវព្រៃឈើជប៉ុន និងសាកលវិទ្យាល័យ Kyushu នៃប្រទេសជប៉ុន បន្តការអនុវត្តគំរោងស្រាវជ្រាវរួមគ្នាអំពីព្រៃឈើ ដោយចុះសិក្សាស្រាវជ្រាវពីវដ្ដនៃទឹកដីព្រៃឈើ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃល្បោះ និងបានចុះប្រមូលទិន្នន័យបានចំនួន ១២ លើក និងចុះប្រមូលសំណាកដី រុក្ខជាតិសំរាប់សិក្សាពីកាបូនស្ដុកក្នុងដីព្រៃឈើបានចំនួន ៤លើក។

- អនុវត្តគំរោងសាកល្បងអភិវឌ្ឍន៍កសិរុក្ខកម្ម បានផ្ដោតសំខាន់ទៅលើ ការបណ្ដុះបណ្ដាលសហគមន៍មូលដ្ឋាន នូវបច្ចេកទេសដាំដុះជាលក្ខណៈចម្រុះនូវប្រភេទឈើហូបផ្លែ និងដំណាំប្រភេទឈើក្នុងស្រុកផ្សេងៗ ក្នុងតំបន់ព្រៃរេចរឹល និងដាំជាលក្ខណៈគ្រួសារ ចំនួន ០៣ ភូមិ ក្នុងខេត្តកំពតនិងក្រចេះ ។ គម្រោងនេះ មានគោលបំណងលើក កំពស់សហគមន៍មូលដ្ឋាននិងថែរក្សាគម្របព្រៃឱ្យ បានគង់វង្ស។

- គម្រោងស្ដារព្រៃឈើឡើងវិញ ទទួលបានការឧបត្ថម្ភពីមូលនិធិ Dawin និងមានគោលបំណងដើម្បីសិក្សាស្វែងយល់អំពីវិធីសាស្ត្រ នៃការស្ដារព្រៃឈើតាមលក្ខណៈធម្មជាតិ ដោយបង្កើតជាថ្នាលបណ្ដុះកូនឈើសម្រាប់ ធ្វើការពិសោធន៍ក្នុងតំបន់ព្រៃឈើស្ដារឡើងវិញ និងធ្វើការដាំដុះកូនឈើទាំងនោះ នៅក្នុងតំបន់ដែនសមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ដែលអនុវត្តដោយមន្ត្រីវិទ្យាស្ថានស្រាវជ្រាវសហការជាមួយមន្ត្រីការិយាល័យ ផ្សព្វផ្សាយ

- សហការជាមួយស្ថាប័នកូតគាមសាស្ត្រឃុនមីញនៃសាធារណៈរដ្ឋប្រជាមានិតចិន វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងសត្វព្រៃបានប្រមូលនិងកំណត់អត្តសញ្ញាណរុក្ខជាតិបានចំនួន ៣៩០ ប្រភេទ ហើយកិច្ចសហប្រតិបត្តិ ការជាមួយវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងផលិតផលព្រៃឈើជប៉ុន (FFPRI)

បានធ្វើការប្រមូលទិន្នន័យក្នុងឡូត៍គំរូអចិន្ត្រៃយ៍ នៅខេត្តកោះកុង និងកំពង់ធំ ដើម្បីធ្វើការសិក្សាគណនាសន្និធិកាបូនក្នុងព្រៃរបស់កម្ពុជា ។

**៥.៤.១.៥- ការងារសហប្រតិបត្តិការអន្តរជាតិ**

នៅក្នុងឆ្នាំ ២០១០ កិច្ចសហប្រតិបត្តិការអន្តរជាតិ បានទទួលលទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងនោះ

- គម្រោងគាំទ្រពីអង្គការ ITTO ថវិកាសរុបចំនួន ១,២ លានដុល្លារ អភិវឌ្ឍតំបន់ត្រីកោណមរកតប្រកបដោយជោគជ័យសម្រាប់អនុវត្តរយៈពេល ៣ ឆ្នាំ

- គម្រោង UN-REDD សន្យានឹងផ្តល់ថវិកាចំនួន ៣ លានដុល្លារ ហើយប្រទេសជប៉ុនផ្តល់ថវិកាសម្រាប់គម្រោង Forest Preservation ចំនួន ១០ លានដុល្លា សម្រាប់ទិញឧបករណ៍សម្ភារៈ អនុវត្តនៅឆ្នាំ ២០១១ ហើយគម្រោងនេះនឹងមានការផ្តល់នូវអគារមួយ ដែលត្រូវសាងសង់នៅក្នុងបរិវេណមជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើ និងសត្វព្រៃ

- គម្រោងដែលនឹងត្រូវចាប់ផ្តើមនៅឆ្នាំ ២០១១ គឺគម្រោងការគ្រប់គ្រងព្រៃឈើដោយនិរន្តភាពក្រោមជំនួយឧបត្ថម្ភថវិការតាមរយៈ UNDP ដែលមានទឹកប្រាក់ ២.២លានដុល្លារ

- មានគម្រោងផ្សេងៗជាច្រើនទៀត បានអនុវត្តកន្លងមក ពិសេសពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងការងារស្រាវជ្រាវ។ល។

**៥.៤.១.៦- ការពង្រឹងការអនុវត្តច្បាប់**

**ក- ការចុះបង្ក្រាបបទល្មើសព្រៃឈើនៅទូទាំងប្រទេស**

- បទល្មើសរុបដែលបានចងក្រងសំណុំរឿងបទល្មើស បញ្ជូនទៅតុលាការដំបូងរាជធានី ខេត្តតាមនីតិវិធីច្បាប់ស្តីពី ព្រៃឈើមានចំនួន ១.៣៧៧ ករណី

- សំណុំរឿងដែលបានបញ្ជូនមក ត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទបទល្មើសចំនួន ១.៥០៧ករណី ក្នុងនោះបញ្ចប់សំណុំរឿងចំនួន ៥៤២ករណី កំពុងចងក្រងសំណុំរឿង ៣០ករណី

- សមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើមូលដ្ឋាន បានចុះធ្វើការត្រួតពិនិត្យ និងចាប់ឃាត់ឈើល្មើសច្បាប់ ពីបណ្តាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចនៅតាមបណ្តាខេត្តមួយចំនួន ដែលបានលួចកាប់ឈើពីប្រភពខាងក្រៅនាំមករក្សាទុក ធ្វើសន្និធិខុសច្បាប់ក្នុងដីសម្បទានរបស់ខ្លួនចំនួន ១៤ករណីមានបរិមាណឈើចម្រុះប្រភេទចំនួន ១.៣៣៧ ម៣។

**ខ-ការបង្ក្រាបបទល្មើសព្រៃឈើដែលជួបប្រទះការលំបាក និងលេចធ្លោគួរឲ្យកត់សំគាល់**

រាល់ករណីដែលបានកើតឡើងនេះ រដ្ឋបាលព្រៃឈើបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងស្ថាប័នតុលាការ ដើម្បីនាំយកជនល្មើសមកផ្តន្ទាទោសតាមច្បាប់ហើយដែរ ។

តាមការសង្កេតនូវសកម្មភាពបទល្មើសព្រៃឈើ នៅប៉ុន្មានខែចុងឆ្នាំ ២០១០ ហាក់ដូចជាចាប់ផ្តើមកម្រើកឡើងវិញ ពិសេសចាប់ពីពេលដែលជនល្មើសមួយចំនួន ដែលសមត្ថកិច្ចបានធ្វើការចោទប្រកាន់ទៅតុលាការក្នុងអំឡុង ពេលយុទ្ធនាការទ្រង់ទ្រាយធំកន្លងមក ត្រូវបានរួចខ្លួន ហើយបានចាប់ផ្តើមធ្វើសកម្មភាពបង្កបទល្មើសព្រៃឈើឡើងវិញ ដោយផ្លាស់ប្តូររូបភាពប្រព្រឹត្តល្មើស ពីទ្រង់ទ្រាយធំដោយចេញមុខមកជារូបភាពរូបភាពលាក់មុខ និងបំបែកទៅជាទ្រង់ទ្រាយតូចៗពិបាក នឹងបង្ក្រាប។

**៥.៤.១.៧- ការវាយតម្លៃធនធានព្រៃឈើក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច**

ដោយអនុវត្តតាមប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលព្រៃឈើបានទទួលសំណើសុំវាយតម្លៃពីក្រុមហ៊ុនចំនួន ៤១ ក្នុងនោះ បានអនុវត្ត

រួចចំនួន ៤ ក្រុមហ៊ុន និង២៧ក្រុមហ៊ុន កំពុងប្រព្រឹត្តិកម្មទិន្នន័យ ហើយក្រុមហ៊ុនចំនួន ១០ បានស្នើសុំពន្យា ពេលវាយតម្លៃធនធានព្រៃឈើ។ ការវាយតម្លៃធនធាន គឺជាវិធានការមួយចាំបាច់ ដើម្បីបង្កើនការប្រមូលចំណូលពីផលព្រៃឈើដែលនឹងត្រូវឈូសឆាយ ទប់ស្កាត់ បាតុភាពអសកម្មលើការប្រមូលឈើពីក្រៅតំបន់មកបន្ទំ។

**៤.៤.១.៨- ការងារដេញថ្លៃនិងការពិគ្រោះថ្លៃផល អនុផលព្រៃឈើ**

ការដេញថ្លៃជាសាធារណៈនូវផល អនុផលព្រៃឈើដែលរឹបអូសបានពីការបង្ក្រាបបទល្មើសព្រៃឈើ តាមអំណាចសាលក្រម តាមដីកាសម្រេចរបស់តុលាការ សេចក្តីសម្រេចពិន័យអន្តរការណ៍ ដីកាសម្រេចរឹបអូសឈើសន្និធិគ្មានម្ចាស់នៅតាមបណ្តាខេត្តមួយចំនួនទទួលបានលទ្ធផល ដូចខាងក្រោមៈ

i - ឈើចម្រុះប្រភេទដេញថ្លៃរួចជាស្ថាពរ

រដ្ឋបាលព្រៃឈើបានធ្វើការដាក់ដេញថ្លៃនិងពិគ្រោះថ្លៃជាសាធារណៈរួចជាស្ថាពរនូវបរិមាណឈើចម្រុះប្រភេទចំនួន ៤.២៦២ ម៣ បានទឹកប្រាក់សរុបចំនួន ២១.៣៦៦.៥៧៩.២២២រ០០។

i - ឈើចម្រុះប្រភេទដេញថ្លៃរួចហើយត្រូវបានអតិថិជនបោះបង់ចោល

បរិមាណឈើចម្រុះប្រភេទចំនួន ១.៦៤៦ម$^{៣}$ បានធ្វើការដេញថ្លៃរួចហើយ តែត្រូវបានអតិថិជនបោះបង់ចោល រដ្ឋបាលព្រៃឈើបានធ្វើការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ មានទឹកប្រាក់សរុបចំនួន ១.៥៩៤.១៣៤.២៥៦រ០០ បង់ចូលថវិកាជាតិ ក្នុងនោះខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ២៧៦ ម$^{៣}$ ស្មើនឹង ១០០.៧៧២.២៣៦រ០០ ខណ្ឌរដ្ឋបាលព្រៃឈើកោះកុង ១៩០ម$^{៣}$ ស្មើនឹង ៣៦៧.៨១០.៤២០រ០០។

ចំពោះឈើដេញថ្លៃនៅខណ្ឌរដ្ឋបាលព្រៃឈើកណ្តាលចំនួន ១.៣៦៩ម$^{៣}$ ដែលអតិថិជនយឺតយ៉ាវក្នុងការបង់ប្រាក់នោះ ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុញ្ញាតឲ្យអតិថិជនធ្វើការបង់ប្រាក់បង្គ្រប់លើទឹកប្រាក់ដែលបានរឹបអូសតាមលិខិតលេខ ៦៥១កសក ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១១។ ដោយឡែក ឈើនៅខណ្ឌរដ្ឋបាលព្រៃឈើកោះកុងចំនួន ១៩០ម$^{៣}$ ត្រូវបានធ្វើការដេញថ្លៃឡើងវិញបានរួចរាល់ជាស្ថាពរហើយ ។

iii- ឈើចម្រុះប្រភេទប្រកាសដាក់ដេញថ្លៃតែគ្មានអតិថិជនចូលរួមដេញថ្លៃ

ឈើចម្រុះប្រភេទដែលបានដាក់ដេញថ្លៃ ២ លើករួចមកហើយ តែពុំមានអតិថិជនណាចូលរួមដេញថ្លៃមានចំនួន ១.៧២៦ ម$^{៣}$ ។ ករណីនេះរដ្ឋបាលព្រៃឈើនិងចាត់ការតាមនីតិវិធីបន្តទៀត។

iv- ឈើចម្រុះប្រភេទដែលបានធ្វើសន្និធិខុសច្បាប់នៅតាមឃ្លាំងនិងសណ្ឋាគារ

ឈើដែលបានធ្វើការចាប់ឃាត់ក្នុងយុទ្ធនាការ ពិសេសនៅតាមបណ្តាសណ្ឋាគារ និងឃ្លាំងស្តុកដើម្បីប្រើប្រាស់នៅខេត្តសៀមរាបនោះ រដ្ឋបាលព្រៃឈើបានចេញសេចក្តីជូនដំណឹងជាបន្តបន្ទាប់ ដោយប្រកាសឲ្យម្ចាស់ផល អនុផលព្រៃឈើដែលធ្វើសន្និធិគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើទាំងនោះចូលខ្លួនមកបង់ពិន័យអន្តរការណ៍ផ្អែកតាមលិខិតលេខ ៧៤៣ សជណ.កស ចុះថ្ងៃទី ០១-០៧-២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ចាប់ពីការជូនដំណឹងនោះរួចមក រហូតមកទល់ពេលនេះ រដ្ឋបាលព្រៃឈើបានរៀបចំសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការចំនួន ០៥ ករណី ដើម្បីចាត់ការតាមនីតិវិធី ហើយ ០៣ ករណីទៀត ម្ចាស់ ធ្វើសន្និធិផល អនុផលព្រៃឈើល្មើសច្បាប់បានសារភាពទោសកំហុស និងស្នើសុំបង់ពិន័យអន្តរការណ៍ ហើយ ខណ្ឌរដ្ឋបាលព្រៃឈើ សៀមរាបកំពុងចាត់ការតាមនីតិវិធី ។

v-ក្រុមហ៊ុនដែលដេញថ្លៃឈើបានហើយស្នើនាំចេញទៅបរទេស

កន្លងមក ក្រុមហ៊ុន វ៉ាន់ នានហុង អ៊ិនធើត្រេដ ខូអិលធីឌី សាមីឌី ជាតំណាងដេញថ្លៃផល ដែល

បានអនុផលព្រៃឈើនៅកំពង់ចាម បានស្នើសុំនាំចេញទៅបរទេស។ បច្ចុប្បន្ន ដើម្បីជានាសុវត្ថិភាពនិងគុណភាពឈើទាំងនោះ ក្រុមហ៊ុនបានស្នើសុំដឹកឈើនៅតាមបណ្តាគោលដៅនានាទៅកាន់ឃ្លាំងរបស់ខ្លួន ស្ថិតនៅភូមិបេង ឃុំជា ស្រុកមេមត់ ខេត្តកំពង់ចាម ហើយរដ្ឋបាលព្រៃឈើ បានឯកភាពតាមសំណើរបស់ក្រុមហ៊ុន ។

**៥.៤.១.៩- ការងាយស្រួល**

មានការផ្តួចផ្តើមចង្អុលបង្ហាញនិងគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំជាតិគ្រប់ស្ថាប័ន ជាពិសេសពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ផ្ទាល់ និងការចូលរួមពីថ្នាក់ដឹកនាំក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ពិសេសថ្នាក់ដឹកនាំដែលមានជំនាញអាជីពដើម និងបទពិសោធន៍ច្រើនពីផ្នែកព្រៃឈើ។

មានច្បាប់ស្តីពី ព្រៃឈើគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីព្រៃឈើច្បាស់លាស់និងបទបញ្ជាជាច្រើនរបស់រាជរដ្ឋាភិបាលសម្រាប់ជាមូលដ្ឋានពង្រឹងការគ្រប់គ្រង និងអនុវត្តច្បាប់ក្នុងវិស័យព្រៃ ឈើទូទាំងប្រទេស ។

មានការចូលរួម និងគាំទ្រយ៉ាងសកម្មពីកងយោធពលខេមរភូមិន្ទ នគរបាល អាជ្ញាធរ ស្ថាប័នពាក់ព័ន្ធអង្គការអន្តរជាតិ ដែលជាដៃគូរអភិវឌ្ឍនិងពីប្រជាពលរដ្ឋគ្រប់ទិសទី និងមន្ត្រីរដ្ឋបាលព្រៃឈើភាគច្រើនបំផុតមានសមត្ថភាពជំនាញ ស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យសម្រេចជោគជ័យ។

មានក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ព្រៃឈើនិងបរិស្ថាន ជាយន្តការសម្របសម្រួលផ្តល់ជំនួយសហប្រតិបត្តិការ និងជាវេទិកាពិគ្រោះយោបល់របស់គ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ ផ្នែករដ្ឋាភិបាលដៃគូអភិវឌ្ឍ ។

**៥.៤.១.១០- ការលំបាក និងឧបសគ្គ**

- ខ្វះខាតធនធានមនុស្ស ថវិកា សម្ភារ និងការលើកទឹកចិត្តដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឱ្យនៅបំរើការងារនៅតំបន់ដាច់ស្រយាល និងមធ្យោបាយសម្រាប់ដំណើរការវិស័យព្រៃឈើ ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា

- ជនប្រព្រឹត្តបទល្មើសតែងតែផ្លាស់ប្តូរវិធីសាស្ត្រក្នុងការប្រមូលផលឈើ ដឹកជញ្ជូន និងកាប់រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិក្រោមរូបភាពផ្សេងៗ

- កិច្ចសហការ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការត្រួតពិនិត្យ-បង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើ តែងជួបប្រទះការលំបាកយឺតយ៉ាវនិងមានវិវាទជាមួយជនល្មើស ព្រមទាំងមានការលួចវាយបំផ្លាញបង្គោលព្រំដែលបានបោះរួច

- ប្រជាជនមូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើ នៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើហើយការគ្រប់គ្រងជនចំណាកស្រុកនៅមានការធូររលុងពីសំណាក់អាជ្ញាធរមូលដ្ឋានដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ ។

**៥.៤.២- វាយតម្លៃ និងសំណើ**

- ជារួមគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើ ដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋបាលព្រៃឈើ នឹងអនុវត្តផែនការសកម្មភាព ដើម្បីឱ្យមានប្រសិទ្ធភាពខ្ពស់

- អន្តរាគមន៍ទៅក្រសួងមហាផ្ទៃណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ពង្រឹងការគ្រប់គ្រងស្ថិតិ និងការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាជនចំណាកស្រុក និងជំរុញការអនុវត្តអនុក្រឹត្យស្តីពី វិធានប្រើប្រាស់ដីព្រៃរបស់រដ្ឋសំរាប់ការដាំឈើ ដើម្បីបង្កើនផ្ទៃដីគំរបព្រៃឈើឈានឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ដែលបានកំណត់រក្សាគំរបព្រៃឈើ ៦០ ភាគរយ នៅឆ្នាំ ២០១៥

- បង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាន និងព្រះរាជអាជ្ញា ឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងតំបន់និងជាមួយប្រទេសជិតខាង ក៏នឹងត្រូវបានយកចិត្តទុកដាក់ពង្រឹងពង្រីកជាប្រចាំតាមរយៈកិច្ចសហការទ្វេភាគី និងការចូលរួមអនុវត្តកម្មវិធីតំបន់ ឬអន្តរជាតិ ដូចជា FLEG, ASEAN-WEN ។

**៥.៤.៣-វិធានការ**

-ពង្រឹងសាមគ្គីភាព ក្រមសីលធម៌ វិន័យ ការចាត់តាំង ភាពស្មោះត្រង់ មានឆន្ទៈក្នុងការបំពេញការងារ និងជម្រុញកំណត់ព្រំប្រទល់ដែនព្រៃឈើធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង ១.០០០ គីឡូម៉ែត្រ

- រៀបចំអនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពគ្រប់គ្រងព្រៃឈើ នៅគ្រប់កម្រិតនៃរដ្ឋបាលព្រៃឈើ ដោយធ្វើការសិក្សាសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងរៀបចំព្រៃគុបដេញថ្លៃសម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើក្នុងស្រុក រួមទាំងព្រៃគុបក្នុងតំបន់អាងទំនប់វារីអគ្គិសនីនានាដូចជា វារីអគ្គិសនី ឫស្សីជ្រុំ សេសាន២ តាតៃ...

- ពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា បទបញ្ញត្តិលិខិតបទដ្ឋានពាក់ព័ន្ធនិងវិស័យព្រៃឈើ(ច្បាប់ស្តីពីព្រៃឈើ បទបញ្ជាលេខ ០១-០២សជណ និងអនុសាសន៍របស់សម្តេចតេជោ) ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាត ទប់ស្កាត់និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលា ទន្ទឹមនឹងការពង្រឹងវិន័យការងារចំពោះមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មសាធារណៈ និងអភិបាលកិច្ចល្អនៃវិស័យព្រៃឈើ

- ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការពិន័យ អន្តរការណ៍

- តាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតំបន់ ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០ កន្លែងបន្ថែមទៀតព្រមទាំងជំរុញការកំណត់តំបន់សក្តានុពលសម្រាប់សហគមន៍ព្រៃឈើ ឱ្យបានពីរលានហិកតា តាមការកំណត់ក្នុងកម្មវិធីព្រៃឈើជាតិ

- ផ្តល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចំការព្រៃដាំ ដែលផ្តល់ផលប្រយោជន៍ច្រើនយ៉ាង ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់នៅក្នុងតំបន់ព្រៃរេចរឹល តាមរយៈការបង្កើនដាំដុះព្រៃឈើ ការចែកជូនប្រជាពលរដ្ឋនូវកូនឈើសម្រាប់ដាំតាមគេហដ្ឋាន តាមទីសាធារណៈ វត្តអារាម ការប្រារព្ធបុណ្យរុក្ខទិវា ៩ កក្កដា ទូទាំងប្រទេស រៀបចំបង្កើត

ស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ ថ្នាលបណ្តុះកូនឈើ សួនដាំឈើអនុស្សាវរីយ៍ សួនអាពាហ៍ពិពាហ៍ និងបន្តអភិវឌ្ឍគុណភាពសេណេទិចពូជ និង បច្ចេកទេសដាំដុះឱ្យកាន់តែមានប្រសិទ្ធភាព...

- បង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារតាមរយៈការរៀបចំផែនការគ្រប់គ្រង និងធ្វើការអភិវឌ្ឍសេវាកម្ម បរិស្ថាន រួមទាំងទេសចរណ៍ធម្មជាតិនិងឥណទានកាបូនព្រៃឈើ ដើម្បីបង្កើតការងារ និងប្រភពចំណូលបន្ថែមជូនប្រជាជន និងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពិភពលោក ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការឡើងកំដៅនៃភពផែនដី

- សហការជាមួយដៃគូនានា អនុវត្តគម្រោងការបណ្តុះបណ្តាលពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងរៀបចំវគ្គបណ្តុះបណ្តាលចាំបាច់នានា រួមទាំងប្រពន្ធ័ព័ត៌មានភូមិសាស្ត្រព្រៃឈើ (GIS) និងបំពាក់សម្ភារៈដល់អង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋាន ឱ្យមានលទ្ធភាពផលិតផែនទីប្រើប្រាស់ដោយខ្លួនឯង

- លើកកំពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយព្រៃឈើ តាមរយៈការផលិតសម្ភារ និងឯកសារបច្ចេកទេសជាទំរង់រឹង និងទន់ សម្រាប់យកទៅធ្វើការចែកផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញរលកធាតុអាកាស សារព័ត៌មាន ទស្សនាវដ្តី និង ចុះផ្សព្វផ្សាយផ្ទាល់នៅតាមមូលដ្ឋានភូមិស្រុក វត្តអារាម សាលារៀន...

- បង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ បង្កើតតំបន់ឬស្ថានីយស្រាវជ្រាវព្រៃឈើ-សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍដែលមានស្រាប់ និងស្វែងរកដៃគូថ្មីៗទៀតស្របតាមតម្រូវការអភិវឌ្ឍរបស់សង្គមជាតិ និងអន្តរជាតិ

- បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញ ឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្ម ដោយធ្វើការដាំដុះឈើប្រណិត និងថែរក្សា ការពារចំការព្រៃពូជ និងប្រមូលគ្រាប់ពូជឈើ ដើម្បីដាំដុះបន្ត និងបង្កើតសួនអាពាហ៍ពិពាហ៍ និងសួនដាំឈើអនុស្សាវរីយ៍នៅតាមបណ្តាខេត្តខណ្ឌរដ្ឋបាលព្រៃឈើ ទូទាំងប្រទេស

- កសាងហេដ្ឋារចនាសម្ព័ន្ធ ការិយាល័យ កន្លែងស្នាក់អាស្រ័យ រៀបចំធនធានមនុស្សនិងលិខិតបទដ្ឋានក្រោមច្បាប់ដើម្បីអនុវត្តរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើថ្មីតាមអនុក្រឹត្យលេខ ១៨៨ អន.ក្រ ចុះថ្ងៃទី ១៤-១១-២០០៨ និងធ្វើការកែសម្រួលសេចក្តីព្រាងអនុក្រឹត្យស្តីពី សម្លៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ

- ធ្វើការអភិវឌ្ឍផែនការនិងគម្រោងសំណើសកម្មភាពព្រៃឈើ និងសត្វព្រៃ ដោយខិតខំទំនាក់ទំនងសម្របសម្រួល ដើម្បីស្វែងរកនិងទទួលបាននូវការគាំទ្រផ្គត់ផ្គង់ធនធានហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ដំណើរការអនុវត្តផែនការសកម្មភាពព្រៃឈើឆ្នាំ ២០១១ ឱ្យបានសម្រេច ជាពិសេសតាមរយៈក្រុមការងារបច្ចេកទេសកំណែទម្រង់ព្រៃឈើ និងបរិស្ថាន។

### ៥.៥- **ការងារជលផល** (ឧបសម្ព័ន្ធទី ៣៩-៤១)

នៅក្នុងឆ្នាំ ២០១០ នេះ រដ្ឋបាលជលផលបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះ មានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការបង្កើតស្រះជម្រកត្រី ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស

ការបង្ក្រាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងបទដ្ឋានបច្ចេកទេសមួយចំនួនទៀតដែលបានរៀបចំត្រូវបានពិនិត្យ កែសម្រួល និងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តជានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព ។

ជាមួយការរីកចំរើននេះដែរក្នុងឱកាសប្រារព្ធទិវាមច្ឆជាតិ ១ កក្កដា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** តែងតែបានផ្តល់អនុសាសន៍ដ៏ថ្លៃថ្លាពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍវិស័យជលផលដែលទាក់ទងដល់ការបង្ក្រាបបទល្មើស ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង ឧបករណ៍ឆក់ត្រី ការបង្កើតកន្លែងអភិរក្សធនធានជលផល ការរៀបចំនិងគ្រប់គ្រងពង្រឹងសហគមន៍នេសាទ ជំរុញការអភិវឌ្ឍវារីវប្បកម្ម ការថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងជាដើម ។ល។

ដោយឡែកទៀត ក្រោយពីបានដាក់ចេញនូវវិធានការឱ្យគ្រប់អធិការដ្ឋាន និងខណ្ឌរដ្ឋបាលជលផលទាំងអស់អនុវត្តតាមអនុសាសន៍របស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានថ្លែងក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលឆ្នាំ ២០០៩ និងទិសដៅវិធានការ ២០១០ រួចមក ឃើញថាសកម្មភាពទាំងអស់នេះមានការវិវឌ្ឍន៍រីកចំរើនគួរជាទីមោទនៈ។ ជាមួយគ្នានេះដែរ រដ្ឋបាលជលផលក៏បានសហការជាមួយគម្រោងអង្គការក្រៅរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយនានា ក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយវារីវប្បកម្ម និងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល។

### ៥.៥.១-លទ្ធផល

### ៥.៥.១.១-អាជីវកម្មនេសាទ

#### ក- អាជីវកម្មនេសាទទឹកសាប

ការធ្វើអាជីវកម្មនេសាទទឹកសាបសរុបបានចំនួន ៤០៥.០០០ តោន ក្នុងនោះ៖

- អាជីវកម្មឡូត៍នេសាទ-នេសាទសិប្បកម្មរដូវនេសាទឆ្នាំ ២០១០ អនុវត្តបាន ១២៥.០០០តោន ស្មើនឹង ៩៦,១៥% នៃផែនការ ១៣០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៥.០០០ តោន

- នេសាទគ្រួសារក្នុងដែននេសាទឆ្នាំ ២០១០ អនុវត្តបាន ១៦០.០០០ តោន ស្មើនឹង ៩៤,១២% នៃផែនការ ១៧០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៥.០០០ តោន

- នេសាទគ្រួសារក្នុងវាលស្រែឆ្នាំ ២០១០ អនុវត្តបាន ១២០.០០០ តោន ស្មើនឹង ៨០% នៃផែនការ ១៥០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៥.០០០ តោន ។

#### ខ- អាជីវកម្មនេសាទសមុទ្រ

ការធ្វើអាជីវកម្មនេសាទសមុទ្រអនុវត្តបាន ៨៥.០០០តោន ស្មើនឹង ១០៦,២៥% នៃផែនការ ៨០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ១០.០០០ តោន។

### ៥.៥.១.២- ការអភិវឌ្ឍន៍វារីវប្បកម្ម

បច្ចុប្បន្នសកម្មភាពវារីវប្បកម្មកំពុងត្រូវបានទទួលស្គាល់ និងមានការចូលរួមយ៉ាងខ្លាំងពីគ្រប់ស្រទាប់ប្រជាពលរដ្ឋ និងរដ្ឋអំណាចមូលដ្ឋាននៅគ្រប់ រាជធានី ខេត្តទូទាំងប្រទេស។ នេះដោយសារមានការខិតខំប្រឹងប្រែងរបស់រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត ព្រមទាំងមានការឧបត្ថម្ភគាំទ្រពីអង្គការដៃគូអភិវឌ្ឍន៍នានា។ រដ្ឋបាលជលផលបានយកចិត្តទុកដាក់ ជំរុញការរៀបចំបង្កើតកន្លែងបង្កាត់ភ្ញាស់កូនត្រីពូជ នៅតាមភូមិ ឃុំមួយចំនួនទូទាំងប្រទេស ដោយបង្រៀនកសិករឱ្យចេះបច្ចេកទេសផលិត

កូនត្រីពូជ និងចិញ្ចឹមត្រីទទួលបានជោគជ័យ។ លទ្ធផលទទួលបានរបស់ផ្នែកវារីវប្បកម្មមានដូចខាងក្រោមៈ

- ការចិញ្ចឹមត្រី បង្គា អនុវត្តបានចំនួន ៦០.០០០ តោន (ត្រី ៥៩.៩៣៥ តោន បង្គា ៦៥ តោន) ស្មើ នឹង ១០០% នៃ ផែនការ ៦០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ១០.០០០ តោន ឬកំណើន ២០% ប្រចាំឆ្នាំ

- ការចិញ្ចឹមក្រពើអនុវត្តបាន ២៨៣.០០០ ក្បាល ស្មើ ១៤១,៥០% នៃផែនការ ២០០.០០០ ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៩៨.០០០ ក្បាល

-ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១១០.៤៤០.០០០ ក្បាល ស្មើនឹង ១៣៨% នៃផែនការ ៨០.០០០.០០០ ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៤០.៦៩០.០០០ ក្បាល

- បានបង្កើតកន្លែងភ្ញាស់ត្រីនៅទូទាំងប្រទេសបានចំនួន ២៧៣ កន្លែង ដែលក្នុងនោះមាន ២៦០ កន្លែង ជារបស់ប្រជាជនតាមរយៈការផ្តល់បច្ចេកទេសពីរដ្ឋបាលជលផល

- បានបង្កើតសហគមន៍ស្រះជម្រកត្រីបានចំនួន ៦៥៥ កន្លែង ដែលនៅក្នុងខេត្តកំពង់ស្ពឺច្រើនជាងគេចំនួន ១៥៥ កន្លែង និងខេត្តសៀមរាបចំនួន ៩០កន្លែង។ កន្លែងដែលបានរៀបចំហើយធ្វើឱ្យផលត្រីតាមវាលស្រែកើនពី ៤-៦ ដង ជាមធ្យម។

**៥.៥.១.៣- ការកែច្នៃផលនេសាទ**

- ការកែច្នៃផលនេសាទទឹកសាបអនុវត្តបាន ៤៣.០០០ តោន ស្មើ ៧១,៦៧% នៃផែនការ ៦០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៤.០០០ តោន

- ការកែច្នៃផលនេសាទសមុទ្រអនុវត្តបាន ៥.៦០០ តោន ស្មើ ៩៣,៣៣% នៃផែនការ ៦.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ១០០ តោន

- ការផលិតទឹកត្រីអនុវត្តបាន ៣៥.០០០.០០០លីត្រ ស្មើ ៧០% នៃផែនការ ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៧.០០០.០០០ លីត្រ ។

**៥.៥.១.៤- ការនាំចេញផលនេសាទ**

ការនាំចេញផលនេសាទស្រស់ និងកែច្នៃគ្រប់ប្រភេទអនុវត្តបាន ៣៥.០០០ តោន ស្មើ ១០០% នៃផែនការ ៣៥.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង ៥.០០០ តោន។

**៥.៥.១.៥- ការងារអភិវឌ្ឍន៍សហគមន៍នេសាទ**

នៅក្នុងឆ្នាំ ២០១០ រដ្ឋបាលជលផលពុំមានការរៀបចំសហគមន៍នេសាទបន្ថែមថ្មីទេ ពីព្រោះចំនួនសហគមន៍នេសាទ ដែលបានរៀបចំកន្លងមកគឺគ្របដណ្តប់នៅស្ទើរគ្រប់កន្លែងសំខាន់ៗ នៃដែននេសាទដែលសមស្របសម្រាប់ រៀបចំសហគមន៍នេសាទអស់ហើយ។ ដូច្នេះ សកម្មភាពដែលបានអនុវត្តឆ្នាំ ២០១០ នេះ គឺផ្តោត លើការពង្រឹង និងជំរុញការចុះបញ្ជីសហគមន៍នេសាទ សរុបចំនួន ២៣៦ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចហើយ ។

ចំពោះការរៀបចំបំពេញបែបបទឯកសារសហគមន៍នេសាទ ដែលបានអនុវត្តនៅក្នុង ឆ្នាំ ២០១០ នេះ នៅតែបន្ត ដើម្បីជំរុញការចុះបញ្ជីសហគមន៍នេសាទ ជាបន្តបន្ទាប់បន្ថែមទៀត ក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មការដែលផុតអាណត្តិ ការសម្របសម្រួលរៀបចំ និងកែសម្រួលលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ការសម្របសម្រួល ចុះឈ្មោះសមាជិកសហគមន៍នេសាទ ការរៀបចំធ្វើផែនទី

សហគមន៍នេសាទ និងរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ នៅក្នុងឆ្នាំ ២០១០ សហគមន៍នេសាទចំនួន ៣៩ សហគមន៍ ត្រូវបានចុះកិច្ចព្រមព្រៀងជាមួយនាយខណ្ឌរដ្ឋបាលជលផល ហើយបានបញ្ជូនមករដ្ឋបាលជលផល ដើម្បីរៀបចំផ្ញើជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងចុះបញ្ជីជាផ្លូវការ។ ដោយឡែកក្នុងឆ្នាំ ២០១០ ធនាគារក្តាមដែលបានបង្កើតឡើងសរុបចំនួន ២៨ កន្លែង ស្មើនឹង ៨៤ បែ ក្នុងនោះ ខេត្តកោះកុងមានចំនួន ៩ កន្លែង ស្មើនឹង ២៥ បែ ខេត្តព្រះសីហនុមានចំនួន ១១ កន្លែង ស្មើនឹង ៣២ បែ និងខេត្តកំពតមានចំនួន ៨ កន្លែង ស្មើនឹង ២៧ បែ ក្នុងនោះមេក្តាមដែលបានលែងចូលក្នុងបែសរុបបានចំនួន ៩.៥៦៣គីឡូក្រាម ស្មើនឹង ៧០.០០០ក្បាល ដែលបានលែងកូនក្តាមប្រមាណជិត ៩៨.០០០ លានក្បាល ចូលធម្មជាតិវិញ ។

**៥.៥.១.៦- ការងារអភិរក្សជលផល**

សកម្មភាពអភិរក្សជលផលត្រូវបានរៀបចំទាំងនៅទឹកសាប និងសមុទ្ររួមមាន ៖

- ការអភិរក្សផ្កាថ្ម ស្មៅសមុទ្រ បានចំនួន ១.៣០០ ហិកតា និងបោះបង្គោលការពារព្រៃលិចទឹក និង ព្រៃកោងកាងចំនួន ១៤០ ហិកតា
- ការអភិរក្សផ្សោតនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលធ្វើឱ្យចំនួនផ្សោតស្លាប់ថយចុះពី ១៥ ក្បាល មកនៅត្រឹម ៥ ក្បាល
- បានធ្វើការផ្សព្វផ្សាយស្តីពីសារៈសំខាន់ នៃដែនជម្រកជលផល ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ និងមុខងារនៃកន្លែងអភិរក្សចំនួន ១០ លើក ដោយមានអ្នកពាក់ព័ន្ធចូលរួមចំនួន ២.៥០០ នាក់
- លែងកូនត្រី និងកូនបង្កងបានចំនួន ៤.៦១៦.០០០ លានកូន និងត្រីមេពូជ ១៧ តោន។

**៥.៥.១.៧- ការការពារប្រភពធនធានជលផល**

បទល្មើសនេសាទ ជាប្រធានបទមួយដែលគ្រប់ថ្នាក់នៃរដ្ឋបាលជលផល បានយកចិត្តទុកដាក់យ៉ាងខ្លាំង និងធ្វើជាប្រចាំ។ ក្នុងឆ្នាំ ២០១០ នេះ មានបទល្មើស ៨.០៧៩ ករណី (ទឹកសាប ៥.៤៥៧ និងសមុទ្រ ២.៦២២ ករណី) ដែលជាលទ្ធផលមាន ៖

- ពិន័យ ចំនួន ៣០៤ ករណី
- បញ្ជូនទៅតុលាការ ចំនួន ១៨៤ ករណី
- បំផ្លាញវត្ថុតាង ចំនួន ៧.៥៩១ ករណី
- ទោសជាប់ពន្ធនាគារ ចំនួន ៨២ នាក់
- ទឹកប្រាក់ពិន័យ និងលក់វត្ថុតាងអនុវត្តបាន ៣៨៦.៥៣៨.៥០០ រៀល។

**៥.៥.១.៨- ការងារផ្សព្វផ្សាយ**

ចំពោះការផលិតឯកសារ និងការផ្សព្វផ្សាយ រដ្ឋបាលជលផលបានខិតខំជំរុញដល់រាជធានី ខេត្តទាំងអស់ ឱ្យដាក់តាំងរូបភាពប៉ាណូផ្សព្វផ្សាយនៅតាមទីប្រជុំជននានា អំពីការហាមឃាត់ប្រព្រឹត្តបទល្មើសនេសាទ និងការចូលរួមអភិរក្សប្រភពធនធានជលផល។ ក្រៅពីនេះ មានបើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដល់សមាជិកសហគមន៍ អាជ្ញាធរដែនដី និងកងកំលាំងប្រដាប់អាវុធ លើប្រធានបទ ការអភិវឌ្ឍន៍វារីវប្បកម្ម ការអភិរក្សធនធានជលផល ការកែច្នៃក្រោយការប្រមូលផល ។ល។

ដោយឡែក ការផ្សព្វផ្សាយច្បាប់អនុវត្តបានចំនួន ១៤៣ វគ្គ ដែលមានអ្នកពាក់ពន្ធ័ចូលរួមចំនួន ៨.៧៧៩ នាក់ ក្នុងនោះស្រីចំនួន ២.៤៨៤ នាក់ ។

**៨.៨.១.៩- ការងារស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ**

ការងារស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការដៃគូនានាដូចជា DFID, DANIDA, JICA, MRC, ADB, FAO, IDA, World Fish Center ជាដើម ។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប និងនាយកដ្ឋានជំនាញ ជាអង្គភាពអនុវត្តផ្ទាល់ ។

**៨.៨.១.១០- ការងាររៀបចំច្បាប់ និងលិខិតបទដ្ឋាននានា**

ក្នុងឆ្នាំ ២០១០ កន្លងមកនេះ បានរៀបចំអនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសចំនួន ៣១ ក្នុងនោះ មួយចំនួនត្រូវបានអនុម័ត និងមួយចំនួនទៀតនៅជាសេចក្តីព្រាង។

**៨.៨.១.១១- ការងារហិរញ្ញវត្ថុ**

ប្រាក់ចំណូលពីគ្រប់ខេត្ត រាជធានីប្រមូលបាន ៨.២៤៧.៥៧៧.៩២៥ រៀល ស្មើ ៩០,៥១% នៃផែនការ ៩.១១២.០០០.០០០ រៀល ក្នុងនោះមានប្រាក់ចំណូលពីៈ

| | |
|---|---|
| - ថ្លៃឈ្នួលឡូត៍នេសាទ | ៥.៩៨៣.២៣០.០០០ រៀល |
| - ប្រាក់ជានាស្តាពរ | ៧២០.៨១០.០០០ រៀល |
| - ថ្លៃឈ្នួលដែននេសាទសមុទ្រ | ៩៧៤.៣៥៣.០៨៩ រៀល |
| - ប្រាក់ពិន័យ និងលក់វត្ថុតាង | ៣៨៦.៥៣៨.៥០០ រៀល |
| - បំណុលឆ្នាំចាស់ | ៣៤.១៨០.០០០ រៀល |
| - ចំណូលផ្សេងៗៈ | |
| + រដ្ឋបាលជលផល (ឈ្នួលអាគារ ពោងចក្រ) | ៦០.៣២៦.៦៣៦ រៀល |
| + រាជធានី ខេត្ត | ៨៧.៩៣៩.៧០០ រៀល |

**៨.៨.២-ការវាយតម្លៃ និងសំណូមពរ**

**ក- ការវាយតម្លៃ**

ដើម្បីជានាដល់ការគ្រប់គ្រងធនធានជលផលមានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយនិរន្តរភាព គឺអាស្រ័យលើការចូលរួមទទួលខុសត្រូវរបស់មន្ត្រីជំនាញ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ អ្នកនេសាទវិស័យឯកជន ជាពិសេសឡូត៍នេសាទផងដែរ។ ដោយឡែក សកម្មភាពថែរក្សាការពារប្រភពធនធានជលផលត្រូវមានមធ្យោបាយ សម្ភារ ថវិកា និងប្រេងឥន្ធនៈគ្រប់គ្រាន់ ដើម្បីធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងសារៈសំខាន់នៃធនធានជលផលដល់អ្នកនេសាទក៏ដូចជាសហគមន៍នេសាទ និងប្រជាពលរដ្ឋទូទៅ ។

បញ្ហាជាគន្លឹះ គឺស្ថិតនៅត្រង់កិច្ចសហការជួយទប់ស្កាត់បទល្មើសរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងជាពិសេសបំផុតស្មារតីទទួលខុសត្រូវខ្ពស់ និងស្នេហាវិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់ ក្នុងការតស៊ូការពារធនធានជលផលឱ្យបានគង់វង្ស សម្រាប់ទុកឱ្យកូនចៅជំនាន់ក្រោយៗទៀត ។

ខ- សំណូមពរ

- ស្នើសុំជ្រើសរើសមន្ត្រីបច្ចេកទេសជលផលចំនួន ៩០ នាក់ ដើម្បីជំនួសមន្ត្រីចូលនិវត្តន៍អស់ចំនួន ១១០ នាក់ និងមួយចំនួនទៀតផ្ទេរក្របខណ្ឌចេញពីរដ្ឋបាលជលផល

- បង្កើនថវិកាសំរាប់ពង្រឹងការងារសហគមន៍នេសាទ ការអភិវឌ្ឍន៍វារីវប្បកម្ម ការសិក្សាស្រាវជ្រាវ ការអភិរក្ស ការបង្រ្កាបបទល្មើសនេសាទ និងការផ្សព្វផ្សាយជាដើម

- សំណើសុំថវិកា សម្ភារ និងបង្កើនបរិមាណប្រេងឥន្ធនៈ សម្រាប់ផ្តល់ដល់អធិការដ្ឋាននិងរដ្ឋបាលជលផល ដើម្បីប្រើប្រាស់ទប់ស្កាត់បង្រ្កាបបទល្មើសជលផលឱ្យមានប្រសិទ្ធភាព ។

**៤.៥.៣- វិធានការ**

- ជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ដោយរៀបចំបណ្តុះបណ្តាលលើមុខជំនាញបច្ចេកទេសក្នុងប្រទេស និងក្រៅប្រទេស ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទ និងកសិករចិញ្ចឹមត្រីផង

- បន្តការងារសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីកិច្ចអភិវឌ្ឍវិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល

- បន្តលែងប្រភេទពូជត្រីក្នុងស្រុកចូលតំបន់ទឹកធម្មជាតិឱ្យបានគ្រប់ឃុំ ដើម្បីបង្កើនផលស្តុកមច្ឆជាតិ បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសនៅតាមសហគមន៍ ឡូត៍នេសាទ សាលារៀន និងវត្តអារាម ។ល។

- បង្កើនការលែងកូនបង្កងក្នុងវាលទំនាបលិចទឹក ដើម្បីធ្វើឲ្យផលនេសាទបង្កងកើនឡើងវិញ

- បន្តការពារ និងអភិរក្សធនធានជលផល ដើម្បីធានាការប្រើប្រាស់ និងការអភិវឌ្ឍន៍ធនធានជលផល ប្រកបដោយនិរន្តរភាពសំដៅដល់ការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកំរិតជីវភាព រស់នៅរបស់ប្រជាជនកម្ពុជា

- ខិតខំបន្តអនុវត្តនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ** "ធ្វើឱ្យទីណាមានទឹកទីនោះ មានត្រីឡើងវិញ"

- ជំរុញការរៀបចំឯកសារ និងលិខិតពាក់ព័ន្ធ ដើម្បីឱ្យសហគមន៍នេសាទមួយចំនួនទៀត បានចុះបញ្ជី ទទួលស្គាល់ជាផ្លូវការ

- បន្តជំរុញការរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រីឱ្យបានច្រើនបន្ថែមទៀតនៅតាមឃុំ

- បង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ និងជំរុញការងាររៀបចំផែនការគ្រប់គ្រងដល់គ្រប់សហគមន៍នេសាទ

- បន្តនិងបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី

- ពង្រឹងការងារគ្រប់គ្រងតាមឋានានុក្រមគ្រប់គ្រងការងារ និងអង្គការវិន័យសណ្តាប់ធ្នាប់ការងារ

- បន្តធ្វើការអភិរក្សផ្សោតទន្លេមេគង្គនៅខេត្តក្រចេះ និងស្ទឹងត្រែង ដោយសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ អភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់

- បង្កើនប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មានក្នុងប្រព័ន្ធអ៊ីនធឺណែតឱ្យកាន់តែប្រសើរឡើងថែមទៀត

- ជំរុញឱ្យមានប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព

- បន្តការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងផ្តល់សេវាកម្មបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាកែច្នៃ និងគុណភាពនៃផល ផលិតផលជលផលឱ្យកាន់តែប្រសើរឡើង

- បន្តនិងជំរុញការអនុវត្តការងារស្រាវជ្រាវលើផ្នែកអេកូឡូស៊ី និងជីវសាស្ត្រវារីជាតិ ព្រមទាំងផ្នែកសេដ្ឋកិច្ចសង្គម និងតំលៃ ផលិតផលត្រីក្នុងទីផ្សារ

- សិក្សាស្រាវជ្រាវតាមដានស្ថានភាពការធ្វើអាជីវកម្មនេសាទសមុទ្រ និងបង្កើនសកម្មភាពត្រួតពិនិត្យ និងបង្រ្កាបបទល្មើសជលផលតាមបណ្តាខេត្ត និងការពារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

## ៥.៦-ការងារសេវាកម្ម និងការគាំទ្រ

### ៥.៦.១-លទ្ធផលការងារគោលនយោបាយផែនការ និងវិនិយោគ

លទ្ធផលសម្រេចបានឆ្នាំ ២០១០ ក្នុងក្របខ័ណ្ឌខាងលើជាគន្លឹះសំខាន់ នៃការងារដំណោះស្រាយការលំបាកដែលរាំងស្ទះនានា ទាមទារឱ្យមានការត្រួតពិនិត្យតាមដាន និងវាយតម្លៃច្បាស់លាស់ត្រឹមត្រូវតាមការអនុវត្តជាក់ស្តែង ទើបមានមូលដ្ឋានគ្រឹះ ដើម្បីធ្វើការសម្រេចចិត្តកែលម្អ ក្នុងគ្រប់គ្រងនិងដឹកនាំបានល្អ។ សភាពការណ៍ និងលទ្ធផលតាមផ្នែកនីមួយៗ នៃការងារបម្រើសេវាកម្មនេះ មានដូចខាងក្រោម៖

**ក- ការងារផែនការគោលនយោបាយ**

**ក.១-ការងារគោលនយោបាយយុទ្ធសាស្រ្ត**

-បន្តតាមដានការអនុវត្ត និងរបាយការណ៍ជឿនលឿន នៃលទ្ធផលសម្រេចបាន ចំពោះការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកំពស់ការអភិវឌ្ឍវិស័យកសិកម្ម។

-រៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣

-រៀបចំផែនកសាងផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ណែនាំតម្រង់ទិស និងជំរុញតាមដានការអនុវត្ត ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទតាមកម្មវិធី និងអនុកម្មវិធីស្របតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០០៩-២០១៣

-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធីប្រចាំឆ្នាំ (Program Budgeting) នៃក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តថវិកា (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ជំរុញការកសាងគម្រោងតាមទម្រង់ P3 និង P4 ដោយផ្អែកតាមកម្មវិធី អនុកម្មវិធីរបស់អនុវិស័យនីមួយៗ

-ពិនិត្យកែលំអ និងណែនាំតម្រង់ទិសចំពោះការលើកគំរោង P3 និង P4 ដោយកំណត់ឱ្យបានច្បាស់លាស់ នូវគោលដៅ លទ្ធផលចុងក្រោយ សូចនាករ និងធនធានដែលមាន

-ពិនិត្យនិងវាយតម្លៃលទ្ធផលសម្រេចបាន ដោយផ្អែកលើសូចនាករដែលកំណត់ និងលើកទិសដៅអនុវត្តបន្ត

-សម្រសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានាដើម្បីលើកជាសំណើតម្រង់ទិសនៅឆ្នាំខាងមុខ

**ក.២- ការងារវិនិយោគសាធារណៈ និងជំនួយអភិវឌ្ឍន៍ផ្លូវការ**

### ក.២.១-ការងារវិនិយោគសាធារណៈ

នៅក្នុងឆ្នាំ ២០១០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំស្នើសុំគម្រោងវិនិយោគសាធារណៈ ២០១១-២០១៣ សម្រាប់វិស័យកសិកម្ម និងបានដាក់ស្នើទៅក្រសួងផែនការមានដូចតទៅ៖

-គម្រោងស្នើសុំថ្មីមានចំនួន ៤០គម្រោង មានថវិកាសរុបចំនួន ៤៣០,៣៥៨,៧៥៩ ដុល្លារអាមេរិក

-គម្រោងកំពុងដំណើរការមានចំនួន១៦ គម្រោងមានថវិកាសរុបចំនួន ៤៣,៤៣៥,៧៧២ ដុល្លារអាមេរិក

ជាលទ្ធផលក្រសួងផែនការបានរៀបចំច្របាច់បញ្ចូលគ្នា នូវបណ្តាគម្រោងពីគ្រប់ក្រសួងស្ថាប័ននៃគម្រោងកម្មវិធីវិនិយោគសាធារណៈ ២០១១-២០១៣ បីឆ្នាំរំកិល។ ដោយឡែក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យឃើញ មានដូចតទៅ៖

១-គម្រោងកំពុងដំណើរការ (On-going Project) ចំនួន ០៨ គម្រោង គឺជាជំនួយបច្ចេកទេស (Technical assistance) ដែលមានទឹកប្រាក់ចំនួន **៦២,៨៦៩,៩០០** ដុល្លារអាមេរិក

២-គម្រោងផែនការសម្រាប់អនុវត្ត (Planned-Project) ចំនួន ៣៧ គម្រោង ដែលរួមមាន៖

-គម្រោងវិនិយោគជាទុន ១៧ គម្រោង (Invt. project) ដែលមានទឹកប្រាក់សរុបចំនួន **២៣៨,៧០១,០០០** ដុល្លារអាមេរិក

-គម្រោងជំនួយបច្ចេកទេស ២០ គម្រោង (Tech. asst.proj.) ដែលមានទឹកប្រាក់សរុបចំនួនចំនួន **១,៥០០,០០០** ដុល្លាអាមេរិក។

### ក.២.២-ការងារផែនការថវិកាតាមកម្មវិធី

នៅឆ្នាំ ២០១០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងថវិកាចំណាយតាមកម្មវិធីសម្រាប់ឆ្នាំ ២០១១ ហើយត្រូវបានអនុម័ត ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចំនួនសរុប ១៤.៤៩១.៤០០.០០០ រៀល ដែលជាថវិការដ្ឋ ក្នុងនោះ ៖

ក-**កម្មវិធីទី១** : មានទឹកប្រាក់ចំនួន ៧.០៣៥.៤០០.០០០ រៀល អនុវត្តដោយ ៖

១-អគ្គនាយកដ្ឋានកសិកម្មមាន ៤៦គម្រោង ប្រើប្រាស់ថវិកាចំនួន ៤.៥៩១.៩៥៥.៥០០រៀល

២-នាយកដ្ឋានផែនការ និងស្ថិតិ មាន ០៤គម្រោង ប្រើប្រាស់ថវិកាចំនួន ២៣៧.០០០.០០០រៀល

៣-នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលមាន០៥គម្រោងមានថវិកាចំនួន ១.៩៥២.០០០.០០០រៀល

៤-អគ្គនាយកដ្ឋានកៅស៊ូ មាន ០២ គម្រោង ប្រើប្រាស់ថវិកាចំនួន ១៥០.០០០.០០០ រៀល

៥-នាយកដ្ឋាននីតិកម្មកសិកម្ម មាន ០៣ គម្រោង ប្រើប្រាស់ថវិកាចំនួន ៧៧.០០០.០០០ រៀល

**ខ-កម្មវិធីទី២**: មានទឹកប្រាក់ចំនួន ៤៨៨.០០០.០០០ រៀល អនុវត្តដោយ ៖

១-នាយកដ្ឋានផែនការ និងស្ថិតិ មាន ០៥ គម្រោង ប្រើប្រាស់ថវិកា ១៦០.០០០.០០០ រៀល

២-នាយកដ្ឋានកសិ-ឧស្សាហកម្ម មាន ០៩គម្រោង ប្រើប្រាស់ថវិកា ៣២៨.០០០.០០០ រៀល

**គ-កម្មវិធីទី៣**: មានទឹកប្រាក់ចំនួន ៥៤៩.០០០.០០០ រៀល អនុវត្តដោយ ៖

១-នាយកដ្ឋានផែនការ និងស្ថិតិ មាន ០២ គម្រោង ប្រើប្រាស់ថវិកា ៨៩.០០០.០០០ រៀល

២-អគ្គនាយកដ្ឋានកៅស៊ូ មាន ០៣ គម្រោង ប្រើប្រាស់ថវិកា ៧៣.០០០.០០០ រៀល

៣-នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មាន ០១គម្រោងប្រើប្រាស់ថវិកា ៧០.០០០.០០០រៀល

៤-នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មាន ០៣គម្រោងមានថវិកា ៥៩.០០០.០០០រៀល

៥-អគ្គនាយកដ្ឋានកសិកម្ម មាន ០១ គម្រោង ប្រើប្រាស់ថវិកាចំនួន ៤០.០០០.០០០ រៀល

៦-នាយកដ្ឋានកិច្ចការរដ្ឋបាល មាន ០១ គម្រោង ប្រើប្រាស់ថវិកាចំនួន ៥០.០០០.០០០ រៀល

៧-នាយកដ្ឋាននីតិកម្មកសិកម្ម មាន ០១ គម្រោង ប្រើប្រាស់ថវិកាចំនួន ៥០.០០០.០០០ រៀល

៨-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មាន ០៤ គម្រោង ប្រើប្រាស់ថវិកា ១១៨.០០០.០០០រៀល

ឃ-កម្មវិធីទី៤ : មានទឹកប្រាក់ចំនួន ១.៩៧២.០០០.០០០ រៀល អនុវត្តដោយ ៖

-រដ្ឋបាលជលផល ចំនួន ២៣ គម្រោង ប្រើប្រាស់ថវិកា ១.៩៧២.០០០.០០០ រៀល

ង-កម្មវិធីទី៥ : មានទឹកប្រាក់ចំនួន ៤.៤៤៧.០០០.០០០ រៀល អនុវត្តដោយ ៖

-រដ្ឋបាលព្រៃឈើ ចំនួន ៣២ គម្រោង ប្រើប្រាស់ថវិកា ៤.៤៤៧.០០០.០០០ រៀល

**ក-៣-ការងារវិនិយោគឯកជន**

គិតត្រឹមដើមខែ កុម្ភៈ ឆ្នាំ ២០១១ នេះ ស្ថិតិក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យារួច ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានចំនួន ៩៦ ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ១,០១២,៩០២ ហិកតា ស្ថិតនៅក្នុងខេត្តចំនួន ១៧។

-គិតត្រឹមរយៈពេលដូចគ្នានេះ ស្ថិតិក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលបានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដែលមាន ផ្ទៃដីតូចជាង ១០០០ ហិកតា និង បានចុះ កិច្ចសន្យារួច ជាមួយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត មានចំនួនសរុប ៣៩ ក្រុមហ៊ុន ស្ថិតនៅក្នុងខេត្តចំនួន ០៨ លើផ្ទៃដីសរុបចំនួន ៣១,៥៩៣ ហិកតា

-គិតត្រឹមដើមខែ កុម្ភៈ ឆ្នាំ ២០១១ នេះ ស្ថិតិក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលបានលុបគោលការណ៍ និងកិច្ចសន្យាមានចំនួន ៤៨ក្រុមហ៊ុន លើផ្ទៃដីចំនួន ៤៥២.៤៦១ហិកតា

-ក្រុមហ៊ុនដែលមានផ្ទៃដីធំជាង ១០.០០០ ហិកតា ដែលជាកម្មវត្ថុនៃការកាត់បន្ថយមានចំនួន ០៩ ក្រុមហ៊ុន ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការចរចាកាត់បន្ថយផ្ទៃដីឱ្យនៅត្រឹម ១០.០០០ ហិកតា ដោយផ្អែកតាមអនុក្រឹត្យស្តីពី សម្បទានដីសេដ្ឋកិច្ច។ ជាលទ្ធផលក្រុមហ៊ុនចំនួន ០៤ បានឯកភាពកាត់បន្ថយផ្ទៃដីនៅត្រឹម ឬក្រោម ១០.០០០ ហិកតា ០២ ក្រុមហ៊ុន កំពុងតែអនុវត្ត និង ០៣ ក្រុមហ៊ុន បានឯកភាពកាត់បន្ថយ តែបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា បានលុបគោលការណ៍ និងកិច្ចសន្យារួចហើយ។

**ខ-ការងារសម្របសម្រួលតាមដាន និងវាយតម្លៃគំរោង**

**ខ.១- ការងារសម្របសម្រួល តាមដាន និងវាយតម្លៃថវិកាតាមកម្មវិធី**

- បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការកសាងសមត្ថភាពលើការងារតាមដាន និងវាយតម្លៃថវិកាតាមកម្មវិធីចំនួន ០២ វគ្គ ដែលមានសិក្ខាកាម មកពីបណ្តាអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងចំនួន ១៤៤ នាក់ ចូលរួម

- បានបញ្ចប់ចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ ២០១០

- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តថវិកាតាមកម្មវិធី ឆ្នាំ ២០១១ និង ឆ្នាំ ២០១២ ។

**ខ.២- ការងារសម្របសម្រួលគម្រោងជំនួយបច្ចេកទេសរបស់អង្គការ FAO**

បានសម្របសម្រួលលើការងារសិក្សាវិភាគគោលនយោបាយគាំទ្រ ដល់ការកាត់បន្ថយភាពក្រីក្រ សម្រាប់វិស័យកសិកម្ម ក្នុងនោះរួមមាន ៖

-រៀបចំសិក្ខាសាលាពិគ្រោះយោបល់បានចំនួន ០១ លើក

-បានសម្របសម្រួលបញ្ចប់របាយការណ៍ការសិក្សាវិភាគគោលនយោបាយសម្រាប់ (១) ការអភិវឌ្ឍអង្គការកសិករ (២) ការប្រើប្រាស់ដីកសិកម្ម (៣) ពង្រឹងការផ្តល់សេវាកម្មដល់ថ្នាក់ស្រុក និងបានដាក់ជូនក្រសួង ដើម្បីសុំការឯកភាពយល់ព្រម។

**ខ.៤- ការងារសម្របសម្រួលលើយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក**

ជារួមបានសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក បញ្ចប់ការរៀបចំធ្វើសុខដុមនីយកម្មលើកម្មវិធីក្រោមយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក ដែលមានផ្នែកសំខាន់ៗចំនួន ០៦ ទាក់ទងទៅនឹង ៖ (១) គោលនយោបាយ និងបទបញ្ញត្តិ (២)ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស (៣) ការស្រាវជ្រាវ និងការអប់រំ (៤) សន្តិសុខស្បៀង (៥) ការគ្រប់គ្រងធនធានទឹក និងដីកសិកម្ម (៦) ៖ កសិ-ពាណិជ្ជកម្ម និងទីផ្សារ។ ផ្នែកនៃកម្មវិធីទាំង ៦ នេះ នឹងប្រើប្រាស់ថវិកាសរុប ៥០១.២៩៥.០០០ ដុល្លារអាមេរិក សម្រាប់អនុវត្តរយៈពេល ០៤ ឆ្នាំ (២០១០-២០១៣)។ ឯកសារនេះ ត្រូវបានក្រសួងអនុម័តជាផ្លូវការ។

**គ-ការងារស្ថិតិ**

ជារួមការងារស្ថិតិកសិកម្មត្រូវបានពង្រឹង និងបន្តជំរុញខាងសមត្ថភាពធនធានមនុស្ស ជំនាញបច្ចេកទេស និងវិធីសាស្ត្រ នៃការធ្វើអង្កេតនិងជំរឿន។ ផ្នែកស្ថិតិកសិកម្មជាសេនាធិការមានយន្តការនៃការដឹកនាំគ្រប់គ្រង ប្រមូល វិភាគ ចងក្រង និងចែកចាយនៃទិន្នន័យស្ថិតិកសិកម្ម។ លទ្ធផលសង្ខេបតាមផ្នែកមានដូចខាងក្រោម ÷

**គ.១- ផ្នែកតាមដានបូកសរុប និងវិភាគទិន្នន័យ**

-ការផ្តល់ទទួលព័ត៌មាន និងរបាយការណ៍តាមបណ្តានាយកដ្ឋានក្រោមឱវាទក្រសួង និងតាមបណ្តារាជធានី ខេត្ត ដែល ពាក់ពន្ធ័ការងារប្រព័ន្ធទិន្នន័យស្ថិតិកសិកម្ម

-តាមដានការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សា និងរដូវប្រាំង ដំណាំកសិកម្មនានា និងដំណាំអចិន្ត្រៃយ៍ ដើម្បីធ្វើការវាយតម្លៃលើផ្ទៃដីដាំដុះ ទិន្នផល បរិមាណផលប្រចាំឆ្នាំ

-តាមដានពិនិត្យ វាយតម្លៃ វិភាគ និងធ្វើរបាយការណ៍ជាប្រចាំស្តីពី ល្បឿនបង្កបង្កើនផលស្រូវរដូវវស្សា និងរដូវ ប្រាំង និងដំណាំរួមផ្សំឆ្នាំ ២០១០-២០១១ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-វិភាគ និងបកស្រាយលើទិន្នន័យ ដែលបានបញ្ចូលក្នុងប្រព័ន្ធអេឡិចត្រូនិចរួច ដើម្បីផ្ទៀងផ្ទាត់លើផ្ទៃដី ទិន្នផល បរិមាណផល ដែលបានប្រមូលតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-ពិនិត្យវាយតម្លៃ និងសិក្សាវិភាគទិន្នន័យ ដែលបានបញ្ចប់ការដាំដុះដំណាំរដូវវស្សា និងប្រាំង ដើម្បីធ្វើការវាយតម្លៃប៉ាន់ស្មានតុល្យភាពស្បៀងប្រចាំឆ្នាំតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-តាមដានទឹកភ្លៀង និងគ្រោះធម្មជាតិ (រាំងស្ងួត ទឹកជំនន់ សត្វល្អិត) នៅតាមបណ្តារាជធានី ខេត្ត និងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន ដើម្បីធ្វើការកែច្នៃ និងវិភាគសកម្មភាពការងារបង្កបង្កើនផលដំណាំកសិកម្មរដូវវស្សា និងរដូវប្រាំង។

សកម្មភាព និងលទ្ធផលការងារនេះ បានផលិតចេញជារបាយការណ៍កសិកម្មរៀងរាល់សប្តាហ៍ផ្ញើជូនខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសដោយឡែកមួយចំនួនទៀត ដូចជារបាយការណ៍ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សៀវភៅស្ថិតិកសិកម្មប្រចាំឆ្នាំ ។ល។

**គ.២- ផ្នែករៀបចំវិធីសាស្ត្រអង្កេត និងជំរឿនកសិកម្ម**

-ធ្វើការជ្រើសរើសចំនួនភូមិ ចំនួនគ្រួសារនិងចំនួនសំណាកគំរូតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស ដើម្បីសម្រាប់ដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងឆ្នាំ ២០១០-២០១១

-ធ្វើទម្រង់បញ្ជីសំណួរថ្នាក់ភូមិ សម្រាប់ការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំង

-ធ្វើបញ្ជីឈ្មោះគ្រួសារដាំដំណាំស្រូវក្នុងភូមិ ដែលត្រូវធ្វើការជ្រើសរើសចៃដន្យសំណាកគំរូ បញ្ជីសំណួរអង្កេតស្ទង់ទិន្នផលដំណាំស្រូវ និងស្លាកកំណត់ត្រាដំណើរការធ្វើអង្កេតស្ទង់

-ធ្វើការជ្រើសរើសគ្រួសារចៃដន្យតាមប្រព័ន្ធអេឡិត្រូនិច ដើម្បីអនុវត្តការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និង រដូវប្រាំងប្រចាំឆ្នាំ ២០១០-២០១១ តាមបណ្តារាជធានី ខេត្ត

-ធ្វើការសាកល្បងលើសំណាកគំរូតាមប្រភេទស្រូវ (ស្រាល កណ្តាល និងធ្ងន់) នៅមូលដ្ឋានស្រុក ភូមិ និងគ្រួសារ និងដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងឆ្នាំ ២០១០-២០១១

-ដំណើរការធ្វើអង្កេតស្ទង់ទិន្នផលដំណាំអចិន្ត្រៃយ៍ឆ្នាំ ២០១០

-បង្កើត និងកែច្នៃទម្រង់សម្រាប់ធ្វើការអង្កេតក្នុងប្រព័ន្ធអេឡិត្រូនិច ដើម្បីងាយស្រួលក្នុងការបញ្ចូល និងវិភាគទិន្នន័យ

-បែងចែកទិន្នន័យមួយចំនួនទៅតាមលំដាប់បណ្តារាជធានី ខេត្ត ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធពត៌មានស្ថិតិថ្នាក់ជាតិ

-ធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំលើកទី ២៣ នៃគណៈកម្មការស្ថិតិកសិកម្មប្រចាំតំបន់ អាស៊ី-ប៉ាស៊ីហ្វិក នៅខេត្តសៀមរាប ដែលមានបណ្តាប្រទេសចូលរួមសរុបចំនួន ១៧ ប្រទេស

-សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ដើម្បីសិក្សាស្រាវជ្រាវនូវវិធីសាស្ត្រ សម្រាប់ការគិតគូរគណនាកំណើនរបស់វិស័យកសិកម្ម GDP ប្រចាំឆ្នាំ

-សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) អង្គការ FAO និងការស្វែងរកថវិកាពីដៃគូអភិវឌ្ឍ ដើម្បីដំណើរការធ្វើជំរឿនកសិកម្មនៅឆ្នាំ ២០១២។

ជារួម សមត្ថភាពនៃការធ្វើអង្កេតស្ទង់ទិន្នផលស្ថិតិកសិកម្ម ដោយមានការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល បានជំរុញឱ្យដំណើរការងារនេះ មានការរីកចម្រើនបន្ថែមនូវការអភិវឌ្ឍន៍បច្ចេកទេសថ្មីៗបានមួយកម្រិត តែទោះជាយ៉ាងណាក្តី ក៏ការធ្វើអង្កេតស្ទង់ស្ថិតិកសិកម្ម នៅមានការសេសសល់ការងារជាច្រើនទៀតដែលមិនអាច ឬមិនបានធ្វើដោយកត្តាផ្សេងៗ ដូចជាខ្វះខាតថវិកា និងធនធានមនុស្សនៅមានកំរិតនៅឡើយ។

**ឃ-ការងារទីផ្សារកសិកម្ម**

សេវាព័តមានទីផ្សារកសិកម្ម ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែល្អប្រសើរឡើង ស្របទៅតាមគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីលើកកំពស់ពិពិធភាពកសិកម្ម និងការប្រកួតប្រជែងទីផ្សារ។ ការខិតខំកន្លងមកនេះ បានជំរុញនូវលទ្ធភាពចូលដល់ទីផ្សារនៃផលិតផលកសិកម្ម និងអាចឱ្យកសិករក្រីក្រទទួលបាននូវតម្លៃសមរម្យ ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ។

**ឃ.១- ផ្នែកសេវាព័ត៏មានទីផ្សារកសិកម្ម:**

នៅក្នុងឆ្នាំ ២០១០ ក្រោមការគាំទ្រពីគម្រោង CAMIP (CIDA) បានពង្រីកទៅកាន់៣ខេត្តគឺកំពង់ធំ កំពង់ស្ពឺ និងពោធិ៍សាត់។ សេវាព័ត៌មានទីផ្សារកសិកម្មបានធ្វើសកម្មភាព ដោយផ្តោតទៅលើការផ្សព្វផ្សាយព័ត៌មានថ្លៃទីផ្សារកសិកម្មតាមរយៈ ១-វិទ្យុ និងទូរទស្សន៍ ២-ព្រឹត្តិបត្រ័តម្លៃប្រចាំខែ និងឆ្នាំ ៣-គេហទំព័រ

(www.agriculturalmarketinformation.org.kh) និងប្រព័ន្ធផ្ញើសារជាអក្សរ SMS។ តម្លៃកសិផលត្រូវបានធ្វើការផ្សព្វផ្សាយតាមវិទ្យុជាតិ AM 918 និងវិទ្យុនៅខេត្តគោលដៅពីម៉ោង ៥:៥៥-៦:00 ល្ងាច និងទូរទស្សន៍អាស៊ីអាគ្នេយ៍។ គម្រោងក៏បានរៀបចំផលិតជាឯកសារអប់រំស្តីពី សាលាទីផ្សារកសិករចំនួន ១៦ ហើយបានសហការជាមួយស្ថានីយ៍ទូរទស្សន៍ជាច្រើន ដើម្បីធ្វើការចាក់ផ្សាយ។

**ឃ.២- ផ្នែកអភិវឌ្ឍន៍ទីផ្សារ:**

ផ្នែកនេះ បានផ្តោតទៅលើសកម្មភាពវគ្គបណ្តុះបណ្តាលគ្រូបង្គោលសាលាទីផ្សារកសិករ ការប្រើប្រាស់ការផ្ញើសារជាអក្សរ SMS ការបញ្ច្រាបយេនឌ័រ និងការធ្វើទស្សនកិច្ចសិក្សាជាដើម ដូចជា៖

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសាលាទីផ្សារកសិករបានចំនួន ១ វគ្គ
- បើកវគ្គសាលាទីផ្សារកសិករ បានចំនួន ៧៥ វគ្គ កសិករចូលរួមចំនួន ១៨៨៨នាក់ (ស្ត្រី១០៧៩នាក់)
- វគ្គបណ្តុះបណ្តាលធ្វើចំណាត់ថ្នាក់បន្លែបានចំនួន ៧ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣១៩នាក់
- វគ្គបណ្តុះបណ្តាលអំពី របៀបប្រើប្រាស់ផ្ញើសារជាអក្សរបាន ៧ លើក អាជីវករចូលរួម ១៨៨នាក់ (ស្ត្រី១៣៥នាក់)
- វគ្គបញ្ច្រាបយេនឌ័របានចំនួន ១២វគ្គ កសិករចូលរួម ៣៣០ នាក់ (ស្ត្រីចំនួន ២១៩នាក់)
- សិក្ខាសាលាពង្រឹងសមត្ថភាពមន្ត្រីទីផ្សារកសិកម្មចំនួន៣លើក
- បញ្ជូនគ្រូបង្គោលនិងអាជីវករទៅធ្វើទស្សនៈកិច្ចសិក្សា នៅប្រទេសវៀតណាមចំនួន ២លើក មានអ្នកចូលរួមចំនួន៦០នាក់។

ជារួម វគ្គបណ្តុះបណ្តាលសាលាទីផ្សារកសិករ និងសេវាព័ត៌មានតម្លៃកសិផលតាមរយៈការផ្ញើសារជាអក្សរ ជាពិសេសចំនួនសារជាអក្សរដែលអាជីវករ និងអ្នកប្រើប្រាស់ព័ត៌មានតម្លៃ បានផ្ញើចូលមកប្រព័ន្ធមានការកើនឡើងជាលំដាប់គឺពី ១៤០-២៥០ SMS/ថ្ងៃ។ ជាលទ្ធផលនៃសេវាព័ត៌មានទីផ្សារកសិកម្មគឺ បានជួយឱ្យអ្នកផលិតបង្កើនទូវតម្លៃបន្ថែម និងប្រាក់ចំណូល ជាពិសេសកសិករ និងអាជីវករ ទទួលបានផលប្រយោជន៍យ៉ាងច្រើន ពីការប្រើប្រាស់សេវាព័ត៌មានទីផ្សារកសិកម្មនេះ។ កសិករមានសមត្ថភាពធ្វើផែនការ និងសម្រេចចិត្តថាតើនឹងផលិតអ្វី ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារ តើលក់ផលិតផលទៅឱ្យអ្នកណា តើលក់នៅទីផ្សារណា ដើម្បីទទួលបានតម្លៃខ្ពស់ ជាពិសេសមានលទ្ធភាពក្នុងការតថ្លៃជាមួយនឹងឈ្មួញកណ្តាល។

**ង-ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

- ចូលរួមសិក្ខាសាលាស្តីពី ការចាប់ផ្តើមរៀបចំផែនការសកម្មភាពជាតិ សម្រាប់កែលម្អលក្ខខណ្ឌរស់នៅរបស់សហគមន៍ និងប្រព័ន្ធបរិស្ថានដែលកំពុងប្រឈមនឹងភាពសឹករិចរិល និងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា រៀបចំដោយគម្រោងពង្រឹងសមត្ថភាព និងបញ្ច្រាបការគ្រប់គ្រងដីធ្លីដោយចីរភាពនៅកម្ពុជា នៅខេត្តព្រះសីហនុ។
- ចូលរួមសិក្សាស្តីពី តម្រូវការព័ត៌មាន ឥរិយាបទ និងការអនុវត្ត ការគ្រប់គ្រងដីធ្លីដោយចីរភាពនៅកម្ពុជា រៀបចំដោយគម្រោងពង្រឹងសមត្ថភាព និងបញ្ច្រាបការគ្រប់គ្រងដីធ្លីដោយចីរភាព នៅកម្ពុជា នៅខេត្ត តាកែវ ព្រះវិហារ និងកំពង់ស្ពឺ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានរៀបចំដោយសកលវិទ្យាល័យភ្នំពេញ សហការនិងឧបត្ថម្ភដោយ វិទ្យាស្ថានបរិស្ថានប្រទេសកូរ៉េ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រៀបចំឡើងដោយនាយកដ្ឋានអង្កេត ពិនិត្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សហការនិងឧបត្ថម្ភដោយអង្គការ American Friends Service Committee (AFSC) និងអង្គការ Assessment Center for Environment & Engineering(ACEE) នៃសាធារណរដ្ឋ ប្រជាមានិតចិន។

**៨.៦.២-វាយតម្លៃ និងសំណើ**

ជារួម ការងារផែនការ និងស្ថិតិ គឺជាសេនាធិការឱ្យក្រសួងក្នុងផ្នែកការងារគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសេដ្ឋកិច្ច និងវិនិយោគ។ ការងារវិភាគគោលនយោបាយយុទ្ធសាស្ត្រ និងការកសាងកម្មវិធី និងគម្រោងការងារនានា ជាបញ្ហាគន្លឹះ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យ។ កន្លងមកក្នុងឆ្នាំ ២០១០ ការងារក្នុងផ្នែកនេះ សម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំកន្លងមក និងតាមផែនការដែលបានគ្រោងទុក។ ក៏ប៉ុន្តែជាមួយនឹងការខិតខំរបស់យើង ឱ្យការងារកាន់តែមានលក្ខណៈវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច មានភាពជឿនលឿននោះ យើងក៏ជួបការប្រឈមនិងបញ្ហាខ្វះៗ ដូចជា កង្វះធនធានមនុស្សដែលមានសមត្ថភាពបរិបូរណ៍ និងមធ្យោបាយសម្ភារធ្វើការ។ល។ ដែលទាំងនេះទាមទារឱ្យមានការជួយគាំទ្រពីថ្នាក់ដឹកនាំក្រសួង ការចូលរួមពីអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងារនេះ កាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត។

**៨.៦.៣-វិធានការ**

-ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៩-២០១៣ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រដ៏ទៃទៀត របស់រាជរដ្ឋាភិបាល ដូចជា យុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងយុទ្ធសាស្ត្រកសិកម្ម និងទឹក

-ជំរុញការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការគាំទ្រការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-សិក្សាលទ្ធភាពនៃការរៀបចំកសាងផែនការមេ សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មរយៈពេល និងវែង ២០១២-២០៣៥

-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធី (Program Budgeting) នៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ទុនវិនិយោគរបស់រដ្ឋ ឱ្យចំទិសដៅអាទិភាព និងមានប្រសិទ្ធភាពខ្ពស់

-បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ជួយដោះស្រាយនូវទំនាស់ផ្សេងៗ ដល់ក្រុមហ៊ុនវិនិយោគឯកជន ក្នុងវិស័យកសិកម្ម និងបន្តស្រាវជ្រាវដោះស្រាយបញ្ហាដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ និងដីសម្បទាន ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ។ ជាពិសេសអនុវត្តកិច្ចសន្យា និងការបង់ប្រាក់ កក់ជូនរាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនដែលបាន ចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ

-បន្តបច្ចុប្បន្នភាពលើការរៀបចំ ចងក្រងប្រមូលពត័មាន និងទិន្នន័យគម្រោង ដែលផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងត្រៀមលក្ខណៈចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

-ជំរុញការរៀបចំ និងបន្តយន្តការតាមដានរល្បឿនការងារបង្កបង្កើនផលឆ្នាំ ២០១១ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស និងពង្រឹងសមត្ថភាពត្រួតពិនិត្យ លើការងារស្ថិតិកសិកម្មពីថ្នាក់កណ្តាលដល់មូលដ្ឋាន ដើម្បីសម្រួលដល់ការប្រមូល បញ្ចូល វិភាគ និងចងក្រងទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ

-ជំរុញយន្តការការធ្វើអង្កេតស្ទង់ទិន្នផលដំណាំស្រូវ អង្កេតដំណាំផ្សេងៗ ដំណាំអចិន្ត្រៃយ៍ និងការប្រមូលទិន្នន័យប្រព័ន្ធពត៌មាន ស្ថិតិកសិកម្ម ដើម្បីឱ្យប្រព័ន្ធស្ថិតិកសិកម្មមានតម្លាភាព និងនិរន្តរភាព

-បង្កើនសមត្ថភាពបច្ចេកទេស ក្នុងការប្រមូល កែច្នៃ និងផ្ទៀងផ្ទាត់ទិន្នន័យ ស្ថិតិឱ្យមានតម្លាភាព និងប្រសិទ្ធិភាពល្អប្រសើរ សម្រាប់អ្នកប្រើប្រាស់ស្រាវជ្រាវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ

-ខិតខំស្វះស្វែងរកថវិកាពីដៃគូអភិវឌ្ឍនានា និងបន្តសហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ និងអង្គការ FAO ដើម្បីអនុវត្តគម្រោងធ្វើអង្កេត និងជំរឿនកសិកម្មនាឆ្នាំខាងមុខ

-បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មរាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្ម ឱ្យកាន់តែល្អប្រសើរឡើង ដើម្បីចងក្រងព្រឹត្តិប័ត្រប្រចាំខែ ប្រចាំឆ្នាំ ជាមូលដ្ឋានសម្រាប់ផ្សព្វផ្សាយបន្តដល់ប្រជាកសិករនៅតាមជនបទ

-ពង្រឹងគុណភាពការប្រមូលព័ត៌មានតម្លៃកសិផលនិងធ្វើឲ្យមានភាពជឿជាក់ និងជានាឱ្យបានជាព័ត៌មានទីផ្សារកសិផលនឹងទៅដល់កសិរនៅថ្នាក់ភូមិឃុំ

-បន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ និងបោះពុម្ពខិត្តប័ណ្ណ និងពិនិត្យតាមដានការប្រមូលព័ត៌មានថ្លៃទីផ្សារនៅតាមរាជធានី ខេត្ត និងសិក្សាបញ្ហាទីផ្សារ ដែលធ្វើឱ្យមានឥទ្ធិពលដល់ការប្រែប្រួលតម្លៃរបស់ផលិតផល។

## ៥.៦.២-ការងារសហប្រតិបត្តិការអន្តរជាតិ

### ៥.៦.២.១-លទ្ធផល

ក- កិច្ចការអាស៊ានកសិកម្ម

បានសម្របសម្រួលស្នើសុំគោលការណ៍ និងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំចំនួន ៣ គឺ ៖

- កិច្ចប្រជុំលើកទី ៩ នៃក្រុមការងារស្តីពី ការផ្តួចផ្តើមរៀបចំវិញ្ញាបនប័ត្រព្រៃឈើអាស៊ាន
- កិច្ចប្រជុំលើកទី ៧ នៃក្រុមការងារអាស៊ានស្តីពី អាហារ Halal និង
- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី ៣២ កិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន បូក ៣ លើកទី ១០ កិច្ចប្រជុំអាស៊ាន-SPS លើកទី ២ និងកិច្ចប្រជុំអមផ្សេងទៀត ដែលបានសម្រេចលទ្ធផលសំខាន់ៗ មួយចំនួនដូចជា ៖

១. គោលការណ៍ណែនាំ និងកំណត់ស្តង់ដា និងគុណភាពផលិតកម្មកសិកម្ម សម្រាប់អនុវត្តនូវភូតគាមអនាម័យ កម្រិតជាតិពុលអតិបរមា ស្តង់ដារផ្លែឈើ និងការគ្រប់គ្រងព្រៃឈើ។

២. ស្នើឲ្យមានកិច្ចសហប្រតិបត្តិការ និងការចូលរួមពីដៃគូអភិវឌ្ឍ ព្រមទាំងអង្គការអន្តរជាតិនានា ក្នុងការ អនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងក្នុងតំបន់អាស៊ាន។

៣. ផ្តល់អាទិភាពជាសំខាន់ដល់ការងារស្រាវជ្រាវ និងផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការប្រែប្រួលជាតុអាកាស ដែលជាកត្តាសំខាន់សម្រាប់ការរក្សាសន្តិសុខស្បៀង និងផលិតភាពកសិកម្ម។

៤. រៀបចំឯកសារយុទ្ធសាស្ត្រសហប្រតិបត្តិការអាស៊ានបូក ៣ ស្តីពីសន្តិសុខស្បៀង កសិកម្ម និងព្រៃឈើ សម្រាប់រយៈពេលវែង។

៥. ផែនការសកម្មភាព ២០១១-២០១២ និងបង្កើតក្រុមការងារចំនួន ៣ គឺ ក្រុមការងារភូតគាមអនាម័យ អនាម័យសត្វ និងសុវត្ថិភាពអាហារ ដែលជាយន្តការ និងឧបករណ៍ សម្រាប់ជំរុញកិច្ចសហប្រតិបត្តិការលើការងារ អនាម័យ និងភូតគាមអនាម័យ។

ខ. កិច្ចសហប្រតិបត្តិការទ្វេភាគី-ពហុភាគី

- ថ្នាក់ដឹកនាំក្រសួងបានជួបពិភាក្សា និងពិភាក្សាជាមួយប្រតិភូមកពី ប្រទេសចិន ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន ដាណឺម៉ាក អូស្ត្រាលី សាធារណរដ្ឋកូរ៉េ បង់ក្លាដេស ជប៉ុន និងឥណ្ឌា

- បានសម្របសម្រួលរៀបចំ និងទទួលការអនុម័តគម្រោងស្នើសុំជំនួយអភិវឌ្ឍផ្លូវការពីរដ្ឋាភិបាលជប៉ុនចំនួន ២ គម្រោង គឺ Hatchery Training for Marine Seed Production និង Capacity Building in Forestry Sector (REDD Program)

- បានចុះហត្ថលេខាលើឯកសារអនុស្សរណៈនៃការយោគយល់គ្នាចំនួន ៤ ពិធីសារចំនួន ២ កំណត់ហេតុព្រមព្រៀងគម្រោងចំនួន ២ និងលិខិតប្តូរសារចំនួន ១ ជាមួយដៃគូអភិវឌ្ឍ។ (តារាងខាងក្រោម)

តារាងអនុស្សរណសហប្រតិបត្តិការជាមួយប្រទេសដៃគូអភិវឌ្ឍ

| ល.រ | ប្រភេទនៃកិច្ចសហប្រតិបត្តិការ | ជាមួយប្រទេស | ថវិកា | កាលបរិច្ឆេទចុះហត្ថលេខា |
|---|---|---|---|---|
| ១. អនុស្សរណៈនៃការយោគយល់គ្នា | | | | |
| 1 | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា | អូស្ត្រាលី | A$ ៤៣.៦៦២.០០០ | ០៥/០២/២០១០ |
| 2 | ការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម | ប្រទេសចិន [1] | | ១៨/០៣/២០១០ |
| 3 | គម្រោងសហការកសិកម្មអន្តរជាតិ (KOPIA) | ប្រទេសកូរ៉េ [2] | | ១២/០៤/២០១០ |
| 4 | កិច្ចសហប្រតិបត្តិការអនាម័យ និងភូតគាមអនាម័យលើផ្នែកត្រួតពិនិត្យអនាម័យសត្វ និងភូតគាមអនាម័យ | ប្រទេសចិន [3] | | ២២/១០/២០១០ |
| ២. ពិធីសារ | | | | |
| 1 | ការនាំអង្ករកម្ពុជាទៅកាន់ប្រទេសចិន | ប្រទេសចិន [3] | | ២២/១០/២០១០ |
| 2 | ការនាំផលិតផលដំឡូងមីកម្ពុជាទៅកាន់ប្រទេសចិន | ប្រទេសចិន [3] | | ១៣/១២/២០១០ |
| ៣. កំណត់ហេតុព្រមព្រៀងអនុវត្តគម្រោង | | | | |
| 1 | Japanese Technical Cooperation for Agricultural Productivity Promotion Project in West Tonle Sap | ប្រទេសជប៉ុន [4] | | ១៨/០៨/២០១០ |
| 2 | Japanese Technical Cooperation under the JICA Partnership Program for Project on Development of Agro-processing Technology through Rehabilitation of Traditional Industry in Cambodia | ប្រទេសជប៉ុន [4] | Yen ៤៥.៤៦៥.០០០ | ២៩/០៩/២០១០ |
| ៤. លិខិតប្តូរសារ | | | | |
| 1 | ការផ្តល់ឡដីវឧស្ម័នចំនួន ៣០០ | ប្រទេសចិន [5] | RMB ២.៤០០.០០០ | ១៣/១២/២០១០ |

(1) ក្រសួងកសិកម្ម នៃសាធារណរដ្ឋប្រជាមានិតចិន
(2) រដ្ឋបាលអភិវឌ្ឍន៍ជនបទ នៃសាធារណរដ្ឋកូរ៉េ (RDA)
(3) អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក នៃសាធារណរដ្ឋប្រជាមានិតចិន (AQSIQ)
(4) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA)

គ. កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ

- បានបំពេញបែបបទ ទាក់ទងនឹងការស្នើសុំចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង របស់អង្គការក្រៅរដ្ឋាភិបាល អន្តរជាតិចំនួន ១៤ ដែលមានគម្រោងសរុបចំនួន ២១

- បានរៀបចំទិវាពិភពលោក ប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថាន ក្រោមកិច្ចសហការជាមួយគម្រោងពង្រឹងសមត្ថភាព និងបញ្ញាបការគ្រប់គ្រងដីធ្លីដោយចីរភាព និងទិវាស្បៀងអាហារពិភពលោកលើកទី ៣០ ដោយសហការជាមួយអង្គការ FAO និង WFP ក្រោមប្រធានបទ "United Against Hunger" ដែលជាសារមួយ

សម្រាប់អ្នក ចូលរួម ក្នុងការរួមគ្នាថែរក្សាធនធានដី និងធានាការផលិតស្បៀងឲ្យមាននិរន្តរភាព។

តារាងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលបានចុះកិច្ចព្រមព្រៀងគម្រោង

| ល.រ | ឈ្មោះ អង្គការ | ចំនួន គម្រោង | ទីតាំងអនុវត្តគម្រោង | ថវិកាគម្រោង | | | ថេរវេលា គម្រោង |
|---|---|---|---|---|---|---|---|
| | | | | $ US | $ Au | € | |
| ១ | CI | ១ | ពោធិ៍សាត់ កំពង់ស្ពឺ និងកោះកុង | ២.៧០០.០០០ | | | ៣ ឆ្នាំ |
| ២ | WCS | ៥ | ព្រះសីហនុ កោះកុង បាត់ដំបង សៀមរាប កំពង់ធំ ព្រះវិហារ និង មណ្ឌលគិរី | ៤.៩២៩.៦២៦ | | | ៣ ឆ្នាំ |
| ៣ | FAO | ២ | ទូទាំងប្រទេស | ១.២៥១.៨៧២ | | | ៣ ឆ្នាំ |
| ៤ | SNV | ១ | កំពង់ចាម កណ្ដាល ស្វាយរៀង តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពត ពោធិ៍សាត់ បាត់ដំបង សៀមរាប កំពង់ធំ និងព្រៃវែង | ៥.៨១៣.០៨០ | | | ៣ ឆ្នាំ |
| ៥ | WA | ១ | កោះកុង និងកំពង់ស្ពឺ | ៦.១០២.៤៨១ | | | ៣ ឆ្នាំ |
| ៦ | IVY | ១ | ស្វាយរៀង | ៤៥០.០០០ | | | ២ ឆ្នាំ |
| ៧ | InSTEDD | ១ | ទូទាំងប្រទេស | ៣៩២.៥៩៤ | | | ៣ ឆ្នាំ |
| ៨ | ACIAR | ៣ | ទូទាំងប្រទេស | | ១.២២៦.២២៥ | | ៣ ឆ្នាំ |
| ៩ | FIDR | ១ | កំពង់ឆ្នាំង | ៥១.២៣០ | | | ១ ឆ្នាំ |
| ១០ | JVC | ១ | សៀមរាប | ៤៥៨.០០០ | | | ៣ ឆ្នាំ |
| ១១ | GAA | ១ | រតនគិរី | | | ៥០៧.០០០ | ២ ឆ្នាំ |
| ១២ | GRET | ១ | បាត់ដំបង សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ និងកំពត | | | ២.១៧៦.០៩៣ | ១,៥ ឆ្នាំ |
| ១៣ | SAJ | ១ | កំពង់ឆ្នាំង | ៦៨៣.៨២០ | | | ៣ ឆ្នាំ |
| ១៤ | AFSC | ១ | ព្រះសីហនុ និងកោះកុង | ៨២៤.៧២០ | | | ៣ ឆ្នាំ |
| សរុប | | ២១ | | ២៣.៦៥៧.៤២៣ | ១.២២៦.២២៥ | ២.៦៨៣.០៩៣ | |

- បានចុះពិនិត្យការអនុវត្តគម្រោងរបស់អង្គការចំនួន ៤ រួមមាន អង្គការ NH, WA, FIDR, GRET និង AFSC នៅក្នុងខេត្តកំពង់ឆ្នាំង កោះកុង កំពង់ស្ពឺ បាត់ដំបង កំពង់ចាម កំពង់ធំ កំពត ព្រៃវែង សៀមរាប ស្វាយរៀង និង ព្រះសីហនុ ។

**ឃ. កិច្ចការកសិ-ពាណិជ្ជកម្មពិភពលោក**

- បានចូលរួមប្រជុំរៀបចំច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ជាមួយគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និង ក្រសួងពាក់ព័ន្ធ និងបានសម្របសម្រួលប្រមូលព័ត៌មានស្ដីពី អាជ្ញាប័ណ្ណនាំចូលក្នុងស្ថាប័នសាមី ដើម្បីជូន ដំណឹងទៅអង្គការ ពាណិជ្ជកម្មពិភពលោកតាមរយៈក្រសួងពាណិជ្ជកម្ម

- បានរៀបចំបញ្ជូនជម្រើសស្តង់ដារកូដិច (Codex) ដែលពាក់ព័ន្ធនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទៅក្រសួងពាណិជ្ជកម្ម។

**៥.៦.២.២-វាយតម្លៃ និងសំណើ**

ក្នុងឆ្នាំ ២០១០ នេះ ការងារសហប្រតិបត្តិការអន្តរជាតិ សម្រេចបាននូវស្នាដៃ និងលទ្ធផលល្អគួរ កត់សម្គាល់។ ជាក់ស្តែងមានអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាក្នុងក្របខណ្ឌទ្វេភាគី-ពហុភាគី និង អាស៊ាន បានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង អនុស្សរណៈនៃការយោគយល់គ្នា ពិធីសារ។ល។ ជា មួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសហការអនុវត្ត និងពង្រឹងធនធានមនុស្ស ក្នុងន័យ រួមចំណែកអភិវឌ្ឍវិស័យកសិកម្មកម្ពុជា។

៥.៦.២.៣-វិធានការ

នៅក្នុងឆ្នាំ ២០១១ ក្រសួងមានផែនការរៀបចំកិច្ចប្រជុំចំនួន ៤ ដូចខាងក្រោម ៖

១. កិច្ចប្រជុំលើកទី ៦ នៃក្រុមការងារសហប្រតិបត្តិការកសិកម្ម ក្រោមក្របខ័ណ្ឌ ACMECS

២. កិច្ចប្រជុំលើកទី ១៩ នៃក្រុមការងារជលផលអាស៊ាន

៣. កិច្ចប្រជុំលើកទី ១៨ នៃក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយកសិកម្មអាស៊ាន និង

៤. កិច្ចប្រជុំពិសេសលើកទី ៣២ នៃឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន និងកិច្ចប្រជុំពិសេសលើកទី ១០ នៃឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានបូក ៣។

ជាងនេះទៅទៀត ក្រសួងនឹងបន្តយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួន តាមរយៈការសិក្សាស្វែងយល់ និងពង្រឹងសមត្ថភាព ដើម្បីបង្កើនប្រសិទ្ធភាព នៃការសម្របសម្រួល និងទំនាក់ទំនងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ ព្រមទាំងប្រទេសនានាសម្រាប់ជំរុញការអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលបំណងចូលរួមចំណែកអនុវត្ត គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ របស់រាជរដ្ឋាភិបាល។

## ៥.៦.៣-ការងារកិច្ចការរដ្ឋបាល

៥.៦.៣.១-លទ្ធផល

ឆ្នាំ ២០១០ នេះ ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញតួនាទីយ៉ាងសកម្មលើការងារ រៀបចំ និងចរាចរឯកសារ ផ្សព្វផ្សាយច្បាប់ គោលការណ៍ផ្សេងៗ។

ក- ផ្នែករៀបចំ និងចរាចរឯកសារ

ក-១-ផ្នែកទទួលលិខិតចូល

-ទទួលពីស្ថាប័ននានាសរុបចំនួន ៤.៣៥២ ច្បាប់

-ទទួលពីនាយកដ្ឋានក្រោមឱវាទសរុបចំនួន ៤.៣១៩

-ទទួលពីគ្រប់រាជធានី-ខេត្តសរុបចំនួន ១.៣០៩ ច្បាប់

ក-២-ផ្នែកទទួលលិខិតចេញ

-បញ្ជូនទៅក្រសួងស្ថាប័នផ្សេងៗនាយកដ្ឋានរាជធានី-ខេត្ត បានចំនួន ៨.៣៣១ ច្បាប់ មាន ៨៥៨ ច្បាប់

-សេចក្តីសម្រេច និងប្រកាសសរុបចំនួន ៦៨៦ ច្បាប់

-ថតចម្លងបែងចែកចេញទៅអង្គភាពក្រោមឱវាទសរុបចំនួន ៣៦២ ច្បាប់

-បញ្ជូនលិខិតបទដ្ឋានចុះក្នុងរាជកិច្ចសរុបចំនួន ២០ ច្បាប់ ។

ខ-ការងារសន្តិសុខ អនុវត្តបានល្អប្រសើរដូចជា ៖

-ភ្ញៀវមកពីនាយកដ្ឋានក្រោមឱវាទក្រសួងចំនួន ៥.៧៩២ នាក់

-ភ្ញៀវមកពីបណ្តាអន្តរក្រសួងចំនួន ៧៧៧ នាក់

-ភ្ញៀវមកពីបណ្តាខេត្ត-រាជធានី ចំនួន ១.១៤៩ នាក់

-ភ្ញៀវជាអតិថិជនចំនួន ៤.១៤៧ នាក់

-ភ្ញៀវអន្តរជាតិចំនួន ៨៩៤៣ នាក់

៥.៦.៣.២-វាយតម្លៃ និងសំណើ

ជារួម ការងារកិច្ចការរដ្ឋបាល បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។

៥.៦.៣.៣-វិធានការ

- បណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែករដ្ឋបាល ផ្នែកជំនាញ និងភាសាបរទេស

-បន្តពង្រឹងប្រសិទ្ធិភាពការងារគ្រប់គ្រងរដ្ឋបាល និងពង្រឹងការងារគ្រប់គ្រង និងបែងចែកបញ្ជូនលិខិត ស្នាមតាមបែបបទរដ្ឋបាលឱ្យបានទាន់ពេលវេលា

## ៥.៦.៤-ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ ២០១០ នេះ ការងារនីតិកម្មកសិកម្ម បានផ្តោតលើសកម្មភាពដូចខាងក្រោម៖

-ពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្ម តាមរយៈការត្រួតពិនិត្យនៅពេលនាំចូលជាក់ស្តែងរបស់ ក្រុមហ៊ុននាំចូលចែកចាយ និងតាមដាន ត្រួតពិនិត្យជាប្រចាំ ដល់សកម្មភាពធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារកសិកម្មនៅ គ្រប់មូលដ្ឋានរាជធានី ខេត្ត ដើម្បីតម្រង់ទិសឱ្យអាជីវករ ឱ្យអនុវត្តតាមនីតិវិធីនៃច្បាប់ និងអនុវត្តនូវវិធានបមាណី ចំពោះប្រភេទសម្ភារកសិកម្ម ដែលធ្វើការផ្គត់ផ្គង់លើទីផ្សារ ត្រូវមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរជាចាំបាច់លើសំបក វេចខ្ចប់នៃប្រភេទសម្ភារកសិកម្មនីមួយៗ។ ការអនុវត្តច្បាប់ត្រូវបានអនុវត្ត ទន្ទឹមនិងការដាក់ទណ្ឌកម្មលើសកម្មភាពល្មើស រួមមានការចេញលិខិតព្រមានដល់អាជីវករ និងចងក្រងសំណុំរឿងទៅតុលាការ ព្រមទាំងការឃាត់ទុកវត្ថុតាង និងឃាត់ខ្លួនជនល្មើស។

-ពង្រឹងយន្តការគ្រប់គ្រងសម្ភារកសិកម្មនីតិកម្មកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្តច្បាប់ ការលើកកំពស់ប្រសិទ្ធភាពការគ្រប់គ្រង និងអនុវត្តកម្មវិធីផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានរាជធានីខេត្ត នូវការយល់ដឹងផ្នែកបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធព្រមទាំង តម្រូវការនូវនីតិវិធីនៃច្បាប់ក្នុងការធ្វើអាជីវកម្ម សម្ភារកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥.៦.៤.១-លទ្ធផល

ក-ការងារអាជីវកម្មសម្ភារកសិកម្ម

ក.១-ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្ម៖ មានចំនួន ៥៣ ក្រុមហ៊ុន។

ក.២-ការផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្ម ៖ មានចំនួន ៣៥ ក្រុមហ៊ុន សរុបចំនួន ២៣៨ មុខ និងប្រមូលប្រាក់ចំណូលបានមក ពីការបង់កំរៃសេវាចុះបញ្ជិកាសម្ភារកសិកម្មបង់ចូលថវិការដ្ឋបានចំនួន ៦៥.៧០០.០០០(ហុកសិបប្រាំលាន ប្រាំពីររយពាន់រៀល)។

ក.៣-ការផ្តល់លិខិតអញ្ញាតឱ្យនាំចូលសម្ភារកសិកម្ម ៖ មានចំនួន ៦២ ក្រុមហ៊ុន និង ៨៩ ករណីនាំចូលដូចខាងក្រោម៖

-ជីកសិកម្ម ចំនួន ២២៥.៨៥២,១២ តោន និង ១០០ កាតុង

-ថ្នាំកសិកម្ម ចំនួន២.៥០៩,៥ តោន ៥០ ដប និង ១២៦.000 លីត្រ

-ចំណីសត្វ ចំនួន ១៦២.៨០០ តោន ៣១.៨០២,២ M/T ៥១១.០០០ Ps និង ៣០០ លីត្រ

-បសុឱសថ ចំនួន ៧៩,៣៨៨,០៧ គីឡូក្រាម ១៧៦.០០០ Vials ១.៥០០ Boxes ២០.៨០០ Blister bags និង ១.០០០ Btls

- បរិក្ខាបសុពេទ្យចំនួន ២៧.០០០ Sachets ៧៦៩.០០០ Pcs និង ៣០០ Bottles

-ពូជដំណាំចំនួន ៥៣៧.៥២០,១ តោន

-វត្ថុធាតុដើមសម្រាប់ផលិតស្រាបៀរ ៤៦៤ មុខ។

ខ.ការងារនីតិកម្មកសិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម

ខ.១-ការសិក្សា និង អភិវឌ្ឍលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម

-សេចក្តីព្រាងច្បាប់ស្តីពីថ្នាំកសិកម្ម និងជីកសិកម្មត្រូវបានស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាល និងកំពុងឆ្លងអង្គប្រជុំនៃទីស្តីការគណៈរដ្ឋមន្ត្រី

-សេចក្តីព្រាងប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់កិច្ចបញ្ជិកាថ្នាំកសិកម្ម ត្រូវបានរៀបចំ និងបញ្ចប់ សេចក្តីព្រាងបឋមរួច

-សេចក្តីណែនាំស្តីពីវិធានការពង្រឹងការត្រួតពិនិត្យគុណភាពសម្ភារកសិកម្ម លេខ ១៣៨៣ កសក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១០

-ចងក្រងឯកសារស្ថិតិលិខិតអនុញ្ញាត បញ្ជិកា នាំចូលសម្ភារកសិកម្មឆ្នាំ ២០១០ និងបញ្ជិកាថ្នាំកសិកម្មផុសុពលភាព ២០០៣-២០០៧ ដើម្បីជាឯកសារមូលដ្ឋាន សម្រាប់ពង្រឹងការអនុវត្តច្បាប់ ចំពោះសកម្មភាពអាជីវកម្មសម្ភារកសិកម្ម និងដាក់ឱ្យអនុវត្តនៅគ្រប់រាជធានី ខេត្ត

-សិក្សារៀបចំគោលការណ៍ណែនាំ សម្រាប់វគ្គអប់រំសមត្ថភាពវិជ្ជាជីវអាជីវករសម្ភារកសិកម្ម ដើម្បីជាបទដ្ឋានឯកភាពក្នុងការអនុវត្តគ្រប់រាជធានី ខេត្ត

-សិក្សាបោះពុម្ពបរិយាយប័ណ្ណ កូនសៀវភៅណែនាំ សម្រាប់កម្មវិធីអប់រំផ្សព្វផ្សាយ

-សិក្សាបកប្រែ និងបោះពុម្ពឯកសារអនុសញ្ញា Rotterdam ស្តីពីនីតិវិធីនៃ ការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីគ្រោះថ្នាក់ និង ថ្នាំពុលកសិកម្មក្នុងពាណិជ្ជកម្មអន្តរជាតិ។

ខ.២-ការងារផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម

-អនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ ការយល់ដឹងផ្នែកគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម បានចំនួន ១០ រាជធានី ខេត្ត គោលដៅ ដែលមានសិក្ខាកាមចូលរួមចំនួន ៨០១ នាក់

-ផ្តល់បទឧទ្ទេសនាមក្នុងវគ្គអប់រំ សមត្ថភាពវិជ្ជាជីវដល់អាជីវករសម្ភារកសិកម្មនៅខេត្តចំនួន ០៣ ខេត្ត តាកែវ ០២ វគ្គ (៣២២ នាក់) បន្ទាយមានជ័យ ០១ វគ្គ (១០៣ នាក់) និងបាត់ដំបង ០១ វគ្គ (២១១ នាក់) សរុបអាជីវករ ចំនួន ៦៣៦ នាក់

-បានដំណើរការកិច្ចប្រជុំបូកសរុបការងារនីតិកម្មកសិកម្មប្រចាំឆមាសទី ១ និងប្រចាំឆ្នាំ ២០១០ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការងារគ្រប់គ្រងសម្ភារកសិកម្ម និងលើកទិសដៅបន្តឆ្នាំ ២០១១ ដែលមានការចូលរួមពីមន្ត្រីនីតិកម្មកសិកម្ម ថ្នាក់កណ្តាល និងរាជធានី ខេត្ត ។

គ-ការងារវិវាទកសិកម្ម និងស្រាវជ្រាវ

គ.១-ការត្រួតពិនិត្យការនាំចូលសម្ភារកសិកម្ម

-ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតនាំចូល ឆ្នាំ ២០០៩ (គិតចាប់ពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៨ ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩) ៖ មាន ៤២ ក្រុមហ៊ុន នាំចូល ២៣ ករណី

- បានស្នើរសុំវិធានការទណ្ឌកម្មចំពោះក្រុមហ៊ុន ចំនួន ២៧ ក្រុមហ៊ុន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចចេញលិខិតព្រមាន ចំនួន ០៧ ក្រុមហ៊ុន ០៣ ក្រុមហ៊ុនបាន បោះបង់អាជីវកម្ម និង ០៨ ក្រុមហ៊ុន ក្រសួងបានសម្រេចឱ្យធ្វើការអប់រំណែនាំ និងធ្វើការតាមដានបន្ត។

-ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតនាំចូលឆ្នាំ ២០១០ (គិតពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១០) ៖ មានចំនួន ៤៨ ក្រុមហ៊ុន បាននាំចូល ៦៩ ករណី

- ក្រុមហ៊ុនបានធ្វើប្រតិវេទន៍ជូនក្រសួង និង បានត្រួតពិនិត្យ ៖ មានចំនួន ២៣ ក្រុមហ៊ុន បាននាំចូល ៣២ ករណី
- ក្រុមហ៊ុនមិនបានធ្វើប្រតិវេទន៍ជូនក្រសួង និង បានត្រួតពិនិត្យ ៖ មានចំនួន ១៦ ក្រុមហ៊ុន បាននាំចូល ២៤ ករណី
- ក្រុមហ៊ុននិរាករណ៍លិខិតអនុញ្ញាត ៖ ចំនួន ០១ ក្រុមហ៊ុន (០១ ករណី)
- ក្រុមហ៊ុនមិនទាន់ធ្វើការនាំចូល ៖ ចំនួន ០៨ ក្រុមហ៊ុន (០៨ ករណី)
- ក្រុមហ៊ុនដែលបានបញ្ឈប់ការធ្វើអាជីវកម្ម ៖ ចំនួន ០១ ក្រុមហ៊ុន (០១ ករណី)
- ក្រុមហ៊ុនដែលមិនទាន់បានត្រួតពិនិត្យ ៖ ចំនួន ០២ ក្រុមហ៊ុន (០៣ ករណី)
- ស្នើសុំវិធានទណ្ឌកម្មចំពោះក្រុមហ៊ុន ចំនួន ២៧ ក្រុមហ៊ុន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចចេញលិខិតព្រមានចំនួន ១០ក្រុមហ៊ុន និងសម្រេចធ្វើការអប់រំណែនាំ និងធ្វើការតាមដានបន្តចំនួន ០៤ ក្រុមហ៊ុន និង ១៣ ក្រុមហ៊ុនទៀតរង់ចាំការសម្រេចរបស់ក្រសួង។

**គ.២-ការតាមដាន ត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្ម លក់ចែកចាយសម្ភារកសិកម្មក្នុងរាជធានី ខេត្ត**

-បានចុះត្រួតពិនិត្យ និងណែនាំដល់អាជីវករធ្វើអាជីវកម្មសម្ភារកសិកម្ម នៅក្នុងខេត្តចំនួន ១៤ខេត្តគោលដៅបាន ចំនួន ៣៥៦ ដេប៉ូ ដោយបានទទួលលទ្ធផល និង ចាត់វិធានការដូចខាងក្រោម ៖

- ធ្វើកិច្ចសន្យាកែតម្រូវ បានចំនួន ៤៣ ករណី
- ដកហូតយកសំណាក បានចំនួន ៧៨ គំរូសំណាក
- ដុតកំទេចគ្រាប់ពោតក្លែងគុណភាពនៅខេត្តបាត់ដំបង ចំនួន ២៤ការ៉ុង (៣៣៦ គីឡូក្រាម)
- ដកហូតយកទុកវត្ថុតាងជាបណ្តោះអាសន្ន ម៉ាស៊ីនដេរមាត់បាវចំនួន ០៧ គ្រឿង
- សំបកបាវសម្រាប់ធ្វើការក្លែងបន្លំ ចំនួន ១៥៣ សំបក
- ឃាត់ទុកជីគីមីប្រភេទ DAP ក្លែងគុណភាពចំនួន ២០ បាវ និងប្រគល់ឱ្យមន្ទីរកសិកម្មខេត្តកំពង់ស្ពឺដោះស្រាយតាមនីតិវិធី។

-បានធ្វើសហប្រតិបត្តិការជាមួយសមត្ថកិច្ច នៃនាយកដ្ឋានប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃក្រសួងមហាផ្ទៃ ដោយបានបង្ក្រាបបទល្មើសធ្វើអាជីវកម្ម ផ្គត់ផ្គង់ចែកចាយ បសុឱសថ អាហារបំប៉នសត្វ ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានីភ្នំពេញ និងបានរឹបអូសវត្ថុតាងបានចំនួន ៤០៤ កេស ក្នុងនោះមានបសុឱសថ ចំនួន ៣៩៨ កេស និងអាហារបំប៉នសត្វចំនួន ០៦ កេស។

-ចុះបង្ក្រាបបទល្មើសជីគីមីក្លែងបន្លំម៉ាកសញ្ញាក្បាលក្របី របស់ក្រុមហ៊ុនឃីតាក់គ្រុប ស្ថិតនៅខេត្តកំពង់ស្ពឺ ដោយបាន រឹបអូសជី UREA(46-0-0) សញ្ញាក្បាលក្របីផលិតនៅ ប្រទេសចិន ចំនួន ៣៩ បាវ និងបានឃាត់ទុករថយន្ត ០១ គ្រឿង ម៉ាក HYUNDAI និងប្រគល់ឱ្យ មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ដោះស្រាយតាមសមត្ថកិច្ច និងនីតិវិធី។

**ឃ- ការងារនីតិកម្មកសិកម្មរាជធានី ខេត្ត**

**ឃ.១-ការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសម្ភារកសិកម្ម**

ចំនួនមូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្មគ្រប់រាជធានី ខេត្ត មានចំនួន ២.២៤៨ កន្លែង ក្នុងនោះ

- មូលដ្ឋានដែលមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម មានចំនួន ១.៧៩៤ កន្លែង (៨០% ប្រៀបធៀប

ឆ្នាំ ២០០៩ មាន ៦៦%)

- មូលដ្ឋានដែលគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម មានចំនួន ៤៥៤ កន្លែង (២០% ប្រៀបធៀបឆ្នាំ ២០០៩ មាន ៣៤%)

យ.២- ការសកម្មភាពត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារកសិកម្ម

បានធ្វើសកម្មភាពត្រួតពិនិត្យមូលដ្ឋានអាជីវកម្មសរុបចំនួន ៧៨៩ លើក ត្រូវជា ១.៧២៦ ដេប៉ូ

- បានចាត់វិធានការ ចំពោះបទល្មើស ដែលប្រព្រឹត្តដោយម្ចាស់មូលដ្ឋានអាជីវកម្មតាមរយៈ
- ចេញលិខិតព្រមានដោយមន្ទីរកសិកម្ម ចំនួន ១៥ ករណី
- ធ្វើកិច្ចសន្យាកែតម្រូវ ចំនួន ៣០៧ ករណី
- បញ្ជូនសំណុំរឿងទៅតុលាការ ចំនួន ០៣ ករណី។

យ.៣- សកម្មភាពផ្សព្វផ្សាយអប់រំការយល់ដឹងអំពីសម្ភារកសិកម្ម

បានអនុវត្តកម្មវិធីផ្សព្វផ្សាយ និងចុះធ្វើការណែនាំផ្ទាល់ដល់អាជីវករចំនួន ៦២០ លើក គ្របដណ្តប់លើ ឃុំចំនួន ៣២៦ ឃុំ និង ១៣៤ ស្រុក និង មានអ្នកចូលរួមសរុបចំនួន ១១.៥៥៧ នាក់។

#### ៥.៦.៤.២-វាយតម្លៃ និងសំណើ

ទោះជាភាពខ្វះខាតក្នុងការគ្រប់គ្រងសម្ភារកសិកម្ម នៅតែមានសេសសល់នៅឡើយ ប៉ុន្តែភាពជឿនលឿន ចំពោះមុខបានធ្វើឱ្យមានការប្រែប្រួលច្រើនក្នុងការគ្រប់គ្រងសម្ភារកសិកម្មបច្ចុប្បន្ន ដែលបានបង្ហាញនូវការខិតខំ សកម្មរបស់អង្គភាពនីតិកម្ម កសិកម្មកន្លងមកក្នុងការជំនះលើរាល់ឧបសគ្គ និងភាពខ្វះខាត។ លទ្ធផលនេះនឹងបង្កនូវភាពសុទិដ្ឋិនិយមសម្រាប់អង្គភាព ឱ្យបន្តបេសកកម្មរបស់ខ្លួនទៅមុខទៀតរហូតទទួលបានជោគជ័យស្របតាមទិសដៅកំណត់។

#### ៥.៦.៤.៣-វិធានការ

១-ការគ្រប់គ្រងសម្ភារកសិកម្ម

-ជំរុញការកែលម្អលើសេចក្តីព្រាងច្បាប់ស្តីពីថ្នាំកសិកម្ម និងសម្ភារកសិកម្ម ដើម្បីដាក់ឆ្លងកិច្ចប្រជុំផ្ទៃក្នុងក្រសួង និងបន្តបញ្ជូនសុំការយល់ព្រមនៅថ្នាក់អន្តរក្រសួង និងរាជរដ្ឋាភិបាល

-បន្តពង្រឹងសមត្ថភាពថ្នាក់ជាតិ និងមូលដ្ឋាន សម្រាប់ការគ្រប់គ្រងសម្ភារកសិកម្មប្រកបដោយប្រសិទ្ធភាព

-បន្តជំរុញការត្រួតពិនិត្យ និង ការអនុវត្តច្បាប់លើការធ្វើអាជីវកម្មសម្ភារកសិកម្ម

-បន្តអនុវត្តកម្មវិធីផ្សព្វផ្សាយការយល់ដឹងផ្នែកគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងសម្ភារកសិកម្ម ឱ្យបានកាន់តែទូលំទូលាយដល់មូលដ្ឋាន

-បន្តការស្វែងរកដៃគូរអភិវឌ្ឍន៍ និងទ្រទ្រង់ចំពោះដំណើរការរបស់អង្គភាព ក៏ដូចជាបន្តអនុវត្តគម្រោងជំនួយ ទាំងអស់ដែលមានស្រាប់ឱ្យមានប្រសិទ្ធភាព។

២-ផ្នែកនីតិកម្ម និង ផ្សព្វផ្សាយច្បាប់កសិកម្ម

-ជំរុញសហការជាមួយអង្គភាពជំនាញ ដើម្បីសិក្សាអភិវឌ្ឍន៍លិខិតបទដ្ឋានបន្ថែមទៀត ដែលត្រូវការចាំបាច់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ របស់គោលនយោបាយកសិកម្មជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល។

### ៥.៦.៥-ការងាររដ្ឋបាល និងសវនកម្មផ្ទៃក្នុង

### ៨.៦.៨.១-លទ្ធផល

#### ៨.៦.៨.១.១-ការងារអធិការកិច្ច

**ក- សកម្មភាព**

បានចូលរួមដោះស្រាយបាតុភាព ពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តការងារ និងចុះស្រាវជ្រាវករណីផ្ទុះឡើងនូវបាតុភាពធំៗ បានល្អប្រសើរនៅមូលដ្ឋាន ៖

-ចុះពិនិត្យលើសំណើសុំកាត់ចេញនូវផ្ទៃដីទំហំ ១៩២ ហិកតា ដែលមានផលប៉ះពាល់ជាមួយប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារ ស្ថិតនៅភូមិ ពពាល ឃុំ រហាល ស្រុក ព្រះនេតព្រះ ខេត្ត បន្ទាយមានជ័យ ពីដែនតំបន់ព្រៃឈើ

-ចុះពិនិត្យ ស្រាវជ្រាវ បាតុភាព និងធ្វើការណែនាំ នៅអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ និងសិក្សាស្រាវជ្រាវពាក្យបណ្តឹងលើមន្ត្រីផ្នែករដ្ឋបាលព្រៃឈើខេត្តកំពង់ស្ពឺ

-ចុះសិក្សាវាយតម្លៃ-ផ្ទៀងផ្ទាត់លើដីសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនអាយអិនជីហ្វូលឌីង

-ចុះពិនិត្យមើលប្រព័ន្ធការពារភ្លើង (ព្រៃលិចទឹក) និងអាងទំនប់ ១៦អាង ដែលអាជ្ញាធរខេត្តកំពុងធ្វើការទម្លាយនៅខេត្តពោធិសាត់ កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង

-ចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៅកន្លែងចែកចាយសត្វ សត្តឃាតដ្ឋាន និងកន្លែងលក់សាច់ ក្នុងរាជធានី ភ្នំពេញ

-ចុះពិនិត្យជាក់ស្តែងទីតាំងដីចំនួន ០៥ កន្លែង របស់មន្ទីរកសិកម្មខេត្ត បាត់ដំបង ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

-បានចូលរួមពិនិត្យ រៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាស ដែលពាក់ព័ន្ធនឹងអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ខ- លទ្ធផលការងារ**

*ខ.១-* ក្រសួងបានសម្រេចឱ្យរដ្ឋបាលព្រៃឈើ មានវិធានការអប់រំណែនាំដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានយកចិត្តទុកដាក់អនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួន ពិសេសត្រូវយកចិត្តទុកដាក់លើការងារជំនាញ និងកត្តាសាមគ្គីភាពផ្ទៃក្នុងឱ្យបានល្អប្រសើរ

*ខ.២-* ក្រសួងបានសម្រេចឱ្យរដ្ឋបាលជលផល យកចិត្តទុកដាក់បង្កើនសមត្ថកិច្ចរដ្ឋបាលជលផលខណ្ឌ ផ្នែក សង្កាត់ បន្តចុះទប់ស្កាត់ និងបង្ក្រាបថែមទៀតនូវបទល្មើសជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព

*ខ.៣-* ក្រសួងបានឯកភាពឱ្យអគ្គនាយកដ្ឋានកសិកម្មចាត់វិធានការលើករណីបាតុភាពដី នៅមជ្ឈមណ្ឌលកសិកម្មទន្លេបាទី

*ខ.៤-* តាមរយៈលិខិតលេខ ៣២៨៤ កសក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០ ចំពោះ ករណីផ្ទៃដី ០.៣០០២ ហិកតា ស្ថិតនៅភូមិតាត្រាវ ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ជាទ្រព្យសម្បត្តិអង្គភាពការិយាល័យកសិកម្មកសិកម្មស្រុករមាសហែក នៃមន្ទីរកសិកម្មខេត្តស្វាយរៀង រៀបចំបែបបទ និងឯកសារពាក់ព័ន្ធបង្ហាញ តុលាការបានគ្រប់គ្រាន់ ដើម្បីស្នើសុំតុលាការអនុវត្តសាលក្រម។

*ខ.៥-* តាមរយៈលិខិតលេខ ៤២៩៨ កសក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ក្រសួងបានសម្រេចឱ្យរដ្ឋបាលជលផលចាត់វិធានការដូចខាងក្រោម៖

-ដាក់វិធានការដល់អធិការដ្ឋាន ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល ឱ្យយកចិត្តទុកដាក់ក្នុងការបង្ក្រាបទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទនារដូវបិទនេសាទនេះ

-នៅរដូវបើកនេសាទឆ្នាំក្រោយៗទៀត ខណ្ឌរដ្ឋបាលជលផលកំពង់ធំ ត្រូវកំណត់ទីតាំងលបណរ៉ាវឱ្យបានច្បាស់លាស់ត្រឹមត្រូវលើទីតាំងដែលបានកំណត់ ក្នុងប្រកាសរបស់ក្រសួងកសិកម្មកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចៀសវាងជាន់លើទីតាំងនាឡូត៍នេសាទលេខ ៤ និងឡូត៍បំរុងបាឡូត

-ណែនាំដល់អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទដែលប្រើសាច់អួនក្រឡាតូចជាង ៥ ស.ម ជំនួសវបាំងព្រួលឬស្សីឲបានត្រឹមត្រូវតាមច្បាប់កំណត់

-ចាត់វិធានការជាបន្ទាន់អំពី តារាងប្រកាសសន្និធិផលនេសាទទាន់ពេលវេលា កុំឱ្យមានការខុសឆ្គងដូចឆ្នាំកន្លងមក មានត្រីឆ្តោចិញ្ចឹមខុសច្បាប់ លួចដឹករាល់យប់ៗ ម្យ៉ាងទៀត រដ្ឋបាលជលផលត្រូវត្រួតពិនិត្យការធ្វើសន្និធិនេះ ឱ្យបានត្រឹមត្រូវចៀសវាង ការប្រកាសសន្និធិច្រើនលើសលប់ លើផលនេសាទដែលមានជាក់ស្តែង

-ត្រូវជំរុញការអនុវត្តស្មារតីលិខិតរបស់ក្រសួងលេខ ៧៣៥៩ កសក ចុះ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពី ករណីចិញ្ចឹមត្រីឆ្តោពិសោធន៍ឱ្យបានត្រឹមត្រូវ ការអនុញ្ញាតឱ្យរដ្ឋបាលជលផលអាចធ្វើពិសោធន៍នេះបាន គឺត្រូវមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមុនដែលកន្លងមកខណ្ឌ រដ្ឋបាលជលផល ជុំវិញបឹងទន្លេសាបចេញលិខិតអនុញ្ញាតឱ្យមានចិញ្ចឹមត្រីរ៉ស់ និងត្រីឆ្តោពិសោធន៍ជាច្រើនកន្លែងជារូបភាពបន្ទំពុំមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង ឲនេសាទ។

**ខ.៦**-តាមរយៈលិខិតលេខ ៤៩៤៩ កសក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់វិធានការ ដូចខាងក្រោម ៖

**ខ.៦.១- មន្ទីរកសិកម្មរាជធានី-ខេត្ត**

-ចាត់វិធានការទប់ស្កាត់បទល្មើសលួចនាំចេញ-នាំចូលសត្វ និងផលិតផលមានដើមកំណើតពីសត្វឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព។ ចំពោះគោក្នុងស្រុកដឹកនាំចេញទៅប្រទេសវៀតណាម ត្រូវត្រួតពិនិត្យឱ្យបានម៉ត់ចត់ កុំឱ្យមានដឹកលើសចំនួនក្នុងលិខិតអនុញ្ញាត

-ការប្រមូលលោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ ត្រូវយកចិត្តទុកដាក់ប្រមូលឱ្យអស់លទ្ធភាពទៅតាមចំនួនសត្វជាក់ស្តែង

-លិខិតអនុញ្ញាតឱ្យដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពី សត្វក្នុងការចុះទិដ្ឋាការរបស់មន្ទីរកសិកម្ម ត្រូវចុះហត្ថលេខាដោយប្រធានមន្ទីរ ឫអនុប្រធានមន្ទីរករណីមានលិខិតប្រគល់សិទ្ធិពីប្រធាន

-ការចេញលិខិតអនុញ្ញាតឱ្យដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើត ពិសេសជ្រូករស់ត្រូវធ្វើការត្រួតពិនិត្យឱ្យបានច្បាស់លាស់មុននឹងចេញលិខិត អនុញ្ញាតដឹកជញ្ជូនឱ្យអតិថិជន ឬអាជីវករចៀសវាងដាច់ខាតការក្លែងបន្លំជ្រូករស់ ដែលលួចដឹកចូលពីប្រទេសជិតខាងជាជ្រូកក្នុងស្រុក

**ខ.៦.២- មន្ទីរកសិកម្មខេត្តកំពត**

ត្រូវបែងចែកការងារថ្នាក់ដឹកនាំការិយាល័យ ផលិតកម្ម និងបសុព្យាបាលខេត្តឲបានច្បាស់លាស់ ដូចជាមន្ត្រីទទួលបន្ទុកចេញលិខិតអនុញ្ញាតឱ្យដឹកជញ្ជូនសត្វ និងរៀបចំទុកដាក់ឯកសារឱ្យមានរបៀបរៀបរយ។

**ខ.៦.៣-នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

បានពិនិត្យពិចារណា និងចាត់វិធានការក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យផលិតកម្ម និងបសុព្យាបាល ពិសេសការដឹកជញ្ជូនសត្វនៅទូទាំងប្រទេសឱ្យបានម៉ឺងម៉ាត់។

**គ-សន្និដ្ឋាន**

កន្លងមកទោះបី អគ្គាធិការដ្ឋានបានជួបប្រទះនូវការលំបាកខ្វះខាតសម្ភារៈបរិក្ខា មធ្យោបាយបម្រើការងារ និងប្រេងឥន្ធនៈសម្រាប់ចុះបំពេញការងារក្តី ក៏មន្ត្រីទាំងអស់បានខិតខំប្រឹងប្រែងពុះពារនូវការលំបាកទាំងនោះ ដើម្បីអនុវត្តការងារសម្រេចបានលទ្ធផលគួរឱ្យកត់សំគាល់។

**ឃ-វិធានការ**

-ពង្រឹងសមត្ថភាពមន្ត្រីឱ្យខិតខំរៀនសូត្រនូវបទពិសោធន៍ល្អៗ ដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព

-ភ្ជាប់សភាពការណ៍ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តការងារ

-ចុះត្រួតពិនិត្យ ស្រាវជ្រាវ ការងារដឹកនាំគ្រប់គ្រងរបស់មន្ទីរកសិកម្មរាជធានី-ខេត្ត ដោយផ្តោតលើការងារប្រពលវប្បកម្មដំណាំស្រូវលើគោលការណ៍ធម្មជាតិ និងវិស័យផលិតកម្ម និងបសុព្យាបាល

-ចុះត្រួតពិនិត្យការទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទគ្រប់ប្រភេទនៅរដូវបើកនេសាទ និងបិទនេសាទ ព្រមទាំងការងារដឹកនាំរបស់អធិការដ្ឋាន ខណ្ឌ ផ្នែក និង សង្កាត់ រដ្ឋបាលជលផល

-ចុះផ្ទៀងផ្ទាត់ការអនុវត្តកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចគ្រប់បណ្តាក្រុមហ៊ុន និងត្រួតពិនិត្យផលិតផលព្រៃឈើបានមកពីការឈូសឆាយដីសម្បទានសេដ្ឋកិច្ច

-ចុះត្រួតពិនិត្យ និងស្រាវជ្រាវបទល្មើសព្រៃឈើ ការដកហូតដីព្រៃឈើជាសម្បត្តិរដ្ឋវិញ និងការធ្វើអាជីវកម្មព្រៃគុបផ្តល់ផលក្នុងស្រុក ព្រមទាំងត្រួតពិនិត្យលើការងារគ្រប់គ្រងរបស់អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ ដោយបញ្ជ្រាបច្បាប់ប្រឆាំងអំពើ ពុករលួយជាការរំលឹកដល់មន្ត្រីយើង

-ចុះតាមដាន និងផ្ទៀងផ្ទាត់ការនាំសត្វជ្រូក និងគោ ក្របី ឆ្លងកាត់។

## ៥.៦.៥.១.២-សវនកម្មផ្ទៃក្នុង

**ក- សកម្មភាពចុះធ្វើសវនកម្មតាមកម្មវិធីសវនកម្មឆ្នាំ ២០១០**

ក្នុងឆ្នាំ២០១០ នេះ អង្គភាពចំនួន ៣៤ ត្រូវបានធ្វើសវនកម្មផ្ទៃក្នុងស្មើនឹង ៨០,៩៥% នៃផែនការក្នុងនោះមាន ៖

- អង្គភាពថ្នាក់កណ្តាល ចំនួន ០៥ អង្គភាព
- គ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ០៥ អង្គភាព
- មន្ទីរកសិកម្មរាជធានី-ខេត្ត ចំនួន ២៤ អង្គភាព ។

**ខ-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

- បានចុះធ្វើសវនកម្មលើបញ្ជីសារពើភ័ណ្ឌ និងបានណែនាំអង្គភាពពាក់ព័ន្ធ កែតម្រូវ និងពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- បានណែនាំអង្គភាពក្រោមឱវាទពាក់ព័ន្ធ ដោះស្រាយវិវាទដីធ្លី និងអគាររដ្ឋ ដែលប្រជាពលរដ្ឋ ឬអង្គភាពផ្សេងកាន់កាប់។

**គ-ការគ្រប់គ្រងហិរញ្ញវត្ថុ**

- មន្ទីរកសិកម្មភាគច្រើនបានបង្កើតរដ្ឋទេយ្យចំណូល និងតែងតាំងរដ្ឋទេយ្យករចំណូល និងបានអនុវត្តការចុះបញ្ជី គណនេយ្យទ្វេភាគតាមគោលការណ៍ហិរញ្ញវត្ថុ

- ការប្រមូលចំណូលរបស់អង្គភាពមួយចំនួនមិនបានគ្រប់ផែនការ និងបង់ចូលថវិការដ្ឋមានភាពយឺតយ៉ាវ

- មានបំណុលមួយចំនួននៅមិនទាន់បានដោះស្រាយឱ្យជ្រះស្រឡះ ដូចជាបំណុលសម្ភារកសិកម្ម ចំណូលឡូត៍ នេសាទ ស្រូវពូជ និងបំណុលត្រូវបង់ចូលថវិការដ្ឋផ្សេងៗ

- គ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួន មិនបានអនុវត្តគណនេយ្យទ្វេភាគ រីឯការចំណាយថវិកាក៏ពុំទាន់បានសុំការអនុម័តពីក្រុមប្រឹក្សាភិបាល

### ៥.៦.៥.២-វាយតម្លៃ និងសំណើ

ជារួម ការងារសវនកម្មលើការចុះធ្វើការស្រាវជ្រាវបាតុភាពអសកម្ម ព្រមទាំងការណែនាំកែលម្អនៅមន្ទីរកសិកម្មខេត្ត រតនគីរី មណ្ឌលគីរី ពោធិ៍សាត់ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ទទួលបានលទ្ធផលល្អប្រសើរ តាមផែនការសកម្មភាពប្រចាំឆ្នាំ។

**ការងាយស្រួល**

- តាមរយៈសារាចរលេខ ០១ សរ.ណន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តា ក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងដែលតែងតែណែនាំ និងផ្តល់អនុសាសន៍ល្អៗដល់ការងារសវនកម្ម

- មន្ត្រីមានការកើនចំណេះដឹងជាងមុនដោយសារមានការបណ្តុះបណ្តាលជាបន្តបន្ទាប់

- អង្គភាពរងសវនកម្មភាគច្រើនបានបង្កលក្ខណៈ និងគាំទ្រដល់ការងារសវនកម្ម ។

**ការលំបាក**

- មន្ត្រីមិនទាន់មានជំនាញសវនកម្មគ្រប់គ្រាន់ និងមិនទាន់មានបទពិសោធពេញលេញ ដែលទាមទារត្រូវធ្វើការស្វែងយល់ និងទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់

-ការកំណត់រយៈពេលចុះបេសកកម្មមានរយៈពេលខ្លី និងថវិកាសម្រាប់ចុះបំពេញបេសកកម្ម និងសម្ភារការិយាល័យនៅមានកំរិត

### ៥.៦.៥.៣-វិធានការ

- បន្តស្វែងយល់លិខិតបទដ្ឋាន ច្បាប់ និងប្រមូលព័ត៌មានដែលពាក់ព័ន្ធការងារសវនកម្ម

- ពង្រឹងការអនុវត្តការកិច្ចសវនកម្មតាមច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា

- បន្តចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំឡើង ដោយក្រុមប្រឹក្សាកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តរៀបចំបញ្ចប់សេចក្តីព្រាង ផែនការយុទ្ធសាស្ត្រសវនកម្ម ឆ្នាំ២០១១-២០១៣ និងផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ ២០១១

- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ ២០១១

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសវនកម្មជាតិ និងសវនកម្មផ្ទៃក្នុងតាមស្ថាប័ននានា

- ចុះតាមដានការកែលម្អរបស់អង្គភាពរងសវនកម្ម និងបន្តសហការជាមួយក្រុមជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី ADB នៃគម្រោង PFMRDP Component 2 (Public Financial Management for Rural Development )។

## ៥.៦.៦-ការងារស្រាវជ្រាវកសិកម្មឆ្នាំ ២០១០

ក្នុងកិច្ចសហការយ៉ាងស្អិតរមួតជាមួយមន្ទីរកសិកម្ម រាជធានី ខេត្តចំនួន ១៥ នាយកដ្ឋានជំនាញពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ កសិកម្មកម្ពុជាបាន (១)បន្តអភិវឌ្ឍ

ពូជដំណាំចំនួន ១៨ ប្រភេទ ដែលជាសរុបមានចំនួន ៣.៣៣៩ បញ្ជីក និងសំណាក (២)ធ្វើយុវកម្មពូជស្រូវអភិរក្សចំនួន ៥៩០ បញ្ជីក (៣)បង្កាត់ពូជស្រូវចំនួន ១០ បង្កាត់ និងដាំជ្រើសរើសស្រទ្បាយស្រូវចំនួន ៦ ជំនាន់ (៤)ធ្វើពិសោធន៍សរុបចំនួន ៩១ ប្រភេទ ដែលមានចំនួនពិសោធន៍សរុប ៧១៥ កន្លែងលើដំណាំចំនួន ១៥ ប្រភេទ (៥)ធ្វើអង្កេតបានចំនួន ៩ ប្រភេទ (៦)ធ្វើការប្រជុំជាមួយកសិករចំនួន ៣៤ ក្រុម សរុប ចំនួន ៥៣៧ នាក់ (៧)ប្រារព្ធទិវាស្រែបង្ហាញ (៨)បណ្ដុះបណ្ដាលកសិករ (៩)បោះពុម្ព និងបែងចែកឯកសារចំនួន ៥ ប្រភេទ។

**៥.៦.៦.១–លទ្ធផល**

**ក– ការងារពិសោធន៍ស្រាវជ្រាវបង្កើនផលិតភាពដំណាំ**

-បានបញ្ចេញពូជស្រូវផ្កាច័ន្ទសែនសរជូនកសិករប្រើប្រាស់ជាផ្លូវការណ៍។ ពូជផ្កាច័ន្ទសែនសរ ជាពូជស្រូវ កណ្ដាល ប្រកាន់រដូវ និងចាប់ចេញផ្កាក្នុងកំឡុងថ្ងៃ ៥-១២ ខែវិច្ឆិកា។ កម្ពស់ដើមរបស់ពូជស្រូវ "ផ្កាច័ន្ទសែនសរ" ប្រែប្រួលពី ១៥០-១៦០ ស.ម និងមានចំនួនដើមបែកផលពី ៧-១០ ដើមក្នុងមួយគុម្ពអាស្រ័យទៅតាមជីជាតិដី។ ពូជនេះ មានចំនួនគ្រាប់ក្នុងមួយកួរពី ១៦៩-២៣៣ គ្រាប់ មានប្រវែងកួរ ២៥-២៨ ស.ម មានទិន្នផលប្រែប្រួលពី ៣,៥ ទៅ ៤,៥ តោន/ហ.ត

-ពូជស្រូវ ជលសារ គ្រូ អ៊ីអ៊ែរកេសរ និងខា ១២ នៅតែធន់ទ្រាំមជ្ឈមទៅនឹងមមាចត្នោត

-ការពិសោធន៍បង្កុំបច្ចេកវិទ្យាលើដំណាំស្រូវវស្សារបស់វិទ្យាស្ថាននៅខេត្តកំពង់ចាម និងសៀមរាប បានបង្ហាញថា ការដាំដុះតាមទម្លាប់កសិករផ្ដល់ទិន្នផលប្រមាណត្រឹមតែ ២,៧៥ តោន/ហ.ត ប៉ុណ្ណោះ ចំណែកឯការប្រើបង្កុំបច្ចេកទេសរបស់វិទ្យាស្ថាន (ពូជ ការគ្រប់គ្រងដី និងទឹក) បានផ្ដល់ទិន្នផលប្រមាណជិត ៤ តោន/ហ.ត គឺខ្ពស់ជាង ទម្លាប់កសិករ ៤៥% ហើយបើគិតជាប្រាក់ចំណេញសុទ្ធ គឺមានចំនួន ២ ដងនៃទម្លាប់កសិករ

-អាសូត (N) ជាកត្តាកំណត់ការដុះលូតលាស់ និងទិន្នផលស្រូវតំបន់ទំនាប នៅពេលដែលការផ្គត់ផ្គង់ផូស្វាត (P) និងប៉ូតាស្យូ (K) បានគ្រប់គ្រាន់តាមកម្រិតណែនាំ

-ការប្រើប្រាស់ជីអាសូតកម្រិតទ្វេដងនៃកម្រិតណែនាំ (១០០:២៣:៣០) លើពូជស្រូវស្រាលមិនប្រកាន់រដូវ ផ្ដល់នូវទិន្នផល ៣,៧ តោន/ហ.ត គឺខ្ពស់ជាងកម្រិតណែនាំ (៥០:២៣:៣០) ប្រមាណជាង ២៣%។ ប៉ុន្តែ ចំពោះពូជស្រូវកណ្ដាល និងធ្ងន់ប្រកាន់រដូវ ការប្រើជីលើសពីកម្រិតណែនាំ មិនផ្ដល់ផលលើសឡើយ

-ការដាំដុះសណ្ដែកបាយក្រោយពេលប្រមូលផលស្រូវវស្សាលើក្រុមដីព្រៃខ្មែរ និងប្រទះឡាង តាមរយៈការប្រើប្រាស់បង្កុំបច្ចេកទេសបឋមរបស់កាឌី បានផលពី ៧៧០ ទៅ ១៥០០ គ.ក្រ សមមូលទៅនឹងប្រាក់ចំណេញដុលពី ១,៥ លាន ទៅ ៥,០ លានរៀល

-បង្កើតបាននូវឧបករណ៍លើករងដាំសណ្ដែកបាយលើដីស្រែវស្សា

-ការដាំប៉េងប៉ោះគ្របដោយប្លាស្ទីកនារដូវប្រាំង អាចបង្កើនផលដល់ទៅ ២៦% ច្រើនជាងមិនគ្រប។

**ខ– ការងារពិសោធន៍ស្រាវជ្រាវអំពីពិពិធកម្មដំណាំ**

-បង្កើតបាននូវបង្កុំបច្ចេកទេសបឋម សម្រាប់ការដាំដុះសណ្ដែកបាយ និងសណ្ដែកដីក្រោយពេលប្រមូលផលស្រូវវស្សា លើក្រុមដីព្រៃខ្មែរ និងប្រទះឡាង ដោយមានប្រភពទឹកស្រោចស្រពបន្ថែម

-ប្រព័ន្ធកសិកម្មគម្រូ គឺជាប្រព័ន្ធមួយដ៏ល្អ និងសមស្រប សម្រាប់កសិករក្រីក្រអនុវត្ត ពីព្រោះបានផ្ដល់នូវស្ថេរភាពខាងចំណីអាហារ និងបរិស្ថានល្អ ព្រមទាំងបង្កើនប្រាក់ចំណូល។ នាឆ្នាំ ២០១០

កសិករអនុវត្តប្រព័ន្ធកសិកម្មគំរូបានទទួលប្រាក់ចំណូលចំនួនជាង ៨ លានរៀល លើប្រាក់ចំណាយចំនួនជាង ៣ លានរៀល ព្រមទាំង នៅសល់ស្រូវទុកហូបគ្រប់គ្រាន់ទៀតផង។

**គ– ការអង្កេត និងវាស់វែង**

-តាមរយៈការស្រង់ស្ថិតិពីក្នុងខេត្តចំនួន ១៤ កន្លងមកបានបង្ហាញថា ចំនួនកសិករដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានកើនពី ១៧% នាឆ្នាំ ២០០៣ រហូតដល់ ៥៩% នាឆ្នាំ ២០០៨ ដែលបរិមាណនេះ សមាមាត្រទៅនឹងបរិមាណផលស្រូវបន្ថែមរហូតដល់ ០,៤៧ លានតោន និងប្រាក់ ចំណេញដុលជាង ៨៩ លានដុល្លារអាមេរិក។




-កសិករ ក្នុងខេត្តតាកែវ និងកំពតប្រមាណ ៥០% និងក្នុងខេត្តកំពង់ធំ ប្រមាណ ១២% បានធ្វើស្រែបង្កើនរដូវ។ មូលហេតុ នៃការធ្វើស្រែបង្កើនរដូវនេះ ដោយសារតែមានប្រភពទឹកក្រោមដី (ខេត្តតាកែវ) មានប្រព័ន្ធប្រឡាយទឹក និងពូជស្រូវទំនើបមិនប្រកាន់រដូវ និងផ្តល់ទិន្នផលខ្ពស់។

-នៅខេត្តកំពត កសិករភាគច្រើនបានលក់ផលិតផលបន្លែឱ្យទៅអ្នកប្រមូលទិញក្នុងស្រុកទឹកឈូរ និងមួយចំនួន ទៀតលក់ទៅឲ្យអ្នកលក់បន្លែ នៅទីផ្សារក្នុងតំបន់ និងផ្សារសាមគ្គីកំពត។ អ្នកប្រមូលទិញបានលក់បន្តឱ្យឈ្មួញ ហើយឈ្មួញភាគច្រើន បានលក់បន្តទៅផ្សារក្នុងរាជធានីភ្នំពេញ ខេត្តកោះកុង និងខេត្តព្រះសីហនុ។

-ក្នុងស្រុកស្អាង និងស្រុកកៀនស្វាយ កសិករម្ចាស់ចម្ការបន្លែភាគច្រើន បានដឹកបន្លែរបស់ខ្លួនមកលក់ឱ្យអ្នកលក់នៅផ្សារដើមគរ នាគមាស និងច្បារអំពៅ។

-កសិករនៅខេត្តបាត់ដំបង និងប៉ៃលិនបានយល់ឃើញថា ពោតគឺជាដំណាំចម្ការ ដែលមានសារៈសំខាន់សម្រាប់ដាំដុះដើមរដូវវស្សាជាងគេ និងបន្ទាប់មកគឺសណ្តែកដី ល្ង និងសណ្តែកបាយ។

**ឃ– ការផ្សព្វផ្សាយបច្ចេកវិទ្យា**

-បានធ្វើទិវាស្រែបង្ហាញចំនួន ១១ ដែលមានមន្ត្រីបច្ចេកទេស ផ្សព្វផ្សាយ និងកសិករចូលរួមចំនួន ១២៧៩ នាក់

-បានទទួលស្វាគមន៍ និងបង្ហាញអំពី ការងាររបស់វិទ្យាស្ថានជូនគណៈប្រតិភូថ្នាក់ជាតិ របស់ប្រទេសចំនួន ៣ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិព្រមទាំងលោកគ្រូ អ្នកគ្រូ និងនិស្សិតបរទេសចំនួន ៣៨៩ នាក់

-បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុមាតុភូមិយើង (FM 101.25) ចំនួន ៨ លើក ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុជាតិកម្ពុជាចំនួន ១ លើកស្តីពីពូជស្រូវសំខាន់ៗទាំង ១០ សម្រាប់ជំរុញផលិតកម្មស្រូវ និង

ការនាំចេញអង្ករ និងវិទ្យុ ABC អូស្ត្រាលីជាភាសាខ្មែរចំនួន ៩ លើក ព្រមទាំងបានផ្តល់បទសម្ភាសន៍ចំនួន ២ លើក ដល់ទូរទស្សន៍ជាតិកម្ពុជា និងទូរទស្សន៍បាយ័ន

-មានអ្នកបើកស្រាវជ្រាវគេហទំព័រ (www.cardi.org.kh) និង (www.crkb.org.kh) រកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ១០១.២០០ នាក់ ហើយគិតជាមធ្យមមានប្រមាណ ៣០៤ នាក់/ថ្ងៃ ដែលក្នុងនោះ ប្រទេសកម្ពុជាចំនួន ៤០% សហរដ្ឋអាមេរិកចំនួន ១៣% អូស្ត្រាលី ៦% ជប៉ុនចំនួន ២% និងប្រទេសផ្សេងៗទៀត (៨៧ ប្រទេស) ចំនួន ៣៩%។ មានអ្នកមកស្រាវជ្រាវឯកសារនៅបណ្ណាល័យចំនួន ៣១១ នាក់។

ង– ការបណ្តុះបណ្តាល និងបោះពុម្ពឯកសារ

-បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន ១៨ វគ្គ ដែលមានអ្នកចូលរួមសរុប ៦១៩ នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងប្រជុំនានាក្នុងប្រទេសចំនួន ១០ លើក ដែលមានមន្ត្រីវិទ្យាស្ថានចូលរួមសរុបចំនួន ១២ នាក់ និងក្រៅប្រទេសចំនួន ២៤ វគ្គ ដែលមានមន្ត្រីវិទ្យាស្ថានចូលរួមសរុបចំនួន ២៩ នាក់

-បានផ្តល់ និងទទួលដឹកនាំនិស្សិតសរសេរសារណាចំនួន ២០នាក់ និងបញ្ជូនមន្ត្រី ២នាក់ ទៅជួយបង្រៀននៅសកលវិទ្យាល័យភូមិន្ទកសិកម្ម

-បានសរសេរអត្ថបទវិទ្យាសាស្ត្រអំពីលទ្ធផលការងារស្រាវជ្រាវ និងបោះពុម្ពតាមរយៈទស្សនាវដ្តីវិទ្យាសាស្ត្រ និងសៀវភៅសន្និសីទបានចំនួន ៣ អត្ថបទ

-បានរៀបចំបោះពុម្ព និងចែកចាយឯកសារចំនួន ៤ ប្រភេទគឺ ទស្សនាវដ្តីកសិកម្ម ព្រឹត្តិបត្រព័ត៌មានកសិករ (ចំនួន ៦ប្រភេទ) ខិត្តប័ណ្ណព័ត៌មានស្តីពី ធនធានពិន្ទុរុក្ខជាតិសម្រាប់ស្បៀងនិងកសិកម្ម និងសៀវភៅរបាយការណ៍ (សមិទ្ធផល ១០ ឆ្នាំ និងរបាយការណ៍ ២០០៣-២០០៩) ដែលមានចំនួនសរុបប្រមាណ ៣៣.៩១៣ ច្បាប់ជូនថ្នាក់ ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល នាយកដ្ឋានក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធ។ បានរៀបចំឯកសារស្តីពី បច្ចេកទេសដាំដុះដំណាំស្រូវ និងបានផលិតជាថាសឯកសារស្តីពីទស្សនកិច្ចសិក្សា និងទិវាស្រែ បង្ហាញរបស់វិទ្យាស្ថានសម្រាប់ធ្វើការចែកចាយដល់អង្គភាពពាក់ព័ន្ធ។

ច– ការប្រារព្ធពិធីសំខាន់ៗ

-បានប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សារណៈ នៃកិច្ចព្រមព្រៀងស្តីពី ការបង្កើតមជ្ឈមណ្ឌលកសិកម្មអន្តរ ជាតិកូរ៉េ (KOPIA) រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលអភិវឌ្ឍន៍ជនបទ នៃសាធារណៈរដ្ឋកូរ៉េ ដែលចុះហត្ថលេខា ដោយ**ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង H.E. Kim, Jae Soo, Administrator, RDA ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុម ប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-បានលើកស្ទើ និងការពារប្រកបដោយជោគជ័យនូវពូជស្រូវចំនួន ១០ ពូជ (សែនពិដោរ ជលសារ អ៊ីអ៊េរ៦៦ ផ្ការំដួល ផ្ការំដេង ផ្ការមៀត ផ្កាច័ន្ទសែនសរ រំពងជ័យ ខា៤ និង ខា៦) តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់លើការកំណត់ពូជស្រូវក្នុងស្រុកសំខាន់ៗចំនួន ១០ ពូជ ដែលជាគោលដៅអាទិភាពជំរុញផលិតកម្មដំណាំស្រូវ និងការនាំចេញអង្ករ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានរៀបចំតាំងពិព័រណ៍ពូជស្រូវចំនួន ១០ ពូជ ដែលបានកំណត់តាមគោលនយោបាយជម្រុញផលិតកម្ម ស្រូវ និងការនាំចេញអង្ករ ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកសិកម្មអាស៊ានលើកទី ៣២ the 10 th AMAFF+3 and 2nd ASEAN-China SPS នៅវិមានសន្តិភាព និងបានគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** អំពី លក្ខណៈសំខាន់ៗរបស់ពូជស្រូវទាំង ១០ ពូជ ស្ថិតិដំណាំស្រូវ ចាប់ពីឆ្នាំ ១៩០០ មកដល់ឆ្នាំ២០០៩ និងការទទួលយករបស់កសិករចាប់ពីឆ្នាំ ២០០៣ មកដល់ឆ្នាំ ២០០៨ ព្រមទាំង ផលចំណេញបន្ថែម ដែលបានមកពីការដាំដុះពូជស្រូវបញ្ចេញដោយវិទ្យាស្ថាន

-បានទទួលស្វាគមន៍ និងជម្រាបជូននូវវឌ្ឍនភាពផលិតកម្មកសិកម្មជាតិ ព្រមទាំងការងារស្រាវជ្រាវ និងផ្សព្វផ្សាយរបស់វិទ្យាស្ថានជូនដល់គណៈប្រតិភូជាន់ខ្ពស់នានារួមមាន (១)គណៈប្រតិភូកិច្ចប្រជុំថ្នាក់ រដ្ឋមន្ត្រីកសិកម្ម អាស៊ានលើកទី ៣២ (២)គណៈប្រតិភូជាន់ខ្ពស់ប្រទេសឥណ្ឌូនេស៊ី ដឹកនាំដោយ H.E Dr. Laode Ida, Deputy Speaker, The House of Regional Representatives, The Republic of Indonesia រួមដំណើរដោយ **ឯកឧត្តម ឈិន គឹមឃាត** សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា (៣)គណៈប្រតិភូក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទនៃសាធារណៈរដ្ឋកូរ៉េ ដឹកនាំដោយ H.E Chung Seung, អនុរដ្ឋមន្ត្រី (៤)គណៈប្រតិភូបណ្ឌិតសភាវិទ្យាសាស្ត្រ កសិកម្មខេត្តក្វាងស៊ី ដឹកនាំដោយ Prof. Yang-rui Li, President of Guangxi Academy of Agricultural Sciences (GXAAS) (៥)គណៈប្រតិភូមកពីស្ថានទូត Saudi Arabia ដែលដឹកនាំដោយ Mr. Chio Eanjun (៦)ទទួលដំណើរទស្សនកិច្ចរបស់ Dr. Prasanna Boddupalli, Director, Global Maize Program និង(៧)និស្សិតបរទេសចំនួន ១៦ នាក់ មកពីសាកលវិទ្យាល័យ និងសាលាជំនាញចំនួន ១១ នៅសហរដ្ឋអាមេរិក

-បានធ្វើការប្រជុំក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានចំនួន ២ លើក ពិនិត្យលើផែនការណ៍ថវិកាឆ្នាំ ២០១១ ដែលវិទ្យាស្ថានស្នើទៅក្រសួង វឌ្ឍនភាពការងាររបស់វិទ្យាស្ថាន និងការងារផ្សេងៗមួយចំនួនទៀត។

### ៥.៦.៦.២- វាយតម្លៃ និងសំណើ

ក្នុងឆ្នាំ ២០១០ ថ្នាក់ដឹកនាំ និងមន្ត្រី-និយោជិតទាំងអស់បានខិតខំប្រឹងប្រែងដឹកនាំ និងបំពេញការកិច្ច ដើម្បីកសាង និងអភិវឌ្ឍន៍វិទ្យាស្ថាន ដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ស្របតាមវិធានការ ដែលបានលើកឡើងក្នុងឆ្នាំ ២០០៩។ សមិទ្ធផលសំខាន់ៗមានជាអាទិ៍ (១)បានលើកស្នើ និងការពារប្រកបដោយជោគជ័យនូវ ពូជស្រូវចំនួន ១០ ពូជ តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់លើការកំណត់ពូជស្រូវក្នុងស្រុកសំខាន់ៗ ចំនួន ១០ ពូជ ដែលជាពូជអាទិភាព សម្រាប់អនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់ ព្រះរាជាណាចក្រកម្ពុជា (២)បានបញ្ចេញជាផ្លូវការណ៍នូវពូជស្រូវកណ្តាលប្រកាន់រដូវមួយពូជ គឺពូជផ្កាច័ន្ទសែនសរ (៣)បច្ចេកទេសក្នុងការគ្រប់គ្រង និងថែទាំដំណាំ (៤)បច្ចេកទេសក្រោយពេលប្រមូលផល និង(៥)បានផ្សព្វផ្សាយបច្ចេកទេសដល់កសិករ ព្រមទាំងអ្នកពាក់ព័ន្ធតាមមធ្យោបាយផ្សព្វផ្សាយផ្សេងៗ។ ទន្ទឹមនឹងនេះ វិទ្យាស្ថានបានបន្ត កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការងារបណ្តុះបណ្តាល ព្រមទាំងផ្សព្វផ្សាយតាមរយៈការបោះពុម្ពឯកសារ បច្ចេកទេសនានា និងគេហទំព័ររបស់វិទ្យាស្ថាន។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រី-និយោជិតទាំងអស់ និងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានមានសំណូមពរសំខាន់ៗចំនួនបីដូចខាងក្រោម៖

-សំណើឲ្យមានការបង្កើនថវិកាពរដ្ឋាភិបាលសម្រាប់វិស័យស្រាវជ្រាវ និងបន្តជម្រុញឱ្យប្រទេសផ្តល់ជំនួយពង្រឹងស្ថាប័នស្រាវជ្រាវជាតិបន្ថែមទៀត និងជាពិសេសផ្នែកហិរញ្ញវត្ថុ សម្រាប់ការងារគ្រប់គ្រងប្រតិបត្តិការរបស់វិទ្យាស្ថាន

-សំណើជួយគាំទ្រដល់បច្ចេកវិទ្យា ដែលបានអភិវឌ្ឍន៍ដោយវិទ្យាស្ថាន និងប្រើប្រាស់ដោយប្រុងប្រយ័ត្ននូវបច្ចេកវិទ្យាបរទេសជាពិសេស ពូជដំណាំ ដែលផលិតផលអាចឈានដល់ការនាំចេញ

-សំណើសុំផ្តល់នូវធនធានមនុស្សប្រកបដោយគុណភាពបន្ថែមទៀត ដោយសារមន្ត្រីវិទ្យាស្ថានមួយចំនួនបានចូលនិវត្តន៍ជាបន្តបន្ទាប់។

### ៥.៦.៦.៣- វិធានការ

-បន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ ហើយប្រកបដោយគុណភាពល្អប្រពៃធន់ទ្រាំទៅនឹងទឹកជំនន់ គ្រោះរាំងស្ងួត និងកំដៅ ពូជស្រូវអាយុកាលខ្លីជាង ១០០ ថ្ងៃ និងបន្តធ្វើការស្រាវជ្រាវដោយប្រើវិធីសាស្ត្ររួមគ្នាប្រកបដោយសុវត្ថិភាព និងមាននិរន្តរភាព ដើម្បីជួយកសិករក្នុងការការពារការបាត់បង់ទិន្នផលដំណាំ និងប្រាក់ចំណេញ

-បន្តស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា នៃប្រព័ន្ធគ្រប់គ្រងដីជាតិដី សារធាតុចិញ្ចឹម ប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងនិរន្តរភាពខ្ពស់ ដើម្បីជួយប្រជាកសិករក្នុងការបង្កើន និងធ្វើឲ្យមានស្ថេរភាពទិន្នផលដំណាំនៅក្នុងប្រព័ន្ធកសិកម្ម នៃតំបន់ទំនាបតំបន់ស្រោចស្រព និងតំបន់ខ្ពង់រាប តាមរយៈការធ្វើឲ្យកាន់តែប្រសើរឡើងនូវចំណេះដឹងលើផ្នែកគ្រប់គ្រងដី និងសារធាតុចិញ្ចឹមដំណាំ

-បន្តសិក្សារកលទ្ធភាពបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្មក្នុងប្រព័ន្ធកសិកម្ម នៃតំបន់ទំនាប និងតំបន់ខ្ពង់រាប នៃប្រព័ន្ធផលិតកម្មដំណាំកសិកម្ម

-បន្តស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍សមត្ថភាពវិភាគក្នុងមន្ទីរពិសោធន៍ ផ្នែកវិភាគដី ទឹក រុក្ខជាតិ ជំងឺរុក្ខវិទ្យា និងជាលិកាវប្បកម្ម

-បន្តពង្រឹង និងជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិករ និងអ្នកពាក់ព័ន្ធនានា តាមរយៈការបោះពុម្ពផ្សាយ គេហទំព័រ កាសែត វិទ្យុ និងទូរទស្សន៍។

## ៥.៦.៧-ការងារផ្សព្វផ្សាយកសិកម្ម និងពង្រឹងសហគមន៍កសិកម្ម

ដើម្បីចូលរួមលើកកំពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មក្នុងឆ្នាំ ២០១០ នេះ ការងារផ្សព្វផ្សាយកសិកម្មបានដឹកនាំសម្របសម្រួលការសកម្មភាពការងារផ្សព្វផ្សាយកសិកម្មនៅក្នុង រាជធានី-ខេត្តទាំង ២៤ និងសហការជាមួយអង្គភាពជំនាញនានា មន្ទីរកសិកម្មរាជធានី-ខេត្ត គម្រោង/កម្មវិធីនានា និងភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន (NGOs) និងរដ្ឋអំណាចមូលដ្ឋានក្នុងការផ្សព្វផ្សាយ ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មលើសកម្មភាពសំខាន់ៗដែលរួមមាន ១).ការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយកសិកម្ម និងកសិករ ២).ការអភិវឌ្ឍន៍ប្រព័ន្ធកសិកម្ម ៣).ការរៀបចំ និងពង្រឹងអង្គការកសិករ និងសហគមន៍កសិកម្ម ៤).ការអបរំ និងផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម និង៥).ចូលរួមការកែលំអផលិតកម្មស្បៀង និងរកចំណូល ជាលក្ខណៈគ្រួសារ។

### ៥.៦.៧.១- លទ្ធផល

#### ៥.៦.៧.១.១. ការបណ្តុះបណ្តាលកសិករ

ការបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្មមាន វិធីសាស្ត្របណ្តុះបណ្តាល និងផ្សព្វផ្សាយដល់

មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ និងឃុំ បណ្តុះបណ្តាលពីការដឹកនាំគ្រប់គ្រង ការធ្វើផែនការ និងការធ្វើជំនួញដល់ សហគមន៍កសិកម្ម ការធ្វើទស្សនៈកិច្ចសិក្សា សាលារៀនស្រែកសិករ និងទិវាបង្ហាញ។ល។

ក. ទស្សនៈកិច្ចសិក្សា

បានរៀបចំទស្សនៈកិច្ចសិក្សាដល់មន្ត្រីកសិកម្មខេត្ត និងស្រុក និងកសិករគំរូ ចំនួន ៣ លើ ដែលមានមន្ត្រីកសិកម្មចូលរួមចំនួន ៤៣ នាក់ និង កសិករ ចំនួន ៧៦ នាក់ មកពីខេត្ត បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ រតនគីរី និងព្រៃវែង មកទស្សនៈសិក្សានៅខេត្តព្រៃវែង កំពង់ស្ពឺ តាកែវ និងកំពត ដើម្បីផ្លាស់ប្តូរ បទពិសោធន៍ពីប្រព័ន្ធកសិកម្មចំរុះ ការដាំបន្លែផ្ទះសំណាញ់ វារីវប្បកម្ម ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការចិញ្ចឹមសត្វ និងការកែច្នៃចំណីសត្វ។

ខ. បណ្តុះបណ្តាលកសិករ

បានបណ្តុះបណ្តាលកសិករចំនួន ៩៦០វគ្គ មានកសិករចូលរួមសរុបចំនួនជាង ២៨ ពាន់នាក់ មានស្ត្រីជា ១០ ពាន់នាក់ តាមរយៈការបណ្តុះបណ្តាល បច្ចេកទេសកសិកម្ម និងសាលារៀនស្រែកសិករ ពីបច្ចេកទេសកសិកម្មនានាដូចជា ផលិតកម្មដំណាំស្រូវ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ដំណាំបន្លែ (ផលិតបន្លែសរីរាង្គ និងបន្លែ សុវត្ថិភាព និងដាំបន្លែផ្ទះសំណាញ់ ដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងចិញ្ចឹមត្រីក្នុងស្រះនិងក្នុងស្រែ និងការដាំឈើពហុប្រយោជន៍ តាមគ្រួសារ និងសួនដំណាំគ្រួសារ វិធានការការពារនិងគ្រប់គ្រងដំណាំ និងជីជាតិដី និងប្រព័ន្ធកសិកម្មចំរុះ ដែលមានកសិករសរុបជាង ២០ ពាន់នាក់ ក្នុងនោះមាន ស្រីចំនួនជាង ៩ ពាន់នាក់។

កសិករគំរូឆ្នើម និងទទួលបានបានស្នាដៃក្នុងផលិតកម្មកសិកម្ម តាមរយៈការសិក្សាបច្ចេកទេសកសិកម្ម និងការធ្វើបង្ហាញ និងផ្សព្វផ្សាយបន្ត ទៅកសិករបានជោគជ័យមានចំនួន ៦០២ នាក់ ក្នុងនោះមានស្រី ៣៨ នាក់។ តាមរយៈ សន្និបាតកសិករទូទាំងប្រទេសលើកទី២ ដែលមានកសិករគំរូចូលរួមចំនួន ១៧៤ នាក់ បានប្រលងប្រជែងលើប្រធានបទ ចំនួន ៦ គឺ យើងបានជ្រើសរើសកសិករជ័យលាភី ដែលមានស្នាដៃក្នុងផលិតកម្មកសិកម្ម ចំនួន ៣០ នាក់ មានស្រី ៤ នាក់ ដែលក្នុងនោះមានលើប្រធានបទប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ៥នាក់ ប្រព័ន្ធកសិកម្មចំរុះ ៥នាក់ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារចំនួន ៥ នាក់ ការចិញ្ចឹមត្រី ចំនួន ៥ នាក់ ការកែច្នៃគ្រឿងយន្ត និងឧបករណ៍កសិកម្មចំនួន ៥ នាក់ និងការកែច្នៃផលិតផលកសិកម្មនិងជលផលចំនួន ៥ នាក់។

**៥.៦.៧.១.២. ការងារអភិវឌ្ឍន៍ប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ច**

ការអភិវឌ្ឍន៍ប្រព័ន្ធកសិកម្មបានអនុវត្តវិធីសាស្រ្តវាយតំលៃ និងធ្វើផែនការដោយមានការចូលរួម ការអភិវឌ្ឍន៍ បច្ចេកទេសដោយមានការចូលរួម និងការអភិវឌ្ឍន៍កញ្ចប់បច្ចេកទេសផ្សព្វផ្សាយកសិកម្ម

ក. ការវាយតំលៃប្រព័ន្ធកេ្សត្រ-បរិស្ថានៈការវាយតំលៃប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ

គឺជាវិធីសាស្រ្ត និងឧបករណ៍មួយ ក្នុងការវិភាគប្រព័ន្ធកសិកម្ម និងប្រព័ន្ធជីវិតរស់នៅនៅមូលដ្ឋានសម្រាប់ កំណត់បញ្ហា ដំណោះស្រាយ និងសកម្ម ភាពជាអទិភាពព្រមទាំងការរៀបចំផែនការ ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការរបស់រាជរដ្ឋាភិបាល។ នៅឆ្នាំ២០១០នេះ ការសិក្សាការវិភាគប្រពន្ធ័កេ្សត្រ-បរិស្ថានឃុំចំនួន ៦១ ឃុំ យើងបានវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំសរុប ចំនួន ៥៨៦ ឃុំ ។

ខ. ការគ្រប់គ្រងទិន្នន័យគ្រឹះប្រព័ន្ធកសិកម្ម

*បានរៀបចំប្រព័ន្ធទិន្នន័យគ្រឹះប្រព័ន្ធកសិកម្ម ដោយរក្សាទុកនូវព័ត៌មាន សម្រាប់រៀបចំផែនការស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យកសិកម្ម ទៅតាមតម្រូវការជាក់ស្តែងរបស់កសិករ នៅមូលដ្ឋាន ហើយប្រព័ន្ធទិន្នន័យនេះ បានរក្សាទុកទិន្នន័យចំនួន ៩២៦ឃុំ នៅនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ៧៧ ឃុំទៀតស្ថិតនៅជាសៀវភៅឯកសារ នៅតាមការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តគោលដៅ។*

គ.ការអភិវឌ្ឍន៍បច្ចេកវិទ្យាដោយមានការចូលរួម

*ដោយផ្អែកលើការវាយតំលៃប្រព័ន្ធក្សេត្រ-បរិស្ថាន នៅក្នុងឆ្នាំ ២០១០នេះ ដោយសហការជាមួយកសិករ ធ្វើស្រែបង្ហាញ ធ្វើទិវាបង្ហាញ និងការតាមដានពិព័ណ៌ផលិតផល កសិកម្ម ពីបច្ចេកទេសកសិកម្មនានា ដូចជាដំណាំស្រូវ ដំណាំបន្លែ ដំណាំរួមផ្សំ ចិញ្ចឹមសត្វ និងចិញ្ចឹមត្រីក្នុងស្រះ និងក្នុងស្រែ និងការឈើពហុប្រយោជន៍តាមគ្រួសារ និងសួនដំណាំគ្រួសារ វិធានការការពារ និងគ្រប់គ្រងបំផ្លាញពី សមាសភាពចង្រៃ។ល។ ដើម្បីរៀបចំជាបង្គុំបច្ចេកទេសផ្សព្វផ្សាយកសិកម្ម ដូចជាបទដ្ឋានអនុវត្តបច្ចេកវិទ្យា។*

ឃ.ការពិនិត្យតាមដាន និងវាយតំលៃដោយមានការចូលរួម

*បានធ្វើការ តាមដាន និងវាយតំលៃពីការទទួលយក និងការសាយភាយបច្ចេកទេស និងព័ត៌មានកសិកម្ម ជាមួយកសិករនៅ ក្នុងខេត្ត គោលដៅនៃកម្មវិធីផ្សព្វផ្សាយកសិកម្ម។*

**៥.៦.៧.១.៣. ការអភិវឌ្ឍអង្គការកសិករ និងសហគមន៍កសិកម្ម**

ក. ការរៀបចំបង្កើតសហគមន៍កសិកម្ម

*ការរៀបចំសហគមន៍កសិកម្មមាន ផលប្រយោជន៍សំខាន់ក្នុងការ ផ្តល់អំណាចដល់កសិករ និងសហគមន៍កសិករ ក្នុងការសម្រេចចិត្ត និងការគ្រប់គ្រងដោយខ្លួនឯង លើការរៀបចំ ផែនការផលិតកម្មកសិកម្ម ការប្រមូលផ្តុំផលិតផល ការលក់ ផលិតផលក្នុងទីផ្សារ និងទទួលបាននូវសេវាគាំទ្រនានា មានសេវាបច្ចេកទេសកសិកម្ម ស្រោចស្រព ឥណទានជនបទ ទីផ្សារ ការធ្វើកសិ-ធុរៈកិច្ច សហគ្រាស ធុនតូច និងមធ្យម។ល។ នៅឆ្នាំ ២០១០ នេះ សហគមន៍កសិកម្មបានចុះបញ្ជីទទួលស្គាល់ផ្លូវការចំនួន ២១ និងសហគមន៍កសិកម្ម ចំនួន ២០ ទៀតកំពុងបំពេញបែបបទចុះបញ្ជីជាផ្លូវការពីមន្ទីរកសិកម្មខេត្ត។ ហើយជាសរុបមកដល់បច្ចុប្បន្ននេះមាន សហគមន៍កសិកម្ម បង្កើតជាផ្លូវការបាន ចំនួន ២០០ នៅក្នុង ២៣ ខេត្ត ដែលមាន សមាជិកជាង ២១ ពាន់នាក់ និងចំនួនភាគហ៊ុនជាង ៦៧ ពាន់ ដែលមានទុនសរុបជាង ២,២៨០ ពាន់លានរៀល។ សហគមន៍កសិកម្ម មាន ក្រុមប្រឹក្សាភិបាលសរុបចំនួន ៩១០ នាក់ និងគណៈត្រួតពិនិត្យ ៥៥០ នាក់។*

ខ. ការគាំទ្រសហគមន៍កសិកម្ម

*ជួយពង្រឹងសមត្ថភាពគ្រប់គ្រងដឹកនាំសហគមន៍ ការធ្វើផែនការផលិតកម្មអាជីវកម្ម និងធ្វើជំនួញ និងការគ្រប់គ្រងបញ្ជីគណនេយ្យ ដល់សហគមន៍សហគមន៍ ៣៤ សហគមន៍ ដែលមានថ្នាក់ដឹកនាំសហគមន៍ចូលរួមចំនួនសរុប ១១៥០ នាក់ មានស្ត្រី ៣២៨ នាក់។ ដោយសហការជាមួយសារជីវកម្មទេសចរណ៍ ណូគីយូ ជប៉ុន មានផ្តល់ម៉ាស៊ីនកិនស្រូវខ្នាតតូចដល់សហគមន៍កសិកម្ម ចំនួន ២០ គ្រឿង នៅក្នុងខេត្តចំនួន ១១។ បានគផ្តល់ទុនគាំទ្រសហគមន៍កសិកម្មចំនួន ១៥ ដែលមានថវិកាសរុប ៣០ លានរៀល។*

គ. ការតាំងពិព័ណ៌ផលិតផលសហគមន៍កសិកម្ម

*បានដឹកនាំសមាគមន៍កសិកម្មចំនួន ០៤ មកតាំងពិព័ណ៌ លក់ផលតផលកសិកម្ម ក្នុងការតាំង*

*ពិព័ណ៌ពាណិជ្ជកម្មស្តីពី ខេត្តមួយផលិតផលមួយ នៅមជ្ឈមណ្ឌលកោះពេជ្រ នាថ្ងៃទី ១៥-១៨ ខែធ្នូ ឆ្នាំ ២០១០ ដែលមានសហគមន៍កសិកម្មចំនួន ០៤ ចូលរួម មានសហគមន៍កសិកម្មម្រេច ខេត្តកំពត សហគមន៍ចំប៉ី និងសហគមន៍សែនព្រះរាម ខេត្តតាកែវ និងសហគមន៍ត្បូងក្រពើស្ទឹងសែន ខេត្តកំពង់ធំ។ បានសហការ ជាមួយសម្ព័ន្ធសហករណ៍កសិកម្មជប៉ុន យកផលិតផលកែច្នៃចំនួន របស់សហគមន៍កសិកម្មកម្ពុជា ទៅតាំងពិព័ណ និងតាំងលក់ នៅមជ្ឈមណ្ឌលតាំងពិព័ណ៌ផ្លាសានៅក្នុងយ៉ូកូហាម៉ា ប្រទេសជប៉ុន។*

ឃ. រៀបចំច្បាប់ និងលិខិតបទដ្ឋានច្បាប់

*បានរៀបចំប្រកាសស្តីពីលក្ខន្តិកៈគំរូ ពីការរៀបចំបុរេសហគមន៍កសិកម្ម និងសេចក្តីប្រកាសស្តីពីការរៀបចំសហភាពសហគមន៍កសិកម្ម។ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសហករណ៍កសិកម្ម និងគោលនយោបាយជាតិស្តីពីសហករណ៍កសិកម្ម។*

**៥.៦.៧.១.៤. ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានកសិកម្ម**

*មានគោលដៅជួយដល់កសិករ និងសហគមន៍កសិករ ក្នុងការបង្កើននូវបរិមាណ និងគុណភាពផលិតផលកសិកម្ម តាមរយៈបង្កើនការយល់ដឹង និងការទទួលបាននូវចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម ពីផលិតកម្មដំណាំ ដំណាំកៅស៊ូ ការចិញ្ចឹមសត្វ វារីវប្បកម្ម កេរ្សត្រ-រុក្ខកម្ម សួនដំណាំគ្រួសារ ការគ្រប់គ្រងធនធានធម្មជាតិ ដី ធនធានជលផល និងព្រៃឈើ)។ល។ សកម្មភាពសំខាន់មានៈ*

ក. កម្មវិធីកសិកម្មតាមទូរទស្សន៍ជាតិ

*បានរៀបចំឯកសារបច្ចេកទេស និងបទយកការណ៍ពីវិស័យកសិកម្ម ដែលចាក់ផ្សាយរៀងរាល់ថ្ងៃសៅរ៍វេលាម៉ោង ៦:៣០ នាទីដល់ម៉ោង ៧:០០ ព្រឹក ពីផលិតកម្មស្រូវ ដំណាំបន្លែ ដំណាំរួមផ្សំ ប្រព័ន្ធកសិកម្មចំរុះ បច្ចេកទេសក្រោយពេលប្រមូលផល ការអភិវឌ្ឍន៍ដំណាំកៅស៊ូ ការចិញ្ចឹមសត្វ វារីវប្បកម្ម សហគមន៍នេសាទ សហគមន៍ព្រៃឈើ និងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ (ធនធានជលផល និងព្រៃឈើ)។*

ខ. នាទីចុះស្រែជាមួយកសិករៈ

*បានរៀបចំកម្មវិធីចុះស្រែជាមួយកសិករ ដែលផ្សព្វផ្សាយរៀងរាល់ថ្ងៃព្រហស្បតិ៍ ពីបទពិសោធន៍កសិករឆ្នើមក្នុងផលិតកម្មកសិកម្ម ដំណាំបន្លែសុវត្ថិភាព វារីវប្បកម្មជាលក្ខណៈគ្រួសារ ផលិតកម្មស្រូវ ១០ពូជសម្រាប់នាំចេញ ការអភិវឌ្ឍន៍ដំណាំកៅស៊ូ ឡជីវឧស្ម័ន និងការប្រែប្រួលអាកាសធាតុ ការចិញ្ចឹមគោ-ក្របី និងការគ្រប់គ្រងជំងឺអុតក្តាម។*

គ. នាទីវេទិការស្វែងយល់ពីកសិកម្ម

*បានផលិត និងចាក់ផ្សាយតាមទូរទស្សន៍ជាតិពី ការអនុវត្តកសិកម្មល្អលើ ផលិតផលបន្លែ និងផ្លែឈើស្រស់ ការស្វែងយល់ពីដំណាំកៅស៊ូ វារីវប្បកម្ម ភ្នាក់ងារសុខភាពសត្វភូមិ និងការអភិវឌ្ឍន៍ ការចិញ្ចឹមសត្វ និងជីវសុវត្ថិភាព។*

ឃ.ផ្សព្វផ្សាយអត្ថបទបច្ចេកទេសកសិកម្មតាមវិទ្យុជាតិ

*បាន ៥២ អត្ថបទ ចាក់ផ្សាយចំនួន ១២៤ លើក រៀងរាល់ថ្ងៃច័ន្ទ និងថ្ងៃព្រហស្បតិ៍។*

ង. សហការជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាននានា

*សហការជាមួយវិទ្យុជាតិចូលរួមរៀបចំផលិត ឯកសារបច្ចេកទេស ក្នុងកម្មវិធីជីវិតយើងសង្គមយើង ជាមួយវិទ្យុ ជាមួយវិទ្យុ ១០១.២៥ FM ផ្សព្វផ្សាយពី បច្ចេកទេសកសិកម្ម ។*

ច. ការផលិត និងចែកចាយឯកសារផ្សព្វផ្សាយកសិកម្ម

*បោះពុម្ព និងចែកចាយទស្សនាវដ្តីកសិកម្ម ប្រចាំត្រីមាសទី១ ទី លេខ ២ ទី៣ និងទី ៤ ឆ្នាំ ២០១០ ចំនួន ៥២០០ ច្បាប់ និងទស្សនាវដ្តីសមិទ្ធផលកសិកម្មប្រចាំឆមាសទី ១ និងទី ២ ចំនួន ២៦០០ ច្បាប់ កូនសៀវភៅបច្ចេកទេសចំនួន ៣៥,០០០ ច្បាប់ និង ប៉ូស្ទ័រចំនួន ១៦,០០០ ច្បាប់។*

ឆ.ពិព័រណ៍ផលិតផលកសិកម្ម

*ចូលរួមរៀបចំពិព័រណ៍ផលិតផលនាំចេញ-នាំចូល និងខេត្តមួយផលិតផលមួយ លើកទី៥ ដោយសម្របសម្រួល ឱ្យសហគមន៍កសិកម្មចំនួន ៤ មកចូលរួមពិព័រណ៍ នៅមជ្ឈមណ្ឌលកោះពេជ្រ និងចូលរួមរៀបចំ ពិព័រណ៍ ផលិតផលកសិកម្មនៅប្រទេសចិន និងពិព័រណ៍ក្នុងបុណ្យជាតិនានា។*

៥.៦.៧.២-វាយតម្លៃ និងសំណើ

*សមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលធំៗជាច្រើន ជាមូលដ្ឋានគាំទ្រដល់ក្តីសង្ឃឹម និងលទ្ធភាពនៃការសម្រេចបាននូវចក្ខុវិស័យ គឺវិស័យកសិកម្មកម្ពុជាកំពុងតែមានការវិវត្តប្រកប ដោយអត្ថន័យទាំងបរិមាណ និងគុណភាព ជាពិសេសប្រជាកសិករកាន់តែមានសមត្ថភាពជានាបាននូវភាពម្ចាស់ការនៅក្នុងដំណើរការផលិតកម្ម ដោយសារការខិតខំរបស់រាជរដ្ឋាភិបាលដែលបាន និងកំពុងធ្វើឲ្យមានការរីកចម្រើនជាបណ្តើរៗ នូវមូលដ្ឋានបម្រើឱ្យផលិតកម្ម និងពាណិជ្ជកម្មសិកម្ម។ ទន្ទឹមនឹងនោះ ផ្សព្វផ្សាយពូជដំណាំមានគុណភាព បច្ចេកទេសដាំដុះ និងថែទាំដំណាំថ្មីៗ និងយន្តការសម្របសម្រួលទីផ្សារផលិតផលកសិកម្ម។ល។ ព្រមជាមួយគ្នានេះ ប្រជាកសិករក៏កំពុងតែមានការកែប្រែទម្លាប់ និងផ្នត់គំនិតជាបណ្តើរៗ ក្នុងការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្ម និងពិពិធកម្មដំណាំត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស*

៥.៦.៧.៣-វិធានការ

*-សិក្សាវាយតម្លៃ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ និងសេវាផ្សព្វផ្សាយកសិកម្មនៅកម្ពុជា*

*-បន្តពង្រីកការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្មស្រុក និងអ្នកផ្សព្វផ្សាយកសិកម្មឃុំ និងភូមិ*

*-បន្តរៀបចំទស្សនកិច្ចសិក្សាដល់កសិករ តំណាងសហគមន៍កសិកម្ម និងមន្ត្រីផ្សព្វផ្សាយកសិកម្ម*

*-បន្តរៀបចំ និងពង្រឹងការអភិវឌ្ឍន៍សហគមន៍កសិកម្ម ការរៀបរំ និងពង្រឹងសមត្ថភាពសហគមន៍ រៀបចំបណ្តាញធុរកិច្ចសហគមន៍កសិកម្ម និងបន្តរៀបចំច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ស្តីពី សហករណ៍កសិកម្ម*

*-រៀបចំសន្និបាតកសិករ និងសហគមន៍កសិកម្មទូទាំងប្រទេស*

*-បន្តរៀបចំពិព័រណ៍ផលិតផលកសិកម្ម សេវា និងឯកសារផ្សព្វផ្សាយកសិកម្ម*

*-បន្តការសិក្សាវាយតំលៃ និងវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យគ្រឹះ ពីប្រព័ន្ធកសិកម្ម ពង្រីកការអនុវត្តអភិវឌ្ឍន៍បច្ចេកទេសដោយមានការចូលរួម និងវិភាគសេដ្ឋកិច្ចប្រព័ន្ធ កសិកម្ម*

*-បន្តពង្រឹង និងពង្រីកការអប់រំ និងផ្សព្វផ្សាយកសិកម្មតាមរយៈ ការរៀបចំ និងចែកចាយឯកសារផ្សព្វផ្សាយ កសិកម្ម និងទស្សនាវដ្តីកសិកម្ម កម្មវិធីកសិកម្មតាមទូរទស្សន៍ និងវិទ្យុជាតិរៀបចំនាទីចុះស្រែជាមួយកសិករ វេទិកាស្វែងពីកសិកម្ម និងការផ្សព្វផ្សាយព័ត៌មានកសិកម្មតាមបណ្តាញផ្សព្វផ្សាយនានា។*

## ៥.៦.៨-ការងារគ្រឿងយន្តកសិកម្ម (ឧបសម្ព័ន្ធទី ៤២-៤៤)

ក្នុងឆ្នាំ២០១០ ដោយការគាំទ្រពង្រឹងសេវាកម្មគ្រឿងយន្តកសិកម្មចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងដំណើរការប្រពលវប្បកម្មឆ្ពោះទៅបង្កើនផលិតភាព និងគុណភាពកសិកម្ម និងកាត់បន្ថយការបាត់បង់។ នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានិយមការប្រើប្រាស់គ្រឿងយន្តកសិកម្ម កំពុងមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពី ដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា ។

### ៥.៦.៨.១-លទ្ធផល

**ក- ស្ថានភាពគ្រឿងយន្តកសិកម្ម ៖**

ក្នុងឆ្នាំ ២០១០នេះ ស្ថិតិគ្រឿងយន្តកសិកម្ម សរុបបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជាមានដូចខាងក្រោម៖

-ត្រាក់ទ័រចំនួន ៦២០០គ្រឿង កើនលើសឆ្នាំ ២០០៩ចំនួន ៥០៥គ្រឿង

-គោយន្តចំនួន ៦៦.៥៤៨គ្រឿង កើនលើសឆ្នាំ ២០០៩ ចំនួន ១៣.៣២៨គ្រឿង

-ម៉ាស៊ីនបូមទឹកចំនួន ១៦៦.៦៣៣គ្រឿង កើនលើសឆ្នាំ ២០០៩ ចំនួន ១៦៥៩គ្រឿង

-ម៉ាស៊ីនច្រូតចំនួន៩៤៧គ្រឿង ម៉ាស៊ីនបោក និងបូតស្រូវចំនួន ១៤.៣៩០គ្រឿង

-ម៉ាស៊ីនកិនស្រូវចំនួន ៤៨.២១៧គ្រឿង កើនលើសឆ្នាំ ២០០៩ ចំនួន ៥៩៧គ្រឿង។

**ខ. ការងារបច្ចេកទេសផលិតកែច្នៃ និងការផលិត**

ឆ្នាំ ២០១០ នេះ ដើម្បីចូលរួមចំណែកបង្កើនផលិតភាពកសិកម្ម តាមរយៈការប្រើប្រាស់គ្រឿងយន្ត និងឧបករណ៍កសិកម្ម នាយកដ្ឋានគ្រឿងយន្តកសិកម្ម ខិតខំជំរុញការងារយ៉ាងសកម្មសិក្សាស្រាវជ្រាវ កែច្នៃ ផលិត និងផ្សព្វផ្សាយដល់ប្រជាកសិករទូទាំងប្រទេស ដោយសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

-បានផលិតឧបករណ៍សំអាតស្មៅ និងជ្រួយដី រ៉ូឡូស៊ីឡាំងដែកបន្ទះបានចំនួន ៥៩គ្រឿង

-បានផលិតត្បាល់បក់ស្រូវប្រើអាគុយចំនួន ០៤គ្រឿង

-បានកែច្នៃផលិតឧបករណ៍អូសដាំស្រូវជាជួរចំនួន ០១គ្រឿង។

**គ. ការផ្ទេរបច្ចេកវិទ្យាគ្រឿងយន្តកសិកម្ម**

-បានដំណើរការបើកវគ្គបំពាក់បំប៉នអំពី ការប្រើប្រាស់ ថែទាំ និងជួសជុល ការបាត់បង់ក្រោយប្រមូលផល ការធ្វើបង្ហាញអំពីការរៀបចំដី និងប្រមូលផល បានចំនួន ៤០វគ្គ មានកសិករចូលរួមសរុបចំនួន ៩១៣នាក់

-បានអនុវត្តការងារអន្តរាគមន៍ស្តារប្រឡាយសរុបចំនួន ៨.៣៣៨ម៉ែត្រ ក្នុងនោះ ៖ ស្រុកអង្គរជ័យ ខេត្តកំពតចំនួន ៥.៣៣៨ម ខេត្តព្រៃវែងចំនួន ៣០០០ម

-បានឈូសពង្រាបខ្នងទំនប់ប្រវែង ៦០០០ម នៅខេត្តព្រៃវែង និងបានភ្ជួររាស់ដីជូនយុទ្ធជនពិការតាកែនកោះស្លាចំនួន ២៤៥ ហិកតា

-បានជួសជុល និងដាក់ឲ្យដំណើរការឡើងវិញម៉ាស៊ីនបូមទឹកស្ថានីយ៍ពោធិលាស់ចំនួន ០២គ្រឿង។

### ៥.៦.៨.២-វាយតម្លៃ និងសំណើ

ជារួមការអនុវត្តន៍រាល់សកម្មភាពការងារក្នុងវិស័យគ្រឿងយន្ត ឃើញមានការប្រែប្រួលល្អប្រសើរដោយប្រជាកសិករមានការនិយមប្រើប្រាស់នូវ គ្រឿងយន្ត-ឧបករណ៍កសិកម្មខ្នាតតូច ក៏ដូចជាមានការ

ចូលរួមពីឯកជន ក្នុងការផលិតកែច្នៃបំពេញនូវសេចក្តីត្រូវការសមស្របទៅនឹងតំបន់ផលិតកម្ម ក្នុងនោះ ការទទួលយកនូវបច្ចេកវិជ្ជា វិស័យគ្រឿងយន្ត គឺ ៖

- ពង្រឹងការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម
- ពង្រីកការអភិវឌ្ឍន៍ និងការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម

៥.៦.៨.៣-វិធានការ

-ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យគ្រឿងយន្តកសិកម្មខេត្ត-ក្រុង និងរៀបចំផែនការដាក់ឱ្យផ្នែកនេះ ដំណើរការបានល្អប្រសើរឡើងវិញ ដោយត្រូវបង្កើនកិច្ចសហការជាមួយដៃ គូអភិវឌ្ឍនានា រួមទាំងវិស័យ ឯកជនផង ដើម្បីអភិវឌ្ឍយន្តូបនីយកម្មកសិកម្ម នៅកម្ពុជាឲ្យមានប្រសិទ្ធភាព និងចីរភាព

-ត្រូវរៀបចំនូវបណ្តាញការងារគ្រឿងយន្តកសិកម្ម រវាងកសិករដែលជាអ្នកប្រើប្រាស់ និងអ្នកលក់ ឬសិប្បកម្មផលិត ឬកែច្នៃគ្រឿងយន្តទាំងនោះឲ្យមាននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

-ត្រូវរៀបចំឲ្យមានជាទស្សនកិច្ចសិក្សា និងសហប្រតិបត្តិការបច្ចេកទេសជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ផងដែរ ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ ។

## ៥.៦.៩-ការងារកសិ-ឧស្សាហកម្ម

៥.៦.៩.១-លទ្ធផល

ក- ការងារផែនការ និងគណនេយ្យ

- បានរៀបចំសេចក្តីព្រាងផែនការសកម្មភាព ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជ-រដ្ឋាភិបាលដំណាក់កាលទី ២ (២០០៩-២០១៣) បានរៀបចំបញ្ចូនគម្រោងផែនការសកម្មភាពមេគង្គ-ជប៉ុន

- បានរៀបចំគម្រោងវិនិយោគសាធារណៈ ០៣ ឆ្នាំ រំកិល ២០១០-២០១៣ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពី ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាលសម្រាប់ការកែច្នៃកសិផល និងបច្ចេកទេសក្រោយប្រមូលផល

- បានធ្វើរបាយការណ៍ចំណូលចំណាយថវិការដ្ឋរបស់នាយកដ្ឋានប្រចាំឆ្នាំ ២០១០ សរុបចំនួន ៦១៨.៨២៦.៧១៩ ៛ ក្នុងនោះ ៖

  - ថវិកាតាមកម្មវិធី ចំនួន ៣១៩.៥៧៦.០០០ ៛
  - ថវិកាមិនមែនកម្មវិធី ចំនួន ២៩៩.២៥០.៧១៩ ៛។

ខ- ការងារអនុវត្តន៏គម្រោង

អនុវត្តកម្មវិធីទី ២ ជម្រុញការនាំចូលទីផ្សារនៃផលិតផលកសិកម្មសម្រាប់ឆ្នាំ ២០១០ រួមមានអនុកម្មវិធីចំនួន ០៣ ដោយចំណាយថវិការដ្ឋសរុបចំនួន ៣១៩.៥៧៦.០០០៛ ក្នុងនោះ៖

-អនុកម្មវិធីទី ១ ការបណ្តុះបណ្តាលកសិករអំពី " ការកែច្នៃ និងផ្សំចំណីសត្វ" ដោយអនុវត្តក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០ នាក់ ចំណាយថវិការដ្ឋអស់ ១០៩.១៩០០០៛

-អនុកម្មវិធីទី ៤ ការបណ្តុះបណ្តាលកសិករសហគមន៍អភិវឌ្ឍន៍កសិកម្មអំពី " ការផលិតផលតាមកិច្ចសន្យា" ដោយអនុវត្តន៍ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០នាក់ ចំណាយថវិកា រដ្ឋអស់ ១១១.១៥០.០០០៛

-អនុកម្មវិធីទី ៥ "បង្កើនការយល់ដឹង និងការលើកកម្ពស់ស្តង់ដាគុណភាព សុវត្ថិភាព និងការចេញវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលកសិកម្ម" សរុបចំនួន ៣៩០នាក់ ចំណាយថវិការដ្ឋអស់ ៩៩.២៣៦.០០០៛។

គ- ការងារនីតិកម្ម

-បានកំពុងប្រមូលទិន្នន័យ និងឯកសារពាក់ព័ន្ធ ដើម្បីត្រៀមរៀបចំធ្វើសេចក្តីព្រាងអនុក្រិត្យ ឬច្បាប់ស្តីពី " គុណភាពសុវត្ថិភាព ផលិតផលកសិកម្ម"

-បានត្រៀមរៀបចំតាក់តែងសេចក្តីព្រាងប្រកាសស្តីពី " ការគ្រប់គ្រង និងប្រមូលទិន្នន័យស្ថិតិសហគ្រាសធុនតូច និងមធ្យមវិស័យកសិកម្ម"

-បានចូលរួមប្រជុំជាបន្តបន្ទាប់ លើសេចក្តីព្រាងអនុក្រឹត្យស្តីពី " ផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅថ្នាក់ក្រសួងទីស្តីការគណៈរដ្ឋមន្ត្រី រហូតដល់សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ព្រមទាំងទទួលការអនុម័ត នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ និងបានចុះហត្ថលេខាដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចេញជាអនុក្រឹត្យនាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

ឃ- ការងារដីសម្បទានសេដ្ឋកិច្ច:

-បានទទួលរបាយការណ៍ស្តីពី " សកម្មភាព នៃការអនុវត្តរបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ពីមន្ទីរកសិកម្មខេត្ត ស្ទឹងត្រែង កំពង់ធំ កំពង់ឆ្នាំង ពោធិសាត់ ក្រចេះ កំពត កំពង់ចាម សៀមរាប និងខេត្តព្រះសីហនុ

-ក្រុមការងារនាយកដ្ឋានកសិ-ឧស្សាហកម្មបានចុះត្រួតពិនិត្យវាយតម្លៃការអនុវត្តន៍ របស់ក្រុមហ៊ុនដីសម្បទានដីសេដ្ឋកិច្ចដល់ទីវាលក្នុងខេត្ត សៀមរាប ព្រះវិហារ ឧត្តរមានជ័យ រតនៈគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ កំពង់ចាម ស្វាយរៀង បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ធំ

-បានចូលរួមប្រជុំឆ្លងរបាយការណ៍ស្តីពី ការចុះពិនិត្យការងារសកម្មភាព របស់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច នៅតាមបណ្តាខេត្តចំនួន ០៨ ដូចជា កំពង់ស្ពឺ ព្រះសីហនុ កំពត កោះកុង ព្រះវិហារ សៀមរាប រតនគិរី និងស្ទឹងត្រែង

-បានចូលរួមសហការជាមួយមន្ត្រី និងថ្នាក់ដឹកនាំក្រសួងកសិកម្ម ដើម្បីត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត កំពង់ធំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ រតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ កំពង់ចាម បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រះសីហនុ និងខេត្តកោះកុង។

ង- ការងារកសិកម្ម និងកសិ-ឧស្សាហកម្ម:

-បានសម្របសម្រួល និងផ្ញើរបាយការណ៍ជូនក្រសួង នាកិច្ចប្រជុំថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០១០ របស់ក្រុមការងារផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម

-បានចូលរួមប្រជុំពិភាក្សាលើការរៀបចំកម្មវិធី Proposal Agenda (G-PSF) សម្រាប់កិច្ចប្រជុំក្រុមការងារកសិកម្ម កសិ-ឧស្សាហកម្មឆ្នាំ ២០១១

ច- ការងារសហប្រតិបត្តិការអន្តរជាតិ:

ក្នុងឆ្នាំ ២០១០ កន្លងមកនេះនាយកដ្ឋានកសិ-ឧស្សាហកម្ម បានធ្វើការសហការជា មួយអង្គការ និងបណ្តាប្រទេសអន្តរជាតិដូចជា:

-អង្គការ FAO បានសហការលើការរៀបចំផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាកម្មរយៈពេល ០៥ ឆ្នាំ (២០១១-២០១៥) ក្នុងនោះក៏បានរៀបចំជា Road Map សម្រាប់សកម្មភាពលម្អិតរយៈពេល ០២ ឆ្នាំ ដោយបានបញ្ចប់ចេញជាសេចក្តីព្រាងចុងក្រោយដាក់ជូន អង្គការ FAO នៅចុងខែ វិច្ឆិកា ឆ្នាំ ២០១០

-អង្គការ UNIDO បានសហការលើការងារស្រាវជ្រាវការបាត់បង់ក្រោយពេលប្រមូលផល នៃផលិតផលកសិកម្ម នៅតាមបណ្តាខេត្តសំខាន់ៗ ដូចជា ខេត្ត បាត់ដំបង កំពង់ចាម ប៉ៃលិន បន្ទាយមានជ័យ និងខេត្តកំពង់ធំ ជាដើម។

៥.៦.៩.២- វាយតម្លៃ និងសំណើ

-ឆ្លងតាមលទ្ធផលជាក់ស្តែងកសិ-ឧស្សាហកម្ម សម្រេចបានតាមរយៈពេលកន្លងមកនេះ បានបង្ហាញឱ្យឃើញនូវកិច្ចសហការការងារល្អ និងសកម្មភាពចូលរួមបំពេញភារៈកិច្ចគ្រប់ផ្នែកជំនាញ ដោយជំហរទទួលខុសត្រូវខ្ពស់ ដែលជាចលករនាំឱ្យយើងមានសង្ឃឹម និងជឿជាក់ថាទៅថ្ងៃមុខយើងនឹងអាចទទួលបាននូវលទ្ធផលល្អជាវិជ្ជមានថ្មីៗថែមទៀត

-ត្រូវរកដីប្រមាណពី ២០ ទៅ ៥០ ហិកតា ដើម្បីរៀបចំបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវបណ្តុះបណ្តាល វិស័យកសិ-ឧស្សាហកម្ម

-ពិនិត្យលទ្ធភាពដោយសហការជាមួយ អង្គការអន្តរជាតិ ឬផ្នែកឯកជន ដើម្បីបង្កើតមន្ទីរពិសោធន៍ជាតិ សម្រាប់វិភាគផលិតផលកសិកម្ម និងកសិ-ម្ហូបអាហារ។

៥.៦.៩.៣- វិធានការ

-ពិចារណាធ្វើការបង្កើតការិយាល័យពាក់ព័ន្ធ ទៅនឹងការងារបច្ចេកវិទ្យាក្រោយពេលប្រមូលផល វេចខ្ចប់ និងរក្សាទុក (Post harvest Technology, Packaging and Storage)

-ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យកសិ-ឧស្សាហកម្ម និងមន្ត្រីកសិ-ឧស្សាហកម្មខេត្តនានា ដើម្បីឱ្យមន្ត្រីតាមមូលដ្ឋានធ្វើសកម្មភាពក្នុងតួនាទីរបស់ខ្លួន ពិសេសលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃដំណើរការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ទូទាំងព្រះរាជាណាចក្រកម្ពុជា

-បង្កើនកិច្ចសហប្រតិបត្តិការជាមួយសប្បុរសជន អង្គការអន្តរជាតិ ស្ថាប័នឯកជន ដើម្បីស្វែងរកការគាំទ្រទាំងថវិកា និងបច្ចេកទេស។

## ៥.៦.១០-ការងារយេនឌ័រ

អនុលោមតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានលើកឡើងជាគន្លឹះ "**ដើម្បីស្ត្រី**" ទន្ទឹមនឹងនោះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពក្រោមឱវាទជាសេនាធិការ បានខិតខំប្រឹងប្រែង អនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ទទួលបានស្នាដៃ និងជោគជ័យល្អប្រសើរគួរជាទីមោទនៈ។

៥.៦.១០.១-លទ្ធផល

ក.ការបណ្តុះបណ្តាល

បានបើកវគ្គបណ្តុះបណ្តាលចំណេះដឹងយេនឌ័រ ដល់មន្ត្រីរាជការថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត ក្រោមឱវាទបានចំនួន ១១ វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៥៧៤នាក់ ក្នុងនោះមានស្ត្រីចំនួន ១០៦ នាក់។

ក្រៅពីនេះ បានបញ្ចូលកម្មវិធីបណ្តុះបណ្តាល ស្តីពីចំណេះដឹងយេនឌ័រទៅក្នុង កម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលរបស់គ្រឹះស្ថានបណ្តុះបណ្តាលកសិកម្មទាំង៣គឺ កលវិទ្យាល័យភូមិន្ទកសិកម្មសាលា

ជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាមផងដែរ។ ក្នុងនោះសាកលវិទ្យាល័យភូមិន្ទកសិកម្មបានបញ្ចូលមុខវិជ្ជាយេនឌ័រ ក្នុងវិស័យកសិកម្ម សម្រាប់ថ្នាក់បរិញ្ញាប័ត្រវង់ផ្សព្វផ្សាយកសិកម្មនៅភ្នំពេញ និងនៅសាខាខេត្តបាត់ដំបង និងថ្នាក់បរិញ្ញា ប័ត្រ បច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម។

ទន្ទឹមនឹងនោះ បានបណ្តុះបណ្តាលចំណេះដឹងជំនាញបច្ចេកទេសដល់មន្ត្រីរាជការដូចជា៖

-ក្នុងប្រទេសរយៈពេលខ្លីបានចំនួន ៤២ នាក់ ជានារី ០៧ នាក់ វគ្គវិក្រិត្យការ មន្ត្រីជាន់ខ្ពស់ចំនួន ០២នាក់ និងមន្ត្រីមធ្យមចំនួន ០១នាក់

-ក្រៅប្រទេសថ្នាក់បណ្ឌិតបាន ០២នាក់ ថ្នាក់អនុបណ្ឌិតបានចំនួន ១១នាក់ ក្នុងនោះ ជាស្ត្រី ចំនួន ០១នាក់ និងការបណ្តុះបណ្តាលរយៈពេលខ្លីបានចំនួន១០២នាក់ ក្នុងនោះជាស្ត្រីបានចំនួន ១៦នាក់។

**ខ-ការងារចាត់តាំង:**

បានចេញប្រកាសតែងតាំងចំនួន ១១ លេខ មានមន្ត្រីសរុបចំនួន ៦៨នាក់ ក្នុងនោះ មានស្ត្រីចំនួន០៥នាក់ ។

-អង្គភាពថ្នាក់កណ្តាលមានចំនួន៤៤នាក់ ជាស្ត្រីចំនួន០៣នាក់ ដែលបានតែងតាំង

- តម្លើងថ្នាក់អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មចំនួន០១នាក់
- តម្លើងថ្នាក់ប្រធាននាយកដ្ឋានចំនួន០២នាក់ និង អនុប្រធាន នាយកដ្ឋានចំនួន១៤នាក់
- តម្លើងថ្នាក់ប្រធានការិយាល័យចំនួន ១០នាក់ ជានារីចំនួន ០១នាក់ និងថ្នាក់អនុប្រធានការិយាល័យចំនួន ១៤នាក់ ជានារីបានចំនួន០២នាក់។

-អង្គភាពថ្នាក់មូលដ្ឋានរាជធានី ខេត្ត មានចំនួន០៨នាក់ ក្នុងនោះ មានស្ត្រីចំនួន០២នាក់ ដែលបានតែងតាំង

- តម្លើងថ្នាក់ប្រធានការិយាល័យចំនួន០៣នាក់ ជានារី០៣នាក់ និងថ្នាក់អនុការិយាល័យចំនួន០៣នាក់
- តម្លើងថ្នាក់ប្រធានការិយាល័យកសិកម្មស្រុកបានចំនួន០២ នាក់ជានារី ០១នាក់

**គ-ការងារសហប្រតិបត្តិការ:**

- បានខិតខំសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីជំរុញឱ្យដំណើរការផលិតកម្ម និងអាជីវកម្មកសិកម្មបានលទ្ធផលល្អតាមរយៈការពង្រីកមុខរបរបន្ថែម ប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទសេដ្ឋកិច្ចទីផ្សារសេរីឆ្ពោះទៅរកភាពជឿនលឿន ក៏ដូចជា ក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ច ពិភពលោកដែលរាជរដ្ឋាភិបាល នៅតែចាត់ទុកថាវិស័យកសិកម្ម ជាវិស័យដែលមានអាទិភាពនឹងមានសារសំខាន់ជាងគេ ក្នុងការលើកកម្ពស់ជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ជាពិសេសការកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គមកម្ពុជាទាំងមូល។

-បានចូលរួមយ៉ាងសកម្មក្នុងការធ្វើបទបង្ហាញអំពីបទពិសោធន៍ របស់ខ្លួនក៏ដូចជាការចូលរួមប្រជុំផ្សេងៗ តាមការអញ្ជើញរបស់ក្រសួងកិច្ចការនារី អន្តរក្រសួង និងការស្នើសុំពីបណ្តាអង្គភាពនានាក្រោមឱវាទ។ ជាពិសេសគ្រប់គម្រោងសហប្រតិបត្តិការទាំងអស់ ដែលកំពុងអនុវត្តបច្ចុប្បន្ននៅក្នុងវិស័យកសិកម្ម តាមអនុវិស័យនានាមិនដែលរំលងអំពី ការបញ្ចូលសកម្មភាពយេនឌ័រទៅក្នុង ផែនការសកម្មភាពរបស់ខ្លួនឡើយដូចជា នៅក្នុងគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយ ADB, IFAD, FAO, ECOSORN ជាដើម..។ល។

-បានសហការជាមួយគណៈកម្មការជាតិទន្លេមេគង្គកម្ពុជា ក្នុងការរៀបចំផែនការការងារយេនឌ័រ ក្នុងវិស័យគ្រប់គ្រងធនធានទឹក និងធនធានធម្មជាតិ។

- បានទទួលជួបតំណាងអង្គការអន្តរជាតិ ដែលមានបំណងស្វែងយល់អំពីការចូលរួម របស់ស្ត្រីក្នុងវិស័យកសិកម្ម។

**ឃ-ការងារចូលរួមសហគមន៍**

-បច្ចុប្បន្នមានសហគមន៍អភិវឌ្ឍន៍កសិកម្មនៅកម្ពុជាសរុបចំនួន ១១២ សហគមន៍ ដែលមានសមាជិកសរុបចំនួន ៨.៦២៨ នាក់ ក្នុងនោះមានស្ត្រីចូលរួមប្រមាណ ១.៨៨៩ នាក់ (ប្រហែល ២៥ ភាគរយ) ដែលមានទីតាំងក្នុង ២១រាជធានី-ខេត្ត។

-មានស្ត្រីជាច្រើនបានចូលរួមក្នុងគំរោង FAO-IPM របស់អគ្គនាយកដ្ឋានកសិកម្ម ដោយបានបើកវគ្គបណ្តុះបណ្តាលកសិករលើមុខជំនាញដំណាំស្រូវ បន្លែ ពោត ឪឡឹក សណ្តែកបាយ និងប្រព័ន្ធកសិកម្មចម្រុះដោយមានកសិករ ចូលរួមចំនួន ១៥០.១១៣ នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៣.១៥៤ នាក់ ស្មើនឹង ៤២.០៧ ភាគរយ។ ជាមួយនេះក្រុមការងារយេនឌ័រ នៃក្រសួងបានចលនានារីឱ្យចូលរួមក្នុងកម្មវិធីចុះស្រែជាមួយកសិករ ដោយបានចុះជួយច្រូតស្រូវជូនកសិករចំនួន ០៣លើក និងមាននារីចូលរួមប្រមាណ ២០០ នាក់ ក្នុង០១លើក។

-បានសហការជាមួយគំរោង ពង្រឹងសមត្ថភាព និងបញ្ញាបការគ្រប់គ្រងដីធ្លីដោយចេរភាពនៅកម្ពុជា (SLMP) ក្នុងគោលបំណងផ្តល់ចំណេះដឹងដល់ស្ត្រីជនបទ លើការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាពក្នុងផលិតកម្មកសិកម្ម។

-បានសហការជាមួយគំរោង ព័ត៌មានទីផ្សារកសិកម្ម (CAMIP) ក្នុងគោលបំណងឱ្យស្ត្រីជនបទ និងស្ត្រីជាអាជីវករលក់ដុំ និងលក់រាយនូវផលិតផលកសិកម្ម ទទួលបាននូវព័ត៌មាននៃតំលៃផលិតផលកសិកម្មដោយមានកសិករសរុបចំនួន ១.៣៣៥ នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៥៤ នាក់ និងអាជីវករសរុបចំនួន ៣៣៨នាក់ ក្នុងនោះមានស្ត្រី ២០៥ នាក់។ ក្រៅពីនេះ ក៏បានធ្វើការ បណ្តុះបណ្តាលចំណេះដឹងយេនឌ័រក្នុងព័ត៌មានទីផ្សារកសិកម្ម ដល់មន្ត្រីពាក់ព័ន្ធបានចំនួនសរុប ១៤ នាក់ ក្នុងនោះមាន ស្ត្រី ៨ នាក់។

-សហគមន៍នេសាទចំនួន ៤៦៩សហគមន៍ ដែលមានទីតាំងនៅតាមរាជធានី ខេត្តចំនួន ២១ រួមមានកន្លែងអភិរក្សចំនួន ២៤៩ កន្លែង តាមរាជធានី-ខេត្ត ចំនួន ១៨ មានប្រជាពលរដ្ឋសរុបចំនួន ១២៦.៤៩០ គ្រួសារ ដែលមានសមាជិកសរុបចំនួន ២៧៧.០៤៤នាក់ ក្នុងនោះមានស្ត្រីចំនួន ១០០.៥៣៨នាក់ (៣៦%) ចូលរួមផងដែរ។

-សហគមន៍ព្រៃឈើនៅទូទាំងប្រទេសមានចំនួន ៤២៨ គ្របដណ្តប់លើផ្ទៃដីព្រៃឈើចំនួន ៣៨០.៨៩៧ ហិកតា ដែលស្ថិតនៅក្នុង ២០ ខេត្ត ៨០ ស្រុក ១៩៤ ឃុំ ៧០៧ ភូមិ និង៩១ស្រុក ២៤៦ឃុំ ៧៥៤ភូមិ និងមានការចូលរួមពីប្រជាជនចំនួន ១១៤.១៣៩គ្រួសារ ដែលមានសមាជិកសរុបចំនួន ៣២១.៧០១នាក់ ក្នុងនោះស្ត្រីចំនួន ១៥៥.១០៨នាក់ ស្មើនិង ៤៨.២១ភាគរយ។ ជារួមសហគមន៍ព្រៃឈើមានការរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំ គឺនៅឆ្នាំ ២០០៤ មានសហគមន៍ព្រៃឈើចំនួន ២៦៤ នៅឆ្នាំ ២០០៨ មាន ៣៦០ សហគមន៍ និងឆ្នាំ ២០១០ មានដល់ទៅ ៤២៨ សហគមន៍។

-សហគមន៍ព្រៃឈើចំនួន ១២៤ មានផ្ទៃដីចំនួន ១៤៥.០៣៩ ហ.ត ស្ថិតនៅក្នុង ០៩ ខេត្ត ២៧ ស្រុក ៦៥ ឃុំ ២៣៤ ភូមិ ដែលទទួលស្គាល់ពីប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយមានការចូលរួមពីប្រជាជន ចំនួន ៣៣.៦៩៦ គ្រួសារ។

**៤.៦.១០.២-វាយតម្លៃ និងសំណើ**

គោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មកំពុងដំណើរការអនុវត្តកិច្ចការរបស់ខ្លួនឆ្ពោះទៅរកសមភាពយេនឌ័រ ដោយផ្តោតគោលដៅទៅលើស្ត្រី និងបុរសជាពិសេសទៅលើស្ត្រីក្នុងន័យធ្វើយ៉ាងណាឱ្យមានតុល្យភាពនៃការចូល រួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌។ បច្ចុប្បន្ននេះ ក្រុមការងារយេនឌ័របានអនុវត្តសកម្មភាព បញ្ជ្រាបចំណេះដឹងយេនឌ័រជូនមន្ត្រីរាជការគ្រប់កំរិតតាមទិសដៅទី១នៃគោលនយោបាយបានប្រមាណជា ៧៦ ភាគរយនៃផែនការ ដែលបានគ្រោងទុក ជាពិសេសដោយអនុលោមតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាននិងកំពុងតែបន្តបញ្ជ្រាបនូវសកម្មភាពយេនឌ័រតាមគ្រប់រូបភាពតាមអនុវិស័យនីមួយៗ ក្នុងន័យចូលរួមបង្កើនផលិតភាពកសិកម្មពិពិធកម្មរូបនីយកម្មកសិកម្ម ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋតាមទិសដៅអភិវឌ្ឍសហសវត្សរ៍នៅកម្ពុជា។

**៤.៦.១០.៣-វិធានការ**

-បន្តអនុវត្តទិសដៅទាំង ៤ នៃគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឱ្យទទួលបាន លទ្ធផលល្អប្រសើរតាមផែនការតំណាក់កាលទី២ឆ្នាំ២០១០-២០១៣ និងបន្តកិច្ចសហការល្អរវាងអង្គភាពយេនឌ័រ និងគម្រោងអភិវឌ្ឍន៍នានា ក្នុងការបញ្ជ្រាបសកម្មភាពយេនឌ័ររទៅ ក្នុងវិស័យកសិកម្មតាមគ្រប់រូបភាព

-បន្តអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួង ដោយជំរុញអង្គភាពជំនាញពាក់ព័ន្ធ និងមន្ទីរកសិកម្ម រាជធានី ខេត្តឱ្យខិតខំជំរុញនិងបង្កើនផលិតភាពកសិកម្ម ដោយណែនាំឱ្យកសិករចេះធ្វើប្រពលវប្បកម្មនិងពិពិធកម្មកសិកម្ម ការចិញ្ចឹមសត្វ វារីវប្បកម្ម ការគ្រប់គ្រងទឹក កសិ-រុក្ខកម្ម ការគ្រប់គ្រងអភិវឌ្ឍធនធានជលផល និងអនុផលព្រៃឈើដែលបម្រើឱ្យវិស័យស្បៀង និងអាហារូបត្ថម្ភ

-បន្តកិច្ចសហការជាមួយអង្គការជាតិ អន្តរជាតិ ក្រសួងស្ថាប័ន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បី លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្មស្របទៅតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍសហសវត្សរ៍នៅកម្ពុជា

-យកចិត្តទុកដាក់ប្រើប្រាស់កម្លាំងយុវនារី និងយុវជននៅមូលដ្ឋាន ដែលកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការងារផលិតកម្មកសិកម្ម និងអនុវត្តតាមអនុសាសន៍ទាំង ១៣ ចំណុចរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

-បន្តពង្រឹងពង្រីកការងារសង្គមដោយមានការចូលរួមពីយេនឌ័រឱ្យបានទូលំទូលាយ។

## ៥.៧- ធនធានមនុស្ស និងថវិកា

### ៥.៧.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

**៥.៧.១.១-លទ្ធផល**

ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធិភាព

ការងារប្រកបដោយសមធម៌ និងជាគោលដៅចម្បង ក្នុងការលើកស្ទួយសមត្ថភាពធនធានមនុស្ស ស្រប តាមជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយការអភិវឌ្ឍន៍ប្រទេស ដែលជាជ្រុងមួយ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ បានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាន មនុស្សមានជាអាទិ៍ ការងារគ្រប់គ្រងមន្ត្រីរាជការ ការងាររៀបចំមន្ត្រីកាន់មុខតំណែង ការងាររៀបចំស្នើសុំគ្រឿងឥស្សរិយយស ការងាររៀបចំបៀវត្ស និងប្រាក់ធានារ៉ាប់រងសង្គម ការងាររៀបចំតម្លើងកាំបៀវត្ស ការងាររៀបចំដាក់មន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ និងការងារអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យស្របទៅតាម គោលការណ៍ច្បាប់ និងលិខិតបទដ្ឋាននានា។

បច្ចុប្បន្នដំណើរការផលិតកម្មកសិកម្ម បានកំពុងវិវឌ្ឍន៍តាមរបត់នៃទីផ្សារសេរី ដូចនេះ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចនៃអង្គភាពនីមួយៗ ចាំបាច់ត្រូវតែកែលំអឱ្យសមស្របតាមសភាពការណ៍ជាក់ស្តែង។ វិស័យកសិកម្មអាចអភិវឌ្ឍន៍ទៅបានគឺ តម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងធនធានមនុស្សមាន សមត្ថភាពសមស្រប នៅតាមបណ្តាលអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៧,១៤៥ នាក់ នារីចំនួន ១,១៩៣ នាក់ ស្មើនឹង ១៦.៦៩% ក្នុងនោះ អង្គភាពថ្នាក់កណ្តាលមានចំនួន ៤.២៩៨ នាក់ នារីចំនួន ៦៨៣ នាក់ ស្មើនឹង ១៥.៨៩% និងអង្គភាពថ្នាក់រាជធានី ខេត្ត មានចំនួន ២,៨៤៧ នាក់ នារីចំនួន ៥១០នាក់ ស្មើនឹង ១៨.០៤%។

ដើម្បីពង្រឹងការងារគ្រប់គ្រង និងដឹកនាំនៅតាមបណ្តាអង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការ តែងតាំង ផ្ទេរសម្រួលភារកិច្ច និងផ្អាកមុខតំណែងមន្ត្រីរាជការចំនួន ៦៨នាក់ ក្នុងនោះ មន្ត្រីរាជការនារី ចំនួន ៥នាក់ ត្រូវបានតែងតាំងជាថ្នាក់ដឹកនាំការិយាល័យ។

ក្នុងការបំពេញបន្ថែមក្របខណ្ឌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែងទទួលក្របខណ្ឌថ្មី ពីរាជរដ្ឋាភិបាលជារៀងរាល់ឆ្នាំ លើកលែងតែឆ្នាំ ២០១០ ដែលត្រូវបានបង្កក។ ក្នុងឆ្នាំ ២០១០ ក្រសួងបាន បែងចែកមន្ត្រីក្របខណ្ឌថ្មីដែលបានជ្រើសរើសនៅក្នុងឆ្នាំ ២០០៩ ចំនួន ១៨០នាក់ ឱ្យទៅបម្រើការងារ នៅតាមអង្គភាពក្រោមឱវាទក្រសួង ដើម្បីជំនួសឱ្យមន្ត្រីរាជការដែលបានចូលនិវត្តន៍ចំនួន ២៥៨នាក់។

ពាក់ព័ន្ធនឹងការងារបៀវត្ស ក្រៅពីការងារតម្លើងថ្នាក់កាំរិត ដែលត្រូវបានបង្កក នាយកដ្ឋានបុគ្គលិក រៀបចំដាក់មន្ត្រីឱ្យចូលនិវត្តន៍ចំនួន ២៥៨នាក់ ជ្រើសរើស និងបែងចែកបុគ្គលិកជាប់កិច្ចសន្យាចំនួន ១៦៨នាក់ និងពលករអណ្តែតចំនួន ៧៥៩នាក់ និងបានដាក់មន្ត្រីឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៨នាក់ និងដាក់ឱ្យចូលបំរើការងារវិញ បន្ទាប់ពីមានការអនុញ្ញាតឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៦នាក់។ ទន្ទឹមនេះ បានពិនិត្យកែសម្រួល ការប្រែប្រួលស្ថានភាពមន្ត្រីរាជការ និងគ្រួសារ ឆ្នាំ២០១១ ក្នុង តារាងបៀវត្សគ្រប់អង្គភាពថ្នាក់កណ្តាល។

លើការងារអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបានពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបណ្តុះ បណ្តាលរយៈពេលខ្លី និងវែង ក្នុង និងក្រៅប្រទេស ចំនួន ១៦០នាក់ ក្នុងប្រទេសចំនួន ៤៥នាក់ ក្រៅ ប្រទេសចំនួន ១១៥នាក់ ក្នុងនោះរយៈពេលខ្លីមានចំនួន១៤៧នាក់ រយៈពេលវែងមានចំនួន ១៥នាក់ (ថ្នាក់បណ្ឌិតចំនួន ២នាក់ អនុបណ្ឌិតចំនួន ១១នាក់ វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់២នាក់ និងមធ្យម១នាក់)។ ទន្ទឹមនឹងនេះ សម្របសម្រួលគ្រប់ការងារពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ធនធានមនុស្ស ជាមួយគ្រឹះស្ថាន សិក្សាទាំង៣ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្ម

កំពង់ចាម) របស់ក្រសួង និងដៃគូរអភិវឌ្ឍន៍។

នៅក្នុងការរៀបចំកែសម្រួលរចនាសម្ព័ន្ធចាត់តាំង របស់អង្គភាពក្រោមឱវាទក្រសួង ឱ្យស្របតាមការអភិវឌ្ឍន៍វិស័យកសិកម្ម បានរៀបចំប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានកៅស៊ូ នាយកដ្ឋានផែនការ និងស្ថិតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម។ ទន្ទឹមនឹងនេះដែរ បានរៀបចំប្រកាសប្តូរឈ្មោះការិយាល័យស្រុក ក្រុង ដោយអនុលោមតាមព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត នានាទូទាំងប្រទេស។ ក្នុងឆ្នាំ២០១០នេះ បានផ្តល់គ្រឿងឥស្សរិយយសចាប់ពីមេដាយការងារសំរិទ្ធ រហូតដល់មេដាយជាតូបកា ជូនមន្ត្រីកសិកម្មទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្តបានចំនួន ២០៣៧នាក់។

នៅក្នុងយុទ្ធនាការជំរឿនមន្ត្រីរាជការឆ្នាំ ២០១០ សហការជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានរៀបចំធ្វើជំរឿនមន្ត្រីរាជការស៊ីវិលថ្នាក់កណ្តាល នៅទីស្តីការក្រសួង នាថ្ងៃទី ៣១ ខែ ឧសភា ដល់ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០។ ចំណែកការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល នៅតាមមន្ទីរកសិកម្ម រាជធានីខេត្តប្រព្រឹត្តទៅជាបន្តបន្ទាប់ចាប់ពីថ្ងៃទី ២៩ ខែ មិថុនា រហូតដល់ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០។

អនុវត្តគំរោងថវិកាតាមកម្មវិធី ដោយបានរៀបចំវគ្គបណ្តុះបណ្តាលលើប្រធានបទ "ការលើកកំពស់សមត្ថភាពមន្ត្រីរាជការ និងពង្រឹងក្របខណ្ឌច្បាប់"។ វគ្គបណ្តុះបណ្តាលសំដៅជានាឱ្យមានការអភិវឌ្ឍន៍ធនធានមនុស្ស លើការអនុវត្តន៍ច្បាប់ ការរៀបចំឯកសាររដ្ឋបាលឱ្យបានត្រឹមត្រូវ និងចាត់ចែងការងារបានទាន់ពេលវេលា និងចំគោលដៅ ដែលរៀបចំសម្រាប់មន្ត្រីមន្ទីរកសិកម្មរាជធានីខេត្តទាំង ២៤ ដែលមានការចូលរួមពីសិក្ខាកាម ថ្នាក់អនុប្រធានមន្ទីរថ្នាក់ការិយាល័យកសិកម្មខេត្ត និងការិយាល័យកសិកម្មស្រុក ចំនួន ១២០នាក់។

ទន្ទឹមនឹងសកម្មភាពអនុវត្ត បានរៀបចំផែនការថវិកា និងផែនការក្របខណ្ឌមន្ត្រីជ្រើសរើសថ្មី ដើម្បីជំនួសមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ក្នុងឆ្នាំ ២០១១ និងបុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែត សម្រាប់អង្គភាពទាំងអស់ ក្រោមឱវាទក្រសួង។

**៥.៧.១.២-វាយតម្លៃ និងសំណើ**

ថ្វីបើមានការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងយ៉ាងណាក៏ដោយ ក៏ការអនុវត្តន៍ភារកិច្ចទាំងនោះ នៅតែជួបប្រទះនូវការលំបាកស្មុគស្មាញជាច្រើនទៀត ដែលនឹងត្រូវមានវិធានការមួយចំនួនសម្រាប់កែលំអ និងដោះស្រាយបន្ថែមទៀតដូចជា៖

- អង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត មួយចំនួនពុំសូវយកចិត្តទុកដាក់ក្នុងការណែនាំ និងចាត់ឱ្យមន្ត្រីជំនាញខាងការងារបុគ្គលិកបំពេញភារកិច្ចរបស់ខ្លួនដូចជា ការរៀបចំ និងការបញ្ជូនសំណុំឯកសារពាក់ព័ន្ធនឹងលាភការ និងផលប្រយោជន៍ របស់មន្ត្រីរាជការរបស់ខ្លួនមិនបានទាន់ពេល។ មន្ត្រីរបស់ខ្លួនបានខំបន្តរៀនសូត្របានទទួលសញ្ញាប័ត្រជំនាញខ្ពស់ ប៉ុន្តែបែរជាមិនបានធ្វើសំណើសុំតម្លើងកាំបៀវត្សឱ្យទៅតាមស្មារតីនៃព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែក និងការខកខានចំពោះការស្នើសុំឡើងថ្នាក់ ឬកាំបៀវត្សជូនមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួនជាដើម

- ការបញ្ជូនសំណុំឯកសាររបស់អង្គភាពមកក្រសួងមិនគ្រប់តាមតម្រូវការ ឯកសារភ្ជាប់មួយចំនួនមិនច្បាស់ និងមិនគ្រប់ចំនួន ហើយនិងមិនបានទាន់ពេលវេលាកំណត់ទៀតផង ។ ជាក់ស្តែងការបញ្ជូនសំណុំឯកសារផ្ទេរ តែងតាំងស៊ប់ ការរៀបចំប្រាក់កំរិតមុខងារ ការផ្តល់ទិន្នន័យអំពី ស្ថានភាពប្រែប្រួល

របស់មន្ត្រីរាជការ សម្រាប់បញ្ចូលក្នុងតារាងបៀវត្សប្រចាំខែ ការធ្វើសំណើសុំគ្រឿងឥស្សរិយយស ការរៀបចំឯកសារតម្លើងកាំបៀវត្សប្រចាំឆ្នាំ ការចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស នៅតែមិនទាន់អនុវត្តបានត្រឹមត្រូវតាមការណែនាំ និងមានការយឺតយ៉ាវមកមិនទាន់ពេលវេលាកំណត់

- ការពង្រាយមន្ត្រីទៅធ្វើការនៅតាមខេត្ត ក្រុងនៅតែជាបញ្ហាប្រឈមដដែល ពិសេសនៅការិយាល័យកសិកម្មថ្នាក់ស្រុកខ្លះ នៃមន្ទីរកសិកម្មខេត្ត-ក្រុងដាច់ស្រយ៉ាល នៅតែខ្វះមន្ត្រីកសិកម្មឈរជើងនៅឡើយ។ ជារៀងរាល់ឆ្នាំក្រសួងបានដោះស្រាយបញ្ជូនមន្ត្រីថ្មីៗបានតិចតួច រីឯមន្ត្រីមានវ័យចំណាស់ មួយចំនួន ត្រូវដាក់ឱ្យចូលនិវត្តន៍ជាបន្តបន្ទាប់ ដែលជាហេតុនាំឱ្យការិយាល័យកសិកម្មស្រុកមួយចំនួន នៅតែខ្វះមន្ត្រីបម្រើការងារ ។

៥.៧.១.៣-វិធានការ

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងគោការណ៍ លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំ អំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តន៍ជាក់ស្តែង ក្នុងការគ្រប់គ្រងធនធានមនុស្ស ឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកំរិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង ដើម្បីជាឯកសារសម្រាប់ក្រសួងប្រើប្រាស់

-រៀបចំឯកសារដាក់មន្ត្រីឱ្យចូលនិវត្តន៍ឱ្យបានទាន់ពេលវេលា និងបន្តការងារ ដែលនៅសេសសល់ពិនិត្យ និងកែលំអលើការងាររៀបចំរចនាសម្ព័ន្ធ សេចក្តីព្រាងប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទក្រសួង

-ជំរុញការអនុវត្តគម្រោងថវិកាតាមកម្មវិធី ដែលបានអនុម័តក្នុងឆ្នាំ ២០១០ សម្រាប់ឆ្នាំ ២០១១

-ជំរុញអនុវត្តគម្រោងថវិកា ដែលបានលើកក្នុងផែនការសកម្មភាព នៃគោលនយោបាយជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

-ចុះត្រួតពិនិត្យជាក់ស្តែងការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងពលករអណ្តែតនៅតាមអង្គភាព និងរាជធានី-ខេត្ត រៀបចំកសាងផែនការសំខាន់ៗមួយចំនួន ដូចជាៈ

+ ផែនការក្របខណ្ឌមន្ត្រីថ្មី

+ ផែនការជ្រើសរើសពលករអណ្តែត

+ ផែនការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា

+ ផែនការថវិកា

-ពង្រឹងការអនុវត្តការងារស្នើសុំគ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការនៅតាមបណ្តាលអង្គភាពនានាចំណុះ ក្រសួងឱ្យបានល្អប្រសើរ ។

### ៥.៧.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ

#### ក- សាកលវិទ្យាល័យភូមិន្ទកសិកម្ម

នៅក្នុងឆ្នាំ ២០១០ នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានអនុវត្តនូវផែនការសកម្មភាពរបស់ខ្លួនដែលបានដាក់ចេញ ហើយសម្រេចបានការកិច្ចសំខាន់ៗ និងចាំបាច់ចំពោះមុខជាច្រើន ដែលធ្វើឱ្យសាកលវិទ្យាល័យភូមិន្ទកសិកម្មមានការរីកចម្រើនជាជំហានៗទាំងបរិមាណ និងគុណភាព និងជានាបាននូវនិរន្តរភាព លើការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបម្រើឲ្យវិស័យកសិកម្មអភិវឌ្ឍន៍ជនបទ និងវិស័យពាក់ព័ន្ធផ្សេងៗទៀតក្នុងការចូលរួមចំណែកស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា។

### ក.១-ស្ថិតិនិស្សិត

ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយ ចំនួននិស្សិតចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម មានការ កើនឡើងជាលំដាប់ពី ៣០៨ នាក់ ក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ដល់ ១៣២៣ នាក់ ក្នុងឆ្នាំ ២០១០-២០១១។ នេះបញ្ជាក់ថាសារៈសំខាន់របស់វិស័យកសិកម្ម ក៏ដូចជាការមានទំនុកចិត្តខ្ពស់របស់និស្សិត និងមាតាបិតា មកលើគុណភាពអប់រំបណ្តុះបណ្តាល របស់សាកលវិទ្យាល័យ ភូមិន្ទកសិកម្ម។







ចំនួននិស្សិតសរុបកំពុងសិក្សានៅក្នុងឆ្នាំ ២០១០-២០១១នេះ មានចំនួន ២៩៧១ នាក់។ មហាវិទ្យាល័យដែលមាននិស្សិតចំនួនច្រើនគឺ វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រ និង វេជ្ជសាស្ត្រសត្វ និង សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ ចាប់ពីឆ្នាំ ១៩៨៥ មកដល់បច្ចុប្បន្ននេះ សាកលវិទ្យាល័យ បានបណ្តុះ បណ្តាលនិស្សិតចំនួន៤៥៧៧ នាក់ ។




ស្ថិតិនិស្សិតបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម ពីឆ្នាំ ១៩៨៥-២០១០

### ក.២- ការអភិវឌ្ឍធនធានមនុស្ស

សាកលវិទ្យាល័យវិទ្យាល័យភូមិន្ទកសិកម្ម បានធ្វើការបណ្តុះបណ្តាលមន្ត្រីសាស្ត្រាចារ្យថ្នាក់ក្រោយឧត្តមនៅក្នុង-ក្រៅប្រទេស ដើម្បីសំដៅពង្រឹងសមត្ថភាព គុណភាពរបស់សាស្ត្រាចារ្យតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ-កិច្ចពិភាក្សា និងសន្និសីទ។ លើសពីនេះទៀត បានអញ្ជើញថ្នាក់ដឹកនាំសំខាន់ៗមកធ្វើបទបង្ហាញជូនសាស្ត្រាចារ្យ និងនិស្សិតទាក់ទងទៅនឹងប្រធានបទមួយចំនួនដូចជា

ប្រព័ន្ធបណ្តាញសុវត្ថិភាពកម្ពុជា បរិស្ថាន និងអភិវឌ្ឍជនបទ ការប្រើប្រាស់សក្តានុពលប្រព័ន្ធជាពសាស្ត្រស្ទឹងជីនីត ការប្រើប្រាស់ស្នប់បូមផ្តោតលើការអភិរក្សថាមពល ការប្រែប្រួលអាកាសធាតុ សក្តានុពលអំពីការបង្កើនផលត្រីតាមរយៈការបង្កើតស្រះជម្រកត្រីសហគមន៍ ការស្វែងរកការងារនាពេលបច្ចុប្បន្ន និងជីវសុវត្ថិភាពកសិដ្ឋានចិញ្ចឹមសត្វ។ល។

**ក.៣- សហប្រតិបត្តិការអន្តរជាតិ**

បច្ចុប្បន្ននេះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយ នឹងគ្រឹះស្ថាន និងសាកលវិទ្យាល័យមួយចំនួនដូចខាងក្រោម៖

| ល.រ | ប្រទេស | ឈ្មោះគ្រឹះស្ថាន និង សាកលវិទ្យាល័យដៃគូសហប្រតិបត្តិការ |
|---|---|---|
| ១ | ម៉ាឡេស៊ី | University Sains Malaysia, University Teknikal Mara SDN. BHD.(Unikl) |
| ២ | ឡាវ | Champasack University, National University of Laos. |
| ៣ | ចិន | Guangxi Academy of Agricultural Science, Guangxi University of China. |
| ៤ | អេស្ប៉ាញ | University of Valladolid |
| ៥ | វៀតណាម | An Giang University, University of Science, National University Ho Chi Minh City, Nong Lam University, Can Tho University, HUE University of Agriculture and Forestry |
| ៦ | ថៃ | MAE FAH LUANG University, Khon kaen University, Mahasarakham University, Mahidol University, RAMBHAI BARNI RAJABHAT University. |
| ៨ | ជប៉ុន | Kyoto University, Japan International Research Center for Agricultural Science (JIRCAS), Kagawa University, Saga University, Tokyo University of Agriculture and Technology, University of TSUKUBA, Waseda University, Tokyo University of Agriculture |
| ៩ | បារាំង | Agence Universitaire de la Francophonie, The Institue National Plytechnique Toulose, Meseum National d'Histoire Naturelle of Paris, VetAgro Sup, Institue d'enseignement et de recherché en alimentation, santé animale, sciences agronomiques et de l'environnement France. |
| ១០ | អ៊ីស្រាអែល | "Agro Studies" the International Center for Agricultural Studies in Israel. |
| ១១ | បែលហ្សិក | VRIJE University Brussel. |
| ១២ | ឥណ្ឌូនេស៊ី | University of Lampung. |
| ១៣ | តៃវ៉ាន់ | Food and Fertilizer Technology Center for the Asian and Pacific Region. |

តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានទទួលជំនាញការបរទេសចំនួន ១១រូប ជាទីប្រឹក្សាបច្ចេកទេសដល់មហាវិទ្យាល័យ និងផ្នែកផ្សេងៗ។ សាកលវិទ្យាល័យបានបញ្ជូននិស្សិតទៅធ្វើកម្មសិក្សា នៅប្រទេសអ៊ីស្រាអែល ចំនួន ៣០នាក់ ទៅប្រទេសជប៉ុនចំនួន ៤នាក់ ប្រទេសអេស្ប៉ាញ ចំនួន ៣នាក់ សហរដ្ឋអាមេរិក ចំនួន ៣នាក់ ព្រមទាំងបានបញ្ជូននិស្សិតចំនួន ៣៨ នាក់ចូលរួមធ្វើកម្មសិក្សាជាមួយនិស្សិតជប៉ុននៅកម្ពុជា។ មិនត្រឹមតែ ប៉ុណ្ណោះ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានទទួលនិស្សិតជប៉ុន ចំនួន ៣៨ នាក់ អេស្ប៉ាញ ៣ នាក់ ម៉ាឡេស៊ី ចំនួន ១១ នាក់ និង និស្សិតមកពីបារាំង ចំនួន ៤នាក់ មកធ្វើកម្មសិក្សានៅកម្ពុជា។ លើសពីនេះទៅទៀត សាកលវិទ្យាល័យបានសហការជាមួយមូលនិធិសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICF) ផ្តល់អាហារូបករណ៍ជាសាច់ប្រាក់ដល់និស្សិតថ្មីចំនួន ៦០ នាក់ជារៀងរាល់ឆ្នាំ ដោយម្នាក់ៗទទួលបាន ៥០.០០០ យេនជប៉ុន។ សាកលវិទ្យាល័យបាននឹង

*បន្តអនុវត្តន៍គម្រោងស្រាវជ្រាវចំនួន ១១ ដែលគម្រោងស្រាវជ្រាវមួយចំនួនបានអនុវត្តន៍ នៅក្នុងមជ្ឈ-មណ្ឌលស្រាវជ្រាវ* **សម្តេច ហ៊ុន សែន** *ដែលមានបន្ទប់ពិសោធន៍ ៩ គឺ បន្ទប់ ពិសោធន៍វិភាគដី វិភាគគ្រាប់ធញ្ញជាតិ ប៉ារ៉ាសិត សាស្ត្របសុ ពេទ្យ ភូតគាមពេគសាស្ត្រ និង ជីវគីមី ។*

**ក.៤-ការបោះពុម្ព**

*សាកលវិទ្យាល័យបានបោះពុម្ពសៀវភៅនិក្ខេបបទ និងសារណាបទបញ្ចប់ការសិក្សារបស់និស្សិតគ្រប់កំរិត ចំនួន ៨៦០០ ក្បាល និង ឯកសារផ្សព្វផ្សាយបច្ចេកទេសផ្សេងៗមួយចំនួនទៀត។*

**ក.៥-សន្និដ្ឋាន និងវាយតម្លៃ**

*តាមរយៈលទ្ធផលដែលសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបានខាងលើ អាចសន្និដ្ឋាន និងវាយតម្លៃបានថា សាកលវិទ្យាល័យបានពង្រឹង និងពង្រីកការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ជាពិសេស លើការអប់រំបណ្តុះបណ្តាលនិស្សិត ការស្រាវជ្រាវ និងការផ្សព្វផ្សាយបច្ចេកទេសវិទ្យាសាស្ត្រដល់កសិករក្នុងមូលដ្ឋានផលិតកម្ម ។*

**ខ- សាលាកសិកម្មព្រែកលៀប**

ខ.១- ការងារគ្រប់គ្រងនិស្សិត

*ឆ្នាំសិក្សា ២០១០-២០១១ មាននិស្សិតសរុបចំនួនសរុបចំនួន ១៦២២ នាក់ នារី ៤៣៤ នាក់ ដែលមាននិស្សិតថ្នាក់បរិញ្ញារង ៤៧៦នាក់ (នារី ១៤០ នាក់ ) និស្សិតបរិញ្ញា ១១៤៦ នាក់ (នារី ២៩៤ នាក់)។*




ខ.២- ការងារបញ្ចប់ការសិក្សារបស់និស្សិត

ខ.២.១- លទ្ធផលបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញារង

*និស្សិតសរុបចំនួន ១៨៩ នាក់ (ស្រី ៤០ នាក់) ក្នុងនោះ និស្សិតជាប់ជាស្ថាពរតាមជំនាញមានចំនួន ១៨៣ នាក់ (នារី ៤០ នាក់)*




*និស្សិតថ្នាក់បរិញ្ញា ចំនួន ៣៤៩ នាក់ ( នារី ៨៥ នាក់ ) ដោយជោគជ័យគឺ ៖*

- *និស្សិតថ្នាក់បរិញ្ញា អាហារូបករណ៍ចំនួន ១០៧ នាក់ ( នារី ៤០ នាក់ )*

- និស្សិតថ្នាក់បរិញ្ញាបណ្ដុះបណ្ដាលបន្ត (ថ្ងៃសៅរ៍-អាទិត្យ) ចំនួន ២៤២នាក់ (នារី ៤៥ នាក់)




ខ.៣- កម្មសិក្សា

ដើម្បីបំពេញក្រេឌីតសិក្សា និងក្រោមការដឹកនាំសាស្ត្រាចារ្យ និស្សិតគ្រប់ដេប៉ាតឺម៉ង់បានចុះកម្មសិក្សា ក្រោយពីបានបញ្ចប់ការសិក្សាទ្រឹស្ដីចំនួន ១៦ លើកនៅតាមមូលដ្ឋានផលិតកម្ម ខេត្ត កំពត កោះកុង ព្រះសីហនុ រតនៈគីរី មណ្ឌលគីរី បាត់ដំបង ប៉ៃលិន សៀមរាប ព្រះវិហារ ស្វាយរៀង និងតាមសហគ្រាសផ្សេងៗ។

ខ.៤- ការងារស្រាវជ្រាវ

ខ-៤-១- ស្ថានីយ៍

សាលាជាតិកសិកម្មព្រែកលៀបបានអនុវត្តការងារស្រាវជ្រាវ ដោយស្ថានីយ៍ផលិតកម្ម និងស្រាវ ជ្រាវបានដឹកនាំនិស្សិតធ្វើពិសោធន៍ក្នុងបរិវេណសាលាជាតិ ៖

- ប្រៀបធៀបជីលាមកសត្វ កំប៉ុស្ដ ជីគីមី NPK លើដំណាំបន្លែយកស្លឹកចំនួន ៥ មុខ ដំណាំបន្លែយកផ្កាចំនួន ២ មុខ ដំណាំបន្លែយកផ្លែចំនួន ៤ មុខ ដំណាំបន្លែយកមើមចំនួន ៣ មុខ
- ប្រៀបធៀបកម្រឹតនៃការប្រើប្រាស់ជីទឹកលើដំណាំបន្លែចំនួន ៥ មុខ
- ប្រសិទ្ធភាពជី EM ពីរប្រភេទលើដំណាំបន្លែយកស្លឹកចំនួន ៥ មុខ
- ទិន្នផលសណ្ដែកដីពីរពូជក្នុងលក្ខខ័ណ្ឌដូចគ្នា
- ទិន្នផលពូជស្រូវរាំងជ័យក្នុងចន្លោះគុម្ពផ្សេងគ្នា ។

ខ-៤-២- មន្ទីរពិសោធន៍

- ធ្វើការវិភាគ ដី និង ទឹក
- កាយវិភាគវិទ្យាសត្វ ពិនិត្យវត្តមានប៉ារ៉ាសិត ក្នុងលាមកសត្វ វីរុសនិងបាក់តេរីក្នុងចំណីសត្វ និងក្នុងឈាមសត្វ និងការវះសត្វជាដើម។

ខ.៥- ការងារសហប្រតិបត្តិការអន្តរជាតិ

បច្ចុប្បន្ននេះ ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងស្រុក សាលាជាតិកសិកម្មព្រែកលៀបបាននិង កំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយ ៖

- វិទ្យាស្ថានសាគរសាស្ត្រនៃសាកលវិទ្យាល័យ Memorial ប្រទេសកាណាដា ក្រោមការឧបត្ថម្ភរបស់ CIDA លើការអភិវឌ្ឍន៍កម្មវិធីសិក្សាវារីវប្បកម្ម និងការបណ្ដុះបណ្ដាលអ្នកផ្សព្វផ្សាយបង្គោលសម្រាប់គម្រោង ការក្នុងស្រែ ក្នុងនោះមានការទទួលយក Internship មកកម្ពុជាផងដែរ
- Ded របស់អាល្លឺម៉ង់ក្នុងការអភិវឌ្ឍន៍សមត្ថភាពមន្ត្រី និងមន្ទីរពិសោធន៍ វិទ្យាសាស្ត្រដី ទឹក និងដី

- JICA ចំពោះការផ្តល់ជំនាញការស្ម័គ្រចិត្តជប៉ុន (Senior Volunteer) ក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សាកសិ-ឧស្សាហកម្ម និងក្នុងការផ្សារអនុវត្តកែច្នៃម្ហូបអាហារ។

**គ- សាលាជាតិកសិកម្មកំពង់ចាម**

នៅក្នុងផែនការអភិវឌ្ឍន៍ឆ្នាំ ២០១០ នេះ ក្រុមប្រឹក្សាភិបាលសាលាជាតិកសិកម្មកំពង់ចាម បានឯកភាព និងសម្រេចអនុម័តនូវកម្មវិធីអភិវឌ្ឍន៍ចំនួន ១០ តាមកម្មវិធីទាំងនោះ ត្រូវបានដាក់ឱ្យដំណើរការដាក់ស្តែងចេញជា ២៦ សកម្មភាពទៅតាមគោលដៅ និងមុខសញ្ញាអភិវឌ្ឍន៍។

**គ.១- ការលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម**

**គ.១.១- ការងារបណ្តុះបណ្តាល**

- និស្សិតដែលបានសិក្សាសរុបចំនួន ១.៤៣២ នាក់ ក្នុងនោះ ស្ត្រី ៥៨៣ នាក់ រួមមាននិស្សិតអាហាររូបករណ៍ចំនួន ១១៩៨ នាក់ស្ត្រី ៥២៤ នាក់ (បរិញ្ញាប័ត្រវិទ្យា សាស្ត្រកសិកម្ម ៧៤៩ នាក់ ស្ត្រី ២៨៨ នាក់ បរិញ្ញាប័ត្ររង បច្ចេកទេសកសិកម្ម ៤៤៩នាក់ ស្ត្រី ២៣៦នាក់) និងនិស្សិតសិក្សាបង់ថ្លៃចំនួន ២៣៤ នាក់ ស្ត្រី ៥៩ នាក់

-និស្សិតថ្នាក់បរិញ្ញាប័ត្ររងបច្ចេកទេសកសិកម្មជំនាន់ទី ១៤ ចំនួន ១២៤ នាក់ ក្នុងនោះ ស្ត្រី ៣៦ នាក់ និងបានប្រលងបញ្ចប់ការសិក្សារបស់ខ្លួនរួចមកហើយ។ ដោយឡែកនិស្សិតថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្មជំ នាក់ទី ៤ ចំនួន១២៤នាក់ ស្ត្រី ៣៨ នាក់ និងនិស្សិតសិក្សាបង់ថ្លៃជំនាក់ទី ៧ ចំនួន ១៣៩ នាក់ ស្រី ២៧ នាក់ បានការពារសារណាបទ បញ្ចប់ការសិក្សារួចរាល់អស់ ហើយដែរ។

**គ.១.២ ការងារពង្រឹងការបណ្តុះបណ្តាល**

សាលាបានរៀបចំកម្មវិធីបណ្តុះបណ្តាលតាមរយៈការផ្តល់ឱកាសឱ្យនិស្សិត-សាស្ត្រាចារ្យបានចុះកម្មសិក្សានិងធ្វើទស្សនៈកិច្ចសិក្សានៅតាមមូលដ្ឋាននានាក្នុងព្រះរាជាណាចក្រកម្ពុជា។

**គ.១.៣ កម្មសិក្សា**

- និស្សិតដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកសិកម្ម ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ ដេប៉ាតឺម៉ង់ដំណាំកៅស៊ូ ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រជលផល ថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី ៤ ជំនាន់ទី ៥ និស្សិតដេប៉ាតឺម៉ង់ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជំនាន់ទី ២ ផ្នែក អាហាររូបករណ៍ចំនួន ១២៨ នាក់ និងនិស្សិតផ្នែកបណ្តុះបណ្តាលបន្តជំនាន់ទី៨ ចំនួន១៣៩នាក់បានចុះកម្មសិក្សា និងចងក្រងសារណាបទបញ្ញាក់ការសិក្សាទៅតាមមន្ទីរ, អង្គភាព ,ស្ថានប័ន និងអង្គការនានា ក្នុងព្រះរាជាណាចក្រកម្ពុជា

- និស្សិតផ្នែកបណ្តុះបណ្តាលបរិញ្ញាប័តរងបច្ចេកទេសកសិកម្មជំនាក់ទី ៥ មានចំនួន ៣២ នាក់ បានកំពុងសិក្សា និងចុះកម្មសិក្សាទៅតាមមូលដ្ឋាននានា ដើម្បីសរសេរបាយការណ៍ បញ្ចប់ការសិក្សានៅឆ្នាំសិក្សា ២០១១ ខាងមុខនេះ។

**គ.១.៤- ការងារកែលម្អហេដ្ឋារចនាសម្ព័ន្ធ-រូបវន្ត និងបំពាក់ទព្វសម្ភារៈ**

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលាជាតិកសិកម្មកំពង់ចាម ត្រូវបានជួសជុលកែលម្អជារៀងរាល់ឆ្នាំពីមួយឆ្នាំទៅមួយឆ្នាំតាមលទ្ធភាពថវិកាដែលរដ្ឋផ្តល់ឱ្យដើម្បីរក្សាឱ្យបាននូវភាពរឹងមាំសោភ័ណភាពសមស្របតាមគោលការណ៍នៃការបណ្តុះបណ្តាល។ ជាមួយគ្នានោះដែរ គ្រឿងទព្វសម្ភារៈក៏ត្រូវបានបំពាក់ឱ្យទៅតាមទំហំនៃការកសាង ជួសជុលលម្អ

**គ.១.៥- ការងារនៅលើដី១០ហិចតា ថ្មពេជ្រវិហារលួង**

-ថែរក្សានិងការពារខឿនគ្រឹះរបងស្ថានីយ៍នៅឃុំវិហារលួងស្រុកត្បូងឃ្មុំដែលបានរៀបចំរួចហើយ

*-កម្មសិទ្ធដីប្លង់ស្របច្បាប់១០ ហិកតា នៅថ្មពេជ្រត្រូវបានកាត់ចេញពីក្រុមហ៊ុនចម្ការកៅស៊ូជុប*

*-អាគារសង់ថ្មីដែលមានទំហំ ៤៦ម x ៩ម មាន៥បន្ទប់ត្រូវបានសាងសង់និងដាក់ឱ្យដំណើរការ។*

គ.១.៦- ការទទួលសិស្សក្រីក្រពីជនបទមកធ្វើការបណ្តុះបណ្តាលលើចំណេះដឹងបច្ចេកទេសកសិកម្ម

*-ក្នុងឆ្នាំ២០០៩-២០១០ កន្លងមកនេះ សិស្សក្រីក្រមកពីតំបន់ដាច់ស្រយាល សិស្សក្រីក្រគ្មានទីពឹងសិស្សកំព្រា និងនារីភេទត្រូវបានសាលាលើកសំណើទៅគណៈកម្មាធិការ ជ្រើសរើសសិស្សចូលរៀនឆ្នាំសិក្សា ២០០៩-២០១០ បានចំនួន ២៤ នាក់ ក្នុងនោះ សិស្សនារីចំនួន ១២នាក់ មកពីខេត្តកំពង់ធំ ក្រចេះ ព្រះវិហារ កំពង់ចាម កណ្តាល និងតាកែវ*

*-បានរៀបចំ និង សម្រួលឱ្យនិស្សិតក្រីក្រចំនួន១០នាក់បានស្នាក់នៅក្នុងសាលា*

គ.១.៧-ការជួយឧបត្ថម្ភដល់កសិករលើចំណេះដឹងបច្ចេកទេសកសិកម្មនិងឥណទានផ្សេងៗ

*ក្រុមសាស្ត្រាចារ្យ១ក្រុមបានចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបំពាក់បំប៉នបច្ចេកទេសកសិកម្ម និងបានជួយសម្រួលជីវភាពជូនប្រជាកសិករនៅក្នុងស្រុកស្ទឹងត្រង់ និង ស្រុកត្រាំកក់(ឃុំញ្ញែងញ៉ង)*

**គ.១.៨- ការពិសោធស្រាវជ្រាវ និងការផ្សព្វផ្សាយ**

*ការងារពិសោធន៍និងស្រាវជ្រាវបានអនុវត្តលើ គំពេងចំនួន ៧ មានដូចតទៅ៖*

*១-សិក្សាពិសោធន៍លើដំណាំស្រូវដោយប្រើជីសរីរាង្គនិងជីគីមី ចំពោះក្រុមដីស្រុក កំពង់សៀ*

*២-សិក្សាពិសោធន៍លើការបង្ហាត់និងចិញ្ចឹមកង្កែប ដោយប្រើចំណីផ្សំស្រេចនិងចំណីធម្មជាតិ*

*៣-សិក្សាពិសោធន៍លើការចិញ្ចឹមជ្រូកកូនកាត់ចំនួន១០ក្បាល ដោយប្រើចំណីផ្សំ និងចំណីធម្មជាតិ*

*៤-សិក្សាពិសោធន៍លើជ្រូកសាច់កូនកាត់ដោយប្រើចំណី ៩៦៣០ របស់ក្រុមហ៊ុនគ្រិនហ្វីត នៅឃុំមៀច ស្រុកព្រៃឈរ ខេត្តកំពង់ចាម*

*៥-សិក្សាពិសោធន៍បង្ហាញអំពី កសិកដ្ឋានពហុប្រយោជន៍ជាលក្ខណៈគ្រួសារ*

*៦-ការធ្វើកសិកម្មចំរុះ ដោយចិញ្ចឹមមាន់ពូជ ត្រីអណ្តែង រុក្ខជាតិ និងបន្លែ*

*៧-ការសោធន៍ដំណាំឪឡឹក និងដំណាំត្រប់ផ្អែម នៅស្រុកត្រាំកក់ ខេត្តតាកែវ។*

**គ.២- សេចក្តីសន្និដ្ឋាន**

*-ផ្អែកតាមការវាយតម្លៃលើសកម្មភាពនៃការអនុវត្តការងារតាមកម្មវិធីទាំង ១០ ខាងលើមកហើយ នោះជាលទ្ធផលទទួលបានមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានជាក់ស្តែងដូចតទៅ ៖*

**ចំណុចខ្លាំង**

*-កិច្ចដំណើរការសកម្មភាពដឹកនាំគ្រប់គ្រងមានលក្ខណៈល្អប្រសើរ និងការយកចិត្តទុកដាក់បំពេញការងាររបស់មន្ត្រី-សាស្ត្រាចារ្យ មានការទទួលខុសត្រូវខ្ពស់*

*-អង្គភាពបានប្រកាន់យកវប្បធម៌ ចែករំលែកស្រឡាញ់រាប់អានគ្នា និងចេះទទួលខុសត្រូវជួយរែកពុនការងារមិនប្រកាន់តួនាទី ឋានៈឬពេលវេលាឡើយ*

*-ការដោះស្រាយបាតុភាពផ្សេងៗ ដែលជាភាពអសកម្មនៅក្នុងអង្គភាព ត្រូវបានលើកយកមកដោះស្រាយតាមរយៈអង្គុយជជែកគ្នាដោយសន្តិវិធី និងយោគយល់។*

**ចំណុចខ្សោយ**

*-ថវិកាសម្រាប់ចរន្តនៅមានការរអាក់រអួលបណ្តាយស្ទះដំណើរការការងារ។*

ផ្អែកលើការវាយតម្លៃពីភាពខ្លាំង និងភាពខ្សោយនៃសកម្មភាពដូចបានបង្ហាញខាងលើ សាលាសូមធ្វើការសន្និដ្ឋានដូចតទៅ ៖

-សាលាជាតិកសិកម្មកំពង់ចាម កំពុងបោះជំហ៊ានក្នុងរូបភាពវិជ្ជមាន ឆ្ពោះទៅកាន់កាអភិវឌ្ឍន៍។ ថ្វីត្បិតសាលាមានចំណុចខ្វះខាតខ្វះៗមែន តែសាលាក៏មានចំណុចល្អជាច្រើនជាគ្រឹះស្ថានអប់រំបច្ចេកទេសផ្នែកឧត្តមសិក្សាលើការអភិវឌ្ឍន៍ធនធានមនុស្សឆ្លើយតបបាននិងរួមចំណែក

-ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់អណត្តិថ្មីនេះ។

### យ- មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

#### យ.១- លទ្ធផលប្រចាំឆ្នាំ ២០១០

ក្នុងឆ្នាំ ២០១០ បានរៀបចំកសាងផែនការ សកម្មភាពការងារ សំដៅធ្វើយ៉ាងណាឱ្យការផ្ទេរបច្ចេកវិទ្យាពីអ្នកស្រាវជ្រាវបច្ចេកទេស លទ្ធភាពពិសោធន៍ស្រាវជ្រាវព័ត៌មានបច្ចេកទេស បានទៅដល់កសិករទូទាំង ២៤ រាជធានី-ខេត្ត។ ជាមួយគ្នានេះដែរ បាននឹងកំពុងធ្វើការសម្របសម្រួល និងសហការជាមួយ អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពជំនាញនានា មន្ទីរកសិកម្មរាជធានី-ខេត្ត គម្រោងកម្មវិធីផ្សេងៗ អង្គភាពក្រៅរដ្ឋាភិបាល និងរដ្ឋអំណាចមូលដ្ឋាន ក្នុងការអនុវត្តសកម្មភាពមួយចំនួន ដែលទាក់ទង និងការងារព័ត៌មានកសិកម្ម។

#### យ.១.២- ការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

-រៀបចំសំណើ សុំប្រើប្រាស់អ៊ិនធឺណេតរបស់រដ្ឋាភិបាល ដែលរៀបចំដោយ អជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (Nida) ជូនថ្នាក់ដឹកនាំក្រសួង

-រៀបចំបង្កើតកម្មវិធី សម្រាប់បែងចែកការប្រើប្រាស់អ៊ិនធឺណេតដល់ថ្នាក់ដឹកនាំក្រសួងជាជំហានដំបូង និងបន្តដល់មន្ត្រីរាជការទាំងអស់នៅក្នុងក្រសួង

-រៀបចំសំណើ សុំអត្ថបទបច្ចេកទេស ច្បាប់ និងបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យកសិកម្មសម្រាប់បញ្ចូលក្នុងគេហទំព័ររបស់ក្រសួង

-ធ្វើការបញ្ចូលទិន្នន័យជាប្រចាំទៅលើគេហទំព័ររបស់ក្រសួង

-រៀបចំបង្កើតគេហទំព័រជូនមន្ទីរកសិកម្មខេត្តកណ្តាល និងរៀបចំបង្កើតគេហទំព័រស្ថិតិកសិកម្ម។

#### យ.១.៣- ការរៀបចំផលិត និងអប់រំផ្សព្វផ្សាយ ឯកសារកសិកម្ម

-បាននិងកំពុងបញ្ចូលព័ត៌មានកសិកម្ម ដែលខុទ្ទកាល័យរដ្ឋមន្ត្រីប្រគល់ឱ្យ

-បាននិងកំពុងតែរៀបចំ និងទំនាក់ទំនងជាមួយនាយកដ្ឋានដែលពាក់ព័ន្ធ ដើម្បីស្នើសុំអត្ថបទផ្សេងៗ និងបច្ចេកទេសកសិកម្មដើម្បីធ្វើការផ្សព្វផ្សាយដល់អតិថិជន។

#### យ.១.៤- បណ្ណាល័យ

បានទទួលនិស្សិត និងអតិថិជន ដែលមកពីបណ្តាសកលវិទ្យាល័យ និងស្ថាប័នផ្សេងៗ ចំនួន ៤២៣នាក់ មកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យ។

#### យ.២- សន្និដ្ឋាន និងវាយតម្លៃ

ជារួមអាស្រ័យដោយមានការគាំទ្រយ៉ាងសកម្មពីរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសពីសំណាក់ ឯកឧត្តម **បណ្ឌិត ច័ន្ទ សារុន** ទាំងផ្នែកស្មារតី បច្ចេកទេស សម្ភារៈ និងថវិកា ជាមួយនិងការខិតខំប្រឹងប្រែងអនុវត្តការងាររបស់មន្ត្រីរាជការ ធ្វើឱ្យការគ្រប់គ្រងព័ត៌មាន និងឯកសារកសិកម្ម មានដំណើរការ និងមានការអភិវឌ្ឍនជាផ្លែផ្កា ដោយស្របតាមគោលដៅអភិវឌ្ឍន៍ឱ្យ

វិស័យបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យាជាតិ និងសាកល។ បច្ចុប្បន្នដោយសារតែមជ្ឈមណ្ឌលទើបតែបង្កើតឡើង និងពុំទាន់មានរចនាសម្ព័ន្ធច្បាស់លាស់ ធ្វើឱ្យមជ្ឈមណ្ឌលជួបផលលំបាកមួយចំនួនដូចជា ៖

-មិនមានមន្ត្រីរាជការគ្រប់គ្រាន់សម្រាប់បម្រើការងារមជ្ឈមណ្ឌល ជាពិសេសមន្ត្រីជំនាញ

-កង្វះខាតសំភារៈសម្រាប់បម្រើការងារមជ្ឈមណ្ឌល ដូចជាម៉ាស៊ីនថតចម្លង ម៉ាស៊ីនបោះពុម្ព និងសម្ភារៈការិយាល័យទូទៅ ដែលសព្វថ្ងៃមជ្ឈមណ្ឌលពឹងផ្អែកទាំងស្រុងលើគម្រោងដៃគូអភិវឌ្ឍន៍ ដើម្បីប្រើប្រាស់សម្ភារៈទាំងអស់នោះ។

**ឃ.៣- វិធានការ**

ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងធានាបាននូវសន្តិសុខ និងសុវត្ថិភាពស្បៀង បង្កើនប្រាក់ចំណូលគ្រួសារ និងកំណើនសេដ្ឋកិច្ចគ្រួសារ មានវិធានការ និងផែនការច្បាស់លាស់សម្រាប់អនុវត្តនាពេលខាងមុខ៖

-ពង្រីកបណ្តាញអ៊ិនធឺណេត ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការសម្រាប់ប្រើប្រាស់ ឱ្យបានទូលំទូលាយជាងមុន

-រៀបចំបង្កើតប្រព័ន្ធសារអេឡិចត្រូនិច (E-mail) ជូនថ្នាក់ដឹកនាំក្រសួង និងបន្តកិច្ចសហការជាមួយអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូអភិវឌ្ឍន៍ ស្ថាប័ន និងអង្គភាពជំនាញផ្សេងៗ ដើម្បីរៀបចំផលិតឯកសារ ទាក់ទងនិងបច្ចេកទេសកសិកម្ម និងព័ត៌មានផ្សេងៗ ដើម្បីធ្វើការផ្សព្វផ្សាយ តាមប្រព័ន្ធវែបសាយរបស់ក្រសួង

-បន្តពង្រឹងសមត្ថភាពដល់មន្ត្រីរាជការគ្រប់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្ម រាជធានី-ខេត្ត

-បន្តអភិវឌ្ឍន៍គេហទំព័រស្ថិតិកសិកម្ម និងជំរុញគេហទំព័រជូនមន្ទីរកសិកម្មខេត្តផ្សេងៗទៀត។

## ៥.៧.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ

### ៥.៧.៣.១-លទ្ធផលប្រចាំឆ្នាំ ២០១០

**ក-ចំណូល**

ក្នុងឆ្នាំ ២០១០ ការប្រមូលចំណូលចូលថវិកាជាតិសម្រេចបានចំនួន ៦២.០៩៣.៤២៧.៤៣១ រៀល ដែលមានប្រមាណ ១៨២ ភាគរយ នៃផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៣៤.២០១.១០០.០០០រៀល។ ក្នុងនោះ ៖

-ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋសម្រេចបានចំនួន ៣៦.៥១៩.៨៨៥.៤៨៥ រៀល ដែលមានប្រមាណ ១២៦% នៃផែនការចំនួន ២៨.៩៩៦.០០០.០០០ រៀល។ ការលើសផែនការនេះ មួយផ្នែកបានមកពីការលក់ឈើល្មើសដែលតុលាការ បានសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ និងការលក់ឈើ ដែលប្រមូលបានពីអាងស្តុកទឹកនៃគំរោងសាងសង់ទំនប់វារីអគ្គិសនី ស្ទឹងអាតៃ។

-ចំណូលផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា ប្រមូលបានចំនួន ៤.០១២.៣៥០.៦៦៥ រៀល ស្មើនឹង ១០៥% នៃផែនការដែលមានចំនួន ៣.៨០៥.០០០.០០០រៀល ក្នុងនេះ មួយផ្នែកធំបានមកពីសេវានៃការត្រួតពិនិត្យ គុណភាពផលិតផល និង ការគោរពបទដ្ឋាន។

-ចំណូលបានមកពីការផាកពិន័យ និង ដាក់ទណ្ឌកម្មចំនួន១៧.៥៧៦.០៨៣.០៩៧ រៀល ស្មើនឹង ១.២៨៤% នៃផែនការ ចំនួន ១.៤០០.០០០.០០០ រៀល។ តាមតួលេខនេះ បញ្ជាក់ថាបទល្មើសនានា បានថយចុះក្នុងឆ្នាំ ២០១០។

-ចំណូលបានមកពីផលផ្សេងៗ និងផលពិសេស ដែលក្រសួងមិនបានលើកក្នុងផែនការ ប្រមូល បាន ចំនួន ៣.៥៨៥.១០៨.១៨៤ រៀល ។

**ខ-ចំណាយ**

ការអនុវត្ត និង គ្រប់គ្រងថវិកាប្រចាំឆ្នាំ ២០១០ សម្រេចបានប្រមាណ ៩៥,៨២% នៃថវិកាកែតម្រូវ។ ការចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានញែកដាច់ពីគ្នារវាងថវិកាតាមកម្មវិធី និងថវិកាមិនមែនកម្មវិធី ដូច្នេះយើងអាចវិភាគខ្ទង់ចំណាយថវិកានីមួយៗដូចខាងក្រោម ៖

**ខ.១-ថវិកាមិនមែនកម្មវិធី** ៖ ការចំណាយលើការងាររដ្ឋបាលប្រចាំថ្ងៃ និងការអនុវត្តប្រចាំឆ្នាំ អនុវត្ត បាន ប្រមាណ ៤១.១៤៩.៩៧២.២៨៤រៀល ស្មើនឹង ៩៦,៤២% នៃថវិកាកែតម្រូវចំនួន ៤២.៦៧៦.៥២០.០០០ រៀល ។ ការចំណាយតាមជំពូកនិមួយៗមានដូចខាងក្រោម ៖

- **-ជំពូក ៦០** ៖ការទិញអនុវត្តជាក់ស្តែងបានចំនួន ៦.៧៥៧.២៣៣.៣៥៥រៀល ស្មើនឹង ៩៧,៩៧% នៃថវិកា កែតម្រូវ ដែលមានត្រឹមតែចំនួន ៦.៨៩៧.០០០.០០០ រៀល
- **-ជំពូក ៦១** ៖សេវាខាងក្រៅ អនុវត្តជាក់ស្តែងបានចំនួន ១.៧២០.៧៦១.៩២០រៀល ស្មើនឹង ៨៩,២៥% នៃថវិកាកែតម្រូវដែលមានចំនួន ១.៩២៨.០០០.០០០ រៀល
- **-ជំពូក ៦២** ៖សេវាខាងក្រៅផ្សេងៗ អនុវត្តជាក់ស្តែងបានចំនួន ៤.៥១៩.៧៨៥.០៦១ រៀល ស្មើ នឹង ៩២,៤៩ % នៃថវិកាកែតម្រូវ ដែលមានចំនួន ៤.៨៨៧.០០០.០០០ រៀល
- **-ជំពូក ៦៣** ៖ពន្ធ និងអាករ អនុវត្តជាក់ស្តែងបានចំនួន ១៣៩.៨៨២.០០០រៀល ស្មើនឹង ៩៩,៩២% នៃច្បាប់ថវិកា ដែលមានចំនួន ១៤០.០០០.០០០ រៀល
- **-ជំពូក ៦៤** ៖បន្ទុកបុគ្គលិកអនុវត្តជាក់ស្តែងបានចំនួន ២០.៣០៥.៧៦២.៧៤០ រៀល ស្មើនឹង ៩៦,៤១% នៃថវិកាកែតម្រូវដែលមានចំនួន ២១.០៦១.៥២០.០០០ រៀល
- **-ជំពូក ៦៥** ៖ឧបត្ថម្ភធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន ៧.៧០៦.៥៤៧.២០៨ រៀល ស្មើនឹង ៩៩,២៧% នៃច្បាប់ថវិកា ដែលមានចំនួន ៧.៧៦៣.០០០.០០០ រៀល ។

**ខ.២-ថវិកាតាមកម្មវិធី** ៖ការចំណាយថវិកាសំដៅសម្រេចឱ្យបានគោលបំណង គោលដៅ និងលទ្ធផល រំពឹងទុក របស់វិស័យនិមួយៗដែលបានកំណត់ពីដើមឆ្នាំ។ ក្នុងឆ្នាំ ២០១០ នេះ ការប្រើប្រាស់ថវិកាតាមកម្ម វិធីមានលក្ខណៈល្អប្រសើរ ច្រើនជៀបនឹងឆ្នាំ ២០០៩ ជាក់ស្តែកក្រសួងអនុវត្តបានចំនួន ១៣.៤២៨.៤៣៨.០៥០ រៀល ដែលមានប្រមាណ ៩៤,០២% នៃថវិកា កែតម្រូវចំនួនប្រមាណ ១៤.២៨៣.០០០.០០០ រៀល។ ការ ចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម ៖

- **-ជំពូក ៦០** ៖ការទិញ អនុវត្តជាក់ស្តែងបានចំនួន ៥.០៩២.១៧៧.៦៩៤ រៀល ស្មើនឹង ៩៥,៨៤% នៃថវិកាកែតម្រូវ ដែលមានចំនួន ៥.៣១៣.០០០.០០០ រៀល
- **-ជំពូក ៦១** ៖សេវាខាងក្រៅ អនុវត្តជាក់ស្តែងបានចំនួន ៥.៣០៦.៧៧០.០៣៤ រៀល មានប្រមាណ ៩៤,៤៨% នៃថវិកាកែតម្រូវដែលមានចំនួន ៥.៦១៧.០០០.០០០ រៀល
- **-ជំពូក ៦២** ៖សេវាខាងក្រៅផ្សេងៗ អនុវត្តជាក់ស្តែងបានចំនួន ២.៩៩៩.៤៩០.៣២២ រៀល ស្មើ នឹង ៩០,២៦% នៃថវិកាកែតម្រូវ ដែលមានចំនួន ៣.៣២៣.០០០.០០០ រៀល
- **-ជំពូក ៦៥** ៖ឧបត្ថម្ភធន និងជំនួយសង្គម អនុវត្តជាក់ស្តែងបានចំនួន ៣០.០០០.០០០រៀល ស្មើនឹង ១០០% នៃច្បាប់ថវិកា ដែលមានចំនួន ៣០.០០០.០០០ រៀល ។







**គ-ការងារផ្គត់ផ្គង់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

-ប្រេងឥន្ធនៈ គិតជាទឹកប្រាក់សរុបចំនួន ៖ ១.៩៩៩.៥១៧.២៥០៛០០ ក្នុងនោះមានៈ-

+ ប្រេងម៉ាស៊ូត មានទឹកប្រាក់ ៖.......១.៦៩០.៤៩១.៧០០៛០០

+ ប្រេងសាំង មានទឹកប្រាក់ ៖..........៣០៤.២២៥.៥៥០៛០០

+ ប្រេងរំអិល មានទឹកប្រាក់ ៖................ ៤.៨០០.០០០៛០០

-សម្ភារការិយាល័យ មានទឹកប្រាក់ចំនួន៖ ....៣៧៦.៦៩០.០០០៛០០

-សម្ភារបរិក្ខារ និងសង្ហារឹម មានទឹកប្រាក់ចំនួន៖ ..... ៦៩៤.៦០៤.០០០៛០០

-ឯកសណ្ឋាន មានទឹកប្រាក់ចំនួន៖.......១៩៧.៥៦៥.០០០៛០០

**ឃ-ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៩ របស់មន្ទីរកសិកម្មខេត្តស្ទឹងត្រែង កំពង់ស្ពឺ ព្រះសីហនុ កណ្តាល កំពង់ឆ្នាំង កំពង់ចាម រតនគីរី ពោធិ៍សាត់ កែប ស្វាយរៀង ព្រៃវែង ប៉ៃលិន អគ្គនាយកដ្ឋានកសិកម្ម ស្ថានីយ៍ទួលសំរោង, មណ្ឌលកសិកម្មទន្លេបាទី មណ្ឌលកសិកម្មក្បាលពោធិ៍ ស្ថានីយ៍គោកត្រប់ ស្ថានីយ៍តាស្ទាង ស្ថានីយ៍ពោធិ៍លាស់ ស្ថានីយ៍ម្រេចវាលរេញ កសិដ្ឋានចំការលើ ស្ថានីយ៍ព្រៃផ្តៅ ស្ថានីយ៍បន្ទាយដែក មណ្ឌលកសិកម្មកប់ស្រូវ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម សាលាជាតិកសិកម្មព្រែកលៀប វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានកសិ-ឧស្សាហកម្ម អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលជលផល អធិការដ្ឋានរដ្ឋបាលជលផល

ខាងត្បូងបឹងទន្លេសាប មេគង្គ ចតុមុខ សមុទ្រ រដ្ឋបាលព្រៃឈើ អធិការដ្ឋាន រដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប ខាងត្បូងបឹងទន្លេសាប មេគង្គ និងឈូងសមុទ្រ។

-ចូលរួមពិនិត្យ វាយតម្លៃនូវគុណភាពបច្ចេកទេស នូវទ្រព្យសម្បត្តិចាស់ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើត ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ មន្ទីរកសិកម្ម ខេត្តកំពង់ឆ្នាំង បាត់ដំបង បន្ទាយមានជ័យ កោះកុង នាយកដ្ឋានកិច្ចការរដ្ឋបាលចំការកៅស៊ូឡាបានសៀក ខេត្តរតនគីរី សាលាជាតិកសិកម្មកំពង់ចាម នាយកដ្ឋានគ្រឿងយន្តកសិកម្ម អគ្គាធិការដ្ឋាន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានផែនការ និងស្ថិតិ និងនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

-ចូលរួមត្រួតពិនិត្យទ្រព្យសម្បត្តិរបស់មន្ទីរកសិកម្មខេត្តកោះកុង ដែលត្រូវផ្ទេរជូនមន្ទីរកសិកម្មខេត្តព្រះសីហនុ

-ចូលរួមពិនិត្យ និងរៀបចំកំណត់ហេតុប្រគល់-ទទួលថវិកា សម្ភារ ទ្រព្យសម្បត្តិរដ្ឋ និងបញ្ឈប់បញ្ជីសម្រាប់ប្រធានរដ្ឋបាលព្រៃឈើចាស់ និងសាកលវិទ្យាធិការចាស់ ព្រមទាំងបើកបញ្ជីសម្រាប់ប្រធានរដ្ឋបាលព្រៃឈើ និងសាកលវិទ្យាធិការរង់ទទួលបន្ទុក រួម ចូលកាន់តំណែងថ្មី

-ចូលរួមត្រួតពិនិត្យឃ្លាំងស្តុកជីគម្រោង KR2 2008 ដែលបានខូចខាត ដោយគ្រោះធម្មជាតិនៅខេត្ត កំពង់ចាម និង ខេត្តព្រៃវែង

-ចុះពិនិត្យ និងតាមដានការលក់ជីជំនួយឥតសំណងរបស់ប្រទេសជប៉ុនឆ្នាំ ២០០៨ នៅខេត្ត បាត់ដំបង, បន្ទាយមានជ័យ និង ខេត្តសៀមរាប

-ចូលរួមប្រគល់-ទទួលទ្រព្យសម្បត្តិជាថ្នូរ នៃការដោះដូរទីតាំងដីមន្ទីរកសិកម្មខេត្ត ដីអតីតការិយាល័យ រុក្ខាប្រមាញ់ និងដីអតីត ការិយាល័យជលផល ខេត្តបន្ទាយមានជ័យ

-ចូលរួមពិភាក្សាការជួរពាក់ព័ន្ធអគារ ០១កន្លែង ស្ថិតនៅផ្លូវមុនីយ៉ាត កែងផ្លូវជ័យវរ្ម័នទី៧ ក្នុងក្រុមទី១ ភូមិទី១៣សង្កាត់ កំពង់ចាម របស់អគ្គនាយកដ្ឋានកៅស៊ូ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌ

-ចូលរួមចុះស្រាវជ្រាវបាតុភាពនៅមន្ទីរកសិកម្ម ខេត្តស្ទឹងត្រែង

-ចូលរួមត្រួតពិនិត្យ បិទបញ្ជីចំណូល-ចំណាយ និងបញ្ជីសារពើភ័ណ្ឌឆ្នាំ ២០០៩ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិ កសិកម្មកំពង់ចាម និងសាលាជាតិកសិកម្ម ព្រែកលៀប

-ចុះពិនិត្យជាក់ស្តែង និងជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្តាឆ្នាំនីមួយៗ នៅមន្ទីរកសិកម្ម ខេត្តកំពង់ធំ

-រៀបចំប្រកាសផ្ទេរម៉ូតូម៉ាក WIN MTC 110-11 ចំនួន ០២គ្រឿង ពីនាយកដ្ឋាននីតិកម្មកសិកម្ម ឱ្យស្ថិត នៅក្រោមការ គ្រប់គ្រងរបស់មន្ទីរកសិកម្មខេត្តតាកែវ

-បានចូលរួមប្រជុំជាមួយ គណ:កម្មការសារពើភ័ណ្ឌសាលាជាតិកសិកម្មព្រែកលៀប ក្នុងការវាយតម្លៃដីធ្លី-អគារ

-ចូលរួមចុះពិនិត្យ និងវាយតម្លៃភាពត្រឹមត្រូវ នៃការដោះដូរស្រូវពូជ IR 66 ចំនួន ១០០ តោន នៅមន្ទីរកសិកម្មខេត្ត បន្ទាយមានជ័យ

-ចូលរួមជាមួយគណ:កម្មការអន្តរក្រសួងចុះសិក្សា ពិនិត្យ និងវាយតម្លៃការដោះដូរទីតាំងឃ្លាំងកសិកម្ម ស្រុក អូររាំងឪ របស់មន្ទីរកសិកម្មខេត្តកំពង់ចាម

-ចូលរួមចុះពិនិត្យចំណូល ចំណាយថវិការដ្ឋ ថវិកាសាកលវិទ្យាល័យផ្ទាល់ ថវិកាគម្រោង និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-ចូលរួមជាមន្ត្រីបណ្តុះបណ្តាលស្តីពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្រោមគម្រោងស្តីពី ការលើកកម្ពស់សមត្ថភាព មន្ត្រីរាជការ និងពង្រឹងក្របខណ្ឌច្បាប់ ដល់មន្ទីរកសិកម្មរាជធានី-ខេត្ត

-ចូលរួមចុះពិនិត្យ និងស្រាវជ្រាវជាក់ស្តែងដីចំនួន ០៥កន្លែង របស់មន្ទីរកសិកម្មខេត្តបាត់ដំបង ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌ

-ចុះពិនិត្យ និងស្រាវជ្រាវជាក់ស្តែងទីតាំងដីអតីតៈការិយាល័យរុក្ខាប្រមាញ់ ខេត្តព្រះវិហារ

-ចូលរួមចុះពិនិត្យ និងប្រកាសផ្ទេ ដីទំហំ ៤៨.០០០ម² របស់មន្ទីរកសិកម្មខេត្តស្ទឹងត្រែង ជូនរដ្ឋបាលជលផល។

**ង-ការងាររៀបចំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ:**

សម្រេចអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈដើម្បីផ្គត់ផ្គង់ទំនិញ សម្ភារបរិក្ខា ការងារសាងសង់-ជួសជុល និងសេវាកម្មផ្សេងៗ ជូនក្រសួង និងអង្គភាពនានាក្រោមឱវាទក្រសួងបានចំនួន ៣៦ គម្រោង (ដេញថ្លៃប្រកួតប្រជែងក្នុងស្រុកចំនួន ១០គម្រោង ពិគ្រោះថ្លៃចំនួន ០៩គម្រោង ស្ទង់តម្លៃចំនួន ០២គម្រោង ចរចាថ្លៃចំនួន ៨គម្រោង និងដេញថ្លៃចំនួន ១៧គម្រោង) ។

**ច-សកម្មភាពការងារគ្រប់គ្រងថវិកាវិនិយោគ**

**ច.១-គម្រោងជំនួយបរទេស និង ថវិកាបដិភាគរបស់រាជរដ្ឋាភិបាល**

ក្នុងឆ្នាំ ២០១០ នេះ មានគម្រោងជំនួយបរទេសចំនួន ៥ បានដំណើរការ ហើយបានស្នើសុំដកថវិកាប្រើប្រាស់ សម្រាប់គាំទ្រគម្រោងមានទឹកប្រាក់សរុបចំនួន ២.៣៦៣.៣៣៥,៨៦ ដុល្លារអាមេរិក ក្នុងនោះថវិកាបដិភាគពីរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៧៥៧.៨៤២,០៤ ដុល្លារអាមេរិក ថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ២៦០.២៥៤,៦៩ដុល្លារអាមេរិក និងពីសហគមន៍ អឺរ៉ុប (EU) ចំនួន ១.៣៤៥.២៣៩,១៣ ដុល្លារអាមេរិក ។

**ច.២-ចំនួនលេខគណនីធនាគារ (Bank Account No.)**

ក្នុងឆ្នាំ ២០១០ នេះ ចំនួនលេខគណនីធនាគារបានថយចុះពី ៤៧គណនី នៅឆ្នាំ ២០០៩ មកនៅត្រឹមតែចំនួន ២៩ គណនី នៅចុងឆ្នាំ២០១០នេះ (គណនីចំនួន ១៨ បានសុំបិទដោយសារគម្រោងត្រូវបញ្ចប់)។ ចំនួនលេខគណនីដែលបានបិទនោះ ផ្អែកលើព័ត៌មានប្រចាំខែពីបណ្តាអង្គភាពពាក់ព័ន្ធក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្រសួងបានផ្តល់របាយការណ៍ប្រចាំខែ ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិស្តីអំពី ស្ថានភាពប្រើប្រាស់គណនីធនាគាររបស់អង្គភាព ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគម្រោងនានានៅតាមប្រព័ន្ធធនាគារដែលបាន និងកំពុងបម្រើការងារ ក្នុងវិស័យកសិកម្ម ។

**ច.៣-ប្រាក់កក់ និងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច**

ប្រាក់កក់ជានាអនុវត្តកិច្ចសន្យាក្នុងឆ្នាំ ២០១០ នេះ មានក្រុមហ៊ុនវិនិយោគចំនួន ១២ ក្រុមហ៊ុនបានបង់ប្រាក់កក់ ជានាការអនុវត្តកិច្ចសន្យាចូលធនាគារជាតិនៃកម្ពុជា មានទឹកប្រាក់សរុបចំនួន ៥៩៨.១០០,០០ដុល្លារអាមេរិក។

#### ៥.៧.៣.២- វាយតម្លៃ និងសំណើ

ជារួមបានឆ្លុះបញ្ចាំងឱ្យឃើញថា ការខិតខំប្រឹងប្រែងអនុវត្ត កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលមានក្រុមការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងដោយបណ្តុំនូវគ្រប់សមាសភាពពីអង្គភាពពាក់ព័ន្ធរបស់ក្រសួង។ ក្រុមការងារនេះ គឺជាយន្តការមួយជាអ្នកដឹកនាំ និងជម្រុញការអនុវត្ត ដល់បណ្តាអង្គភាពក្រោមឱវាទក្រសួងទាំងអស់ លើការគ្រប់គ្រងចំណូល ចំណាយ និងទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែទោះជាយ៉ាង នេះក្តីក៏នៅមានជួបការលំបាកខ្វះទៀត ជាពិសេសសមត្ថភាព និងចំណេះដឹងរបស់មន្ត្រី ដែលជាអ្នកអនុវត្តថវិកាតម្រូវតាំងឱ្យទាន់កម្មវិធីកំណែទម្រង់ ដើម្បីឱ្យការគ្រប់គ្រង និងអនុវត្តថវិកាឱ្យបានកាន់តែប្រសើរចាំបាច់ត្រូវបណ្តុះបណ្តាលបន្ថែម និងត្រូវមានការចូលរួមដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវពីថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីពាក់ព័ន្ធទាំងអស់។

#### ៥.៧.៣.៣- វិធានការ

-ប្រឹងប្រែងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង

-ប្រឹងប្រែងពង្រីកថវិកាតាមកម្មវិធីដល់បណ្តាអង្គភាពក្រោមឱវាទ

-បន្តសហការជាមួយប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ២០១០នៅបណ្តាគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាលឱ្យបានទាន់ពេលវេលា

-សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់ទុនគ្រាដំបូងឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានចប់សព្វគ្រប់

-ចុះត្រួតពិនិត្យ និងពង្រឹងការងារគណនេយ្យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជម្រុញ ការប្រមូលចំណូលបង់ចូលថវិការដ្ឋឆ្នាំ ២០១១ នៅមន្ទីរកសិកម្មខេត្ត-រាជធានី និងអង្គភាពថ្នាក់កណ្តាល

-ត្រៀមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌលម្អិតឆ្នាំ២០១០ នៅតាមមន្ទីរកសិកម្មរាជធានី-ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

-សហការជាមួយអង្គភាពពាក់ព័ន្ធរៀបចំផែនការលទ្ធកម្មប្រចាំ ២០១១ឱ្យបានទាន់ពេលវេលា

-បន្តខិតខំប្រឹងប្រែងរៀបចំឯកសារកិច្ចលទ្ធកម្មសាធារណៈ ឱ្យបានទាន់ពេលវេលា បន្ទាប់ពីទទួលបានលិខិតគោល ការណ៍ជានាចំណាយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខិតខំសិក្សាស្វែងយល់នូវរាល់លិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ

-សហការជាមួយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង គណនេយ្យ ហិរញ្ញវត្ថុ និង លទ្ធកម្មតាមអនុក្រឹត្យលេខ ១៤

-ជំរុញរៀបចំដំណើរការគ្រប់គ្រង និងរៀបចំកិច្ចការយកថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ឱ្យដំណើរការទៅមុខ ។

## ៥.៨- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍

### ៥.៨.១-លទ្ធផល

#### ៥.៨.១.១- គម្រោង JICA

#### ក- លទ្ធផល

**ក-១-** អង្គការ JICA បានផ្តល់ឧបករណ៍ពិសោធន៍ និងរៀបចំដំឡើងនូវឧបករណ៍កសិកម្ម ដែលគិតជាទឹកប្រាក់សរុបចំនួន ២២០.០៧៧ ដុល្លារអាមេរិក

- វគ្គបណ្តុះបណ្តាលលើកទី ២ បានសម្រេចការវិភាគសារធាតុចំនួន ៨ ដូចជា P, K, Cu, Zn, Fe, Mn, Ca & Mg) នៅក្នុងដីគីមី និងបានវិភាគជាតុសកម្មរបស់ថ្នាំកសិកម្មចំនួន ១១ សារធាតុ ថវិកាសរុបចំនួន ៦២.២៥១ ដុល្លារអាមេរិក

- នៅក្នុងវគ្គបណ្តុះបណ្តាលលើកទី ៣ នាយកដ្ឋានទាំងពីរបានកំពុងចាប់ផ្តើមធ្វើការវិភាគសារធាតុ N និង S នៅក្នុងដីគីមី ដែលមានចំនួន ៤៦ សំណាក។ ការវិភាគជាតុសកម្មថ្នាំកសិកម្មចំនួន ១០ សារធាតុបានកំពុងចាប់ ផ្តើមធ្វើការវិភាគ និងវាយតម្លៃ ដោយប្រើប្រាស់ឧបករណ៍ HPLC និង UV-Vis ថវិកាសរុបចំនួន ១៥៧.៨២៦ ដុល្លារអាមេរិក។

**ក-២-** សកម្មភាពការងារផ្សព្វផ្សាយស្តីពី ការប្រើប្រាស់ថ្នាំឱ្យបានត្រឹមត្រូវ និងគុណភាពដីគីមី និង ថ្នាំកសិកម្មបានរៀបចំប័ណ្ណប្រកាស ដើម្បីផ្សព្វផ្សាយជាសាធារណៈនូវថ្នាំកសិកម្មហាមឃាត់ និងរបៀបប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីកំចាត់សត្វមមាចត្នោតលើដំណាំស្រូវ និងបានបកប្រែកាសែតវីដេអូដែលអាជ្ញាធរជី និងថ្នាំកសិកម្ម បានផ្តល់ជូនពីភាសាហ្វីលីពីន មកជាភាសាខ្មែរដែលមានចំណងជើងថា "ការប្រើប្រាស់ថ្នាំកសិកម្មឱ្យបានត្រឹមត្រូវ។

-បានចងក្រងកូនសៀវភៅដើម្បីផ្សព្វផ្សាយដល់អាជីវករលក់ថ្នាំកសិកម្ម

-បានចុះផ្សព្វផ្សាយ និងបានចែកប័ណ្ណប្រកាស និងកូនសៀវភៅដែលគម្រោងបានធ្វើ ដល់អាជីវករលក់ថ្នាំកសិកម្មក្នុងស្រុកកៀនស្វាយ និងកោះធំ

-បានសហការការងារជាមួយអង្គការ FAO , VVOB និង GIZ ដើម្បីពង្រីកការផ្សព្វផ្សាយ និងចែកប័ណ្ណប្រកាសទាំងនោះឱ្យបានច្រើនបន្ថែមទៀត។

**ខ- វិធានការ**

-ពង្រឹងសមត្ថភាពការងារពិសោធន៍ដីគីមី ថ្នាំកសិកម្ម និងមន្ទីរពិសោធន៍

-សេចក្តីព្រាងនៃលិខិតបទដ្ឋានច្បាប់ ដែលពាក់ព័ន្ធនឹងតម្រូវការបមាណីសម្រាប់ការចុះបញ្ជិកា និងក្រោយពេលចុះបញ្ជិកានៃដីគីមី និងថ្នាំកសិកម្ម

-ជំរុញការអនុវត្តន៍កម្មវិធីផ្សព្វផ្សាយស្តីពី ការប្រើប្រាស់ឱ្យបានត្រឹមត្រូវ និងគុណភាពដីគីមី និងថ្នាំកសិកម្ម

### ៤.៨.១.២- គម្រោងអេកូសន

គម្រោងអេកូសនបានចាប់ផ្តើមដំណើរការនាខែ ធ្នូ ឆ្នាំ ២០០៥ ហើយចាប់អនុវត្តសកម្មភាពដំបូងនៅសហគមន៍មូលដ្ឋាននៅពាក់កណ្តាលឆ្នាំ ២០០៦ តាមរយៈគម្រោងខ្នាតតូចមានឈ្មោះថា "គម្រោងឆាប់ទទួលផល"។ ការអនុវត្តនូវគម្រោងទាំងនោះ មានគោលបំណងពីរគឺ ទី១)បម្រើជាវិធានការលើកកម្ពស់ភាពជឿជាក់ ក្នុងការអនុវត្តសកម្មភាពជួយដល់អ្នកភូមិ និងភ្នាក់ងាររាជរដ្ឋាភិបាល និងទី២) ការកសាងសមត្ថភាពអនុវត្តជាក់ស្តែងដល់បុគ្គលិកគម្រោងផងដែរ។

បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយនៃការចុះហត្ថលេខាលើកិច្ចសន្យាទាំងអស់នៅថ្ងៃ ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧ គម្រោងបានចុះកិច្ចសន្យាក្នុងទឹកប្រាក់ ២៤,៥ លានអឺរ៉ូ (៩៤,១%) នៃថវិកាសន្យាសរុបរបស់សហភាពអឺរ៉ុប (២៥ លានអឺរ៉ូ) ក្នុងនោះមានកិច្ចសន្យាខ្នាតធំចំនួន ៤៤ និងកិច្ចសន្យាខ្នាតតូចចំនួន១៨៧។

### ក- លទ្ធផល

#### ក.១- លទ្ធផលសម្រេចបានធៀបនឹងគោលបំណងរួមរបស់គម្រោង (ការកាត់បន្ថយភាពក្រីក្រ)

*ការធ្វើអង្កេតមូលដ្ឋាននៅខែ សីហា ឆ្នាំ ២០១០ បានបង្ហាញថា ៤០% នៃគ្រួសារកសិករនៅក្នុងភូមិគោលដៅបានរួចផុតពីបន្ទាត់ភាពក្រីក្រ ០,៣៩ ដុល្លា/ម្នាក់/ថ្ងៃ (កំណត់ដោយវិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៤) ដែលក្នុងនោះ គម្រោងអេកូសនចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្របានចំនួន ១១%។ គម្រោងអេកូសនមានផលប៉ះពាល់វិជ្ជមានទៅលើ ការកាត់បន្ថយភាពក្រីក្រក្នុងចំណោមកសិករទទួលផលផ្ទាល់ចំនួន ១.៨០០ នាក់ ដែលជួយកាត់បន្ថយភាពក្រីក្រ ក្នុងចំណោមកសិករផ្ទាល់ទាំងនេះ បានរហូតដល់ ២១%។ ការអង្កេតនេះ ក៏បានរកឃើញបន្ថែមទៀតថា មានគ្រួសារប្រមាណ ៥០% នៅ ក្នុងភូមិគោលដៅមានកំណើនប្រាក់ចំណូលក្នុងគ្រួសារ។*

#### ក.២- <u>លទ្ធផលសម្រេចបានធៀបនឹងគោលបំណងគម្រោង (ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច)</u>

*សន្តិសុខស្រូវអង្ករ សម្រេចបាន ៥២% (លើផែនការគម្រោង ៥០%) នៃគ្រួសារកសិករទាំងអស់មានស្រូវ អង្ករហូបគ្រប់គ្រាន់ ធៀបទៅនឹងទិន្នន័យមូលដ្ឋានឆ្នាំ ២០០៦ ដែលគ្រួសារមានស្រូវអង្ករហូបគ្រប់គ្រាន់តែ ២៩%។ រយៈ ពេលខ្វះខាតស្រូវអង្ករជាមធ្យមត្រូវបានកាត់បន្ថយពី ៤ ខែ មកត្រឹម ២,៤ ខែ។ ប្រជាពលរដ្ឋចំនួន ៨៨% ដែលបានសម្ភាសន៍បញ្ជាក់ឱ្យដឹងថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់នូវការចូលរួមពាក់ព័ន្ធនឹងបញ្ហារបស់សហគមន៍ (ការពង្រឹងអំណាចដល់សហគមន៍) ហើយចំនួនស្ត្រីត្រូវបានពិគ្រោះយោបល់ក្នុងកិច្ចអភិវឌ្ឍសហគមន៍ (សមភាពយេនឌ័រ) មានការកើនឡើងទ្វេដង (៦១% ធៀបនឹង ៣៣% នៅក្នុងទិន្នន័យអង្កេតមូលដ្ឋានឆ្នាំ២០០៦)។ មានកំណើនចំនួន ២៣% នៃគ្រួសារដែលមានទស្សនៈវិស័យវិជ្ជមានកាន់តែប្រសើរចំពោះអនាគតរបស់ពួកគេ (ឆ្នាំ២០០៦ មាន ១១,៦% ឆ្នាំ២០១ មាន ៣៤,៩%)។ ប៉ុន្តែចំណាកស្រុកតាមរដូវកាលមានការកើនឡើងគួរឱ្យកត់សម្គាល់រយៈកាល ២ ឆ្នាំចុងក្រោយនេះពី ៣០% ទៅ ៤២% ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក និងខ្យល់ព្យុះកេតសាណា។*

### ខ- សន្និដ្ឋាន

*លទ្ធផលប្រកបដោយផ្លែផ្ការយៈពេល ៥ឆ្នាំ នៃការរួមចំណែករបស់គម្រោងអេកូសន ក្នុងការអភិវឌ្ឍន៍ជនបទ នៅកម្ពុជានាពេលនេះ (២០០៦-២០១០) បានឆ្លុះបញ្ចាំងឱ្យឃើញនូវការយកចិត្តទុកដាក់ និងការទទួលខុសត្រូវរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសហភាពអឺរ៉ុប ដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការល្អក្នុងការអភិវឌ្ឍន៍ជនបទ និងការចូលរួមកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទកម្ពុជា។*

### ៥.៨.១.៣- គម្រោងព័ត៌មានទីផ្សារកសិកម្មនៅកម្ពុជា (CAMIP)

*គម្រោងព័ត៌មានទីផ្សារកសិកម្មកម្ពុជា-កាណាដា* (CAMIP) *គឺជាគម្រោងដែលគាំទ្រ ដោយភ្នាក់ងារ អភិឌ្ឍន៍អន្តរជាតិកាណាដា* (CIDA) *មានថវិកាសរុបចំនួន ៤,២០០,០០០ ដុល្លារកាណាដា ត្រូវបានអនុវត្តរយៈពេល ៤ ឆ្នាំគឺចាប់ពីឆ្នាំ ២០០៦ ដល់ ២០១០។ គម្រោងនេះ បង្កើតឡើងដើម្បីជួយកែលម្អ និងពង្រឹងសមត្ថភាពសេវាព័ត៌មានទីផ្សារកសិកម្ម អនុវត្តគម្រោង* CAMIP *បានអនុវត្តទៅលើរាជធានី ខេត្តចំនួន ១៤ រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពត ព្រះសីហនុ ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ។ លទ្ធផលរំពឹងទុកនៃគម្រោងគឺ ដើម្បីបង្កើនផលិតផលកសិកម្មក្នុងស្រុកជាពិសេសផលិតផលបន្លែ-ផ្លែឈើ បង្កើនប្រាក់ចំណូលកសិករ អាជីវករ។*

សមាសភាពគម្រោងមានពីរផ្នែកសំខាន់ៗគឺ ផ្នែកសេវាព័ត៌មាន ទីផ្សារកសិកម្មផ្សព្វផ្សាយតាមរយៈវិទ្យុ (AM និងFM) ទូរទស្សន៍ព្រឹត្តិបត្រព័ត៌មានប្រចាំខែ-ឆ្នាំគេហទំព័រ (www.agriculturalmarketinformation.org.kh) និងសារ SMS តាមទូរស័ព្ទដៃ។

ផ្នែកអភិវឌ្ឍន៍ទីផ្សារកសិកម្ម ផ្តោតសំខាន់ទៅលើសាលារៀនទីផ្សារកសិករ (FMS) លើដំណាំបន្លែ-ផ្លែឈើ ដល់ក្រុមកសិករ និងអាជីវករ នៅខេត្តគោលដៅតាមរយៈគ្រូបង្គោល FMS រៀបចំប្រជុំការងារ ជំនួញរវាងកសិករ អាជីវករ និងទស្សនកិច្ចសិក្សា ដើម្បីដកស្រង់បទពិសោធន៍នៅក្នុង និងក្រៅប្រទេស។ លទ្ធផលសម្រេចបានរួមមានៈ អាជីវករចំនួន ៦២០ នាក់ បានចុះឈ្មោះក្នុងប្រព័ន្ធ SMS និងបានបញ្ជូនព័ត៌មាន តម្លៃកសិផលមកក្នុងប្រព័ន្ធ។ គ្រូបង្គោល FMS និង ក្រុមអាជីវករចំនួន ១១៨ នាក់ បានទៅទស្សនកិច្ចសិក្សា នៅប្រទេសវៀតណាម ដើម្បីដកស្រង់ពិសោធន៍ពីការងារផលិតកម្ម និងទីផ្សារបន្លែ-ផ្លែឈើ និង មានកសិករ-អាជីវករចំនួន ៨២២ នាក់ ក្នុងនោះ ៤៣៦ នាក់ ជាស្ត្រីបានចូលរួមក្នុង ៣២ វគ្គ ស្តីពីការប្រជុំពិភាក្សា ពីជំនួញផលិតផលបន្លែរវាងកសិករ និង អាជីវករ។

គ្រូបង្គោល FMS ចំនួន ១២៨ នាក់ ស្ត្រីចំនួន ៤៥ នាក់ ត្រូវបានបណ្តុះបណ្តាលក្នុងចំនួន ០៥ វគ្គ ដែលមានសិក្ខាកាមចូលរួមពីមន្ត្រីកសិកម្មរាជធានី ខេត្ត អង្គការជាតិ និងអន្តរជាតិនានា។

កសិករចំនួន ៤,៤០១ នាក់ ក្នុងនោះស្ត្រី ២,៣៦៥ នាក់បានចូលរួម ក្នុង ១៧៩ វគ្គ FMS នៃ ១៣ ខេត្តគោលដៅ ចាប់ពីឆ្នាំ ២០០៨-២០១០ ដែលវគ្គបណ្តុះបណ្តាលនេះ បានធ្វើឱ្យកសិករអាចទទួលបានប្រាក់ចំណូល កើនឡើងពី ២០-៤០%/គីឡូក្រាម ស្មើនឹង ១៤០ ដុល្លា/ឆ្នាំ នៃមួយ ប្រភេទផលិតផលក្រោយពីពួកគាត់អនុវត្តតាមវិធីសាស្ត្រ FMS។

### ៨.៨.១.៤- គម្រោងកម្មវិធី CAVAC

#### ក- លទ្ធផល

ក្នុងឆ្នាំ ២០១០ កម្មវិធីបានផ្តួចផ្តើម គម្រោងការស្រាវជ្រាវបីធំៗ ដោយមានដៃគូរសំខាន់ៗដូចជាមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) អគ្គនាយកដ្ឋានកសិកម្ម (GDA) និងសាកលវិទ្យាល័យ កសិកម្ម (RUA) ស្តីពី ផលិតកម្មបន្លែ ការដាំដុះដំណាំស្រូវ និងបសិដ្ឋកម្ម។ កម្មវិធីបានសាងសង់ ប្រឡាយចំនួនពីរ ដែលកសិករអ្នកដាំដុះ លើសពី១០០០គ្រួសារ ទទួលអត្ថប្រយោជន៍អំពី ការស្រោចស្រពពេញមួយឆ្នាំ។ ការជ្រើសរើសក្រុមការងារមួយភាគធំ បានជានាថា កម្មវិធីកាវ៉ាក់បានបំពេញបានភាគច្រើនបំផុត តាមអ្វីដែលមានព្រមព្រៀង នៅក្នុងផែនការការងារប្រចាំឆ្នាំ២០១០ លទ្ធផលជារួម ៖

-គណៈកម្មាការសម្របសម្រួលថ្នាក់ខេត្ត ត្រូវបានតែងតាំង ហើយនៅពេលបច្ចុប្បន្ននេះ កាវ៉ាក់អាច បើកការិយាល័យ និងរៀបចំកិច្ចប្រជុំនានា

-ការពិគ្រោះយោបល់ អំពីផែនការការងារប្រចាំឆ្នាំ (AWP) ត្រូវបានដឹកនាំ ឲ្យមានដំណើរការ និង AWP ២០១១ ត្រូវបានប្រគល់ជូនសំរាប់ការសម្រេចចិត្ត

-ការរើសបុគ្គលិកគឺជិតបានបញ្ចប់ហើយ និងបុគ្គលិកក៏បាន ទទួលការបណ្តុះបណ្តាលបឋម និងបានបំពេញប្រតិបត្តិការ តាមគម្រោងថវិការ ក្នុង AWP ២០១០ មួយភាគធំ។ គម្រោងធំៗមួយ ចំនួនដូចជា គម្រោងការសម្របសម្រួលថវិការគាំទ្រគោលនយោបាយ និងការសិក្សាអំពីលទ្ធភាព ដែលអាច

មានទឹកផ្គត់ផ្គង់ នៅមិនទាន់បានចេញជារូបរាងនៅឡើយ ហើយនឹងធ្វើឲ្យថយចុះនូវការចាយវាយជាក់ស្តែងជាទូទៅ។ ការពន្យារពេលជាធម្មតារវាងការប្រតិបត្តិ និងការចាយវាយដោយជាក់ស្តែង នឹងជាហេតុបណ្តាលឱ្យមាន ការចំណាយថវិការជាក់ស្តែងត្រូវបានពន្យារពេល។

**ក.១- ការអនិវឌ្ឍន៍កសិពាណិជ្ជកម្ម**

ការវិភាគខ្សែសង្វាក់ផលិតកម្មចំនួនបី ការសិក្សាអំពី គម្រោងផែនការណ៍ ទីផ្សារវត្ថុធាតុដើម ត្រូវបានបញ្ចប់។ កិច្ចព្រមព្រៀងបី ត្រូវបានបញ្ចប់ ជាមួយនឹងកសិពាណិជ្ជកម្ម ក្នុងឆ្នាំ២០១០ ស្របពេលការពិភាក្សាដទៃទៀតកំពុងដំណើរការ។ កិច្ចការងារដែលធ្វើជាមួយនឹងទឹកទន្លេ ទីផ្សារជាក់ស្តែងនានា ត្រូវបានផ្លាស់ប្តូរទៅជា កិច្ចអន្តរាគមន៍នៃការជជែកពិភាក្សាជាសាធារណៈ។

**ក.២- ការគ្រប់គ្រងទឹក**

សហការជាមួយក្រសួងធនធានទឹកនិងឧតុនិយម (MOWRAM) និងមន្ទីរធនធានទឹក និងឧតុនិយម (PDWRAMs) បានរៀបចំគម្រោងជាពសាស្ត្រចំនួន១១ សម្រាប់ការវិនិយោគជាសក្តានុពលនេះគឺទ្វេដង នៃផែនការដើមដំបូង ដែលមានតែ ចំនួនបួនទៅប្រាំមួយគម្រោង។

ការសិក្សាអំពី លទ្ធភាពដែលអាចមានទឹកផ្គត់ផ្គង់មួយ ត្រូវបានដាក់ដេញថ្លៃ និងវាយតម្លៃ ហើយនឹងចាប់ផ្តើមក្នុងខែមករាឆ្នាំ២០១១។ ការដេញថ្លៃសម្រាប់ការសិក្សាទីពីរ ត្រូវបានកំណត់ពេល ជាថ្មីឡើងវិញ រហូតដល់ដើមឆ្នាំ២០១១ និងការសិក្សាអំពី ម៉ាស៊ីនបូមទឹកកំពុងស្ថិតក្រោមការអនុវត្តន៍។

**ក.៣- ការស្រាវជ្រាវ និងការផ្សព្វផ្សាយ**

សកម្មភាពស្រាវជ្រាវនានា កំពុងដំណើរការយ៉ាងល្អ ដោយមានការសិក្សាធំៗចំនួនបី កំពុងស្ថិតក្រោមការអនុវត្តន៍។ សំណើទីបួន គឺរៀបចំជាស្រេចហើយ សម្រាប់ដាក់ជូនគណៈកម្មាការដឹកនាំគម្រោងថ្នាក់ជាតិ (NSC) អនុម័ត។ សម្រាប់ការផ្សព្វផ្សាយ ការវិភាគអំពីសម្ភារៈដែលមានស្រាប់ ត្រូវបានបញ្ចប់ ការបណ្តុះបណ្តាលកសិករគំរូ បានកំពុងនឹងដកការពិសោធន៍ និងការបណ្តុះបណ្តាលដែលបង្កប់អត្ថន័យជ្រាលជ្រៅ ដែលនឹងធ្វើឡើងជាមួយ អ្នកផ្តល់ឲ្យដោយវិស័យឯកជនត្រូវបានគាំទ្រ។ ការវាយតម្លៃអំពី ការផ្សព្វផ្សាយពត៌មាន ត្រូវបានពន្យារពេលទៅ ខែមករានា ឆ្នាំ២០១១វិញ។

**ក.៤- បរិយាកាសដែលអំនោយផលដល់ពាណិជ្ជកម្ម**

-រៀបចំបរិយាកាស ដើម្បីផ្តល់អំណោយផលល្អដល់ផ្នែកពាណិជ្ជកម្មត្រូវបានផ្អាកការជ្រើសរើស ហើយប្រវត្តិរូបត្រូវបានផ្ញើរជូនបន្តទៅ ភាគីជាដៃគូ និងទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិ(AusAID) កាលពីខែវិច្ឆិកា ឆ្នាំ២០១០។

-សិក្ខាសាលាស្តីអំពី គោលនយោបាយនាំអង្ករចេញ ត្រូវបានរៀបចំធ្វើរួមគ្នា ជាមួយនឹង MAFF និង MOWRAM ដើម្បីអង្កេតអំពីវិធីសាស្ត្រល្អបំផុតដែលការ៉ាក់អាចគាំទ្រដល់ គោលនយោបាយស្រូវអង្ករ។ GDA CARDI និងមន្ទីរកសិកម្មខេត្ត បានដាក់ជូនសំណើដើម្បីទទួលបានការគាំទ្រ ក្រោមការសម្របសម្រួលការផ្តល់មូលនិធិគាំទ្រគោលនយោបាយ។ គម្រោងនេះ បានគាំទ្រ MOWRAM ដោយផ្តល់នូវសារពើភ័ណ្ឌសម្រាប់គម្រោងជាពសាស្ត្រ (CSISIS)។

**ខ-បញ្ហាពាក់ព័ន្ធដល់កម្មវិធីផ្សេងៗទៀត**

ការវាយតម្លៃផ្នែកបរិស្ថានសម្រាប់គម្រោងជាពសាស្ត្រ ត្រូវបានបញ្ចប់ និងទីប្រឹក្សារយៈពេលខ្លីម្នាក់ បានធ្វើការវាយតម្លៃនាពេលថ្មីៗនេះ និងបានផ្តល់អនុសាសន៍កែលម្អ សម្រាប់ប្រព័ន្ធវាយតម្លៃ

ក្នុងគម្រោង។ អ្នកឯកទេសផ្នែកយេនឌ័រ គឺថ្មីៗនេះ កំពុងតែពិចារណាពីបញ្ហាយេនឌ័រដាក់លាក់សម្រាប់គម្រោង និងការសិក្សាពីវិសមភាពនៃពិការភាព ក៏កំពុងតែស្ថិតក្រោមការអនុវត្តន៍។

**៤.៨.១.៤- គម្រោងគ្រប់គ្រងដីធ្លីដោយចីរភាព (SLM)**

**ក- លទ្ធផល**

**ក.១- ររៀបចំកម្មវិធីជាតិប្រយុទ្ធប្រឆាំងនឹងឱនភាពដីនៅព្រះរាជាណាចក្រកម្ពុជា**

ក្នុងឆ្នាំ២០១០ នេះ គម្រោងសហការជាមួយ នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងបានរៀបចំឯកសារ កម្មវិធីសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងឱនភាពដីនៅកម្ពុជាសម្រាប់ឆ្នាំ ២០១១-២០២០ បានបញ្ចប់ ១០០% ដែលឯកសារនេះ មានពីរផ្នែក គឺផ្នែក (ក) មានចំនួន ៥ជំពូក ដែលបរិយាយអំពី ស្ថានភាពទូទៅនៅប្រទេសកម្ពុជា និងផ្នែក (ខ) មានចំនួន ៦ជំពូក ដោយបរិយាយពីកម្មវិធីលម្អិតសម្រាប់អនុវត្តរយៈពេល១០ឆ្នាំ។

ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះ គម្រោងបានរៀបចំសិក្ខាសាលាថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ព្រមទាំងកិច្ចប្រជុំ ជាមួយក្រុមការងាររៀបចំកម្មវិធីសកម្មជាតិអំពី ការកសាងឯកសារកម្មវិធីសកម្មភាពជាតិនេះ បានចំនួន ១៣ លើក ដែលមានអ្នកចូល រួមសរុប ចំនួន ៣៣៨ នាក់ ស្ត្រី ៣០នាក់។

**ក.២- ការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនិងមន្ត្រីសមភាគី**

- គម្រោងបានពង្រឹងសមត្ថភាពមន្ត្រីសមភាគីចំនួន ១០លើក សរុបចំនួន ៨នាក់ ស្រី ១នាក់ ដែលក្នុងនោះមកពីនាយកដ្ឋានក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៧នាក់ ស្រី៣នាក់ និងមកពីក្រសួងបរិស្ថានចំនួន ១នាក់ អំពី បច្ចេកទេសវិភាគបញ្ហាឱនភាពដី វិធីសាស្ត្រប្រមូលព័ត៌មានពីការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងដីដោយចីរភាព វិធីសាស្ត្រធ្វើអង្កេតអំពី ការយល់ដឹងលើការគ្រប់គ្រងដីដោយចីរភាព ការចងក្រងមេរៀនអនុវត្ត គម្រូកាសាអង់គ្លេស ការគ្រប់គ្រងគម្រោង និងបច្ចេកទេសរៀបចំផែនទីភូមិសាស្ត្របានចំនួន ៤នាក់។ ការពង្រឹងសមត្ថភាពនេះ បានធ្វើឡើងដោយការអនុវត្តការងារផ្ទាល់ជាមួយគម្រោង ការចូលរួមកិច្ចប្រជុំផ្សេងៗ ការចូលរួមវគ្គបណ្តុះបណ្តាល និងការចូលរួមសិក្ខាសាលានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គម្រោងក៏បានសហការជាមួយមជ្ឈមណ្ឌលកុំព្យូទ័រឱសាញ និងព័ត៌មានភូមិសាស្ត្រ ដើម្បីផលិតផែនទី ដែលទាក់ទងនឹងឱនភាពដីចំនួន១២ផ្ទាំងផងដែរ

- គម្រោងបានពង្រឹងសមត្ថភាពស្ថាប័នតាមរយៈការកសាងកម្មវិធីសកម្មភាពជាតិ ការវិភាគអំពីបញ្ហាឱនភាពដី និងការចងក្រងមេរៀនអនុវត្តគម្រូ របស់ស្ថាប័នពាក់ព័ន្ធផ្សេងៗទាំងក្នុងក្រសួង និងក្រៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានចំនួន ១០ លើក មានចំនួន អ្នកចូលរួមសរុប ២៥១ នាក់ ស្រី ៣០នាក់។

**ក.៣- ការបញ្ជ្រាបការគ្រប់គ្រងដីធ្លីដោយចីរភាព**

- គម្រោងបានសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផលិតនូវឯកសារវីដេអូ ដែលមានរយៈពេល១៩នាទីអំពីការគ្រប់គ្រងដីដោយចីរភាពនៅក្នុងប្រទេសកម្ពុជា ដើម្បីបញ្ជ្រាបព័ត៌មានអំពី បញ្ហាឱនភាពដីនៅកម្ពុជាទៅដល់ថ្នាក់ដឹកនាំប្រទេស និងប្រជាជននៅមូលដ្ឋានឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅ

- គម្រោងបានសហការជាមួយកម្មវិធីជំនួយខ្នាតតូចរបស់ UNDP/GEF នៃប្រទេសកម្ពុជា ដោយបានគាំទ្រថវិកា ទៅអង្គការសេដាក (CEDAC) និងអង្គការសែលអាហ្គ្រីត (CelAgrid)

ដែលកំពុងអនុវត្តដ សកម្មភាពនៅខេត្ត តាកែវ ដើម្បីអនុវត្តគម្រោងការអភិវឌ្ឍន៍ចម្រុះ សម្រាប់សន្តិសុខស្បៀង ក្នុងគោលបំណង ដើម្បីចងក្រងមេរៀនអនុវត្តគម្រូអំពីការគ្រប់គ្រងដីប្រកបដោយចីរភាពកម្រិតកសិដ្ឋានខ្នាតតូច។

- ឯកសារកម្មវិធីសកម្មភាពជាតិត្រូវបានបញ្ជ្រាបក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៩-២០១៣។ គម្រោងបានសិក្សាចងក្រងអំពីការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងដីដោយនិរន្តរភាព ការរស់ស្នង់ចំណេះដឹងរបស់ប្រជាជនអំពី ការគ្រប់គ្រងដីដោយចីរភាព និងការរៀបចំទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថាននៅកម្ពុជា ដែលមានអ្នកចូលរួមមកពី ស្ថាប័នពាក់ព័ន្ធផ្សេងៗសរុបចំនួន ១៨៩ នាក់ ស្រី ៤៣នាក់។

ក.៤- ការចំណាយថវិកា

ថវិកាសរុបរបស់គម្រោងចំនួន ៣៥៤.៥៨៦ដុល្លាអាមេរិក ចំណាយអស់ចំនួន ៣០៩.៦៥៣,០១ ដុល្លារអាមេរិកស្មើនឹង ៨៧ភាគរយ នៅសល់ចំនួន ៤៤.៩៣២ ដុល្លារអាមេរិក ស្មើនិង ១៣ភាគរយ។

**ខ- វិធានការ**

-ជំរុញក្រុមការងាររៀបចំកម្មវិធីសកម្មភាពជាតិដើម្បីពិនិត្យ និងសំអាតឱ្យបានល្អលើសេចក្តីព្រាងចុងក្រោយរបស់កម្មវិធីសកម្មភាពជាតិ

-រៀបចំប្រជុំជាមួយក្រុមប្រឹក្សាភិបាលគម្រោង ដើម្បីពិនិត្យមើលលទ្ធផលសម្រេចបានរបស់គម្រោង និងអនុម័ត

-រៀបចំធ្វើសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីដើម្បីប្រមូលមតិ និងយោបល់ផ្សេងៗក្នុងការធ្វើឱ្យប្រសើរឡើងនូវសេចក្តីព្រាងកម្មវិធីសកម្មភាពជាតិ។

**៥.៨.១.៦- គម្រោង RPRP (IFAD)**

**ក- លទ្ធផល**

ក.១- ដំណើរការអនុវត្តគម្រោងសង្ខេបផ្នែករូបវន្ត និងផ្នែកហិរញ្ញវត្ថុ:

| ល.រ | បិយាយ | ផ្នែករូបវន្ត % | ផ្នែកហិរញ្ញវត្ថុ % |
|---|---|---|---|
| ១ | ផ្នែកវិនិយោគកសិកម្ម | ៧៦.១៧ | ៦៤.២២ |
| ២ | ផ្នែកអភិវឌ្ឍន៍តំបន់ | ៨២.២៧ | ៦២.៧៣ |
| ៣ | ផ្នែកគាំទ្រស្ថាប័ន | ៩៥.៤៥ | ៧៤.៦៨ |
| ៤ | ផ្នែកគាំទ្រថ្នាក់ជាតិ | ៧២.៣៤ | ៦៦.១០ |

ក.២- ផែនការសកម្មភាពការងា៖

ក.២.១- ផែនការសកម្មភាព

-ការផលិតប្រព័ន្ធផ្សព្វផ្សាយ និងបោះពុម្ពឯកសារ

-ធ្វើកិច្ចសន្យាពីការផ្តល់សេវាកម្ម សម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ក្រុមដំណើរការកែច្នៃអាហារ Styling គ្រប់គ្រង

-ក្រុមកសិ-សហគ្រាស និងផ្តល់សេវាសម្រាប់បណ្តុះបណ្តាលជនពិការ និងសហគ្រាសពាណិជ្ជកម្ម

-បោះពុម្ព AESA និងជួយសម្រួលការងារប្រធានសហករនៅតាមខេត្តពេលធ្វើទស្សនកិច្ច

ក.២.២- ផែនការថវិកា សរុបចំនួន ២,៤៨៦,១៣៥.៧៩ ដុល្លាអាមេរិក។

**ខ- បញ្ហាប្រឈម**

-បុគ្គលិកគម្រោងមិនទាន់យល់ពី ការបង្កើត និងការអនុវត្តន៍ តម្លៃប្រតិបត្តអទិភាព (POC)

-ការជ្រើសរើសមន្ត្រីសម្រាប់បម្រើការគម្រោង នៅតាមខេត្ត និងស្រុកកំរិត

-ពង្រឹងក្នុងការសម្របសម្រួលជាមួយអជ្ញាធរដែនដី ដូចជា: ឃុំ ស្រុក ខេត្ត ដើម្បីរៀបចំជាក្រុមការងារ និងមានការគាំទ្រយ៉ាងពេញទំហឹង ពីអជ្ញាធរដែនដី។

**៥.៨.១.៧- គម្រោងសមាសធាតុគម្រោង Rulip (IFAD)**

**ក- របាយការណ៍វឌ្ឍនភាព**

គម្រោងបានអនុវត្ត ស្រុកគោលដៅសរុបចំនួន ១៦ ឃុំចំនួន ២០ និងភូមិចំនួន ១០០ ចំនួនមន្ត្រីអ្នកចូលរួមសរុបចំនួន ១.២០៨ នាក់ ស្ត្រី ៣៦៧នាក់ និងអ្នកចូលរួមវគ្គបណ្តុះបណ្តាលចំនួន ៦០៥ នាក់ ស្ត្រី ២៨៣នាក់ ជាពិសេសកសិករចូលរួមវគ្គបណ្តុះបណ្តាល (កសិករក្រុមកែលម្អជីវភាព និងក្រុមកែលម្អប្រព័ន្ធកសិកម្ម) សរុបចំនួន ៥៤១១នាក់ ស្ត្រី ១៨២៤នាក់ ចំនួនបង្ហាញរបស់កសិករក្រុមកែប្រព័ន្ធកសិកម្ម ក្នុងនោះមានបង្ហាញ ដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (បន្លែ ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក និងចិញ្ចឹមត្រី) ចំនួន ៤៣៧ បង្ហាញ។

សាងសង់ធនាគារស្រូវបានចំនួន ១១៦ កសិករចូលរួមធ្វើទិវាស្រែសរុបចំនួន ៤៩៩០នាក់ ស្ត្រី ១៣៤០នាក់ ចំនួនអ្នកចូលរួមពិព័ណ៌ស្រុក ១២២៥នាក់ ស្ត្រី ៥១៣នាក់ និស្សិតហាត់ការងារ ៥នាក់ ស្រី ១នាក់ និងអ្នកចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនៈកិច្ចសិក្សាក្រៅប្រទេសចំនួន ៩ នាក់ ស្ត្រី ១នាក់ អ្នកទទួលផល: សរុប ១០.៨៤៥ ស្ត្រី ២៩៦១ នាក់ រួមមាន ៖

***-ក្រុមកែលម្អជីវភាព:*** ចំនួនកសិករក្រុមកែលម្អជីវភាព ២៨០១នាក់/ស្ត្រី ៣៨៧នាក់ ចំនួនកសិករក្រុម ទីទ័លក្រ ៣០០នាក់/ស្ត្រី ៧២នាក់ ចំនួនពេទ្យសត្វភូមិ ១៣២នាក់/ស្ត្រី ៣១នាក់

***-ក្រុមកែលម្អប្រព័ន្ធកសិកម្ម:*** ចំនួនកសិករក្រុមកែលម្អប្រព័ន្ធកសិកម្ម ២៨១៩នាក់/ស្ត្រី ៤០១នាក់ ចំនួនគ្រូ បង្គោលដំណើរការសាលារៀនស្រែកសិករ ៨៦នាក់/ស្ត្រី ៣៤នាក់

***-កម្មវិធីបំពេញបន្ថែម:*** អ្នកចូលរួមវគ្គបណ្តុះបណ្តាលការវិភាគកេរ្រត្រ-បរិស្ថានចំនួន ៥នាក់/ស្ត្រី១នាក់ អ្នកចូលរួមវគ្គបណ្តុះបណ្តាលពេទ្យសត្វភូមិចំនួន ៦៨នាក់/ស្ត្រី ៤នាក់ ភ្នាក់ងារផ្សព្វផ្សាយភូមិចំនួន ៧៤នាក់/ស្ត្រី ៣១នាក់ ការធ្វើបង្ហាញប្រព័ន្ធកសិកម្មចម្រុះកសិករចូលរួម ៦១៥នាក់/ស្ត្រី ១១២នាក់ ចំនួនអ្នកចូលរួមពិព័ណ៌ស្រុក ១២២៥នាក់/ស្ត្រី ៥១៣នាក់ អ្នកចូលរួមសិក្ខាសាលាស្តីពី វិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ក្នុងការប្រើប្រាស់ និងទុកដាក់ថ្នាំពុលកសិកម្មចំនួន ១១៥នាក់/ស្ត្រី១៧នាក់ អ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម ថ្នាំសំលាប់សត្វល្អិត ជីគីមី ១០នាក់/៣នាក់ បង្ហាញស្តីពីដំណាំកសិ-ឧស្សាហ៍កម្ម ១០៦នាក់/ស្ត្រី ៥៩នាក់ ចំនួននិស្សិតហាត់ការងារ០២នាក់/ស្ត្រី ១នាក់

***-ការយល់ដឹងពីច្បាប់*** អ្នកចូលរួមវគ្គពង្រឹងបន្ថែមច្បាប់ព្រៃឈើ ច្បាប់ភូមិបាលថ្នាក់ស្រុក និងថ្នាក់ខេត្តចំនួន១៥០នាក់/ស្ត្រី ១៩នាក់ ចំនួនអ្នកចូលរួមផ្សព្វផ្សាយច្បាប់សាធារណៈនៅតាមសហគមន៍ ១៤៤០នាក់/ស្ត្រី ៨៥៧នាក់ ចំនួនអ្នកចូលរួមក្នុងវគ្គពង្រឹងបន្ថែមថ្នាក់ខេត្ត ៣៧នាក់/ស្ត្រី៣នាក់ ចំនួនអ្នកចូលរួមក្នុងវគ្គពង្រឹងបន្ថែមថ្នាក់ខេត្ត ១១៨នាក់/ស្ត្រី១៦នាក់

***-ការគាំទ្រសេវាកម្មកសិកម្ម:*** មន្ត្រីគាំទ្រថ្នាក់ខេត្ត ៥៧នាក់/ស្ត្រី ១៣នាក់ មន្ត្រីគាំទ្រថ្នាក់ស្រុក ៩៦នាក់/ស្ត្រី ២៥នាក់ ភ្នាក់ងារផ្សព្វផ្សាយឃុំ ១២៦នាក់/ស្ត្រី ៦៣នាក់ ក្រុមប្រឹក្សាឃុំ ៥៩នាក់/ស្ត្រី ១០នាក់ ក្រុមស្ត្រីទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ ២២នាក់

*-យេនឌ័រក្នុងវិស័យកសិកម្ម:* ចំនួនអ្នកចូលរួមវគ្គស្តីពីការវិភាគយេនឌ័រ ដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ៦៦នាក់/ស្ត្រី ៤៩នាក់ ចំនួនអ្នកចូលរួមវគ្គស្តីពី គោលគំនិតយេនឌ័រ ៤៩នាក់/ស្ត្រី ៣៣នាក់ ចំនួនអ្នកចូលរួមវគ្គស្តីពី ការប្រើប្រាស់ផ្ទាំងរូបភាពយេនឌ័រ ៦៦នាក់/ស្ត្រី ៤២នាក់ ចំនួនអ្នក ចូលរួមវគ្គស្តីពីរៀបចំផែនការគម្រោងតាមដាន និងវាយតម្លៃ ៩១នាក់/ស្ត្រី ៥៩នាក់ ចំនួនអ្នកចូលរួមវគ្គស្តីពី ជំនាញកែច្នៃម្ហូបអាហារដល់ក្រុមស្ត្រី៦៨នាក់ ក១៨នាក់៣៩០/៥០ ចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការប្រើប្រាស់គោលការណ៍សហគ្រាសខ្នាតតូច និងផែនការជំនួញ ១៨នាក់/ស្ត្រី៧នាក់ និងបណ្តុះបណ្តាលបន្ត ដល់ក្រុមស្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារឃុំចំនួន២៩នាក់។

**ខ- របាយការណ៍ហិរញ្ញវត្ថុ**

| ប្រភពថវិកា | ថវិកាប្រចាំឆ្នាំ | ចំណាយជាក់ស្តែង | ភាគរយសម្រេចបាន |
|---|---|---|---|
| IFAD | ៣.៤២៧.៤៩២,00 | ២.១០៣.៩៣១,២៣ | ៦១,៣៨ |
| បដិភាគរដ្ឋាភិបាល | ១៦៨.៣៨៥,00 | ៦៣.៥៥៨,៩៩ | ៣៧,៧៥ |
| សរុប | ៣.៥៩៥.៨៧៧ | ២.១៦៧.៤៩០,២២ | ៦០,២៨ |

**គ- ផែនការសកម្មភាពគម្រោងឆ្នាំ ២០១១**

| ថវិកាប្រើប្រាស់តាមសមាសភាគ និងអនុសមាសភាគគម្រោង | ថវិកាឆ្នាំ២០១១ | ថវិកាឆ្នាំ២០១២ | ថវិកានៅសល់ |
|---|---|---|---|
| **ក-លើកកំពស់ជីវភាពរស់នៅ** | **2,623,795.69** | **1,496,171.20** | **4,119,966.89** |
| ១-ក្រុមកែលម្អជីវភាព | 701,443.42 | 585,658.35 | 1,287,101.77 |
| ២-ក្រុមកែលម្អប្រព័ន្ធកសិកម្ម | 94,800.00 | 239,198.11 | 333,998.11 |
| ៣-កម្មវិធីបំពេញបន្ថែម | 240,675.45 | 93,249.57 | 333,925.02 |
| ៤-ការយល់ដឹងអំពីច្បាប់ | - | - | - |
| ៥-ការគាំទ្រសេវាកម្មកសិកម្ម | 1,475,440.75 | 462,342.59 | 1,937,783.34 |
| ៦-យេនឌ័រក្នុងវិស័យកសិកម្ម | 111,436.07 | 115,722.59 | 227,158.66 |
| **ខ-ការគាំទ្រវិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងវិស័យកសិកម្ម** | **380,270.00** | **182,424.15** | **562,694.15** |
| ១-ការគាំទ្រកម្មវិធីវិនិយោគកសិកម្មថ្នាក់ខេត្ត | 44,510.00 | 114,000.00 | 158,510.00 |
| ២-ការគាំទ្រវិភាគគោលនយោបាយវិស័យកសិកម្ម | 296,020.00 | 45,970.00 | 341,990.00 |
| ៣-ការគាំទ្រការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម | 39,740.00 | 22,454.15 | 62,194.15 |
| **សរុប** | **3,004,065.69** | **1,678,595.36** | **4,682,661.05** |

### ៥.៨.១.៨- គម្រោង NAPA

**ក- លទ្ធផល**

*គម្រោងបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០០៩ នឹងត្រូវបញ្ចប់នៅឆ្នាំ២០១៣ ហើយ ឆ្នាំ២០១០ គឺជាឆ្នាំទី២ នៃរយៈពេលសរុប៤ឆ្នាំ។ ទន្ទឹមនឹងនោះ តំបន់គោលដៅ គម្រោងកំពុងត្រូវបានអនុវត្តនៅក្នុងស្រុកចិត្របុរី ខេត្តក្រចេះ និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដោយសហការជាមួយ គម្រោងលើកកម្ពស់ជីវភាពរស់នៅតាមជនបទ ឧបត្ថមថវិកាដោយអង្គការ អាយហ្វាដ/យូអ៊ីនឌីភី (IFAD/UNDP)។*

*ដំណើរការគម្រោងមានថវិកាសរុបចំនួន ៣,០៩០,៣៥០ ដុល្លារអាមេរិក ដោយមានការចូលរួមឧបត្ថមពីមូលនិធិ ប្រទេសមានការអភិវឌ្ឍតិចតួច (LDCF) យូអ៊ីនឌីភី និងរាជរដ្ឋាភិបាលកម្ពុជា។*

អង្គភាពគាំទ្រគម្រោង នៃក្រសួងកសិកម្មគឺជាស្ថាប័ននាំមុខក្នុងការអនុវត្តគម្រោង NAPA Follow-up នេះ និងមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការយូអិនឌីភី។ នៅថ្នាក់ជាតិ ក្រសួងកសិកម្ម តាមរយៈអង្គភាព គាំទ្រគម្រោង ដឹកនាំក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមកពី យូអិនឌីភី ក្រសួងធនធានទឹកនិង ឧតុនិយម ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី និងតំណាងមកពីអាជ្ញាធរខេត្ត ផងដែរ។ នៅថ្នាក់ក្រោមជាតិ គម្រោងត្រូវបានអនុវត្តដោយ មន្ទីរកសិកម្ម មន្ទីរធនធានទឹក និងមន្ទីរកិច្ចការនារី ដោយមានកិច្ចសហការ ជាមួយស្ថាប័នដែលពាក់ព័ន្ធដទៃទៀត។ រួមមាន ៖

-ផ្តល់ចំណេះដឹងពីការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលរបស់វាទៅដល់កសិករ និងក្រុមប្រឹក្សាឃុំ ចំនួនប្រមាណ ៥០០ នាក់ នៅក្នុងតំបន់គោលដៅ ដែលនៅក្នុងនោះស្ត្រីមានចំនួនពាក់កណ្តាល

-រៀបចំសិក្ខាសាលាណែនាំស្តីអំពីការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលរបស់វា ទៅដល់ក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក សមាជិកមន្ទីរពាក់ព័ន្ធ រួមទាំងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលចំនួន ៩៣នាក់

-រៀបចំទិវាវាលស្រែកសិករសម្រាប់កសិករចំនួន ១២០នាក់ ដើម្បីចែករំលែកនូវបច្ចេកទេសកសិកម្មល្អៗ តាមរយៈទ្រឹស្តី និងការពិសោធបង្ហាញជាក់ស្តែង

-គាំទ្រឃុំគោលដៅទាំងពីរ ក្នុងពង្រាងកម្មវិធីវិនិយោគឃុំ។ ជាលទ្ធផលអាទិភាពនៃការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានបញ្ចូលទៅក្នុងពង្រាងកម្មវិធីវិនិយោគឃុំឆ្នាំ២០១១

-បង្កើតគណៈកម្មាការក្រុមកសិករប្រើប្រាស់ទឹក នៅក្នុងឃុំទឹកក្រហម ដើម្បីគ្រប់គ្រងនូវរាល់បញ្ហា ជម្លោះ ដែលទាក់ទងនឹងទឹកនាពេលអនាគត

-ពិសោធនិងបង្ហាញពូជស្រូវចំនួន ៣០ ដែលធននឹងទឹកជំនន់ និងគ្រោះរាំងស្ងួត ដល់កសិករជាង ១០០នាក់ (ពាក់កណ្តាលជាស្ត្រី) នៅក្នុងទិវាវាលស្រែកសិករ។ ការពិសោធនិងបង្ហាញនូវពូជស្រូវទាំងនោះត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំង

-កំណត់នូវប្រព័ន្ធធារាសាស្ត្រចំនួន ២ ខេត្តគោលដៅ សម្រាប់ពិសោធនិងបង្ហាញពីប្រព័ន្ធដែលអាចបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ

-ធ្វើការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) នៅក្នុងភូមិគោលដៅចំនួន១៣ ដើម្បីដឹងព័ត៌មានបន្ថែមអំពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

**ខ-វិធានការ**

-គម្រោងមានគោលដៅ កាត់បន្ថយភាពងាយរងគ្រោះលើវិស័យកសិកម្ម ក្នុងប្រទេសកម្ពុជាដែលបណ្តាមកពី ការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យមានប្រភពទឹកឡើងវិញ

-ពង្រឹងសមត្ថភាពស្ថានប័នមូលដ្ឋានលើការគ្រប់គ្រងប្រភពទឹក សម្រាប់ការងារកសិកម្មក្នុងស្ថានភាពដែលមានការប្រែប្រួលអាកាសធាតុ ។

-ជម្រើសក្នុងការធ្វើបង្ហាញបច្ចេកទេសសមស្រប ដែលអាចទទួលយកបាននៅមូលដ្ឋានសម្រាប់ការកាត់បន្ថយនូវហានិភ័យនៃការបម្រែបម្រួលអាកាសធាតុ

-មេរៀននិងបទពិសោធន៍ល្អៗនៃគម្រោងសាកល្បងនេះ នឹងយកទៅអនុវត្តនៅតំបន់ងាយរងគ្រោះផ្សេងទៀតក្នុងប្រទេសកម្ពុជា

-ផ្សព្វផ្សាយនូវចំណេះដឹងដល់សាធារណៈអំពី ការប្រែប្រួលអាកាសធាតុនិងការបន្ស៊ាំ ទាក់ទងនឹងការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម

-ចង្ក្រងនូវករណីសិក្សា បទពិសោធល្អៗ និងចែករំលែកទៅកាន់បណ្តាញចំណេះដឹងសកលលោក របស់យូអឹនឌីភី គឺយន្តការរៀនសូត្រពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Adaptation Learning Mechanism http://www.adaptationlearning.net)

## ជំពូក ៣

# វាយតម្លៃ និង សន្និដ្ឋាន

## VI-វាយតម្លៃរួម

ផ្អែកលើលទ្ធផលទទួលបានក្នុងឆ្នាំ ២០១០-២០១១ កន្លងមកនេះ យើងអាចវាយតម្លៃជារួម ក្នុងការអនុវត្តនារយៈពេលមួយឆ្នាំកន្លងមកនេះ បើទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិរួមមានកង្វះខាតទឹក ដោយសារកូនរដូវប្រាំងនៅពាក់កណ្តាលរដូវវស្សា គ្រោះទឹកជំនន់ ជាពិសេសជំនន់ទឹកភ្លៀងចុងរដូវវស្សា (ចាប់ពីពាក់កណ្តាលខែ តុលាដល់ពាក់កណ្តាលខែវិច្ឆិកា) ព្រមទាំងស្ថិតនៅក្រោមការប៉ះទង្គិចដោយកលយុគវិបត្តិ សេដ្ឋកិច្ចពិភពលោក តែក្រោមការខិតខំប្រឹងប្រែង របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមាន ប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល ដោយមានការចូលរួម ដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្ម មានការកើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងស្រូវរដូវវស្សា ឆ្នាំ២០១០ នេះ ស្ថានភាពផលិតកម្មកសិកម្មបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរទូទាំងប្រទេស។ សរុបផ្ទៃដីស្រូវរដូវវស្សា និងរដូវប្រាំង អនុវត្តបានសរុបជាង ២,៧៩ លានហិកតា ដោយទទួលបរិមាណផលសរុបប្រមាណ ៨,២៤ លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ២,៩៧ តោន/ហិកតា។ ដូច្នេះតុល្យភាពស្បៀង យើងនៅសល់ជាង ២,៥១ លានតោនអង្ករ គិតជាស្រូវជាង ៣,៩៣ លានតោន លើសឆ្នាំមុនជាង ០,៤២ លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំ កន្លងមកជាង ១,២៣ លានតោនអង្ករ។ ផលិតកម្មស្រូវតាមគោលការណ៍ធម្មជាតិ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយមានផ្ទៃដីអនុវត្តសរុបជាង ៥៩.៧៨៥ ហិកតា ជាមួយនិងទិន្នផលមធ្យម ៣,៥៣ តោន/ហិកតា និងមានកសិករអនុវត្ត ប.វ.ស ជាង ១១២ ពាន់គ្រួសារ កើនលើសឆ្នាំមុន ៧.៧១ ភាគរយ ហើយតួលេខនេះ មានការកើនឡើងគួរឱ្យកត់សំគាល់បើប្រៀបធៀបទៅនឹងឆ្នាំ ២០០០ គឺមានតែ ២៨ គ្រួសារ អនុវត្តលើផ្ទៃដីត្រឹមតែ ១,៦ ហិកតា ជាការសាកល្បងតែប៉ុណ្ណោះ។ សូមបញ្ជាក់ថា ខេត្តដែលធ្វើស្រូវប្រព័ន្ធប្រពលវប្បកម្មតាមគោលការណ៍ ធម្មជាតិច្រើនជាងគេ គឺខេត្តតាកែវ ដែលមានចំនួនជាង ៣៤ ពាន់គ្រួសារ លើផ្ទៃដីជាង ២១ ពាន់ហិកតា។ ចំពោះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុនៗ ជារួមឈានមកដល់ពេលបច្ចុប្បន្ន ការងារបង្កបង្កើនផល ឆ្នាំ ២០១០-២០១១ នេះ ទទួលបានផលយ៉ាងល្អប្រសើរ ស្របតាមគោលការណ៍នាំអង្ករចេញរបស់រាជរដ្ឋាភិបាល។

ចំពោះផលិតកម្មសត្វនៅកម្ពុជាជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងគោ-ក្របីត្រូវបាននាំចេញទៅបរទេស។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ ឃើញថាផលិតកម្មគោកើនចំនួន ៤% ក្របីថយចុះ ៣%។ ការចិញ្ចឹមបក្សីពីឆ្នាំ ២០០៦ ដល់ ២០១០ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៧% គឺពី ១៥លានក្បាល ដល់ ២០.៦លានក្បាល។ រីឯដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី និងដំណាំឈើហូបផ្លែផ្សេងៗ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគ ខ្នាតតូច មធ្យម និងធំៗ គួរកត់សម្គាល់ថា មកដល់ឆ្នាំ ២០១០ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសមានចំនួន ១៨១.៤៣០ ហិកតា គឺកើនឡើង ៤២% ប្រៀប

ធៀបទៅនឹងឆ្នាំ ២០០៩ ក្នុងនោះ ការអភិវឌ្ឍន៍វិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

វិស័យព្រៃឈើកំពុងតែត្រូវបានជានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ ដោយខិតខំយ៉ាងណារក្សាឱ្យបាននូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ៦០% នៅឆ្នាំ ២០១៥ រក្សាឱ្យបាននូវតំបន់អភិរក្សព្រៃឈើ កាត់បន្ថយការប្រើប្រាស់អុសដុត/ធ្យូង ដែលមានប្រភពពីឈើធម្មជាតិរបស់គ្រួសារ និងជំរុញការដាំឈើឡើងវិញ តាមរយៈការចូលរួមដាំឈើពីក្រុមហ៊ុនវិនិយោគឯកជន គ្រួសារឯកជនខ្នាតតូច ការប្រារព្ធរុក្ខទិវាជាប្រពៃណី និងការពង្រីក និងអភិវឌ្ឍន៍សហគមន៍ព្រៃឈើថ្មីចំនួន ១០០ កន្លែងបន្ថែមទៀត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង ៣,៨៥% គឺ ពី ៣៩០ ពាន់តោននៅឆ្នាំ ២០០៩ ដល់ ៤០៥ពាន់ តោន នៅឆ្នាំ ២០១០ ហើយអាជីវកម្មនេសាទសមុទ្រសម្រេចបាន ៨៥ ពាន់តោន កើនលើសឆ្នាំមុន ១៣%។ ការអភិវឌ្ឍន៍វារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើសម្រេចបាន ៦០ ពាន់តោន កើនបាន ២០% និងសហគមន៍នេសាទមានចំនួន ៤៦៩ សហគមន៍ត្រូវបានបង្កើតឡើង។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយ ឱ្យបានជាអតិបរមានូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

បន្ថែមជាងនេះទៅទៀត ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាល។ ដូចជាការងារវិនិយោគសាធារណៈបានរៀបចំគម្រោងជាច្រើន សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការបណ្តាក់ទុនវិនិយោគ លើវិស័យកសិកម្មកាន់តែច្រើនឡើង ការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិ មានកិច្ចទំនាក់ទំនងជាមួយអន្តរជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍកាន់តែកើនឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធ នឹងវិស័យកសិកម្មបានកាន់តែច្រើនឡើងជាលំដាប់។

## VII-**ទិសដៅរួម**

វិស័យកសិកម្មជាវិស័យអាទិភាព ដែលរាជរដ្ឋាភិបាលបានកំណត់ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ តាមរចនាសម្ព័ន្ធមុំ បួននៃចតុកោណប្រទាក់ក្រឡាគ្នា។ ចតុកោណយុទ្ធសាស្ត្រទី ១ ពាក់ព័ន្ធនឹងភារៈកិច្ចសំខាន់ៗ ជាស្នូលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺបន្តការលើកស្ទួយវិស័យកសិកម្ម ដែលនៅក្នុងនោះមាន ៤ មុំជាចំបង (១)-ការ លើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម (២)-កំណែទំរង់ដីធ្លីនិងបោសសំអាតមីន (៣)-កំណែទម្រង់វិស័យនេសាទ និងជលផល (៤)-កំណែទម្រង់ព្រៃឈើ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០០៩-២០១៣) ស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយផែនការយុទ្ធសាស្ត្រកសិកម្ម និងទឹក (២០០៦-២០១០) ដែលបានរៀបចំហើយនោះ ក៏បានរៀបចំ និងដាក់បញ្ចូលនូវសកម្មភាពអាទិភាព

តាមផ្នែក និងអនុផ្នែក នៅក្នុងគម្រោងវិនិយោគសាធារណៈ ( PIP ) ឆ្នាំ ២០១១-២០១៣ សំដៅការស្វែងរកប្រភពទុន និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣។ ដោយឡែកសម្រាប់ឆ្នាំ ២០១១-២០១២ នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅរួមមួយចំនួនដូចខាងក្រោម ៖

១-ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០០៩-២០១៣ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រដ៏ទៃទៀត របស់រាជរដ្ឋាភិបាល ដូចជា យុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ យុទ្ធសាស្ត្រកសិកម្ម និង ទឹក ។ល។

២-ជំរុញការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការគាំទ្រការអនុវត្តយុទ្ធសាស្ត្រជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

៣-សិក្សាលទ្ធភាពនៃការរៀបចំកសាងផែនការមេ សម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មសម្រាប់រយៈពេលវែង ២០១២-២០៣៥។

៤-ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមកម្មវិធី (Program Budgeting) នៃក្របខណ្ឌផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីប្រើប្រាស់ទុនវិនិយោគរបស់រដ្ឋ ឱ្យចំទិសដៅ អាទិភាព និងមានប្រសិទ្ធភាពខ្ពស់។

៥-បន្តពង្រឹងដឹកនាំគ្រប់គ្រងរបស់ក្រសួង តាមរូបភាពរដ្ឋបាល ចាត់តាំងយន្តការ វិន័យច្បាប់ និងការកសាងសមត្ថភាព អភិវឌ្ឍន៍ធនធានមនុស្សទៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង ឱ្យស្របតាមដំណើរការអភិវឌ្ឍន៍បច្ចុប្បន្ន។

៦-កែទម្រង់ ការគ្រប់គ្រងគំពោងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ឱ្យបានសមស្របតាមរចនាសម្ព័ន្ធរបស់ក្រសួង។

៧-បង្កើនកិច្ចសហការឱ្យបានកាន់តែប្រសើរឡើង ជាមួយដៃគូអភិវឌ្ឍន៍នានាដូចជាៈ សហគមន៍ផ្តល់ជំនួយផ្នែកឯកជន និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត។

៨-បន្តពង្រឹងការគ្រប់គ្រង តម្រង់ទិសលើការវិនិយោគរបស់ផ្នែកឯកជន ក្នុងវិស័យកសិកម្ម ពិសេសលើការវិនិយោគសម្បទានដីសេដ្ឋកិច្ច និងការវិនិយោគផលិតកម្មខ្នាតតូចដទៃទៀត។

៩-សហការជាមួយដៃគូអភិវឌ្ឍនានា ក្រោមក្របខ័ណ្ឌក្រុមការងារបច្ចេកទេសចំរុះ របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដូចជាៈ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ក្រុមការងារបរិស្ថាន និងព្រៃឈើ ក្រុមការងារបច្ចេកទេសជលផល។ល។

១០-រៀបចំលិខិតបទដ្ឋានផ្សេងៗ ដើម្បីគ្រប់គ្រងធនធានដី ដែលមានលក្ខណៈ គុណភាព អំណោយផលផលិតកម្មកសិកម្ម និងចូលរួមកសាងលិខិតបទដ្ឋានច្បាប់ ក្នុងគោលដៅគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្ម ព្រមទាំងការចែកចាយទិន្នន័យព័តមានទាក់ទង នឹងសម្បទានដីសេដ្ឋកិច្ច ជាសាធារណៈ តាមរយៈ Website របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនេះ ជំរុញការត្រួតពិនិត្យ និងតាមដានពីហេតុប៉ះពាល់បរិស្ថាន លើគ្រប់គម្រោងទាំងអស់ ដែលពាក់ពន្ធ័វិស័យកសិកម្ម។

១១-- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ន រួមមាន៖

- ច្បាប់ការពាររុក្ខជាតិ និងកូតតាមអនាម័យ ច្បាប់ដីកសិកម្ម និងច្បាប់សហគមន៍កសិកម្ម

- រៀបចំគោលនយោបាយជាតិសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម
- អនុក្រឹត្យស្តីពី "ការគ្រប់គ្រងរោងជាងផលិត កែច្នៃ ដំឡើង និងរោងជាងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម"
- អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពី "ការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជ" និងអនុក្រឹត្យស្តីពី "បុណ្យដារលាន"
- ប្រកាសរួមស្តីពី "សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និងការកំចាត់សមាសភាពចង្រៃ"
- ប្រកាសស្តីពី "ការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ"
- វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់និងត្រារបស់មន្ត្រីភូតគាមអនាម័យ

១២- ជំរុញការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗ នូវគោលដៅនៃគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា

១៣- ពង្រឹង និងពង្រីកសមត្ថភាពពិសោធន៍វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកា ដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធូបទកម្មលើផលិតផល និងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកំពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងធានាសុខភាពសាធារណៈ

១៤-ជំរុញបន្ថែមការអភិវឌ្ឍន៍លើវិស័យចិញ្ចឹមសត្វគ្រប់ប្រភេទ ដោយសង្កត់លើការកែលំអពូជចំណីសត្វបញ្ជ្រាបបច្ចេក វិជ្ជាទំនើបក្នុងការចិញ្ចឹមសត្វដល់ស្រទាប់កសិករ និងឡជីវឧស្ម័នក្នុងគោលដៅបង្កើនផលិតភាពសត្វទាំងបរិមាណ និងគុណភាព។

១៥-ពង្រឹងពង្រីកការងារត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជម្ងឺឆ្លងពីសត្វទៅមនុស្ស និងពីមនុស្សទៅសត្វ ឬពីតំបន់មួយទៅតំបន់មួយទៀត តាមរយៈបង្កើនកម្មវិធីយុទ្ធនាការចាក់ថ្នាំការពារសត្វ ជីវសុវត្ថិភាព ពង្រឹងសមត្ថភាពបន្ថែម ដល់ភ្នាក់ងារសុខភាពសត្វភូមិ និងការពិនិត្យចលនាសត្វក្នុងប្រទេស និងក្រៅប្រទេសឱ្យបានត្រឹមត្រូវ។

១៦-ជំរុញការងារសុខភាពសាធារណៈ ដោយផ្តោតជាសំខាន់លើការគ្រប់គ្រងសត្តឃាតដ្ឋាន ការពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសាច់ នៅតាមសត្តឃាតដ្ឋាន និងទីផ្សារ ក្នុងទិសដៅកាត់បន្ថយ ឬលុបបំបាត់ជំងឺឆ្លងតាមរយៈសាច់ និងផលិតផលសាច់ ដើម្បីធានាសុវត្ថិភាពចំណីអាហារដល់ប្រជាពលរដ្ឋ។

១៧-រៀបចំច្បាប់កៅស៊ូពាក់ពន្ធ័នឹងការដាំដុះ ការប្រមូលផល ការកែច្នៃ ការដឹកជញ្ជូន និងការនាំចេញ ជាពិសេសការធ្វើសហប្រតិបត្តិការ និងចូលរួមជាមួយបណ្ឌាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យា និងចំណេះដឹងទូទៅលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ ដោយជំរុញការចេញវិញ្ញាបនប័ត្របញ្ជាក់ គុណភាពកៅស៊ូដល់បណ្តារោងចក្រផលិតជ័រកៅស៊ូ និងខិតខំគៀងគររកប្រភពទុន ពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ នៅទូទាំងប្រទេស។

១៨-ពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ បទបញ្ជា បទបញ្ញត្តិលិខិតបទដ្ឋានពាក់ព័ន្ធនិងវិស័យព្រៃឈើ(ច្បាប់ស្តីពីព្រៃឈើ បទបញ្ជាលេខ ០១-០២ សជណ និងអនុសាសន៍របស់សម្តេចតេជោ) ព្រមទាំងចាត់វិធានការស៊ើបអង្កេតស្រាវជ្រាវ ចុះល្បាតទប់ស្កាត់និងបង្រ្កាបបទល្មើសឱ្យបានទាន់ពេលវេលា ទន្ទឹមនឹងការពង្រឹងវិន័យការងារចំពោះមន្ត្រីមានសមត្ថកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មសាធារណៈ និងអភិបាលកិច្ចល្អនៃវិស័យព្រៃឈើ

១៩-រៀបចំធនធានមនុស្សនិងលិខិតបទដ្ឋានក្រោមច្បាប់ ដើម្បីអនុវត្តរចនាសម្ពន្ធ័រដ្ឋបាលព្រៃឈើតាមអនុក្រឹត្យលេខ ១៨៨ អន.ក្រ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងបន្តសហការជាមួយស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីបោះបង្គោល កំណត់ព្រំប្រទល់ដែនព្រៃឈើឱ្យបានយ៉ាងតិច ១.០០០ គ.ម និងអនុវត្តបន្តកម្មវិធីសហគមន៍ព្រៃឈើជាតិ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍និងអាជ្ញាធរមូលដ្ឋានពាក់ពន្ធ័រៀបចំបង្កើត និង ធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ ឱ្យបានយ៉ាងតិច ១០០ កន្លែង។

២០-ជំរុញដាំព្រៃឈើសម្រាប់បម្រើដល់ពហុប្រយោជន៍ នៃសេដ្ឋកិច្ច-សង្គម និងសេវាបរិស្ថានយ៉ាងតិច ១០.០០០ ហិកតា/ឆ្នាំ និងបណ្តុះកូនឈើចែកចាយជូនប្រជាពលរដ្ឋដាំឱ្យបាន ១០ លានដើម និងរៀបចំបុណ្យរុក្ខទិវាដាំដើមឈើ។ សហការជាមួយដៃគូអភិវឌ្ឍន៍ រៀបចំបង្កើតប្រពន្ធ័គណនេយ្យឥណទានកាបូនព្រៃឈើ (Forest Carbon Accounting System) ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើលើបញ្ហាថ្មីៗ នៃឥណទានកាបូនព្រៃឈើ។

២១-ជំរុញការយកចិត្តទុកដាក់រៀបចំបញ្ចប់ផែនការគ្រប់គ្រងព្រៃឈើ ដោយផ្នែករដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីជាមូលដ្ឋានសំរាប់ការរៀបចំផែនការគ្រប់គ្រងព្រៃឈើជាតិទូទាំងប្រទេស និងដំណើរការគ្រប់គ្រងព្រៃឈើនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយនិរន្តរភាពជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌនិងច្បាប់គោលសំខាន់ៗ ដែលពាក់ពន្ធ័ផ្សេងទៀត។

២២-ជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ដោយរៀបចំបណ្តុះបណ្តាលលើមុខជំនាញ បច្ចេកទេសជលផល ដោយរួមទាំងអ្នកនេសាទ សហគមន៍នេសាទ និងកសិករចិញ្ចឹមត្រីផង និងបន្តការងារសហប្រតិបត្តិការ ជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីកិច្ចអភិវឌ្ឍន៍វិស័យវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផល។

២៣-បង្កើនលែងប្រភេទពូជត្រីក្នុងស្រុកចូលតំបន់ទឹកធម្មជាតិឱ្យបានគ្រប់ស្រុក ដើម្បីបង្កើនផលស្តុកមច្ឆជាតិ បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ និងជំរុញការទាញយកផល ពីធនធានទឹកតាមរយៈការពង្រីកតំបន់អភិវឌ្ឍន៍វារីវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីក្នុងស្រែ។

២៤-ជំរុញបង្កើនទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំការគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រី និងធ្វើការអភិរក្សផ្សោតទន្លេមេគង្គនៅខេត្ត ក្រចេះ និងស្ទឹងត្រែង ដោយសិក្សាស្រាវជ្រាវផ្សព្វផ្សាយអភិវឌ្ឍន៍ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។

២៥-ខិតខំបន្តអនុវត្តអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី " ធ្វើឱ្យទីណាមានទឹក ទីនោះមានត្រីឡើងវិញ និងបង្កើនប្រព័ន្ធ ត្រួតពិនិត្យគុណភាព និងសុវត្ថិភាព ផលិតផលជលផល ជាពិសេសបង្កើនសកម្មភាពត្រួតពិនិត្យ និងបង្រ្កាបបទល្មើសជលផលតាមបណ្តាខេត្ត ឱ្យកាន់តែកាន់ខ្លាំងក្លា។

២៦-សម្របសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានាទាំងវិស័យ និងអនុវិស័យទាំងអស់ ដើម្បីលើកជាសំណើតំរង់ទិសនៅឆ្នាំខាងមុខ និងត្រៀមលក្ខណៈកសាងផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលវែង ២០១២-២០៣៥។

២៧-ជំរុញល្បឿនការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មឆ្នាំ ២០១១-២០១២ នៅតាមបណ្តារាជធានី ខេត្ត ទូទាំងប្រទេស និងពង្រឹងសមត្ថភាពត្រួតពិនិត្យលើការងារស្ថិតិកសិកម្ម ដើម្បីសម្រួលដល់ការបញ្ចូល វិភាគ និងចងក្រងទិន្នន័យស្ថិតិ កសិកម្មប្រចាំឆ្នាំ។ ជាពិសេសបន្តការសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្នុងការធ្វើជំរឿនស្ថិតិកសិកម្ម។

២៨-បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មទាំង ១១ រាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្ម ឱ្យកាន់តែប្រសើរឡើង និងឈានយកពត៌មានទាំង ២៤ រាជធានី ខេត្ត និងបន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារ តាមរយៈ Internet ទូរទស្សន៍ វិទ្យុ និងបោះពុម្ព Leaflet, Booklet។

២៩-បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ និងចុះពិនិត្យ ស្រាវជ្រាវដោះស្រាយទំនាស់ដីរវាងប្រជាពលរដ្ឋ ជាមួយក្រុមហ៊ុនវិនិយោគឯកជន ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួចហើយ និងបន្តពង្រឹងការគ្រប់គ្រងសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនវិនិរយោគរបស់ក្រុមហ៊ុនឯកជនទាំងអស់ ឱ្យបានកាន់តែរឹងមាំហ្មត់ចត់ត្រឹមត្រូវនឹងឈានទៅលុបគោលការណ៍ និងកិច្ចសន្យាចំពោះក្រុមហ៊ុនដែលអសកម្មភាព មិនគោរពតាមលក្ខខ័ណ្ឌនៃកិច្ចសន្យា និងផែនការមេ។

៣០-ជំរុញរៀបចំគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច មានការអំពាវនាវ ដោយដាក់ឱ្យដេញថ្លៃ នូវអតីតទីតាំងសម្បទានដីសេដ្ឋកិច្ចមួយចំនួន ដែលបានលុបគោលការណ៍ និងកិច្ចសន្យាកន្លងមក។

៣១-បន្តសហការចុះត្រួតពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ ២០០៨ នៅតាមគ្រឹះស្ថានសាធារណៈ មានលក្ខណៈរដ្ឋបាល។ ជាពិសេសសហការចុះត្រួតពិនិត្យ ចំណូល-ចំណាយថវិការដ្ឋនៅតាមបណ្តាអង្គភាពរដ្ឋបាលបុព្វហេតុ។

៣២-ជំរុញការត្រួតពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅអង្គភាពថ្នាក់ កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត ហើយធ្វើការស្រាវជ្រាវផ្ទៀងផ្ទាត់ និងទារបំណុល ដែលមន្ទីរកសិកម្មខេត្តអង្គភាព និងបុគ្គលនៅជំពាក់បំណុលអតីតក្រុមហ៊ុនសម្ភារៈកសិកម្ម។

៣៣-ជំរុញការពង្រីកមន្ត្រីទៅធ្វើការនៅតាមខេត្ត-ក្រុង ពិសេសនៅការិយាល័យកសិកម្ម ថ្នាក់ ស្រុក នៃមន្ទីរកសិកម្មខេត្ត-ក្រុងដាច់ស្រយ៉ាល ដើម្បីអភិវឌ្ឍន៍ពង្រីកថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធ ភាពខ្ពស់។

៣៤-ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រង ពិសេសលិខិតបទដ្ឋាននានា និងគោលការណ៍ផ្សេងៗ ដើម្បីបម្រើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការកែទម្រង់។

៣៥-រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មផ្ទៃក្នុង និងបណ្តុះបណ្តាលបច្ចេកទេសសវនកម្ម ដល់មន្ត្រីចុះធ្វើសវនកម្ម តាមកម្មវិធី ដែលបានអនុម័ត និងតាមបញ្ជារបស់ថ្នាក់ដឹកនាំក្រសួង ជាពិសេស ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយអាជ្ញាធរ សវនកម្មជាតិ និងសវនកម្មផ្ទៃក្នុង តាម ស្ថាប័ននានា។

៣៦-កែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកនៅតាមបណ្តាស្ថានីយ៍ស្រាវជ្រាវ និងបន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ ហើយប្រកប ដោយគុណភាពល្អ។

៣៧-ជំរុញពង្រឹងសមត្ថភាពមន្ត្រី ក៏ដូចប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងសាលារៀនស្រែកសិករ នៅថ្នាក់ស្រុក និងមូលដ្ឋានជាពិសេសពង្រឹងការរៀបចំ និងអប់រំផ្សព្វផ្សាយ នូវសម្ភារផ្សព្វផ្សាយកសិកម្ម ដូចជាបទដ្ឋានអនុវត្តបច្ចេកវិទ្យា សៀវភៅណែនាំ វិធីសាស្ត្រផ្សព្វផ្សាយបច្ចេកទេស និងផ្ទាំងរូបភាព។ល។

៣៨-ជំរុញពង្រឹងសមត្ថភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមកសិករ ទាំងការគ្រប់គ្រងការធ្វើផែនការ និងការធ្វើជំនួញនានា ជាពិសេសរៀបចំលិខិតបទដ្ឋានច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនានាដើម្បីធានាការពារផលប្រយោជន៍ របស់សហគមន៍អភិវឌ្ឍន៍កសិកម្ម និងកសិករ។

៣៩-បន្តការអំពាវនាវ និងគៀងគរបន្ថែមទៀតពីអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ផ្នែកហិរញ្ញប្បទាន សហប្រតិបត្តិការ ដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍វិស័យកសិកម្ម។

៤០-បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីពង្រឹង ភាពជាដៃគូ និងភាពជាម្ចាស់លើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យកសិកម្ម។

## VIII វាយតម្លៃ និង សន្និដ្ឋាន

លទ្ធផលការងារក្នុងវិស័យកសិកម្មឆ្នាំ ២០១០-២០១១ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** ជាប្រមុខ និងដោយការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីក្រសួងស្ថាប័នជាតិ អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍផងនោះ បានបង្ហាញឱ្យឃើញពី លទ្ធផលការងារផលិតកម្ម អាជីវកម្ម និងសេវាកម្មកសិកម្មបានទទួលការរីកចម្រើនលើគ្រប់ផ្នែកក្នុងប្រវត្តិសាស្ត្រកម្ពុជាជាពិសេសលើការងារ ផលិតកម្មដំណាំស្រូវ ដែលមានការកើនឡើងខ្ពស់លើសឆ្នាំមុនៗ ក្នុងឆ្នាំ ២០១០ នេះ យើងអនុវត្តបានលើផ្ទៃដីសរុបជាង ២,៧៩ លានហិកតា ដោយទទួលបរិមាណផលសរុបប្រមាណ ៨,២៤ លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ២,៩៧ តោន/ហិកតា។ ដូច្នេះតុល្យភាពស្បៀង យើងនៅសល់ជាង ២,៩១ លានតោនអង្ករ គិតជាស្រូវជាង ៣,៩៣ លានតោន លើសឆ្នាំមុនជាង ០,៤២ លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំ កន្លងមកជាង ១,២៣ លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំធេងណាស់។

តួលេខនេះត្រូវបានវាយតម្លៃ ពីភាពជោគជ័យនៃ កំណើនផលិតផលស្រូវ ដែលបានកើនលើសក្នុងសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ដែលបានកំណត់ថា រហូតដល់ឆ្នាំ ២០១០ ទិន្នផលស្រូវនឹងបានកើនឡើងដល់ ២,៤ តោន/ហិកតា។ ជារួមការធ្វើឱ្យប្រសើរឡើងនូវផលិតកម្មកសិកម្មជាមួយនិងកំណើនទិន្នផលស្រូវនេះ គឺដោយសារមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ពីប្រមុខរាជរដ្ឋាភិបាលគួបផ្សំនឹងអាកាសធាតុអំណោយផលល្អនាចុងរដូវ ប្រជាកសិករមានភាពរីកចម្រើន លើចំណេះដឹង ក្នុងការគ្រប់គ្រងថែរក្សាស្រែចំការ ការផ្លាស់ប្តូរបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានបរិមាណផលខ្ពស់។

ជារួមការវាយតម្លៃវឌ្ឍនភាព ក្នុងវិស័យកសិកម្មត្រូវបានឈានឡើងជាលំដាប់ជារៀងរាល់ឆ្នាំ ដែលជាដំណាក់កាលមួយល្អបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ទន្ទឹមនឹងការកើនឡើងខ្ពស់ នូវផលិតផលស្រូវលើសពីតម្រូវការ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រងនិងដាំដុះព្រៃឈើ ការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូគ្រួសារ និងដំណាំកៅស៊ូឯកជន ត្រូវបានកើនឡើងគួរជាទីមោទនៈ។ រីឯការងារសេវាកម្មផ្សេងៗរួមមាន ការងារសេវាកម្មបច្ចេកទេស និងការងារសេវាកម្ម រដ្ឋបាលគ្រប់គ្រង

*បុគ្គលិក បណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស ការងារគោលនយោបាយផែនការហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹង និងកែលម្អប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមស្ថានភាពជាក់ស្តែង នៃការអភិវឌ្ឍន៍ជាសកល។*

*រាជធានីភ្នំពេញ, ថ្ងៃទី ខែ មីនា ឆ្នាំ ២០១១*

**រដ្ឋមន្ត្រី**